ទស្សនាវដ្ដីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

# ស្វែងរកការពិត



- ការតែងតាំងតំណែងមួយដែលមិនបានបម្រើផលប្រយោជន៍ជនរងគ្រោះ
- អំពើប្រល័យពូជសាសន៍នៅក្នុងបរិបទពិភពលោក

ចែកជូនដោយឥតគិតថ្លៃដល់មន្ទីរស្រុកនិងឃុំទូទាំងព្រះរាជាណាចក្រកម្ពុជា

លេខ១១៦ ខែសីហា ឆ្នាំ២០០៩

**ស្វែងរកការពិត**

ទស្សនាវដ្ដីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

លេខ១១៦ ខែសីហា ឆ្នាំ២០០៩

## មាតិកា

◆ការតែងតាំងតំណែងមួយដែលមិនបានបម្រើផលប្រយោជន៍ជនរងគ្រោះ ....១

◆“យុត្តិធម៌” សម្រាប់ប្រជាជនកម្ពុជា ..........................................២

**ផ្នែកឯកសារ**

◆គង់ សុត ប្រជាជននៅសហករណ៍ស្រែក្រសាំង ...............................៤

**ផ្នែកប្រវត្តិសាស្ត្រនិងការស្រាវជ្រាវ**

◆ពិព័រណ៍មជ្ឈមណ្ឌលឯកសារកម្ពុជានៅខេត្តកំពង់ចាម .....................៩

◆ពិព័រណ៍យុវជនឆ្នាំ២០០៩ នៅក្រុងកំពង់ចាម ...............................១២

◆ឌុប បដិសេធជនរងគ្រោះម្នាក់ទៀតដែលបានជាប់នៅមន្ទីរស-២១ .......១៦

◆អក្សរសិល្ប៍ដែលរស់រានមានជីវិត ...............................................១៩

**ផ្នែកច្បាប់**

◆អំពើប្រល័យពូជសាសន៍នៅក្នុងបរិបទសកលលោក ........................២១

**វេទិកាពិភាក្សាសាធារណៈ**

◆បទពិសោធន៍អប់រំប្រវត្តិសាស្ត្រនិងការអភិវឌ្ឍន៍ជាតិ .....................៣០

◆វិនិច្ឆ័យទោសៈ ដំណើរកាត់សេចក្ដីរបស់តុលាការខ្មែរក្រហម ...........៣៣

**ទំព័រស្រាវជ្រាវរកក្រួសារ**

◆ពិភពលោកនៅសែនឆ្ងាយ ........................................................៤៧



សិស្សានុសិស្សអានសៀវភៅ «ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ»



## រក្សាសិទ្ធិ

មជ្ឈមណ្ឌលឯកសារកម្ពុជា

អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយ
ក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា
ប្រកាសទេសរដ្ឋមន្ត្រីនិងរដ្ឋមន្ត្រីក្រសួងព័ត៌មាន
លេខ០២៩១ពម/៩៩
ចុះថ្ងៃទី២ខែសីហាឆ្នាំ១៩៩៩

រូបថតឯកសារៈមជ្ឈមណ្ឌលឯកសារកម្ពុជា
និងសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង

**ស្នេរលេខនេះ ៖** អៀវ សុផល, ផៀន គួនី, ឡូរ៉ា ម៉ាកដូណល, ចច ជីហ្កាស, ប្រែង ឆក, សំបូរ ម៉ាណារ៉ា, ចន ឆឈីអារី, និង ហេង ខុន **អ្នកនិពន្ធនិងស្រាវជ្រាវ ៖** គាត លក្ខិណា, សោម ប៊ុនថន, ស៊ិន សុធីតា, ទេស ម៉ារ៉ែម **អ្នកបកប្រែៈ** ជា ផល្លា, ទែន សុខស្រីនិត **និពន្ធនាយកទូទៅៈ** ឆាំង យុ **ជំនួយការនិពន្ធនាយកៈ** ទេព ម៉េងឃាន, ញាណ សុជាតិ **ក្រាហ្វិកកុំព្យូទ័រៈ** ស៊ឹម សុភ័ក្ត្រ **គ្រប់គ្រងការចែកផ្សាយៈ** ម៉ម សុផាត Email: dccam@online.com.kh, Homepage: www.dccam.org

*សំបុត្រ:*

# ការតែងតាំងតំណែងមួយដែលមិនបាន បម្រើផលប្រយោជន៍ជនរងគ្រោះ

*ខ្ញុំសរសេរលិខិតនេះដើម្បីបង្ហាញពីក្តីបារម្ភអំពីទម្រង់បែបបទក្នុងការផ្ទេរមុខតំណែងរបស់បណ្ឌិត ហេឡែន ចារីស ពីតួនាទីក្នុងអង្គភាពកិច្ចការសាធារណៈទៅកាន់អង្គភាពជនរងគ្រោះរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ បើតាមខ្ញុំដឹងការតែងតាំងនេះមិនដូចទៅនឹងអ្វីដែលអង្គជំនុំជម្រះតម្រូវឲ្យមានការប្រកួតប្រជែងជាគោលការណ៍ផងទេ ហើយមុខតំណែងសម្រាប់ប្រធានអង្គភាពជនរងគ្រោះនេះមិនដែលបានផ្សព្វផ្សាយជាសាធារណៈសោះ ចាប់តាំងពីពេលដែលអ្នកស្រី គាត បូផល បានសុំលាលែងពីតំណែងនេះ ។ ខ្ញុំព្រួយបារម្ភថា បន្ទាប់ពីការចោទប្រកាន់មកលើអង្គជំនុំជម្រះកន្លងមកស្តីអំពីការជ្រើសរើសបុគ្គលិកមកធ្វើការដែលមិនមានតម្លាភាពសម្រាប់ការិយាល័យរដ្ឋបាល ហើយនិងកិច្ចខិតខំប្រឹងប្រែងដែលបានធ្វើកន្លងមកដើម្បីដោះស្រាយបញ្ហានោះ ការិយាល័យរដ្ឋបាលហាក់បីដូចជាមិនបានធ្វើតាមគោលការណ៍ដែលបានអនុម័តថ្មីទេ ។ ខ្ញុំសង្ឃឹមថា ភាពមិនប្រក្រតីមួយចំនួនក្នុងការផ្លាស់មុខតំណែងរបស់ បណ្ឌិត ចារីស នឹងត្រូវបានដឹងឮជាទូទៅ ហើយនឹងត្រូវបានដោះស្រាយ ។*

*ខ្ញុំក៏មានក្តីបារម្ភផងដែរអំពីការជ្រើសរើសបុគ្គលិកដែលមិនមែនជាជនជាតិខ្មែរសម្រាប់មុខតំណែងប្រធានអង្គភាពជនរងគ្រោះដ៏សំខាន់នេះ ។ បើទោះបីជា បណ្ឌិត ចារីស កាន់លិខិតឆ្លងដែនកម្ពុជាក៏ដោយ ប៉ុន្តែគាត់គឺជាជនជាតិអូស្ត្រាលី ។ តាមគំនិតខ្ញុំ ការតែងតាំងមនុស្សដែលមិនមែនជាជនជាតិខ្មែរគឺមិនបានគោរពដល់ស្មារតីនៃកិច្ចព្រមព្រៀងក្នុងការបង្កើតតុលាការទេ ហើយក៏មិនបានលើកកម្ពស់ភាពជាម្ចាស់ដ៏រឹងមាំសម្រាប់ប្រជាជនកម្ពុជាក្នុងដំណើរការនេះដែរ ។ ទាក់ទងទៅនឹងតំណែងជាប្រធានអង្គភាពជនរងគ្រោះពិសេសនេះ ក្នុងការចាត់តាំងតំណែងនេះសម្រាប់ពលរដ្ឋកម្ពុជា តុលាការបានទទួលស្គាល់សារសំខាន់នៃនិមិត្តរូបនិងការអនុវត្តជាក់ស្តែងក្នុងការបំពេញមុខងារក្នុងតំណែងនេះ ដោយមនុស្សដែលមានដើមកំណើតជាខ្មែរដែលអាចយល់ដឹងពីអារម្មណ៍និងសមានចិត្តជាមួយជនរងគ្រោះក្នុងលក្ខណៈខ្មែរ ។ បច្ចុប្បន្ននេះ អង្គភាពដែលត្រូវធ្វើការយ៉ាងជិតស្និទ្ធបំផុតជាមួយអ្នករួចរស់ជីវិតនឹងដឹកនាំដោយជនបរទេសពីររូប ។ ខ្ញុំមិនមានជំនឿថា នេះជាវិធីល្អប្រសើរដើម្បីជាប្រយោជន៍ដល់តុលាការ និងជនរងគ្រោះនៃរបបកម្ពុជាប្រជាធិបតេយ្យទាំងមូលទេ ។*

*ខ្ញុំមិនជឿថា ការតែងតាំងបណ្ឌិត ហេឡែន ចារីស ជាប្រធានអង្គភាពជនរងគ្រោះគឺទាក់ទងទៅនិងរបៀបវារៈនយោបាយរបស់គណបក្សប្រជាជននិងនិងរដ្ឋាភិបាលទេ ។ ផ្ទុយមកវិញ រដ្ឋាភិបាលចង់រក្សាគម្លាតពីកិច្ចការរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។*

*ម្យ៉ាងវិញទៀត បើសិនជាអង្គការសហប្រជាជាតិពិតជាគាំទ្រដល់ការតែងតាំងមុខតំណែងរបស់ ហេឡែន ចារីស នេះជាការលូកដៃចូលក្នុងកិច្ចការផ្ទៃក្នុងរបស់កម្ពុជា ហើយជារឿងខ្វះក្រមសីលធម៌យ៉ាងខ្លាំងចំពោះជនរងគ្រោះ ។*

*ទាក់ទងទៅនឹងសំណួរដែលចោទសួរអំពីភាពជាពលរដ្ឋកម្ពុជារបស់បណ្ឌិត ហេឡែន ចារីស តើមានការខុសប្លែកគ្នាអ្វីខ្លះរវាងភាពជាពលរដ្ឋ និងជាតិពន្ធនៅក្នុងប្រទេសកម្ពុជា? ជាទូទៅតាមវប្បធម៌ខ្មែរ ប្រជាជនកម្ពុជាមិនមានការបែងចែកឲ្យដាច់ស្រឡះពីគ្នាទេរវាងពាក្យទាំងពីនេះ ហើយប្រជាជនខ្មែរជាទូទៅចង់ដឹងនូវអ្វីដែលហៅថា អត្តសញ្ញាណ ។ សម្រាប់ហេតុផលនេះ ភាពជាពលរដ្ឋកម្ពុជារបស់បណ្ឌិត ហេឡែន ចារីស នឹងមិនមានផលប៉ះពាល់ដល់ដំណើរការសម្រាប់ប្រជាជនកម្ពុជាក្នុងការទទួលបានផលប្រយោជន៍ទេ ។* **ឆាំង យុ**

# “យុត្តិធម៌” សម្រាប់ប្រជាជនកម្ពុជា: ការកាត់ទោសខ្មែរក្រហមអាចនឹងក្លាយទៅជាឆាកកំប្លែង ប្រសិនបើមិនមានការផ្លាស់ប្តូរបុគ្គលិកមួយចំនួនធំ

ពេលដែលម្តាយរបស់ខ្ញុំ និងបងប្អូនបួននាក់ក្សៀសខ្លួនពីរបប ប៉ុល ពត នៅក្នុងឆ្នាំ១៩៧៦ ឪពុកខ្ញុំបានស្លាប់ដោយសារជំងឺរាគមួល និងជំងឺខ្វះជីវជាតិ ក្រោយពីបានស្នាក់នៅក្នុង “មន្ទីរពេទ្យ” ខ្មែរក្រហមដែលមានសត្វល្អិតជាច្រើន ។ ថ្វីត្បិតតែខ្ញុំមានមន្ទិលសង្ស័យយ៉ាងខ្លាំងចំពោះលទ្ធភាពក្នុងការដាក់ទោសឧក្រិដ្ឋជនរបស់តុលាការកាត់ក្តីខ្មែរក្រហមដែលកំពុងដំណើរការនៅភ្នំពេញ តែខ្ញុំសង្ឃឹមថាវានឹងអាចទទួលបានសមិទ្ធផលល្អប្រសើរបំផុត ហើយខ្ញុំថែមទាំងបានចូលរួមក្នុងដាក់ពាក្យបណ្តឹងតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនៅអង្គភាពជនរងគ្រោះជាច្រើនរបស់តុលាការតាំងពីឆ្នាំមុន ។

ប៉ុន្តែខ្ញុំមិនអាចទ្រាំសម្ងំនៅស្ងៀមអង្គុយមើលល្ខោនដែលដ៏គួរឲ្យចង់សើចនេះទៀតឡើយ ។ ដោយមានជំនួយហិរញ្ញវត្ថុពីអ្នកឧបត្ថម្ភជាច្រើន តុលាការខ្មែរក្រហមបានបង្កើតឡើងនៅឆ្នាំ២០០៦ ដើម្បីស្វែងរកយុត្តិធម៌ដល់ជនរងគ្រោះរាប់លាននាក់ក្នុងរបបខ្មែរក្រហមបានជាប់ប្រឡាក់ប្រឡូកនឹងអំពើពុករលួយ ហើយត្រូវបានចោទប្រកាន់ថាមានការគ្រប់គ្រងមិនត្រឹមត្រូវ ។

ព័ត៌មានថ្មីបំផុតបានលេចឮនៅថ្ងៃទី១១ ខែសីហា នៅពេលដែល អ៊ុត ឈន ត្រូវបានតែងតាំងជាទីប្រឹក្សាឯករាជ្យ ។ លោក អ៊ុត ឈន ជាអគ្គសវនករកម្ពុជា និងជាប្រធាននៃអាជ្ញាធរសវនកម្មជាតិដែលទើបតែបង្កើតឡើងបានរយៈពេល៧ឆ្នាំសម្រាប់ត្រួតពិនិត្យទៅលើសកម្មភាពរបស់រាជរដ្ឋាភិបាល ។ រហូតមកដល់សព្វថ្ងៃ អាជ្ញាធរសវនករជាតិនេះមិនទាន់ផ្សព្វផ្សាយរបាយការណ៍ណាមួយជាសាធារណៈនៅឡើយទេ ។ ការតែងតាំងនេះក៏មានការយល់ស្របពីអង្គការសហប្រជាជាតិដែលត្រូវត្រួតពិនិត្យទៅលើអង្គជំនុំជម្រះវិសាមញ្ញ ខាងផ្នែកកម្ពុជា ។

ព័ត៌មាននេះគឺគ្រាន់តែជាការរិះគន់ថ្មីៗដែលមាននៅក្នុងប្រវត្តិសង្ខេបរបស់តុលាការប៉ុណ្ណោះ ។ នៅខែកុម្ភៈ ឆ្នាំ២០០៧ អង្គការគម្រោងយុត្តិធម៌សង្គមដែលមានការឧបត្ថម្ភពី ចច សូរ៉ុស បានបង្ហាញឲ្យឃើញពីការសូកប៉ាន់មួយ ។ ឆ្លងកាត់រយៈពេល ២ឆ្នាំ និងការស៊ើបអង្កេតជាលក្ខណៈអន្តរជាតិអស់រយៈពេល៧ លើកមកសំណួរចាំបាច់បំផុតដែលពាក់ព័ន្ធនឹងការទទួលខុសត្រូវនៅតែមិនទាន់មានចម្លើយ ។ អាជ្ញាធរកម្ពុជានៅតែបង្វៀង និងបដិសេធនូវការប្រព្រឹត្តខុស ។

ការជឿទុកចិត្តទៅលើអង្គជុំនុំជម្រះបានទទួលការប៉ះទង្គិចនៅពេលដែលលោកស្រី គៀត បូផល ប្រធានអង្គភាពជនរងគ្រោះនិងអ្នកការពារសិទ្ធិមនុស្សមានបទពិសោធន៍ លាលែងពីតំណែងក្នុងខែឧសភា ។ នៅថ្ងៃទី១៨ តំណែងរបស់លោកស្រីត្រូវបានជំនួសដោយលោកស្រី ហេឡែន ចារីស ជនជាតិអូស្ត្រាលី ដើម្បី “ពង្រឹង” ដល់ដំណើរការរបស់អង្គជុំនំជម្រះ ។ កាលពីប៉ុន្មានឆ្នាំមុន អ្នកស្រី ហេឡែន ចារីស បានទទួលសញ្ជាតិខ្មែរដើម្បីជាការលើកទឹកចិត្តដល់ការបម្រើការងារដល់រាជរដ្ឋាភិបាលយ៉ាងស្មោះត្រង់របស់លោកស្រីអស់រយៈពេលជាច្រើនឆ្នាំ ។

ឯករាជ្យភាពរបស់អ្នកស្រី ហេឡែន ចារីស ត្រូវបានចោទជាសំណួរថ្មីមួយទៀតនៅ ខែឧសភានៅពេលដែលលោក មីសែល ដេសម៉េន ដែលជាសមាជិកក្រុមមេធាវីការពារក្តីរបស់ នួន ជា បានរកឃើញសំបុត្រសាធារណៈមួយសរសេរដោយ “ក្រុមបក្ខពួកបក្សលេនីននិយម” ក្នុងទស្សនវិស័យជនសង្គមប្រជាធិបតេយ្យជាគណបក្សនយោបាយនៅប្រទេសអូស្ត្រាលី ដែលចុះហត្ថលេខាដោយលោកស្រី ហេឡែន ចារីស និងស្វាមីរបស់គាត់ ។ នេះផ្តល់នូវក្តីខ្វល់ខ្វាយដល់បុគ្គលម្នាក់ដែលមានតួនាទីសំខាន់ក្នុងអង្គជុំនំជម្រះគឺប្រធានការិយាល័យកិច្ចការសាធារណៈ រហូតដល់លោកស្រីត្រូវបានផ្លាស់ប្តូរទៅកាន់ពាក្យបណ្តឹងរបស់ជន

រងគ្រោះនៅដើមឆ្នាំនេះ ។

«យើងក៏ជាអ្នកកាន់លទ្ធិម៉ាកនិយមដែរ ហើយពួកយើងជឿថា «កាបញ្ចប់កំណត់នូវខ្លឹមសារ ។ ក្នុងអំឡុងពេលបដិវត្តន៍និងសង្គ្រាមស៊ីវិល ការយកវិធានការសំខាន់មួយចំនួនមកប្រើពេលខ្លះគឺជាការចាំបាច់និងសមស្រប ។ ដោយប្រឆាំងនឹងអ្នកវណ្ណៈកណ្ដាល និងភ្នាក់ងាររបស់រដ្ឋ យើងមិនត្រូវគោរពច្បាប់ និងគោលការណ៍សីលធម៌ក្លែងក្លាយរបស់អ្នកទាំងនោះទេ» ។ អ្នកស្រី ហេឡែន ចាវីស បដិសេធមិនផ្ដល់ប្រសាសន៍ជាសាធារណៈទៅលើសំបុត្រនោះទេ ។ ក្នុងសន្និសីទកាសែតកាលពីថ្ងៃទី១០ ខែមិថុនា មន្ត្រីទំនាក់ទំនងផ្នែកច្បាប់របស់អង្គការសហប្រជាជាតិម្នាក់បាននិយាយថា នុត រ៉ូសានហូក ដែលជាអនុប្រធានការិយាល័យរដ្ឋបាលនិងអ្នកសម្របសម្រួលដល់ជំនួយការអង្គការសហប្រជាជាតិបាន «គាំទ្រយ៉ាងពេញទំហឹងទៅលើការតែងតាំង បណ្ឌិត ហេឡែន ចាវីស ជាប្រធានថ្មីនៃអង្គភាពជនរងគ្រោះ» ។ ការធ្វើបែបនេះគឺពិតជាមិនគិតដល់ជនរងគ្រោះ ការព្រួយបារម្ភនិងសិទ្ធិរបស់ជនរងគ្រោះឡើយ ។

ក្រុមរបស់បញ្ញវ័ន្តឆ្វេងនិយម និងអ្នកដែលមានគំនិតដូចនឹងលោកស្រី ហេឡែន ចាវីស រួមទាំង ម៉ាលខម ខាលដ៍វេល និង ណាម ចមស្គី មានភាពខុសប្លែកគ្នាបន្តិចបន្តួចពីអ្នកគាំទ្រខ្មែរក្រហមនៅអំឡុងរបបដ៏ឃោរឃៅនោះ ។ នៅពេលនោះ លោក ណាម ចមស្គី បានបដិសេធមិននិយាយអំពីសេចក្ដីថ្លែងការគាំទ្រខ្មែរក្រហមដោយព្រមានថានឹងផ្ដល់ការបដិសេធដ៏សមហេតុផលជាងនេះនៅពេលក្រោយ ។ ប៉ុន្តែ លោកនិងអ្នកដទៃទៀតបានកោតសរសើរការងាររបស់ ខាលដ៍វេល និង ចច ហ៊ីលដីប្រ៊ែន និង ហ្គារ៉េដ ផតតឺ ដែលអត្ថបទ «កម្ពុជារបស់លោកមានចំណេងជើងថាភាពអត់ឃ្លាន និង បដិវត្តន៍» ដូចទៅនឹងព័ត៌មាននៅក្នុងការសែតញូយ៉កថែមស៍របស់ វិលគឺ យូរ៉េនធី ។

ទោះបីជាតុលាការមានបុគ្គលិកច្រើន អ្នកដែលប្រព្រឹត្តខុសក៏កំពុងតែចាកចេញដែរ ។ ការចាកចេញរបស់លោកស្រី គៀត បូផល បានដកហូតភាពជឿជាក់របស់តុលាការ និងការការពារសិទ្ធិរបស់ជនរងគ្រោះ ។ ព្រះរាជអាជ្ញាអន្តរជាតិ លោក រ៉ូបើត ប៉ីទីត នឹងលាលែងពីតំណែងនៅសប្ដាហ៍ក្រោយ ដោយសារតែគាត់ត្រូវត្រឡប់ទៅធ្វើការបម្រើរាជរដ្ឋាភិបាលកាណាដារបស់គាត់ ។ លោក រ៉ូបើត ប៉ីទីត បានទទួលការកោតសរសើរក្នុងការជំរុញឲ្យតុលាការកាត់ទោសបុគ្គលលើសពី៥រូប ដែលផ្ទុយពីការចង់បានរបស់អាជ្ញាធរកម្ពុជា ។ សក្ខីកម្មមិនត្រឹមត្រូវរបស់សាក្សីនៅពាក់កណ្ដាលខែកក្កដា ដូចជានារីពេទ្យ និងអនុប្រធាននៅមន្ទីរស-២១ ដែលជាកន្លែងធ្វើទារុណកម្មដ៏សាហាវរបស់ខ្មែរក្រហម គឺជាកំហុសដ៏គួរឲ្យអាម៉ាស់មួយសម្រាប់ ចៅក្រម មេធាវី ក៏ដូចជាជនរងគ្រោះ ។

កំណត់ត្រានៅពីរឆ្នាំមុន បានបង្ហាញឲ្យឃើញថាតុលាការមិនបានយកចិត្តទុកដាក់ទៅលើការផ្ដល់យុត្តិធម៌ពិតទេ ។ មធ្យោបាយល្អបំផុតដើម្បីកែតម្រូវគឺតុលាការត្រូវចាប់ផ្ដើមជ្រើសរើសបុគ្គលិកសាជាថ្មី រួមទាំងប្រធានការិយាល័យរដ្ឋបាល អនុប្រធាន និងប្រធានអង្គភាពជនរងគ្រោះ ។ យើងជាជនរងគ្រោះគួរតែទទួលបានយុត្តិធម៌ ។

**អៀវ សុផល**

# សេចក្ដីប្រកាសរកប្អូនប្រុស

នាងខ្ញុំឈ្មោះ នាក់ ហោង សព្វថ្ងៃរស់នៅភូមិភ្នំតូច ឃុំស្ដេចគង់ខាងត្បូង ស្រុកបន្ទាយមាស ខេត្តកំពត ឪពុកខ្ញុំឈ្មោះ សោម យេន (ស្លាប់) និងម្ដាយឈ្មោះ អ៊ុន សឹម (ស្លាប់) ។ ខ្ញុំមានបងប្អូនពីរនាក់ គឺខ្ញុំនិងប្អូនប្រុសម្នាក់ទៀតឈ្មោះ នាក់ ធី (បាត់ខ្លួន) ។ ខ្ញុំសូមស្វែងរកប្អូនប្រុសឈ្មោះ នាក់ ធី ដែលបាត់ខ្លួនពេលធ្វើជានិរសារនៅព្រំដែនវៀតណាមនៅមុនឆ្នាំ១៩៧៥ ។ នៅពេលនោះ ធី ទើបតែមានអាយុប្រហែលជា១៨ឬ១៩ឆ្នាំប៉ុណ្ណោះ រួចបានចេញពីផ្ទះទៅធ្វើជានិរសារជាមួយមីងឈ្មោះ ពៅ ជាអ្នកនាំចូល ។ ក្រោយមកខ្ញុំក៏បាត់ដំណឹង ធី រហូត ។

ប្រសិនបើប្អូនបានឃើញសេចក្ដីប្រកាសនេះ ឬបងប្អូនណាស្គាល់ ឬឮដំណឹងអំពីឈ្មោះខាងលើនេះ សូមមេត្តាផ្ដល់ព័ត៌មានមកនាងខ្ញុំតាមរយៈទូរស័ព្ទលេខ ០១៧ ៩២៩ ៩៦១ ឬមេភូមិភ្នំតូចឈ្មោះ មិន ឈុំ ឬទំនាក់ទំនងមកមជ្ឈមណ្ឌលឯកសារកម្ពុជា ។ **សូមអរគុណ**

# គង់ សុត ប្រធានជននៅសហករណ៍ស្រែក្រសាំង តំបន់១០៤

គង់ សុត អាយុ២៨ឆ្នាំ មានស្រុកកំណើតនៅភូមិប្រប់ ឃុំ២ ស្រុក៤៤ តំបន់១០៤ មានប្រពន្ធឈ្មោះ វង់ ទួន បានធ្វើសកម្មភាពក្បត់បដិវត្តន៍ ហើយដើរបំផុសប្រជាជនឲ្យចូលរួមក្នុងសកម្មភាពក្បត់ជាមួយខ្លួន ដោយរៀបចំផែនការបំផ្លាញសម្ភារៈរបស់អង្គការដូចជា នង្គ័ល និងបង្គីអស់ជាច្រើន និងលួចស្បៀងរបស់សហករណ៍មកលាក់ទុកធ្វើជារបស់ខ្លួន។ ក្រោយមក សុត ត្រូវបានអង្គការចាប់ខ្លួននៅថ្ងៃទី២៩ ខែមិថុនា ឆ្នាំ១៩៧៨។

ចាប់តាំងពីកុមារភាពមក សុត រស់នៅជាមួយឪពុកម្ដាយដែលជាកសិករ រហូតដល់ឆ្នាំ១៩៦៧ បន្ទាប់ពីរៀនចប់ថ្នាក់ទី១០ នៅសាលាសង្គមអណ្ដែត ដែលស្ថិតនៅក្នុងភូមិប្រប់ សុត ក៏បានទៅបួសនៅវត្តប្រប់។ រៀនអស់រយៈពេល៣ឆ្នាំ សុត ក៏បានបញ្ចប់ថ្នាក់ទី៣ ក្រោមការបង្ហាត់បង្រៀនរបស់លោកអាចារ្យ លើយ និង សារ៉េត។ នៅឆ្នាំ១៩៦៨ លោកអាចារ្យ សារ៉េត បាននិយាយជាមួយ សុត, កន, ជៀន, និង សំ ដែលជាសិស្សរួមថ្នាក់ជាមួយគ្នា អំពីច្បាប់សេរីអា និងច្បាប់លោកសេរីឲ្យទាំងអស់គ្នាស្ដាប់ រួចសួរថាតើស្គាល់ក្នាក់ងារសម្ងាត់សេរីអាទេ? គាត់ក៏បានបកស្រាយថា ភ្នាក់ងារសម្ងាត់នេះជាក្រុមស៊ើបការណ៍មួយ ដែលមានតួនាទីមួយច្បាស់លាស់ និងមានប្រាក់ខែ។ ពេលនោះ សុត ព្រមទាំងលោកចំនួនបីអង្គទៀតបានយល់ព្រមចូលសេរីអា។ បន្តិចក្រោយមក លោកអាចារ្យ សារ៉េត បានហៅលោកអាចារ្យ លើយ ចូលមកក្នុងបន្ទប់ទៀត ដោយភ្ជាប់ទាំងក្រដាសមួយសន្លឹករាងបួនជ្រុង និងមានរូបផ្កាយមួយនៅពីលើផងរួចនិយាយប្រាប់ថា «យើងទាំងអស់គ្នាបម្រើឲ្យទង់មួយនេះ ដើម្បីការពារលទ្ធិសេរី»។ ក្រោយពីនិយាយចប់ លោកអាចារ្យ សារ៉េត បានប្រគល់ក្រដាសនោះឲ្យលោកអាចារ្យ លើយ ទទួលស្គាល់ រួចឲ្យធ្វើការប្ដេជ្ញាថា «ត្រូវបម្រើលទ្ធិលោកសេរីនេះអស់មួយជីវិត បើសិនជាមានចិត្តវៀចវេរ សូមឲ្យវត្ថុស័ក្ដិសិទ្ធិតាមផ្ដន្ទាទោសចុះ»។ ប៉ុន្មានថ្ងៃក្រោយមក លោកអាចារ្យ សារ៉េត បានណែនាំ សុត និងលោកចំនួនបីអង្គទៀតអំពីភារកិច្ចដែលក្រុមស៊ើបការណ៍សម្ងាត់ត្រូវធ្វើ។ ទីមួយ) កសាងកម្លាំងនៅក្នុងជួរលោក



អ្នកទោស នៅមន្ទីស-២១

សង្ឃបន្ថែមទៀត ដោយណែនាំឲ្យអ្នកទាំងនោះឃើញច្បាស់ពីសង្គមបច្ចុប្បន្ន។ ទីពីរ) បំផុសពីរឿងនយោបាយរវាងលទ្ធិកុម្មុយនីស្ត និងលទ្ធិលោកសេរី ដើម្បីឲ្យគ្រប់គ្នាបានឃើញថាលទ្ធិមួយណាងាយស្រួលជាង ទីបី) ចាត់តាំងខ្សែបន្តប់នៅតាមភូមិឃុំ ដើម្បីស៊ើបការណ៍ពីរឿងខ្មែរក្រហម ប៉ុន្តែត្រូវលាក់ការណ៍ឲ្យជិត។ ក្រោយពីដាក់ផែនការតាមដានខ្មែរក្រហមនៅតាមមូលដ្ឋានរួច សុត ក៏បានអប់រំដល់លោកសង្ឃឯទៀត និងស្រាវជ្រាវរកកន្លែងដែលខ្មែរក្រហមបង្កប់។ លើសពីនេះទៅទៀត សុត បានព្យាយាមនិយាយពីរឿងនយោបាយក្នុងប្រទេស និងរឿងច្បាប់កុម្មុយនីស្តនៅក្នុងជួរលោកសង្ឃដើម្បីឲ្យឃើញថា ខ្មែរក្រហមគឺជាសត្រូវ ដែលបានកាប់សម្លាប់ប្រជាជននៅតាមជនបទក្នុងប្រទេសកម្ពុជាជាបន្តបន្ទាប់។ ម្យ៉ាងទៀត សុត បានអប់រំលោកសង្ឃចំនួនពីរអង្គទៀតឈ្មោះ ព្រីង និង ជិន ដែលជាមិត្តជិតស្និទ្ធឲ្យចូលរួមធ្វើការជាមួយ ប៉ុន្តែមិនទាន់បញ្ចូលជាក្រុមសម្ងាត់សេអ៊ីអានៅឡើយទេ គឺគ្រាន់តែឲ្យជួយបំផុសចលនាលោកសង្ឃ និងស៊ើបរកខ្មែរក្រហមប៉ុណ្ណោះ។

នៅខែកក្កដា ឆ្នាំ១៩៦៩ ក្រោយពីលោកអាចារ្យ សារ៉េត ប្រាប់ សុត ថា រូបគាត់ត្រូវផ្លាស់ទៅនៅភ្នំពេញវិញ គាត់ក៏ផ្តាំឲ្យ សុត ខិតខំធ្វើការងារបន្តទៀត បើមានកិច្ចការអីអាចទាក់ទងជាមួយលោកចៅអធិការវត្តបាន។ ក្រោយមក សុត ក៏បានផ្លាស់ទៅកាន់វត្តប្រប់វិញ ប៉ុន្តែផ្លាស់ទៅបានតែរយៈពេលមួយខែ សុត ក៏សុំលោកអធិការវត្តប្រប់សឹកជាគ្រហស្ថ។ ដោយសារតែលោកចៅអធិការវត្តប្រប់មិនអនុញ្ញាត សុត ក៏ត្រឡប់មកសុំលោកចៅអធិការវត្តកក្តិញ្ញារាម ឈ្មោះ ស៊ិន វិញ (បច្ចុប្បន្ន ត្រូវអង្គការកម្ទេច)។ ពេលនោះ លោកចៅអធិការវត្តក៏អនុញ្ញាតឲ្យ សុត សឹក ប៉ុន្តែលោកសួរថា កាលនៅរៀនជាមួយលោកអាចារ្យ សារ៉េត គាត់មានណែនាំយ៉ាងម៉េចទេ? ពេលនោះ សុត បានប្រាប់ថា មានគ្នាទាំងអស់បួននាក់ ដែលលោកអាចារ្យ សារ៉េត បានចាត់តាំងបញ្ចូលក្នុងក្រុមសម្ងាត់សេអ៊ីអា។ ក្រោយពីឮដូច្នេះ លោកចៅអធិការវត្តក៏នៅស្ងៀម រួចសួរបន្តទៀតថា ចុះមានស្គាល់ឈ្មោះ ទៀវ ដែលជាក្រុមសម្ងាត់សេអ៊ីអាទេ? បើមិនស្គាល់ ពេលត្រឡប់ទៅវិញ ត្រូវស្រាវជ្រាវទាក់ទងជាមួយឈ្មោះ ទៀវ ទើបអាចដឹងពីសភាពការណ៍នៅកន្លែងនោះបាន ប៉ុន្តែត្រូវធ្វើការងារដោយប្រុងប្រយ័ត្ន និងទាក់ទងគ្នាឲ្យបានជាប់កុំឲ្យបែកការណ៍។ ក្រោយពី សុត ត្រឡប់ទៅរស់នៅជាមួយឪពុកម្តាយនៅក្នុងភូមិប្រប់វិញ គាត់ក៏បានជួបជាមួយ ទៀវ (បច្ចុប្បន្នជាប្រជាជននៅភូមិសហករណ៍ស្រែក្រសាំង តំបន់១០៨) ដើម្បីសួរពីសភាពការណ៍នៅក្នុងភូមិ។ បន្ទាប់មក ទៀវ បានណែនាំឲ្យ សុត នៅធ្វើការជាមួយគាត់ បើមានការអីឲ្យទាក់ទងជាមួយគាត់ជាមុន និងជួយពិនិត្យតាមដានសភាពការណ៍នៅក្នុងភូមិជង ហើយត្រូវកសាងកម្លាំងបន្ថែមទៀត។ ចាប់តាំងពីពេលនោះមក រយៈពេល៣ខែមុនពេលរដ្ឋប្រហារ សុត អប់រំបានលោកសង្ឃមួយអង្គឈ្មោះ ទិត នៅវត្តប្រប់ឲ្យជួយស៊ើបការណ៍ក្នុងជួរលោកសង្ឃ និងប្រជាជនម្នាក់ទៀតឈ្មោះ ថែម ដែលរស់នៅក្នុងភូមិប្រប់ជាមួយគ្នា ដោយណែនាំឲ្យធ្វើការជាមួយ ទិត និងមានមេឃុំ ទៀវ ជាអ្នកដឹកនាំ។

នៅឆ្នាំ១៩៧០ ដោយសារតែរដ្ឋប្រហារ សភាពការណ៍ប្រែជាមានការច្របូកច្របល់ខ្លាំង សុត, ទិត, និង ថែម បានជួបប្រជុំគ្នានៅផ្ទះមេឃុំ ទៀវ អំពីស្ថានភាពនៅក្នុងភូមិថា ត្រូវផ្អាកសកម្មភាពមួយរយៈសិន ប្រសិនបើកងទ័ពកុម្មុយនីស្តវាយលុកចូលមកដល់ក្នុងភូមិ។ ក្រោយពីរដ្ឋប្រហារ សភាពការណ៍នៅក្នុងភូមិកាន់តែមានភាពច្របូកច្របល់ខ្លាំងឡើងៗ រហូតដល់មានអ្នកភូមិជាច្រើននាក់បានរត់ភៀសខ្លួនទៅរស់នៅក្នុងភូមិផ្សេងៗទៀត។ ពេលនោះ មេឃុំ ទៀវ បានហៅ សុត, ចាន់, ថង, ណែម, ឡុញ, លឿង, ថែម, ទិត និងកសិករមួយចំនួនទៀតមកចូលរួមប្រជុំដើម្បីរៀបចំផែនការប្រឆាំងកងទ័ពវៀតណាម និងស៊ើបសួរពីដំណឹងរបស់មេឃុំ លៀង។

នៅឆ្នាំ១៩៧១ សួយ (បច្ចុប្បន្នចាប់ខ្លួន) ដែលជាប្អូនជីដូនមួយរបស់មេឃុំ ទៀវ ត្រូវបានវៀតណាមចាត់តាំងឲ្យធ្វើជាប្រធានភូមិប្រប់។ ពេលនោះ ដោយសារសភាពការណ៍មានភាពល្អប្រសើរ ក្រោយពីបានជួបជាមួយ សួយ និង លៀង រួច មេឃុំ ទៀវ បានហៅ សុត និងអ្នកឯទៀតមកចូលរួមប្រជុំ រួចប្រាប់ថា លៀង ដែលពីមុនមកជាខ្សែរយៈរបស់គាត់ បានឡើងធ្វើជាគណៈឃុំ៣ហើយ និងកសាងកម្លាំងបានមួយចំនួនដូចជាឈ្មោះ ដាយ ជំទប់លេខ១ ដា ជំទប់លេខ២ និង ដាំ ជំទប់លេខ៣ (បច្ចុប្បន្ន

ទាំងបីនាក់សុទ្ធតែជាប្រជាជននៅភូមិកំភុន) ចំណែកកម្លាំងថ្មីៗទៀតមិនទាន់ដឹងច្បាស់នៅឡើយ រង់ចាំដំណឹងពី សួយ សិន ព្រោះគាត់ជាក្រុមសម្ងាត់យូរហើយ ។ និយាយចប់ ទៀវ បានលើកឡើងថា ដោយសារសភាពការណ៍មានភាពល្អប្រសើរ ដូច្នេះ ទាំងអស់គ្នាអាចទាក់ទងគ្នាបានស្រួលជាងមុន បើមានសភាពការណ៍អ្វីមិនស្រួល អាចរាយការណ៍ប្រាប់គ្នាបានទាន់ពេលវេលា និងធ្វើសកម្មភាពអប់រំប្រជាជនឲ្យស្អប់បដិវត្តន៍បន្តទៀត ។

នៅពាក់កណ្តាលឆ្នាំ១៩៧២ កងទ័ពខ្មែរក្រហមបានចូលមកដល់ក្នុងភូមិឃុំ រួចចាត់តាំង សួយ ឲ្យធ្វើជាគណៈឃុំ២ ស្រុក៤៤ ។ ក្រោយពីកងទ័ពវិលត្រឡប់ទៅកាន់សមរភូមិវិញ ចាន់ថា បានចុះមកកាន់តួនាទីជាគណៈស្រុក៤៤ ចំណែក សួយ ត្រូវទៅរៀបចំធ្វើមន្ទីរនៅស្រែស្រណុក និងប្រមូលយុវជននិងយុវនារីឲ្យចូលបម្រើការងារនៅក្នុងមន្ទីរ ។ រហូតដល់ខែសីហា សួយ បាន ហៅ សុត, ថុង, សារ៉េម, ប៊ុនលី, ហៃ, ង៉ាយ, និង ដួល ឲ្យចូលទៅធ្វើការនៅក្នុងមន្ទីរជាមួយគាត់ ព្រោះដឹងថាទាំងអស់គ្នាសុទ្ធតែជាក្រុមសម្ងាត់ ដែលនៅក្នុងនោះ ថុង ទទួលផ្នែកយុវជន សារ៉េម ទទួលផ្នែកនារី ចំណែកអ្នកផ្សេងទៀតជួយមើលគ្នា ។ បន្ទាប់មក សួយ បានដាក់ផែនការឲ្យទាំងអស់គ្នាធ្វើការ ដោយដើរបំផុសចលនាក្នុងជួរយុវជនយុវនារីឲ្យរៀបការ និងកសាងកម្លាំងបន្ថែមទៀត ។ ចាប់ពីពេលនោះមក សុត និងអ្នកឯទៀតក៏ចាប់ផ្តើមអនុវត្តផែនការបំផុសផ្នែកសីលធម៌ឲ្យយុវជននិងយុវនារីទាក់ទងគ្នាជាហូរហែ រហូតដល់មានខូចខ្លួនប្រាណជាបន្តបន្ទាប់ និងបែកមុខសញ្ញាដើម្បីជួយធ្វើស្រែប្រជាជន ក្នុងគោលបំណងដោះលែងគោក្របីមិនឲ្យបដិវត្តន៍រឹបអូសយក ។ ក្នុងឆ្នាំនេះ ដោយសារបែកការណ៍រឿងសីលធម៌ខ្លាំងពេក ចាន់ថា បានហៅក្រុមស៊ើបការណ៍សម្ងាត់ និងអ្នកដែលបានកសាងរួចទាំងអស់មកប្រជុំនៅកន្លែងគាត់ផ្ទាល់ពីការផ្លាស់ប្តូរកន្លែងការងាររបស់គាត់ និងណែនាំឲ្យទាំងអស់គ្នាបន្តធ្វើការងារជាមួយ សួយ ក្នុងនោះ ថុង ធ្វើជាប្រធានយុវជនឃុំ២ សារ៉េម ទទួលបន្ទុកផ្នែកនារីឃុំ២ ប៊ុនលី ជាសមាជិកទីមួយ ហៃ ជាសមាជិកទីពីរ ចំណែក សុត ត្រូវទទួលខុសត្រូវខាងពាណិជ្ជកម្មក្នុងឃុំ ដោយត្រូវធ្វើយ៉ាងណាបំផ្លាញបដិវត្តន៍គ្រប់រូបភាព និងឃោសនាបំផុសឲ្យប្រជាជនលែងមានជំនឿលើបដិវត្តន៍បន្តទៀត ។

នៅឆ្នាំ១៩៧៣ សុត បានចុះដាប់នៅតាមមូលដ្ឋានរបស់ប្រជាជន រួចបង្កើតចលនាបំបែកបំបាក់ និងកសាងកម្លាំងឲ្យចូលរួមក្នុងក្រុមស៊ើបការណ៍សម្ងាត់ដើម្បីបំផ្លាញបដិវត្តន៍ ។ នៅក្នុងការដឹកជញ្ជូនផ្នែកពាណិជ្ជកម្ម សុត បានបំផ្លាញរទេះគោក្របីរបស់ប្រជាជនជាបន្តបន្ទាប់ គឺបកេងលុយរដ្ឋនិងសម្ភារៈយកទៅចាយវាយនិងប្រើប្រាស់ផ្ទាល់ខ្លួន បំផ្លាញនង្គ័លនិងរនាស់ និងដើរបំភ័យប្រជាជនឲ្យកាប់ជ្រូកមាន់ទាគោក្របីហូប ហើយបំផុសចលនាឲ្យប្រជាជនខ្ជិលធ្វើការ និងឲ្យប្រជាជនឆាប់យកគ្រួសារ ។ ក្រៅពីនេះ សុត បានឆ្លៀតឱកាសទាក់ទងជាមួយ លៀង ដែលជាប្រធានឃុំ៣ ដោយនិយាយប្រាប់ពីឈ្មោះអ្នកដែលគាត់បានកសាងរួចរួមមាន ខាំ, ដែង, និង សុខ ដែលទាំងអស់គ្នាសុទ្ធតែជាសិស្សថ្នាក់ទី៧ និងមានសញ្ញាតិលាវ ។ ក្រោយមកទៀត សួយ បានណែនាំ សុត ឲ្យខិតខំធ្វើការងារឃោសនាប្រឆាំងបដិវត្តន៍បន្តទៀត ព្រោះទោះបីជាសភាពការណ៍ត្រូវបែកការណ៍ក៏ដោយ ក៏ទាំងអស់គ្នាអាចធ្វើឲ្យរាំងស្ទះដល់ផែនការបដិវត្តន៍ដែរ ។

នៅដើមឆ្នាំ១៩៧៤ ទោះបីជា ចាន់ថា ត្រូវអង្គការចាប់ខ្លួន ប៉ុន្តែការងារនៅតែពង្រីកកម្លាំងឲ្យបានច្រើនបន្តទៀតដើម្បីស៊ីរូងផ្ទៃក្នុងជួរបដិវត្តន៍ ។ ក្រោយមក អង្គការបានដាក់ផែនការឲ្យឡុង លើកទំនប់ជារាងខ្នងអណ្តើក ប៉ុន្តែគាត់បែរជាដឹកនាំឲ្យប្រជាជនធ្វើទំនប់ជារាងបួនជ្រុងទៅវិញ ហើយឲ្យប្រជាជនសម្រុកធ្វើទាំងយប់ទាំងថ្ងៃរយៈពេល៤ថ្ងៃ៤យប់ ដោយមិនឲ្យសម្រាករហូតធ្វើឲ្យប្រជាជនធ្លាក់ខ្លួនឈឺនិងស្លាប់ជាបន្តបន្ទាប់ ។ លើសពីនេះទៅទៀត ការងារនេះធ្វើឲ្យប្រជាជនជួបការលំបាក និងហូបបាយមិនបានគ្រប់គ្រាន់គឺក្នុងមួយកំប៉ុង ហូបរហូតដល់៣ទៅ៤នាក់ក៏មាន ដើម្បីឲ្យអង្គការមើលឃើញថា ខ្លួនបានដឹកនាំប្រជាជនធ្វើដែរ ។ ដល់រដូវធ្វើស្រែ ឡុង និង សួយ បានហៅទាំងអស់គ្នាមកប្រជុំទៀតពីរឿងដាក់ផែនការបំផ្លាញនិងបំផុសប្រជាជនឲ្យយល់ខុសចំពោះបដិវត្តន៍ និងមិនឲ្យធ្វើការដោយបែកមុខសញ្ញារៀងៗខ្លួនគឺ សុត និង ប៊ុនលី ទៅនៅសហករណ៍ត្រពាំងបី ថុង និង ង៉ាយ នៅសហករណ៍ដដែល សារ៉េម និង តួ ទៅនៅសហករណ៍ក្រសាំង ដួល និង ហៃ ទៅនៅសហករណ៍ត្រៀក ក្នុងឃុំ២ទាំងអស់

ចំណែកមនុស្សមួយចំនួនទៀត ត្រូវបន្តសកម្មភាពនៅក្នុងមន្ទីរដដែល ។

នៅដើមឆ្នាំ១៩៧៥ ទាំងខ្សែររយៈចាស់និងថ្មី និងខ្សែរយៈធំៗមួយចំនួនមានដូចជា ថង និង ដែង ដែលបច្ចុប្បន្នជាលេខាស្រុក៤៤ បានរាយការណ៍ពីសកម្មភាពដែលបានធ្វើកន្លងមក ។ ក្រោយពីអ្នកទាំងអស់គ្នាបានរាយការណ៍ចប់ ឡុង បានប្រាប់ឲ្យវិលត្រឡប់ទៅធ្វើការនៅក្នុងមន្ទីរវិញ ហើយគាត់នឹងដាក់ផែនការឲ្យធ្វើបន្តទៀត នៅពេលដែលគាត់វិលត្រឡប់មកពីប្រជុំគណៈស្រុកវិញ ។ នៅពេល ឡុង ត្រឡប់មកដល់មន្ទីរ គាត់បានប្រាប់អំពីសភាពការណ៍នៅពេលប្រជុំ ដែលក្នុងនោះគាត់បានជួបពិភាក្សាជាមួយ ថង, ដែង, និង សា រួចចង់ឲ្យទាំងអស់គ្នាបន្តការតស៊ូតទៅទៀតគឺ ទីមួយ) ឃោសនានិងធ្វើសកម្មភាពឲ្យខ្លាំងក្លាថែមទៀត ទីពីរ) កសាងកម្លាំងឲ្យបានច្រើននៅគ្រប់សហករណ៍ និងធ្វើយ៉ាងណាឲ្យរាំងស្ទះដល់ការតស៊ូបដិវត្តន៍គ្រប់ពេលវេលា ។ ក្រោយពីអ្នកទាំងអស់គ្នាអនុវត្តសកម្មភាពនៅក្នុងមន្ទីរបានតែមួយខែ អង្គការបានប្រកាសឲ្យរំសាយមន្ទីរចាស់ទៅនៅមន្ទីរថ្មី ហើយក៏ចាត់តាំងគណៈសហករណ៍ថ្មីដែរគឺ ប៊ុនលី ធ្វើជាប្រធានសហករណ៍ត្រពាំងបី ថុង ធ្វើជាសមាជិកទីមួយក្នុងសហករណ៍ដដែល ដួល ធ្វើជាប្រធានសហករណ៍ត្រៀក ។ នៅក្នុងសហករណ៍ក្រសាំងបានរយៈពេល៦ខែ សុត បានចូលរួមចលនានៅក្នុងសហករណ៍ជាបន្តបន្ទាប់ ពិសេសចូលរួមក្នុងសកម្មភាពបំផ្លាញ ដូចជា ពេលដើរឆ្មះសត្វយប់បានបាញ់គោក្របីរបស់អ្នកស្រុក រួចប្រាប់ប្រជាជនថាច្រឡំដុតចំបើងឆេះផ្ទះប្រជាជនអស់៥ខ្នង កាប់គោជាច់កែង និងលែងគោក្របីឲ្យស៊ីស្រូវជាដើម ។ ក្រោយពីរំដោះប្រទេសរួច ឡុង និង សួយ បានហៅ សុត និងអ្នកឯទៀតទៅប្រជុំនៅមន្ទីរឃុំ ដើម្បីរិះរកវិធានការផ្សេងបំផ្លាញអង្គការបន្តទៀត ។ រហូតដល់ពាក់កណ្តាលឆ្នាំ១៩៧៥ ក្រោយពីចុះទៅធ្វើការនៅមន្ទីរស្រុកបានរយៈពេលមួយខែ ឡុង, ដែង, និង ថង បានត្រឡប់មកវិញជាមួយគ្នា ហើយដើរមើលតាមសហករណ៍ ។ ក្រោយមក ឡុង, ដែង, និង ថង បានប្រាប់ សុត, ហែម, ជន, ជុន, ទៀវ, ថង, ឡុញ, ចែម, ទិត, លឿង, ចាន់, សារ៉េម, តួ, និង យន ឲ្យប្រជាជនចំនួន៥០នាក់លើកប្រព័ន្ធភ្លឺស្រែនៅសហករណ៍វាំង ក្នុងគោលបំណងបំផ្លាញបដិវត្តន៍ ដោយរំលាយភ្លឺស្រែតូចៗឲ្យអស់ទោះបីដីខ្ពស់ឬទាប ឬផ្សៀងក៏ដោយ ដើម្បីកុំឲ្យប្រជាជនប្រើប្រាស់ទឹកបានតទៅទៀត ព្រោះបើកាលណារំលាយភ្លឺតូចឲ្យទៅជាធំទឹកនឹងរត់មិនស្មើគ្នា ធ្វើឲ្យម្ខាងមានទឹកម្ខាងទៀតអត់ទឹក ដូច្នេះម្ខាងដែលអត់ទឹកនឹងត្រូវខូចចោល ។ នៅចុងឆ្នាំ១៩៧៥ សួយ បានហៅគ្រប់គណៈសហករណ៍ទៅប្រជុំ រួចលើកឡើងថា ឡុង ត្រូវអង្គការដកទៅកាន់មន្ទីរស្រុកវិញ ហើយត្រូវទៅរៀនសូត្រនៅខេត្តស្ទឹងត្រែង ដូច្នេះ គ្រប់គ្នាត្រូវចាត់វិធានការទប់ទល់ចលនាបដិវត្តន៍ និងត្រូវកសាងកម្លាំងបន្ថែមទៀតឲ្យបានច្រើន ។

នៅឆ្នាំ១៩៧៦ ក្រោយពីមានគង់ទ័ពចុះមកសហករណ៍ស្រែក្រសាំងទាក់ទងរកអ្នកដឹងផ្លូវទៅឃុំកំភុន គណៈសហករណ៍ សៃ បានឲ្យ សុត នាំទៅដើម្បីផ្សៀតឱកាសទាក់ទងជាមួយឈ្មោះលៀង ។ ពេលជូនទ័ពទាំងនោះទៅដល់ភូមិកំភុន សុត បានចូលទៅសម្រាកនៅផ្ទះ លៀង មួយយប់ និងឆ្លៀតប្រជុំជាមួយ ដា, ខាំ, ដាយ, ដាំ, និង សុខ អំពីសភាពការណ៍នៅក្នុងឃុំ និងការអនុវត្តផែនការកន្លងមក ។ ស្អែកព្រឹកឡើង សុត បានវិលត្រឡប់មកកាន់ភូមិវិញ ដើម្បីរាយការណ៍ប្រាប់ សួយ ។ ក្រោយពី សួយ បានទទួលផែនការពី ថង, ដែង, និង ថា ឲ្យរៀបចំកម្លាំងដើម្បីធ្វើទំនប់ប្រកក្បឹបណ្តោយផ្លូវលេខ១៩ និងសង់ផ្ទះដើម្បីឲ្យកម្លាំងដែលមកធ្វើទំនប់ស្នាក់នៅ គាត់បានដកកម្លាំងប្រុសៗគ្រប់សហករណ៍ទូទាំងឃុំមកប្រមូលផ្តុំនៅសហករណ៍ស្រែក្រសាំងដើម្បីធ្វើផ្ទះស្នាក់នៅ ធ្វើទំនប់ និងកាប់ឆ្ការព្រៃ ។ ឆ្នាំ១៩៧៦ ថង, ដែង, និង សា បានមកដល់ឃុំ២ និងជួបប្រជុំជាមួយ សុត អំពីរឿងរៀបចំកម្លាំងសង់ផ្ទះឲ្យប្រជាជនស្នាក់នៅ និងបញ្ហាធ្វើទំនប់ ថាជាផែនការរបស់គាត់ មិនមែនជាផែនការរបស់អង្គការទេ ចំណែកផែនការរបស់អង្គការគឺឲ្យប្រជាជនធ្វើចម្ការ ប៉ុន្តែផ្ទុយទៅវិញ គាត់បានដកកម្លាំងប្រុសៗទៅសង់ផ្ទះអស់ ធ្វើដូច្នេះដើម្បីប្រឆាំងនឹងមាគ៌ារបស់អង្គការ ។ ម្យ៉ាងទៀត បើទិសដៅអង្គការឲ្យធ្វើទំនប់តូចដើម្បីយកទឹកធ្វើស្រែប្រាំង មិនចាំបាច់ធ្វើទេ ។ នៅក្នុងការប្រជុំនោះ ថង និង ដែង បានឲ្យ សុត និងអ្នកឯទៀតរាយការណ៍ពីខ្សែរយៈក្បត់នៅក្នុងឃុំ២នេះ និងប្រាប់ថាត្រូវទាក់ទងគ្នាឲ្យជាប់ពីឃុំមួយទៅឃុំមួយទៀត ម្យ៉ាងទៀតត្រូវលាក់ស្រូវទុកតាមព្រៃភ្នំឆ្ងាយៗ ព្រោះ

បើកាលណាបែកការណ៍សម្ងាត់ ទាំងអស់គ្នាអាចរត់ចូលពួនក្នុងព្រៃ ដូច្នេះ ត្រូវធ្វើយ៉ាងណាប្រមូលឲ្យបាន២០០ទៅ៣០០ប៉ោតក្នុងមួយឆ្នាំៗ ។ លើសពីនេះទៅទៀត ចំពោះក្រណាត់និងអំបិលដែលអង្គការផ្តល់ឲ្យត្រូវប្រមូលទុក ចំណែកស្រូវត្រូវត្រៀមទុកឲ្យបានច្រើន ព្រោះពេលណាទាំងអស់គ្នាចេញទៅ អាចយកប្រជាជនមួយចំនួនទៅជាមួយបាន ។ ខែមិថុនា ឆ្នាំ១៩៧៦ សុត បានចូលរួមធ្វើសកម្មភាពនៅក្នុងសហករណ៍ ដោយបំផ្លាញនិងបំភ្លៃមាគ៌ារបស់បក្ស គឺនៅពេលអង្គការឲ្យចិញ្ចឹមជ្រូក មាន់ និងទា សុត មិនឲ្យចិញ្ចឹមទេ ដោយលើកហេតុផលថាគ្មានចំណីឲ្យស៊ី ម្យ៉ាងទៀត ពេលប្រូតកាត់រួច សុត បានដឹកនាំឲ្យប្រជាជនដុតព្រៃឈើ ដុតចំបើង និងជញ្ជ្រាំងនៅតាមស្រែ ក្នុងគោលបំណងធ្វើឲ្យគោក្របីងាប់ដោយសារគ្មានស្មៅស៊ី ។

នៅឆ្នាំ១៩៧៧ សៃ និង សួយ បានហៅឈ្មោះ ផន, ហែម, ជុន, និង សុត ប្រជុំដើម្បីបូកសរុបការងារតាមផ្នែក ទាំងផ្នែកនយោបាយនិងផ្នែកកសាងកម្លាំង ដោយក្នុងនោះ សុត បានប្រាប់ពីកម្លាំងដែលទើបកសាងរួច រួមមាន ណាត់, ជិន, និង ខង ។ ក្រោយមក បន្ទាប់ពី ស៊ិន ឡៃ ដាក់ផែនការលើកទំនប់បន្ថែម សួយ បានហៅ សុត មកប្រជុំ ដើម្បីរៀបចំផែនការប្រឆាំងដោយ ទីមួយ) ទាំងអស់គ្នាជាអ្នកដឹកនាំឲ្យប្រជាជនធ្វើ ទីពីរ) បើមិត្តណាកាន់អីត្រូវបំផ្លាញរបស់ហ្នឹង ទីបី) ត្រូវក្តាប់ឲ្យជាប់ផែនការរបស់ ស៊ិន ឡៃ ទីបួន) ចលនាប្រជាជនមិនឲ្យប្រឹងធ្វើការពេក និងទីប្រាំ) ត្រូវដើរបំផុសឲ្យកងចល័ត និងកងកុមារដើរលួចសម្ភារៈនៅក្នុងសហករណ៍ ។ ជាលទ្ធផល ក្រោយពីប្រជុំរួច ទាំងអស់គ្នាបានរៀបចំអនុវត្តផែនការ ដោយរៀបចំជាកងតូចនិងកងធំ រួចឃោសនាមិនឲ្យប្រជាជនខំធ្វើការពេក និងលួចកាំបិតនិងពូថៅទៅទម្លាក់ចោលក្នុងទឹក ។ ថ្ងៃមួយ ជុន ដែលកាន់កាប់ខាងម៉ាស៊ីនភ្លើង បានដុតម៉ាស៊ីនភ្លើងឲ្យឆេះអស់ ក្រោយមកទៀត សុត បានដឹកនាំយុវជន កែវ ដែលជាកងចល័តទៅលួចអង្ករ៣០កំប៉ុង និងមាន់របស់សហករណ៍៥ក្បាលយកមកស្ងោរហូបជាមួយឈ្មោះ សៃ, ថុង, ផន, ជុន, ហែម, ខង, ជិន, និង សុត ទាំងយប់ ។ បន្ទាប់មកទៀត ជុន បាននាំ សុត ទៅប្រមូលបង្គី ចប និងប៉ែលដាក់មួយកន្លែងហើយចាក់ប្រេងដុត ។ ថ្ងៃក្រោយមកទៀត សុត និង សារ៉េម បានបំផុសឲ្យយុវជននិងយុវនារីធ្វើខុសសីលធម៌ជាមួយគ្នា និងមិនឲ្យខំប្រឹងធ្វើការ ។ ក្រោយពីចប់វគ្គលើកទំនប់ហើយ សៃ បានហៅ សុត, ជុន, ហែម, ទិត, ចែម, ខង, ជិន, ណាត់, ណែម, ឡុញ, ចាន់, និង លឿង មកប្រជុំដើម្បីរៀបចំផែនការថ្មីនៅក្នុងឆ្នាំ១៩៧៨ ទីមួយ) ធ្វើសកម្មភាពនៅក្នុងសហករណ៍គ្រប់រូបភាព ទីពីរ) ប្រឆាំងនឹងផែនការរបស់អង្គការ ទីបី) ត្រៀមលក្ខណៈជម្លៀសអំបិលនិងស្រូវទៅលាក់ទុកក្នុងព្រៃ ទីបួន) បំផុសប្រជាជនថា វៀតណាមជិតចូលមកដល់ទីកន្លែងនេះហើយ ទីប្រាំ) នៅរដូវវស្សាខាងមុខនេះ កុំឲ្យប្រជាជនធ្វើស្រែបានគ្រប់តាមផែនការរបស់អង្គការ និងទីប្រាំមួយ) កសាងកម្លាំងបង្កប់បន្ថែមទៀត ។

មកដល់ឆ្នាំ១៩៧៨ នៅខែកុម្ភៈ សុត បានទាក់ទងខូចសីលធម៌ចំនួនពីរដងជាមួយឈ្មោះ សាវុន ដែលជាយុទ្ធនារីកងចល័តឃុំ២ ។ ដល់ខែមីនា សុត បានដឹកនាំប្រជាជនធ្វើទំនប់តូចៗនៅក្បែរអូរសម្រាប់ដាក់ស្រែប្រាំង រួចលួចទម្លាយចោលដើម្បីមិនឲ្យប្រជាជនមានទឹកដាក់ស្រែ ។ លុះថ្ងៃក្រោយៗមកទៀត សួយ បានហៅ សុត, ថុង, ប៊ុនលី, ដួល, សៃ, ផន, ជុន, និង ហែម មកប្រជុំនៅផ្ទះរបស់ សៃ ម្តងទៀត អំពីផែនការក្បត់ ។ ក្រោយពីប្រជុំរួច នៅថ្ងៃទី២៥ ខែមីនា អង្គការបានហៅ សួយ, សៃ, ផន, និង ហែម ទៅស៊ីងត្រែងជាមួយ ស៊ិន ឡៃ ប៉ុន្តែបានរយៈពេល១០ថ្ងៃក្រោយ ស៊ិន ឡៃ ត្រឡប់មកវិញតែម្នាក់ឯង ចំណែកអ្នកផ្សេងៗទៀតបាត់ដំណឹងរហូត ។ មកដល់ខែមេសា ក្រោយពី សុត ទទួលបញ្ជាពីអង្គការឲ្យដឹកនាំប្រជាជនមួយក្រុមទៅកាប់សសរធ្វើឃ្លាំងដាក់សម្ភារៈ ឲ្យបានក្នុងរយៈពេល១៥ថ្ងៃ ពេលនោះ សុត បានបំផុសប្រជាជនមិនឲ្យខំធ្វើការ ដោយនាំគ្នាដើររកចាប់ត្រី និងរកផ្លែក្តួច ។ លុះដល់ខែឧសភា អង្គការបានចាត់តាំងឲ្យ សុត ទទួលខាងភ្ជួររាស់ ដោយត្រូវភ្ជួរឲ្យរវៃងដីនិងរាស់ឲ្យស្មើ ប៉ុន្តែ សុត បែរជាមិនឲ្យប្រជាជនធ្វើ ។ លើសពីនេះទៅទៀត សុត បានលែងគោក្របីឲ្យស៊ីសំណាបនិងសន្ទូងជាបន្តបន្ទាប់ ពិសេសគ្រាន់តែក្នុងរយៈពេលប៉ុន្មានថ្ងៃប៉ុណ្ណោះ សុត បានបំផ្លាញនង្គ័លអស់ចំនួន៦គ្រឿង ។ លុះព្រឹកស្អែក ថ្ងៃទី២៩ ខែមិថុនា ឆ្នាំ១៩៧៨ សុត ត្រូវបានអង្គការចាប់ខ្លួន ។ **ឆេស ម៉ារ៉ែម**

# ពិព័រណ៍មជ្ឈមណ្ឌលឯកសារកម្ពុជានៅខេត្តកំពង់ចាម

កាលពីថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០០៩ បុគ្គលិករបស់មជ្ឈមណ្ឌលឯកសារកម្ពុជាចំនួន៦រូប បានទៅចូលរួមកម្មវិធីតាំងពិព័រណ៍យុវជនលើកទី៨ ដែលរៀបចំដោយក្រុមប្រឹក្សាយុវជនកម្ពុជា និងវិទ្យាស្ថានសាធារណរដ្ឋអន្តរជាតិ ដែលប្រារព្ធឡើងនៅពហុកីឡដ្ឋាន ខេត្តកំពង់ចាម ។ នៅវេលាម៉ោង៥ល្ងាច បុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជាបានទៅមើលស្តង់តាំងពិព័រណ៍ ប៉ុន្តែការរៀបចំនៅមិនទាន់រួចរាល់ជាស្ថាពរនៅឡើយ ដោយសារអ្នករៀបចំកម្មវិធីនៅមិនទាន់កំណត់ទីតាំងពិព័រណ៍ច្បាស់លាស់ ។

នៅព្រឹកថ្ងៃបន្ទាប់ ក្រុមពិព័រណ៍បានទៅពិនិត្យមើលស្តង់ម្តងទៀត ។ យើងទទួលបានស្តង់ដែលមានបណ្តោយ៣ម៉ែត្រនិងទទឹង៣ម៉ែត្រ ដែលនៅខាងមុខជាប់ស្តង់របស់សកលវិទ្យាល័យវេទមហាបុស្សី ខាងឆ្វេងដៃជាប់សកលវិទ្យាល័យបច្ចេកទេសនៃកម្ពុជា និងខាងស្តាំដៃជាប់ក្រុមហ៊ុនលក់ផលិតផលរបស់ប្រទេសកូរ៉េ(ហ្គូសស៊ី) ។ ក្រុមពិព័រណ៍បានរៀបចំតុបតែងស្តង់លម្អដោយអំពូលភ្លើងនិងចង្ក្រងបដានៅខាងមុខ ដោយមានសរសេរជាអក្សរធំៗថា មជ្ឈមណ្ឌលឯកសារកម្ពុជា នៅចំហៀងខាងឆ្វេងដៃមានសរសេរអក្សរថា យុត្តិធម៌ និងនៅខាងស្តាំដៃសរសេរអក្សរថា ការចងចាំ ចំណែកនៅខាងក្នុងស្តង់មានពាក្យស្វែងរកការពិត ។

នៅថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០០៩ វេលាម៉ោង៧:៣០នាទីព្រឹក កម្មវិធីក៏បានចាប់ផ្តើមបើកសម្ពោធដោយមានការចូលរួមពីលោកជំទាវ ខុង ស៊ុនអេង អភិបាលរងខេត្តកំពង់ចាម លោក ចន វីល្លីស នាយកប្រចាំវិទ្យាស្ថានសាធារណរដ្ឋអន្តរជាតិ លោក ដូល រ៉េនដូល នាយកស្តីទីការិយាល័យអភិវឌ្ឍទូទៅ យូសេដ កញ្ញា ម៉ៅ ពុទ្ធីរ័ត្ន អ្នកសម្របសម្រួលក្រុមប្រឹក្សាយុវជនកម្ពុជា និងស្ថាប័នរដ្ឋ តំណាងអង្គការនានា ព្រមទាំងក្រុមហ៊ុនឯកជនជាច្រើនទៀត ។ បន្ទាប់ពីថ្លែងសុន្ទរកថាចប់ ក្រុមគណៈប្រតិភូបានដើរទស្សនាសកម្មភាពនៃការតាំងពិព័រណ៍នៅតាមបណ្តាស្តង់នីមួយៗ ។ នៅថ្ងៃទីមួយមានសិស្សានុសិស្ស លោកគ្រូអ្នកគ្រូ មន្ត្រីរាជការ អ្នកលក់ដូរ


អ្នកចូលរួមកំពុងអានសៀវភៅ នៅក្នុងស្តង់ពិព័រណ៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជា



សិស្សានុសិស្សកំពុងមើលសៀវភៅដែលចែកជូនដោយមជ្ឈមណ្ឌលឯកសារកម្ពុជា

និងបុគ្គលិកអង្គការនានាដែលមកពីតាមភូមិស្រុកខុសៗគ្នាបានមកចូលរួមយ៉ាងច្រើនកុះករ ។ ដូច្នេះដើម្បីឲ្យកម្មវិធីនេះប្រព្រឹត្តទៅល្អ និងទាក់ទាញចំណាប់អារម្មណ៍របស់អ្នកចូលមកទស្សនា ក៏ដូចជាជំនួយដល់ការយល់ដឹងរបស់យុវជន ពិព័រណ៍យុវជនក៏មានកម្មវិធីជាច្រើនទៀតដូចជា វគ្គបណ្តុះបណ្តាលស្តីពីការពិភាក្សាគោលនយោបាយរបស់យុវជននិងការបោះឆ្នោត សិក្ខាសាលាស្តីពីភាពជាអ្នកដឹកនាំនិងការអភិវឌ្ឍរបស់យុវជន វិធីជ្រើសរើសជំនាញសម្រាប់អាជីព ការសរសេរគម្រោងនិងការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព ។ ស្របពេលជាមួយគ្នានេះ ក៏មានអង្គការ និងក្រុមហ៊ុនឯកជនជាច្រើនដូចជា ក្រុមហ៊ុនបណ្តាញទូរស័ព្ទចល័តសាម៉ាត ក្រុមហ៊ុនទូរស័ព្ទដៃអិលជី ធនាគារអេអុិនហ្សិត រ៉ូយ៉ាល់ និងបណ្តាសាកលវិទ្យាល័យនានាដូចជា សាកលវិទ្យាល័យវេទមហាឫស្សី និងសាកលវិទ្យាល័យបច្ចេកទេសនៃកម្ពុជាចូលរួមផងដែរ ។

គោលបំណងនៃការតាំងពិព័រណ៍យុវជននេះគឺ ១) ផ្តល់ឱកាសឲ្យយុវជនយើងបង្ហាញនូវសមត្ថភាពផ្ទាល់ខ្លួនតាមរយៈការជជែកដេញដោលនិងឆ្លើយសំណួរ ២)ផ្តល់ចំណេះដឹងក្នុងការរៀបចំនិងកំណត់គោលដៅសម្រាប់ជីវិតដើម្បីក្លាយខ្លួនជាថ្នាក់ដឹកនាំនាពេលអនាគត ៣)ផ្តល់ឱកាសឲ្យយុវជនយើងបានរៀនសូត្រពីអ្វីដែលថ្មី ក្លាហានហ៊ានបញ្ចេញមតិយោបល់និងទទួលបាននូវបទពិសោធន៍ថ្មីៗដូចជា ផ្នែកបច្ចេកវិទ្យា កសិកម្ម ច្បាប់ចរាចរណ៍និងសុខភាព ។ សិស្សម្នាក់ឈ្មោះ សុន គីមសួគ៌ អាយុ១៩ឆ្នាំ មកពីវិទ្យាល័យព្រះសីហនុបានរៀបរាប់ថា «នេះជាលើកទីមួយហើយ ដែលខ្ញុំបានចូលរួមនៅក្នុងកម្មវិធីតាំងពិព័រណ៍យុវជននេះ ហើយខ្ញុំគិតថាពិព័រណ៍នេះល្អខ្លាំងណាស់ ព្រោះវាបានផ្តល់នូវចំណេះដឹងល្អៗជាច្រើនដល់យុវជនយើងទាក់ទងទៅនឹងផ្នែកបច្ចេកទេសនិងកសិកម្ម ជាពិសេសធ្វើឲ្យយុវជនក្លាហាន និងហ៊ានបញ្ចេញមតិយោបល់ចំពោះអ្វីដែលខ្លួនគិតថាល្អសម្រាប់សហគមន៍របស់ខ្លួន» ។ ចំណែក សុភាព អាយុ ២២ឆ្នាំ ជាសិស្សមកពីសាកលវិទ្យាល័យស៊ី.យូ.អេស បានរៀបរាប់ប្រាប់ថា «ខ្ញុំចង់ឲ្យមានកម្មវិធីតាំងពិព័រណ៍នេះម្តងទៀតនៅឆ្នាំក្រោយ ព្រោះវាបានផ្តល់ចំណេះដឹងទូលំទូលាយដល់យុវជនយើង ធ្វើឲ្យយុវជនយើងអាចបញ្ចេញស្នាដៃរបស់គេ និងមានលក្ខណៈប្រកួតប្រជែងគ្នា ម្យ៉ាងទៀតការតាំងពិព័រណ៍នេះបានធ្វើឲ្យយុវជនយើងមានគំនិតច្នៃប្រឌិត និងចេះចូលរួមចំណែកជួយដល់សហគមន៍» ។

នៅក្នុងកម្មវិធីតាំងពិព័រណ៍យុវជននេះដែរ មជ្ឈមណ្ឌលឯកសារកម្ពុជាបានដាក់តាំងសៀវភៅជាច្រើនក្បាលដូចជា សត្រូវបងប្អូនឯង ទម្លាយភាពស្ងប់ស្ងាត់ ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ និងសៀវភៅផ្សេងៗជាច្រើនទៀត ព្រមទាំងចែកទស្សនាវដ្តីស្វែងរកការពិតជាភាសាខ្មែរដោយឥតគិតថ្លៃដល់អ្នកដែលបានចូលមកអានសៀវភៅនេះ ។ នៅក្នុងថ្ងៃនោះ ក៏មានសិស្សានុសិស្ស លោកគ្រូអ្នកគ្រូ និងមន្ត្រីរាជការចូលមកអានសៀវភៅ និងសាកសួរព័ត៌មានទាក់ទងទៅនឹងប្រវត្តិសាស្ត្រខ្មែរក្រហម និងរឿងរ៉ាវទាក់ទងនឹងតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមដែរ ។ ទឹម សុវ៉ាត់ អាយុ១៨ឆ្នាំ មកពីវិទ្យាល័យព្រះសីហនុបានរៀបរាប់ប្រាប់ថា «តាមរយៈឯកសារផ្សេងៗ ដែលខ្ញុំបានសិក្សានៅសាលា និងបន្ទាប់ពីអានទស្សនាវដ្តីស្វែងរកការពិតរួច ខ្ញុំជឿជាក់ថាខ្មែរក្រហមពិតជាមានមែននៅក្នុងប្រទេសកម្ពុជា ហើយខ្ញុំគិតថានេះជាទង្វើអាក្រក់ដែលមិនត្រូវឲ្យក្មេងជំនាន់ក្រោយយកតម្រាប់តាមឡើយ ។ ដូច្នេះខ្ញុំសំណូមពរឲ្យយុវជនយើងរៀនសូត្រឲ្យបានច្រើន ព្រោះមានតែចំណេះដឹងនេះទេដែលអាចធ្វើឲ្យមនុស្សយើងដើរទៅរកផ្លូវល្អ ជួយកសាងសង្គម

ជាតិ និងមិនដើរតាមផ្លូវរបស់ខ្មែរក្រហម» ។ សិស្សម្នាក់ឈ្មោះ ហេង ប៊ុនហួរ អាយុ១៧ឆ្នាំ ជាសិស្សមកពីវិទ្យាល័យព្រះសីហនុ បានរៀបរាប់ប្រាប់ថា «ខ្ញុំចង់ឲ្យបញ្ចូលរឿងរ៉ាវទាក់ទងទៅនឹងរបបខ្មែរក្រហមទៅក្នុងកម្មវិធីសិក្សា ដើម្បីឲ្យក្មេងជំនាន់ក្រោយបានដឹង និងមិនដើរតាមទង្វើអមនុស្សធម៌របស់ខ្មែរក្រហម» ។ ខណៈពេលដែលមានមនុស្សជាច្រើនចូលមកទស្សនា យើងសង្ឃឹមថា កម្មវិធីនឹងប្រព្រឹត្តទៅតាមគម្រោងដែលបានគ្រោងទុក ស្រាប់តែក្រុមដែលមកតាំងពិព័រណ៍ទាំងអស់ក៏រៀបចំបិទស្តង់របស់ខ្លួនមុនកាលកំណត់គ្រប់ៗគ្នាទៅវិញ ដោយសារមានខ្យល់និងភ្លៀងធ្លាក់ជាខ្លាំង រហូតធ្វើឲ្យស្តង់ខ្លះទទួលរងការខូចខាតអីវ៉ាន់ដែលដាក់តាំង ។ លើសពីនេះទៅទៀត ដោយសារតែការដួលរលំបង្គោលភ្លើង ធ្វើឲ្យដាច់ចរន្តអគ្គិសនីបំភ្លឺ ទើបក្រុមពិព័រណ៍បានសម្រេចចិត្តបិទស្តង់នៅវេលាម៉ោង៤ល្ងាច ។

នៅថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០០៩ ដែលជាថ្ងៃបញ្ចប់ ក្រុមពិព័រណ៍បានចាប់ផ្តើមបើកស្តង់ម្តងទៀត នៅវេលាម៉ោង៨ព្រឹក ។ នៅថ្ងៃនេះ ទោះបីជាមានភ្លៀងធ្លាក់ពីម្សិលមិញក៏ដោយ ក៏សកម្មភាពនៃការតាំងពិព័រណ៍បានប្រព្រឹត្តទៅយ៉ាងល្អ ហើយសិស្សដែលចូលមកអានសៀវភៅនៅតែមានចំណាប់អារម្មណ៍ទាក់ទងនឹងរឿងរ៉ាវដែលកើតឡើងនៅក្នុងរបបខ្មែរក្រហមដដែល ។ សាន បូរ៉ា អាយុ១៩ឆ្នាំ ជាសិស្សមកពីវិទ្យាល័យគាមាងបានរៀបរាប់ប្រាប់ថា «ខ្ញុំធ្លាប់ឮរឿងរ៉ាវទាក់ទងនឹងរបបខ្មែរក្រហមតាមរយៈការសិក្សានៅក្នុងសាលារដ្ឋ ម្យ៉ាងវិញទៀត ឪពុកម្តាយ


ការចែកសៀវភៅរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា

យាយតា និងពូមីងរបស់ខ្ញុំ សុទ្ធតែធ្លាប់ឆ្លងកាត់របបនេះ ។ ខ្ញុំគិតថា ដើម្បីកុំឲ្យរបបនេះកើតឡើងសាជាថ្មីម្តងទៀត យើងត្រូវបណ្តុះធនធានមនុស្សដើម្បីឲ្យគាត់យល់ដឹងពីសង្គមបានច្រើន ប្រឆាំងអំពើពុករលួយនៅក្នុងសង្គម និងអនុវត្តលទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស ដើម្បីឲ្យប្រជាពលរដ្ឋគ្រប់រូបមានសិទ្ធិបញ្ចេញយោបល់ និងឈរឈ្មោះឲ្យគេបោះឆ្នោតឲ្យ ម្យ៉ាងទៀត ត្រូវផ្តល់ឱកាសឲ្យយុវជនយើងចូលរួមនៅក្នុងសហគមន៍ឲ្យបានច្រើន ជាពិសេសទាំងឪពុកម្តាយនិងលោកគ្រូអ្នកគ្រូត្រូវធ្វើជាគំរូដល់កូនក៏ដូចជាក្មេងៗជំនាន់ក្រោយផងដែរ» ។ នៅពេលរសៀល ក្រុមពិព័រណ៍នៅតែបន្តចែកទស្សនាវដ្តីស្វែងរកការពិតជាច្រើនក្បាលទៅឲ្យសិស្ស និងអ្នកដែលមកចូលអានសៀវភៅ និងចង់ស្វែងយល់បន្ថែមពីរបបខ្មែរក្រហម ។ ស្តង់តាំងពិព័រណ៍សៀវភៅរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា បានរៀបចំបិទនៅវេលាម៉ោង៧យប់ ដោយសារមានមនុស្សច្រើនកុះករមកចូលរួមទស្សនាការប្រគំតន្ត្រី ។ នៅយប់ថ្ងៃដដែលនេះ ក៏មានកម្មវិធីកម្សាន្តច្រើនសម្រាប់យុវជនដែលបានមកចូលរួមទស្សនាដូចជា ការប្រគំតន្ត្រី ល្បែងកម្សាន្ត សំណួរចម្លើយដើម្បីឈ្នះរង្វាន់ និងការប្រកាសឈ្មោះអ្នកដែលបានទទួលជ័យលាភីនៅក្នុងការប្រឡងចម្រៀង ។

នេះជាលើកទី២ហើយដែលពិព័រណ៍យុវជនត្រូវរៀបចំឡើងក្នុងខេត្តកំពង់ចាម បន្ទាប់ពីប្រារព្ធធ្វើនៅខេត្តបាត់ដំបង ខេត្តកំពង់ចាម ខេត្តតាកែវ ខេត្តស្វាយរៀង និងខេត្តពោធិ៍សាត់ ។ រយៈពេលពីរថ្ងៃនៃការដាក់តាំងពិព័រណ៍នេះ មជ្ឈមណ្ឌលឯកសារកម្ពុជាបានចែកសៀវភៅទស្សនាវដ្តីស្វែងរកការពិត បោះពុម្ពផ្សាយក្នុងឆ្នាំ២០០៩ និងសៀវភៅណែនាំពីការកាត់ទោសមេដឹកនាំខ្មែរក្រហម ដល់ភ្ញៀវដែលចូលមកអានសៀវភៅ ។ ទោះបីការតាំងពិព័រណ៍នេះត្រូវរំខានដោយសារសំឡេងធុងបាស់ ខ្យល់បោកបក់ខ្លាំង និងមានភ្លៀងធ្លាក់ច្រើនក៏ដោយ ក៏នៅតែមានភ្ញៀវចូលមកទស្សនាច្រើនជាងការតាំងពិព័រណ៍នៅខេត្តបាត់ដំបងដែរ ។ ដោយមានការចូលរួមយ៉ាងសកម្មពីក្រុមអង្គការយុវជនស្ម័គ្រចិត្ត សិស្ស និស្សិតតាមសាលានានា ទើបធ្វើឲ្យការតាំងពិព័រណ៍នេះអាចប្រព្រឹត្តទៅដោយជោគជ័យ ។

**ឆេស ម៉ារ៉ែម**

# ពិព័រណ៍យុវជនឆ្នាំ២០០៩ នៅក្រុងកំពង់ចាម

ពិព័រយុវជនលើកទី៨ បានចាប់ផ្តើមឡើងនៅចុងសប្តាហ៍ គឺពីថ្ងៃទី១៨-១៩ ខែកក្កដាក្នុងក្រុងកំពង់ចាម ។ ពិព័រណ៍យុវជននេះ បានរៀបចំឡើងដោយមានការគាំទ្រពីអង្គការយុវជនស្ម័គ្រចិត្តកម្ពុជា វិទ្យាស្ថានសាធារណរដ្ឋអន្តរជាតិ និងទីភ្នាក់ងារសហរដ្ឋអាមេរិកដើម្បីអភិវឌ្ឍន៍អន្តរជាតិ ។ នេះជាលើកទីពីរហើយដែលខេត្តកំពង់ចាមបានទទួលភ្ញៀវសំខាន់ចូលរួមក្នុងព្រឹត្តិការណ៍នេះ ប៉ុន្តែហាក់ដូចជាមិនមានវត្តមានជនជាតិបរទេសចូលមកទស្សនាច្រើននោះទេ ។ កាលពីឆ្នាំមុន នៅក្នុងកម្មវិធីរបស់ទូរទស្សន៍ អែមធីវី ដែលឧបត្ថម្ភដោយស្ថានទូតអាមេរិក ទូរទស្សន៍អែមធីវីនៅអឺរ៉ុប និងក្រុមការងាររាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកការជួញដូរមនុស្ស បានចាប់ផ្តើមរៀបចំកម្មវិធី និងប្រគំមន្ត្រីជាបន្តបន្ទាប់នៅក្នុងខេត្តកំពង់ចាម ដើម្បីបង្កើនការយល់ដឹងស្តីពីបញ្ហាជួញដូរមនុស្សឆ្លងកាត់ប្រទេសកម្ពុជា ។ ចំនួនអ្នកដែលបានចូលរួមក្នុងកម្មវិធីប្រគំតន្ត្រីនៅកន្លែងខ្លះមានរហូតដល់៦ម៉ឺននាក់ ។ នៅពេលនេះ ចំនួនអ្នកចូលរួមជាមួយនឹងពិព័រណ៍យុវជនមិនមានលក្ខណៈធំដុំដូចក្នុងកម្មវិធីទូរទស្សន៍អែមធីវីឆ្នាំមុនទេ ប៉ុន្តែវាបានប្រព្រឹត្តទៅដោយរលូនគួរឲ្យភ្ញាក់ផ្អើលនិងសប្បាយរីករាយ ដោយមានការចូលរួមទស្សនាយ៉ាងច្រើនពីប្រជាជន ។

ចំណុចសំខាន់នៃពិព័រណ៍នេះ គឺការផ្សព្វផ្សាយដោយផ្តោតទៅលើយុវជនដែលមានចំនួន៧០ភាគរយ ក្នុងចំណោមប្រជាពលរដ្ឋកម្ពុជាទាំងមូលឲ្យយល់ដឹងពីសារៈសំខាន់នៃការអប់រំនៅក្នុងប្រទេស និងថាតើវានឹងជួយអភិវឌ្ឍប្រទេសដោយរបៀបណា ។ តាមរយៈលោក មាន លុច ដែលជាមន្ត្រីគម្រោងរបស់វិទ្យាស្ថានសាធារណរដ្ឋអន្តរជាតិបានឲ្យដឹងថា យុវជនមានចំនួនតិចតួចនៅឡើយដែលបានចូលរួមនៅក្នុងកិច្ចការងារជាក់ស្តែង ជាមួយរដ្ឋាភិបាលនិងក្នុងសហគមន៍ ។ គាត់សង្ឃឹមថា ការតាំងពិព័រណ៍នេះ






នឹង «ផ្តល់ឲ្យយុវជននូវបទពិសោធន៍សម្រាប់យកទៅអនុវត្តឲ្យបានកាន់តែច្រើននៅក្នុងសង្គមប្រជាធិបតេយ្យ និងការងាររបស់អង្គការ»ផ្សេងៗ ។ ជាពិសេសគាត់ចង់ឲ្យ «យុវជនយល់ដឹងពីប្រព័ន្ធគ្រប់គ្រងរបស់រដ្ឋាភិបាល» ។

ការអប់រំពីលទ្ធិប្រជាធិបតេយ្យនិងកិច្ចការរបស់រដ្ឋាភិបាល ត្រូវបានកំណត់យ៉ាងច្បាស់លាស់នៅក្នុងប្រព័ន្ធអប់រំតាមសាលាក្នុងប្រទេសកម្ពុជា ។ ទាម សារឿន ជាសិស្សថ្នាក់ទី១២ នៅវិទ្យាល័យមួយក្នុងក្រុងកំពង់ចាម ត្រូវបានសុំឲ្យបកស្រាយអំពីនិយមន័យនិងពិពណ៌នាពីលទ្ធិប្រជាធិបតេយ្យ ។ បន្ទាប់មក សារឿន បានរៀបរាប់ថា «លទ្ធិប្រជាធិបតេយ្យគឺសេរីភាពក្នុងការនិយាយស្តី» ។ សារឿន មិនបានផ្តល់ការអត្ថាធិប្បាយច្រើនជាងនេះទេ ពីព្រោះអ្វីដែលបាននិយាយគឺ សារឿន បានចងចាំពីគ្រូដែលបង្រៀននៅសាលា ។ ជាការពិត លទ្ធិប្រជាធិបតេយ្យរួមបញ្ចូលសេរីភាពក្នុងការនិយាយស្តី ប៉ុន្តែថាតើសិទ្ធិផ្សេងទៀត និងលទ្ធិប្រជាធិបតេយ្យពេញលេញផ្តល់ឲ្យដូចម្តេចខ្លះ? ភាពបន្ទាន់សម្រាប់អប់រំយុវជន ដែលជាប់ទាក់ទងនឹងលទ្ធិប្រជាធិបតេយ្យគឺជាចំណុចខ្ពស់បំផុតបើប្រៀបធៀបពេលបច្ចុប្បន្នទៅនឹងថ្ងៃអនាគត ។

នៅក្នុងកិច្ចខិតខំប្រឹងប្រែងដើម្បីសម្រេចឲ្យបានគោលបំណងនេះ ពិព័រណ៍បានដាក់បញ្ចូលកម្មវិធីកំប្លែង និងការអប់រំជាច្រើនទៀត ។ កម្មវិធីកំប្លែងមានសារៈសំខាន់ណាស់ដើម្បីទាក់ទាញចំណាប់អារម្មណ៍យុវជន និងភ្ជាប់សកម្មភាពនេះដើម្បីបង្រៀនយុវជនដោយផ្ទាល់ផងដែរ ។ ល្បែងកម្សាន្ត ការធ្វើការងារជាក្រុម និងការប្រជុំ ជាសកម្មភាពអប់រំមួយក្នុងចំណោមសកម្មភាពអប់រំជាច្រើនទៀតដែលបានប្រព្រឹត្តទៅរយៈពេលពេញមួយថ្ងៃ ។ ភ្ញៀវអាចចូលរួមលេងល្បែងរុំមុខ វាយក្អម ឬល្បែងចោទសួរសំណួរទាក់ទងរឿងនយោបាយ ។ ពិព័រណ៍នេះបានអូសទាញប្រជាជនរាប់រយនាក់ឲ្យចូលមកប្រឡងចម្រៀង និងសម្តែងកាយវិការ ។ អ្នកដែលចូលចិត្តខាងវិស័យចម្រៀងមកពីគ្រប់តំបន់ត្រូវបានផ្តល់ឱកាសដើម្បីបង្ហាញពីសមត្ថភាពច្រៀងរបស់គេរៀងខ្លួន ។ នៅពេលនោះ ក្មេងប្រុសអាយុ៥ឆ្នាំ ក៏បានឡើងច្រៀងនៅលើឆាកដោយមិនមានការភ័យខ្លាចចំពោះមុខទស្សនិកជនរាប់រយនាក់ឡើយ ។

មានសកម្មភាពអប់រំសំខាន់ផ្សេងៗទៀត ដែលជាផ្នែកមួយនៃក្រុមប្រជុំពិភាក្សា ។ សិស្សពីរក្រុម ត្រូវបានផ្តល់ប្រធាន





បទដូចគ្នាមួយដើម្បីសួរដេញដោលទៅវិញទៅមក ដោយសិស្សក្រុមមួយឆ្លើយចម្លើយស្រប ហើយក្រុមមួយទៀតឆ្លើយចម្លើយប្រឆាំង ។ សិស្សទាំងពីក្រុមជជែកគ្នារហូតដល់ពេលវេលាកំណត់ ទើបអ្នកដឹកនាំកម្មវិធីបញ្ឈប់ ។ សិស្សទាំងពីរក្រុមត្រូវឈរនៅមួយកន្លែង បន្ទាប់មកក្រុមផ្សេងៗទៀតត្រូវបោះឆ្នោតជ្រើសរើសថាតើក្រុមមួយណាឈ្នះ ។ ការជជែកដេញដោលនេះជាសកម្មភាពអប់រំដ៏ល្អប្រសើរក្នុងចំណោមសកម្មភាពអប់រំផ្សេងៗទៀត ពីព្រោះវាបានភ្ជាប់ជាមួយការរិះគន់ដើម្បីកែលម្អការពិភាក្សាជាសាធារណៈ ការបោះឆ្នោត និងការចូលរួមជាមួយក្រុមដែលមកពីទីកន្លែងផ្សេងៗគ្នា ។

មានកិច្ចប្រជុំដាច់ដោយឡែកៗពីគ្នាជាច្រើនដែលភ្ញៀវអាចចូលរួម និងអាចជ្រើសរើសទៅតាមចំណង់ចំណូលចិត្តរបស់ខ្លួន ។ កិច្ចប្រជុំអាចឲ្យសិស្សទទួលសារប្រយោជន៍ពីអង្គការដែលទើបបង្កើតថ្មីហៅថា STUDENTs ។ គោលបំណងសំខាន់របស់អង្គការនេះគឺរៀបចំបណ្តុះបណ្តាលសិស្សពីវិធីស្វែងរកការងារ និងទទួលបានអាហារូបករណ៍ បន្ទាប់ពីគេបញ្ចប់ថ្នាក់វិទ្យាល័យ ។ មានសិស្សជាច្រើនមិនដឹងពីគោលបំណងរបស់ខ្លួនច្បាស់លាស់ថាត្រូវធ្វើអ្វីទៀតទេបន្ទាប់ពីបញ្ចប់ថ្នាក់វិទ្យាល័យ ដូច្នេះគោលបំណងសំខាន់បំផុតរបស់អង្គការ STUDENTs គឺដឹកនាំសិស្សឲ្យទៅរកទិសដៅត្រឹមត្រូវ ។

អង្គការ STUDENTs ជាអង្គការមួយក្នុងចំណោមអង្គការនិងក្រុមហ៊ុនឯកជនជាច្រើនដែលចូលរួមក្នុងកម្មវិធីតាំងពិព័រណ៍នេះ ។ សកលវិទ្យាល័យ អង្គការជាតិ-អន្តរជាតិ និងក្រុមហ៊ុនឯកជនជាច្រើនបានរៀបចំយ៉ាងសស្រាក់សស្រាំនៅក្នុងកម្មវិធីតាំងពិព័រណ៍ផងដែរ ។

អង្គការយុវជនស្ម័គ្រចិត្តបានអញ្ជើញអង្គការជាច្រើនមកពីគ្រប់ខេត្ត-ក្រុងក្នុងប្រទេសកម្ពុជា ដើម្បីបង្ហាញពីសកម្មភាពការងារនិងជំនាញផ្ទាល់ខ្លួន ។ កញ្ញា ម៉ៅ ពុទ្ធីរ័ត្ន អ្នកសម្របសម្រួលកម្មវិធីរបស់អង្គការយុវជនស្ម័គ្រចិត្តជឿជាក់ថា «អង្គការយុវជនស្ម័គ្រចិត្ត និងអង្គការដែលគាំទ្រកម្មវិធីនេះនឹងទទួលបានអត្ថប្រយោជន៍ពីគ្នាទៅវិញទៅមក» ។ ការបង្ហាញឲ្យស្គាល់ពីសកម្មភាពការងាររបស់អង្គការនីមួយៗនឹងផ្តល់ឲ្យសិស្សនូវបទពិសោធន៍



សិស្សានុសិស្សចូលរួមពិធីតាំងពិព័រណ៍

ថ្មី និងខុសប្លែកគ្នា និងផ្តល់ជម្រើសជាច្រើននៅពេលចូលមករៀនសូត្រនូវមុខជំនាញដែលគេចូលចិត្ត ។ បន្ថែមពីលើនេះ គោលបំណងសំខាន់នៃការធ្វើសហប្រតិបត្តិការនេះ គឺដើម្បីឲ្យយុវជនទាញយកប្រយោជន៍ពីកិច្ចការទាំងអស់នេះ ។ ដូច្នេះ កញ្ញា ម៉ៅ ពុទ្ធីរ័ត្ន ជំរុញយុវជនឲ្យ «ចំណាយពេលវេលាដើម្បីស្វែងរកស្នាដៃថ្មី និងការដាក់តាំងបង្ហាញនៅក្នុងពិព័រណ៍ផ្សេងៗគ្នា» ។

ចាប់តាំងពីពិធីតាំងពិព័រណ៍មិនទាន់ចាប់ផ្តើម សកម្មភាពជាច្រើនត្រូវបានរៀបចំឡើងដោយមិនគិតពីអាកាសធាតុប្រែប្រួលដែលមិនអាចស្មានទុកមុនបាន ។ ស្ទើរតែពេលមួយថ្ងៃ អាកាសធាតុក្តៅខ្លាំងជាមួយនឹងពន្លឺព្រះអាទិត្យចាំងមកចំស្តង់ពិព័រណ៍ដែលសង់នៅលើទីវាលបាល់ទាត់ ។ ទោះបីយ៉ាងណា វាមិនគួរឲ្យភ្ញាក់ផ្អើលទេដែលធ្វើឲ្យយើងគិតថានឹងមានភ្លៀងធ្លាក់មក ព្រោះវាស្ថិតនៅក្នុងរដូវវស្សា ។ នៅថ្ងៃសៅរ៍ ពិធីតាំងពិព័រណ៍ត្រូវខ្យល់បោកបក់យ៉ាងខ្លាំងបណ្តាលឲ្យរលំដួលរោង ។ ស្តង់ ដំបូល សម្ភារៈ និងដែកទ្រដំបូលរោងដែលចងបាំងពន្លឺថ្ងៃត្រូវបានបំផ្លាញដោយកម្លាំងខ្យល់បោកបក់ ។ ប្រជាជនបានរត់ចាកចេញពីទីនោះ ហើយខ្លះទៀតភ័យស្ទន់ស្ទោររត់រកកន្លែងជ្រក ។ បន្ទាប់ពីខ្យល់ស្ងប់ស្ងាត់ ប្រជាជនចាប់ផ្តើមរៀបចំរោងពិព័រណ៍និងតុបតែងស្តង់របស់ខ្លួនឡើងវិញ ។

អ្នកនឹងមិនគិតថានៅទីនោះទេ ប៉ុន្តែអ្នកហាក់ដូចជាមានអារម្មណ៍ថាកំពុងស្ថិតនៅក្នុងផ្សារទំនើប នៅពេលដែលអ្នកដើរជុំវិញស្តង់តាំងពិព័រណ៍ទាំងនេះ ។ នៅតាមស្តង់នីមួយៗសុទ្ធតែមានដាក់តាំងផលិតផលរបស់ខ្លួន ឬសេវាកម្មសម្រាប់បម្រើជូនអតិថិជន ។ មានក្រុមហ៊ុនជាច្រើនដូចជាក្រុមហ៊ុនទូរស័ព្ទ ក្រុមហ៊ុនលក់គ្រឿងសម្អាងហ្វីឡា ក្រុមហ៊ុនលក់ភេសជ្ជៈយូអែហ្វស៊ី និងធនាគារអេអុិនហ្សិត ដែលជាក្រុមហ៊ុនធំក្នុងពិធីតាំងពិព័រណ៍បានរៀបចំការប្រជុំ និងចាប់ឆ្នោតយករង្វាន់នៅតាមស្តង់រៀងៗខ្លួន ។ មានការផ្សព្វផ្សាយផលិតផលជាច្រើនមុខទៀតនៅតាមបណ្តោយផ្លូវក្នុងកន្លែងតាំងពិព័រណ៍ និងមានផលិតផលខ្លះទៀតបានចែកជូនភ្ញៀវចូលមកទស្សនាដោយមិនគិតថ្លៃ ។ ការខិតខំទាំងអស់នេះហាក់ដូចជាបង្កើតឲ្យមានភាពអ៊ូអរយ៉ាងសម្បើមនៅគ្រប់ស្តង់ដែលអ្នកបានឃើញយ៉ាងហោចណាស់ មានមនុស្សម្នាក់ពាក់អាវ ឬផឹកភេសជ្ជៈដែលមានស្លាកសញ្ញារបស់ក្រុមហ៊ុនមួយ ។ ទោះបីយ៉ាងណាក្តី នៅខណៈពេលនោះក៏មានការផ្សព្វផ្សាយពីផលិតផលរបស់ខ្លួន ឬចាក់បទចម្រៀងដោយបើកសំឡេងខ្លាំងៗ ។ លើសពីនេះទៅទៀត សំឡេងធុងបាស់ខ្លាំងៗចេញពីស្តង់នីមួយៗ បានលាន់ឮនៅពេលតែមួយ ដែលបង្កឲ្យមានការរំខានយ៉ាងខ្លាំង ព្រោះធ្វើឲ្យយើងមិនអាចស្តាប់ឮ ឬពិភាក្សាគ្នាបាននៅកន្លែងនោះ ។

នៅសហគមន៍ក្នុងក្រុងកំពង់ចាមទាំងមូលបានទទួលសារប្រយោជន៍ជាច្រើនពីការតាំងពិព័រណ៍ ដែលរៀបចំដោយអង្គការយុវជនស្ម័គ្រចិត្ត ។ មានអ្នកលក់អាហារជាច្រើននៅច្រកចូលកន្លែងតាំងពិព័រណ៍ និងមានមុខម្ហូបខុសប្លែកពីគ្នាតាមបែបកម្ពុជា ដែលទាក់ទាញភ្ញៀវឲ្យចូលមកទិញ ។ ចំណែកនៅតាមបណ្តោយជញ្ជាំងរបងកីឡដ្ឋានខេត្តកំពង់ចាម មានកំប្លែង និងល្បែងគប់ប៉ឹតប៉ោង ។ យើងត្រូវចំណាយលុយមួយពាន់រៀលដើម្បីទិញព្រួញមួយ បន្ទាប់មកត្រូវយកព្រួញនោះគប់ទៅលើប៉ឹតប៉ោងដែលដាក់តម្រៀបគ្នានៅតាមប្រឡោះឈើដើម្បីយករង្វាន់ ។

គ្រប់កម្មវិធីទាំងអស់បានរៀបចំឡើងសម្រាប់យុវជន ។ ទាំងពីរាត្រី មានអ្នកចម្រៀងល្បីៗនៅក្នុងប្រទេសកម្ពុជាបានមកច្រៀងក្នុងកម្មវិធីប្រគុំតន្ត្រីក្នុងកីឡដ្ឋានក្រុងកំពង់ចាមផងដែរ ។ នៅពេលរសៀល តាមផ្លូវមុខកីឡដ្ឋានក្រុងកំពង់ចាមចាប់ផ្តើមកកស្ទះ ដោយសារចំនួនមនុស្សកាន់តែច្រើនឡើងបានប្រជ្រៀតគ្នាចូលមកទស្សនាការប្រគុំតន្ត្រី ។ នេះជាប្រការមិនល្អនៅពេលរាត្រី និងមិនអាចគ្រប់គ្រងបាននៅពេលចំនួនមនុស្សកាន់តែច្រើនសម្រុកចូលមក និងខ្លះទៀតបានប្រជ្រៀតរកផ្លូវចេញទៅក្រៅកីឡដ្ឋានវិញ ព្រោះកីឡដ្ឋានមានច្រកចេញនិងច្រកចូលតែមួយប៉ុណ្ណោះ ។ ទាំងអស់នេះជាចំណុចអាក្រក់នៅពេលដែលមានស្ថានការណ៍ចលាចលកើតឡើង ។

សរុបមក ពិព័រណ៍យុវជនបានផ្តល់ឱកាសដ៏ល្អសម្រាប់យុវជននិងក្មេងជំទង់ ដែលបានចូលរួមលេងល្បែងកម្សាន្ត និងសកម្មភាពអប់រំ ។ បទពិសោធន៍ និងចំណេះដឹងទាំងនេះ មិនត្រឹមតែបង្កើនគុណសម្បត្តិផ្ទាល់ខ្លួនប៉ុណ្ណោះទេ ថែមទាំងអាចជួយឲ្យគេយល់ដឹងទៅថ្ងៃអនាគតទៀតផង ។ ពិព័រណ៍យុវជននេះ គឺជាព្រឹត្តិការណ៍មួយដែលយើងមិនអាចបំភ្លេចបាន ។

**ខ្យៀន គូនី**

# ឌុច បដិសេធជនរងគ្រោះម្នាក់ទៀតដែលបានជាប់នៅមន្ទីរស-២១



លី ហ៊ី ក្នុងឆ្នាំ២០០៩

សាលាក្តីចាប់ផ្តើមសវនាការនៅថ្ងៃទី៦ ខែកក្កដានេះ ដោយប្រកាសអំពីការដកចេញនូវសាក្សីម្នាក់ពីបញ្ជីឈ្មោះដែលគ្រោងនឹងធ្វើជាសក្ខីកម្មនៅការកាត់ក្តីលើករណី កាំង ហ្គេចអ៊ាវ ហៅ ឌុច ។ បន្ទាប់ពីហេតុការណ៍ដ៏កម្រមួយនៃការធ្វើសក្ខីកម្មដោយ លី ហ៊ី ដើមបណ្តឹងរដ្ឋប្បវេណី ហើយដែលអាចនឹងផ្តល់ពន្លឺដល់ហេតុការណ៍ពិតប្រាកដបន្ថែមទៀត ខ្ញុំរំពឹងថាសាលាក្តីនឹងបន្ថែមបទដ្ឋាននៃការតាមរកព័ត៌មានតាមវិធីផ្សេងទៀត បើមិនដូច្នេះទេសាក្សីច្រើនទៀតនឹងត្រូវបានដកចេញពីបញ្ជី ។

សប្តាហ៍មុន មួយថ្ងៃបន្ទាប់ពីការផ្តល់សក្ខីកម្មដ៏លម្អិតដោយអតីតអ្នកទោសកុមារម្នាក់ឈ្មោះ នង ចាន់ផល ឌុច បានប្រកែកថា នង ចាន់ផល មិនមែនជាអ្នកទោសនៅមន្ទីរស-២១ទេព្រោះក្មេងៗទាំងអស់ត្រូវបានសម្លាប់ដោយគោលនយោបាយអង្គការ ហើយគ្មានកុមារណាម្នាក់អាចគេចខ្លួនពីការសម្លាប់នេះបានទេ ។ ឌុច បានសង្កត់ធ្ងន់ថា មិនមានឯកសារណាមួយបញ្ជាក់ថា ចាន់ផល និងម្តាយរបស់គាត់បានមកដល់ទួលស្លែងទេ ។ ការប្រកែករបស់ ឌុច នេះកើតឡើងនៅពេលរសៀល ហើយបានធ្វើឲ្យដើមបណ្តឹងរដ្ឋប្បវេណីព្រមទាំងមេធាវីក្រុមរន្ធត់ចិត្តជាខ្លាំង ។ ថ្ងៃនេះក្រុមការពារក្តីរបស់ ឌុច បានឈានដល់ដំណាក់កាលថ្មីមួយដោយប្រាប់ទៅតុលាការថា សាក្សីត្រូវតែជាអតីតអ្នកទោសមន្ទីរស-២១ មុននឹងកោះហៅឲ្យមកធ្វើសក្ខីកម្ម ។ ក្រុមការពារក្តីបានបញ្ជាក់ថា ខ្លួនបានតវ៉ាកាលពីមុនរួចហើយ ដូច្នេះមេធាវីក្រុមហើយនិងដើមបណ្តឹងរដ្ឋប្បវេណីអាចសួរសំណួរដល់សាក្សីជាមុន មុននឹងមកធ្វើសក្ខីកម្ម ។ ប្រធានមេធាវីក្រុម លោក និល ណុន បានច្រានចោលសំណើនេះទុកមួយឡែកដោយឆ្លើយតបថា ក្រុមការពារក្តីនឹងទទួលបានឱកាស និងផ្ទៀងផ្ទាត់សេចក្តីថ្លែងការណ៍របស់ លី ហ៊ី ឡើងវិញក្នុងអំឡុងពេលនៃការសួរសំណួររបស់ក្រុមការពារក្តី ។ ប៉ុន្តែមិនយូរប៉ុន្មានបន្ទាប់ពីប្រធានមេធាវីក្រុមបញ្ជាក់ពីការធ្វើសក្ខីកម្មរបស់សាក្សី សំណួរជាច្រើនបានចេញមកពីបន្ទប់កាត់ក្តី ដោយសួរត្រង់ៗទៅកាន់ លី ហ៊ី អំពីថាតើគាត់ជាអ្នកទោសនៅមន្ទីរស-២១ពិតមែនដែរឬទេ ។

លី ហ៊ី ដែលមានអាយុ៥៧ឆ្នាំ មានការលំបាកនឹងយល់ពីសំណួរដែលបានចោទសួរមកលើគាត់ក្នុងការរំឭកហេតុការណ៍ឡើងវិញនៅរវាងឆ្នាំ១៩៧៥-១៩៧៩ ។ បន្ទាប់ពីផ្តាច់ខ្លួនចេញពីកងទ័ពខ្មែរក្រហម ហើយក្រោយពីត្រូវបានចាប់ខ្លួនក្នុងឆ្នាំ១៩៧៥ គាត់បានជាប់ក្នុងមន្ទីរឃុំឃាំងចំនួនបួនកន្លែងផ្សេងៗ ក្នុងនោះមានមន្ទីរសន្តិសុខរបស់មន្ទីរ១៥ គុកពេទ្យវិកលចរិតតាខ្មៅ មន្ទីរស-២១ និងជំរំកែប្រែព្រៃសដែលត្រូវបានគេស្គាល់ថាជាមន្ទីស-២៤ ។ គាត់ហាក់បីដូចជាមានការស្រពេចស្រពិលក្នុងការចងចាំអំពីហេតុការណ៍ដែលគាត់បានជួបប្រទះនៅកន្លែងទាំងបួននេះ ហើយការឆ្លើយក្នុងអំឡុងពេលនៃការធ្វើសក្ខីកម្មក៏មានភាពច្របូកច្របល់ដែរ ។ នៅតាខ្មៅ គាត់បានអះអាងថា គាត់ត្រូវបានសួរចម្លើយបីដង ហើយត្រូវវាយឲ្យសារភាពកំហុស មុននឹងគាត់ត្រូវបានបញ្ជូនទៅមន្ទីរស-២១ ជាកន្លែងដែលគាត់ត្រូវបានសួរចម្លើយតែម្តងគត់ ។ គាត់បានជាប់នៅមន្ទីរស-២១ ប្រមាណជាមួយខែ មុននឹងត្រូវបញ្ជូនទៅកាន់មន្ទីរស-២៤ ជាកន្លែងដែលគាត់គេចខ្លួនរួចដោយហែលទឹកឆ្លងទន្លេពីម្ខាងទៅម្ខាង ។

ពេលអ្នកទោសនៅមន្ទីរស-២១ ទាំងបួននាក់ ដែលបានធ្វើសក្ខីកម្មកាលពីសប្តាហ៍មុន សុទ្ធតែបានបង្ហាញនូវព័ត៌មានលម្អិតស្រដៀងគ្នា ចំណែកឯការធ្វើសក្ខីកម្មរបស់ លី ហ៊ី វិញ មានលក្ខណៈខុសគ្នាពីអ្វីដែលអ្នកទោសទាំងបួននាក់បានឆ្លើយ ។ លី ហ៊ី មិនចាំថាតើគាត់ត្រូវបានថតរូបឬក៏អត់នោះទេ ពេលដែលគាត់ចូលដល់មន្ទីរស-២១ ។ ហ៊ី បាននិយាយថា គាត់មិនទទួលបានលេខសម្គាល់ខ្លួនផងទេ ។ គាត់ត្រូវបានដោះខ្នោះដៃចេញ ហើយ

បានមុជទឹកបីដងក្នុងមួយសប្តាហ៍ នៅខាងក្រោយបន្ទប់ឃុំឃាំង ។ គាត់ក៏ត្រូវបានអនុញ្ញាតឲ្យស្លៀកពាក់ជាធម្មតា ហើយទទួលបានបាយនិងសម្លពីរពេលក្នុងមួយថ្ងៃ ។ គាត់បានពណ៌នាអំពីកងការពារថាជាជនគួរឲ្យខ្លាច ហើយគាត់បានរំឭកថា មានកងការពារម្នាក់បានឲ្យថ្នាំមកគាត់ ។ គាត់មិនបានទទួលរងនូវទារុណកម្មទេ តែគាត់ត្រូវបានវាយធ្វើបាបដោយសារតែធ្វើឲ្យកំពប់ធុងទឹកនោមរួមនៅក្នុងបន្ទប់ឃុំឃាំង ។ នៅពេលមានមនុស្សម្នាក់ស្លាប់នៅក្នុងបន្ទប់ឃុំឃាំង សាកសពត្រូវបានយកចេញភ្លាមៗ ។ ស្ថានភាពនិងលក្ខខណ្ឌដែលគាត់បានរៀបរាប់ មានភាពមនុស្សធម៌ច្រើនជាងអ្នកទោសដទៃទៀតដែលតែងតែពិពណ៌នាក្នុងពេលវេលាយ៉ាងលម្អិតម្តងហើយម្តងទៀត ។ លី ហ៊ា បានបង្ហាញនៅក្នុងតុលាការថា គាត់ដឹងថាគាត់នៅមន្ទីរស-២១ ព្រោះឆ្មាំម្នាក់បានប្រាប់គាត់ថា ទីនេះគឺជាមន្ទីរស-២១ ។

ការបង្ហាញរបស់ លី ហ៊ា កាន់តែធ្វើឲ្យច្របូកច្របល់ចំពោះឯកសារដែលប្រើប្រាស់ដោយអង្គជំនុំជម្រះដើម្បីបញ្ជាក់ច្បាស់ពីរូបគាត់ផ្ទាល់រួមមានដូចជា ប្រវត្តិរូបផ្ទាល់ខ្លួន និងចម្លើយសារភាព ។ ឯកសារទាំងនោះមានត្រឹមតែជាភាសាខ្មែរប៉ុណ្ណោះ ហើយមានកង្វះខាតនូវព័ត៌មានដើម និងយកមកពីមជ្ឈមណ្ឌលឯកសារកម្ពុជា ដែលជាអង្គការក្រៅរដ្ឋាភិបាលមួយមានមូលដ្ឋាននៅទីក្រុងភ្នំពេញ ។

ខណៈពេលដែលឯកសារភាគច្រើនបានដាក់ជូនអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា រួមទាំងពាក្យសុំធ្វើជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ លី ហ៊ា ផង គាត់បានធ្វើឲ្យអង្គជំនុំជម្រះមានការភាន់ច្រឡំយ៉ាងខ្លាំងអំពីធាតុដើមនៃឯកសារដែលសរសេរឡើងដោយ លី ហ៊ា ផ្ទាល់ ហើយគាត់ក៏បានធ្វើឲ្យមានការភាន់ច្រឡំដែរ ពេលដែលគាត់និយាយនៅចំពោះមុខតុលាការនូវឯកសារពាក្យសុំរបស់គាត់ ។ មេធាវីរបស់ លី ហ៊ា ឈ្មោះ អាលែន វើនើ បានស្នើថា ឯកសារទាំងនោះគួរតែអានដើម្បីឲ្យដើមបណ្តឹងរដ្ឋប្បវេណីជ្រាប ។ អាលែន បានទទួលការស្តីបន្ទោសពីសំណាក់ចៅក្រម ស៊ីលវៀ ខាតវ៉្រាយត៍ ដោយសារតែកង្វះខាតនូវឯកសារ ហើយចៅក្រមនោះបានស្នើឲ្យ អាលែន យល់ព្រមអះអាងខ្លួនឯងថាជាសាក្សី គឺ «មានការរៀបចំដោយគ្មានរបៀបរៀបរយ» ។ លោក អាលែន បានពន្យល់តបទៅវិញថា មានបញ្ហាក្នុងការយកឯកសារមកបកប្រែ ហើយនិយាយទៀតថា គាត់បានជួបជាមួយសាក្សីបីដងរួចទៅហើយ មុននឹងសាក្សីឡើងមកបង្ហាញនៅពេលនេះ ។ ចៅក្រម ខាត់វ៉្រាយត៍ បានបញ្ជាក់ថា គាត់និងសហការីរបស់គាត់រំពឹងថា ដើមបណ្តឹងរដ្ឋប្បវេណីនឹងរៀបចំកិច្ចការងារឲ្យបានប្រសើរជាងនេះនៅថ្ងៃក្រោយ ។

ចៅក្រម ឡាវើញ បានបញ្ជាក់ពីបញ្ហានៃធាតុដើមរបស់ឯកសារ ហើយលោក អាលែន វិញបានស្នើថា គាត់អាចយកឯកសារជាលាយលក្ខណ៍អក្សរដែលគាត់បានស្បថស្បែជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជាថា ឯកសារដែលគាត់បានបង្ហាញនេះគឺពិតជាយកពីមន្ទីរស-២១មែន ។ ក្រោយមក ក្រុមការពារក្តីបានសួរសំណួរជាច្រើនអំពីទំនាក់ទំនងគ្នាទៅវិញទៅមករវាង លី ហ៊ា ជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា ។ ស្រដៀងគ្នាទៅនឹងសំណួរដែលសួរទៅ នង ចាន់ផល ដែរ សំណួររបស់ក្រុមការពារក្តីទៅកាន់ លី ហ៊ា អាចមានន័យថា លី ហ៊ា ត្រូវបានមជ្ឈមណ្ឌលឯកសារកម្ពុជាផ្តល់ប្រវត្តិរូបមកគាត់ដែលធ្វើឲ្យគាត់មានគំនិតថា គាត់ត្រូវបានជាប់នៅមន្ទីរស-២១ តែការពិតគាត់បានជាប់នៅមន្ទីរឃុំឃាំងផ្សេងទៅវិញ ។ ក្នុងកាលៈទេសៈខ្លះ ក្រុមការពារក្តីអាចមានការងាយស្រួលឬមិនងាយស្រួលក្នុងការសង្កេតឃើញថា មជ្ឈមណ្ឌលឯកសារកម្ពុជាអាចនឹងមិនអាចមានការលម្អៀងដល់ដំណើរនៃការធ្វើសក្ខីកម្មរបស់ លី ហ៊ា នេះ ។ មជ្ឈមណ្ឌលឯកសារកម្ពុជាបានចំណាយពេល១២ឆ្នាំ ដើម្បីប្រមូលនិងចងក្រងឯកសាររាប់រយពាន់សន្លឹកអំពីរបបខ្មែរក្រហម ហើយឯកសារទាំងនោះមានចំនួនគិតជាភាគរយច្រើនជាងគេបំផុតដែលប្រើសម្រាប់កាត់ទោស ឌុច ដែលផ្តល់ជូនដល់អង្គជំនុំជម្រះដោយមជ្ឈមណ្ឌលឯកសារកម្ពុជា ។ បើសិនជាមជ្ឈមណ្ឌលឯកសារកម្ពុជាពិតជាមានភាពលម្អៀងពិតមែន នេះនឹងជះឥទ្ធិពលយ៉ាងខ្លាំងដល់មជ្ឈមណ្ឌលឯកសារកម្ពុជា ។ បើតាមគំនិតខ្ញុំ គ្មានភ័ស្តុតាងណាមួយដើម្បីបញ្ជាក់ពីការអះអាងរបស់ក្រុមការពារក្តីចំពោះការចោទប្រកាន់ថា មជ្ឈមណ្ឌលឯកសារកម្ពុជាមានការលម្អៀងនោះឡើយ ។

ចំណុចដែលគួរឲ្យចាប់អារម្មណ៍បំផុតនៃដំណើរការកាត់ក្តីថ្ងៃនេះគឺពេលដែល ឌុច ត្រូវបានផ្តល់ឱកាសក្នុងការឆ្លើយតបទៅនឹង

ការធ្វើសក្ខីកម្មរបស់ លី ហ៊ី ។ បន្ទាប់ពីភាពច្របូកច្របល់នៃការសួរនិងឆ្លើយដែលសឹងតែគ្មាននរណាដឹងថានឹងមានរឿងអ្វីកើតឡើង ឌុច បានក្រោកឈរឡើងដោយមានទំនុកចិត្តលើខ្លួនឯង ហើយបានធ្វើសេចក្តីថ្លែងការណ៍យ៉ាងមានរបៀបរៀបរយ ។ ឌុច បានអះអាងថា ឯកសារខ្លួនចេញមកពីមន្ទីរស-២១ ព្រោះមានសេចក្តីកំណត់ចំណាំមួយចំនួនធ្វើឡើងដោយកូនចៅរបស់គាត់ចំនួនពីរនាក់ដែលគាត់នៅចាំបានយ៉ាងច្បាស់ ។ ឌុច បានចង្អុលបង្ហាញថា «អ៊ា ហ៊ី» ដែលជាឈ្មោះរបស់ លី ហ៊ី ហើយមកដល់មន្ទីរស-២១ មុនឆ្នាំ១៩៧៩នោះ ត្រូវបានដាក់ចូលក្នុងបញ្ជី «កម្ទេច» របស់មន្ទីរស-២១ ។ ឯកសារមួយផ្សេងទៀតបានបញ្ជាក់ថា «អ៊ា ហ៊ី» ត្រូវបានដោះលែង ។

នៅក្នុងស្ថានភាពនេះ ហើយស្រដៀងគ្នាទៅនឹងស្ថានភាពនៅមន្ទីរផ្សេងទៀតដែរ ឌុច បានបញ្ជាក់ច្បាស់ថា គ្មានអ្នកទោសណាម្នាក់ត្រូវបានដោះលែងទេ ហើយ ណាត ដែលជាប្រធានមន្ទីរស-២១ ដំបូងបានធ្វើបញ្ជី «ដោះលែងអ្នកទោស» ក្លែងក្លាយដើម្បីលុបលាងការសម្លាប់ដែលគ្មានការបញ្ជាពីថ្នាក់លើ ។ ឌុច បាននិយាយថា «តាមរយៈឯកសារទាំងអស់នេះ បានបញ្ជាក់ច្បាស់ថាសមមិត្ត អ៊ា ហ៊ី បានស្លាប់បាត់ទៅហើយ» ។ ក្នុងនាមជាអតីតគ្រូគណិតវិទ្យាម្នាក់ ឌុច បានបូកដកអាយុទៅតាមថ្ងៃខែឆ្នាំ ហើយបានបញ្ជាក់ថា អាយុរបស់ «អ៊ា ហ៊ី» ដែលបានចុះនៅក្នុងបញ្ជីមិនមានលក្ខណៈស៊ីគ្នាទៅនឹងអាយុរបស់ លី ហ៊ី ទេ ។ ឌុច ក៏បានទទួលស្គាល់ថា លី ហ៊ី បានទទួលរងនូវការឈឺចាប់ ហើយទទួលរងនូវទារុណកម្ម ប៉ុន្តែគាត់បានបញ្ជាក់ថារឿងនេះកើតឡើងនៅមន្ទីរផ្សេងក្រៅពីមន្ទីរស-២១ ។

បញ្ជីឈ្មោះអ្នកទោសដែលបានកែប្រែថ្មីបានបញ្ជាក់ថា អ៊ា ហ៊ី បានចូលដល់មន្ទីរស-២១ នៅថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ១៩៧៥ ។



ប្រវត្តិរូបរបស់ អ៊ា ហ៊ី នៅមន្ទីរស-២១

នៅពេលដែលក្រុមការពារក្តីសួរ លី ហ៊ី ថាគាត់នៅឯណានៅថ្ងៃនោះ? លី ហ៊ី បានឆ្លើយថា គាត់កំពុងរស់នៅក្នុងស្រុកកំណើតរបស់គាត់ ។ មេធាវីការពារក្តីរបស់ លី ហ៊ី មិនបានបញ្ជាក់ឲ្យច្បាស់ ប៉ុន្តែក៏បដិសេធថាការដែលមានឈ្មោះ អ៊ា ហ៊ី នៅក្នុងបញ្ជីអ្នកទោសនោះគឺពិតជា អ៊ា ហ៊ី ដែលមាននៅក្នុងប្រវត្តិរូបនិងចម្លើយសារភាពដែលត្រូវបានយកមកបង្ហាញនៅអង្គជំនុំជម្រះពេញមួយថ្ងៃនោះឡើយ ។

នៅថ្ងៃនេះគ្មាននរណាម្នាក់សាកសួរដោយចំហពីគោលបំណងរបស់ លី ហ៊ី ទេ ។ ម្នាក់ៗហាក់បីដូចជាយល់ថា លី ហ៊ី ជាជនរងគ្រោះដែលមានភាពភ័យរន្ធត់និងបាក់ស្បាត ហើយគាត់បានប្រឹងអស់ពីសមត្ថភាពដើម្បីរំឭករឿងរ៉ាវឡើងវិញកាលពី៣០ឆ្នាំមុនៗ ។ បើទោះជាសក្ខីកម្មរបស់គាត់បញ្ជាក់ថា គាត់អាចមានលទ្ធភាពនឹងត្រូវបានដោះលែងពីមន្ទីរស-២១ ទៅមន្ទីរស-២៤ ហើយអាចនឹងមានលទ្ធភាពរត់រួចពីមន្ទីរស២៤នេះក៏ដោយ ក៏នៅមានភាពស្រពេចស្រពិលថាតើអង្គជំនុំជម្រះនឹងដាក់ទម្ងន់ប៉ុន្មានទៅលើសក្ខីកម្ម លី ហ៊ី ។

**ឡូរ៉ា ម៉ាកដូណល**

# អក្សរសិល្ប៍ដែលរស់រានមានជីវិត

ស្រដៀងគ្នាទៅនឹងអក្សរសិល្ប៍របស់ជនជាតិជ្វីហ្វអឺរ៉ុប បន្ទាប់ពីអំពើប្រល័យពូជសាសន៍ជ្វីហ្វដែរ មនុស្សម្នាក់ៗសុទ្ធតែមើលឃើញអក្សរសិល្ប៍ខ្មែរដែលរស់រានមានជីវិតពីរបបខ្មែរក្រហម ជាផ្នែកមួយនៃការព្យាយាមរបស់អ្នកនិពន្ធមួយចំនួនដើម្បីប្រាប់ពិភពលោកអំពីទំហំនៃការបំផ្លិចបំផ្លាញដែលអ្នកនិពន្ធទាំងនោះនិងប្រជាជនរបស់គេបានឆ្លងកាត់ ។ អក្សរសិល្ប៍នេះ គឺជាកិច្ចខិតខំប្រឹងប្រែងរបស់អ្នកនិពន្ធទាំងឡាយ ដើម្បីអះអាងបញ្ជាក់ខ្លួនឯងនិងប្រាប់ពិភពលោកទាំងមូលថា ការបំផ្លិចបំផ្លាញដ៏ធ្ងន់ធ្ងរដែលបានកើតឡើងគឺជាការពិត ហើយការឈឺចាប់ដែលគេបន្តទ្រាំត្រូវបានផ្តល់យុត្តិធម៌ ។ ក្នុងលក្ខណៈនេះ សកម្មភាពនៃការសរសេរនិពន្ធបានក្លាយជាផ្នែកមួយយ៉ាងសំខាន់ក្នុងដំណាក់កាលនៃការព្យាបាលរបួសសម្រាប់អ្នកនិពន្ធ ហើយនឹងអ្នកអានដែលជាជនជាតិកម្ពុជាទាំងឡាយ ព្រោះថាការសរសេរពីអតីតកាលគឺជាការតស៊ូដ៏លំបាកមួយក្នុងការទ្រាំទ្រការឈឺចាប់ ។ តាមរយៈដំណើរការនៃការសរសេរការចងចាំទាំងឡាយអំពីអំពើប្រល័យពូជសាសន៍ មានសភាពមិនសូវធ្ងន់ធ្ងរនិងស្រពេចស្រពិលដូចមុនទេ ។ ម៉្យាងវិញទៀត អ្នកនិពន្ធទាំងនោះមើលឃើញអំពើប្រល័យពូជសាសន៍ថាជាសារធាតុមួយដែលមានចំណុចចាប់ផ្តើម និងមានទីបញ្ចប់ដែលអាចរៀបរាប់នៅរាល់សម័យកាលទាំងមូលបានតាមពេលវេលា ។





ភាពជោគជ័យនៃដំណើរការនេះត្រូវពឹងផ្អែកទៅលើការឆ្លើយតបជាទូទៅរបស់ពិភពលោកទាំងមូលចំពោះសក្ខីកម្មរបស់អ្នកនិពន្ធទាំងនោះ ។ ក្នុងគោលបំណងលាក់បាំងនូវអត្តសញ្ញាណនិងសន្តិសុខរបស់យើង ប្រសិនបើយើងបំផ្លិចបំផ្លាញសាក្សីរបស់អ្នកនិពន្ធ និងមិនទទួលស្គាល់នូវអ្វីដែលជនរងគ្រោះបាននិយាយ នេះមានន័យថាយើងបានផ្តល់នូវឱកាសតិចតួចដល់ជនរងគ្រោះក្នុងការទទួលបានមកវិញនូវការជាសះស្បើយ និងការបន្តជីវិតរបស់គាត់ទៅកាន់ភាពធូរស្រាលទៅថ្ងៃមុខ ។ ភាពស្មុគស្មាញរបស់ជនរងគ្រោះ និងកំហុសរបស់ជនដៃដល់ ត្រូវបានមើលឃើញក្នុងចំណោមសាធារណជនទូទៅជាមុនសិន មុននឹងជនរងគ្រោះទទួលស្គាល់ពេញលេញថាភាពឈឺចាប់នេះគឺមិនមែនជាទណ្ឌកម្មដែលសមទទួលបាននោះទេ សម្រាប់បទឧក្រិដ្ឋដែលជនដៃដល់ធ្លាប់បានប្រព្រឹត្ត ។

ក្នុងនាមជាអ្នកអានម្នាក់ យើងត្រូវប្រឈមមុខជាមួយនឹងកិច្ចការជាច្រើន ។ តើយើងអាចធ្វើបានដោយវិធីណាចំពោះមនុស្សដែលបានប្រព្រឹត្តបទឧក្រិដ្ឋដែលធ្វើឲ្យអ្នកនិពន្ធទាំងអស់នោះបានឆ្លងកាត់ ដើម្បីយល់ដឹងអំពីរឿងហេតុដ៏ឈឺចាប់ គ្រោះទុរ្ភិក្សនិងអំពើកាប់សម្លាប់? ភាពដាច់ដោយឡែកពីគ្នារវាងអ្នកនិពន្ធនិងសាធារណជនទូទៅគឺមានភាពស្មុគស្មាញណាស់ដោយអសមត្ថភាពរបស់អ្នកនិពន្ធដែលមានទេពកោសល្យបំផុត ដើម្បីថ្លែងអំពីភាពព្រៃផ្សៃនៃការកាប់សម្លាប់និងការសម្លាប់មិនរើសមុខទៅលើប្រជាជនស្លូតត្រង់រាប់រយពាន់នាក់ ដែលមិនអាចបំភាន់បានចំពោះអ្វីដែលបានជួបប្រទះ ។ ប្រការនេះប្រហែលជាអាចពន្យល់បានពីមូលហេតុដែលថាហេតុអ្វីបានជាជនរងគ្រោះនិយាយតិចតួចក្នុងគ្រាដំបូងក្រោយពីប្រទេសត្រូវបានរំដោះ ហើយជនរងគ្រោះហាក់បីដូចជាមានភាពស្ងប់ស្ងាត់ ហើយក៏មិនអាចនិយាយប្រាប់អ្នកផ្សេងដែលមិនបានឆ្លងកាត់ព្រឹត្តិការណ៍ឈឺចាប់នូវអ្វីដែលគាត់បានជួបប្រទះដែរ ។ ដូចដែលបានបកស្រាយនៅក្នុងកំណាព្យ ហើយមើលទៅ

ហាក់បីដូចជាមានភាពបន្ទិតបន្ទំផង និងសេចក្តីត្រូវការចាំបាច់របស់ជនរងគ្រោះផងដើម្បីនិយាយ និងធ្វើជាសាក្សីចំពោះបទឧក្រិដ្ឋ ដែលគាត់បានជួបប្រទះនិងបានរងគ្រោះ ។

ក្នុងនាមជាសិល្បករ អ្នកនិពន្ធទាំងនោះចង់និយាយច្រើនដែលធ្វើឲ្យយើងមានភាពងាយស្រួលក្នុងការយល់ ។ រូបភាពដែលជនរងគ្រោះចងចាំនៅក្នុងចិត្តត្រូវបានបំផ្លិចបំផ្លាញដ៏ធំធេង ។ សេចក្តីត្រូវការក្នុងការធ្វើទំនាក់ទំនង គឺមានសារសំខាន់ជាងរូបភាពនៅក្នុងចិត្តនោះទៅទៀត ។ ហេតុដូច្នេះហើយ អ្នកនិពន្ធហាក់បីដូចជាត្រូវបានបង្ខំឲ្យរំឭកឡើងវិញនូវភាពឈឺចាប់ពីអតីតកាល ។ តាមរយៈការសរសេរ អ្នកនិពន្ធបានវិលត្រឡប់ទៅកាន់ទីកន្លែងដែលឪពុកម្តាយរបស់ខ្លួនបានស្លាប់ ហើយរាល់ការវិលត្រឡប់ទៅកាន់ភាពឈឺចាប់នេះកាន់តែមានភាពជិតទៅៗ ពេលដែលនិយាយនិងធ្វើជាសក្ខីកម្ម ។

អ្នកនិពន្ធដែលរៀបរាប់នៅពេលនេះបានមកដល់សហរដ្ឋអាមេរិកក្នុងនាមជាជនរងគ្រោះក្នុងរបបខ្មែរក្រហម ។ អត្ថន័យដែលអ្នកនិពន្ធទាំងនោះរៀបរាប់នៅក្នុងកំណាព្យ គឺជាបទបុរាណដែលមានប្រភពរហូតដល់សតវត្សរ៍ទី១៦ណោះ ។ ដោយសារតែរបបប៉ុល ពត មិនបានផ្តល់ការអប់រំដល់ប្រជាជន អ្នកនិពន្ធខ្លះបានរៀនពីបទបុរាណនេះនៅពេលដែលអ្នកទាំងនោះរស់នៅជំរំជនភៀសខ្លួនក្នុងទឹកដីថៃ ក្រោយពីគាត់បានគេចខ្លួនពីប្រទេសកម្ពុជា ។ ការដែលអ្នកនិពន្ធជ្រើសរើសបទបុរាណទាំងនោះ គឺមានន័យថាគាត់មានបំណងចង់ថែរក្សានូវវប្បធម៌សិល្បៈដែលបានបាត់បង់កាលពីជំនាន់ ប៉ុល ពត ឡើងវិញ ។ ម្យ៉ាងវិញទៀត ភាពស្មោះស្ម័គ្រទៅនឹងអតីតភាពអាចបញ្ជាក់បានថាជាការបង្ហាញនូវការបូជាកាយចិត្តចំពោះគ្រួសារ លោកគ្រូអ្នកគ្រូ និងមិត្តភក្តិដែលមិនមានសំណាងបានរួចរស់ជីវិត ។ ដូច្នេះ តាមរយៈការថែរក្សាសណ្ឋានសិល្បៈបុរាណ តាមរយៈអក្សរសិល្ប៍ របាំ ឬចម្លាក់នៅតាមប្រាសាទបាយ័នជាដើម សិល្បករបាននិយាយទៅកាន់អ្នកស្លាប់ក្នុងគោលបំណងដើម្បីសងគុណដល់អ្នកទាំងនោះដែលបានស្លាប់ ហើយការធ្វើបែបនេះគឺដើម្បីនិយាយជំនួសឲ្យអ្នកស្លាប់ផងដែរ ។ **ចច ជីហ្កាស**

# ដំណឹងស្វែងរកប្អូនប្រុសឈ្មោះ គង់ មីត



នាងខ្ញុំឈ្មោះ គង់ ថុល អាយុ៦២ឆ្នាំ រស់នៅភូមិព្រិច ឃុំទ្រាល ស្រុកបារាយណ៍ ខេត្តកំពង់ធំ មានឪពុកឈ្មោះ ម៉ុន ជាជនជាតិ បារាំង និងម្តាយឈ្មោះ កែវ វ៉ាត់ ។ នាងខ្ញុំសូមប្រកាសស្វែងរកប្អូនប្រុសឈ្មោះ គង់ មីត ដែលបានបាត់ខ្លួននៅក្នុងរដ្ឋប្រហារទម្លាក់ សម្តេច សីហនុ ឆ្នាំ១៩៧០ ។ ប្រហែលជាឆ្នាំ១៩៩៧ ខ្ញុំបានទទួលដំណឹងពីអ្នកភូមិដែលរស់នៅខណ្ឌស៊ឹងមានជ័យ ថា គង់ មីត បានមករកម្តាយរបស់គាត់ កែ វ៉ាត់ ដែលមានមុខរបរលក់ថ្នាំ ។ ក្រោយមកទៀត ខ្ញុំមិនដែលបានទទួលដំណឹងអ្វីពី គង់ មីត ទៀតទេ ។

ដូច្នេះប្រសិនបើប្អូនប្រុសបានឮ ឬបានអានសេចក្តីប្រកាសនេះ សូមមករកបងតាមអាស័យដ្ឋានខាងលើ ឬតាមរយៈទូរស័ព្ទលេខ ០១២ ៧៨៧ ៥៧៥, ០១២ ៩៩៩ ០៧១, ០៩២ ៥៦៣ ០០៧ ។ សូមអរគុណ ។

# សេចក្តីប្រកាសស្វែងរកកូនស្រី វ៉ាន់ រុំ

នាងខ្ញុំឈ្មោះ ជួប រ៉ែម អាយុ៧១ឆ្នាំ រស់នៅភូមិសាមគ្គី ឃុំអង្គរជ័យ ស្រុកអង្គរជ័យ ខេត្តកំពត ។ នាងខ្ញុំសូមប្រកាសស្វែងរកកូនស្រីឈ្មោះ វ៉ាន់ រុំ ដែលសព្វថ្ងៃមានអាយុប្រហែល៣៨ឆ្នាំ បានបាត់ខ្លួននៅឆ្នាំ១៩៧៥ ។ នៅពេលនោះ វ៉ាន់ រុំ ត្រូវបានប្រធានភូមិឈ្មោះ គឿន បញ្ជូនឲ្យធ្វើស្រែអំបិលនៅកែប ។ ក្រោយមកទៀត ខ្ញុំបានទទួលដំណឹងពីម្តាយមីងរបស់ខ្ញុំឈ្មោះ វ៉ាន់ សឿន ថាគាត់បានជួបជាមួយ វ៉ាន់ រុំ ម្តងនៅក្បែរហាងទឹកត្រីមួយ ។ ចាប់តាំងពីពេលនោះមក ខ្ញុំមិនដែលបានទទួលដំណឹងអ្វីពី វ៉ាន់ រុំ ទាំងអស់ ។

ដូច្នេះបើកូនបានដំណឹងនេះ សូមមកជួបម្តាយនៅភូមិឃុំខាងលើ ឬទំនាក់ទំនងតាមរយៈមជ្ឈមណ្ឌលឯកសារកម្ពុជាតាមទូរស័ព្ទលេខ (៨៥៥) ២៣ ២១១ ៨៧៥ ។ សូមអរគុណ ។

# អំពើប្រល័យពូជសាសន៍នៅក្នុងបរិបទសកលលោក

## សេចក្តីផ្តើម

សូមគោរពលោកគ្រូអ្នកគ្រូ អ្នកស្រាវជ្រាវ អ្នករដ្ឋបាល និងមិត្តភក្តិទាំងអស់ជាទីមេត្រី ។ ថ្ងៃនេះ ជាថ្ងៃដ៏សប្បាយរីករាយជាទីបំផុតដែលខ្ញុំមានឱកាសចូលរួមជាមួយអ្នកទាំងអស់គ្នា ខណៈពេលដែលមជ្ឈមណ្ឌលឯកសារកម្ពុជានិងក្រសួងអប់រំ យុវជន និងកីឡា បានប្រឹងប្រែងយ៉ាងខ្លាំងបញ្ចូលគ្នាដើម្បីដាក់បញ្ចូលប្រវត្តិសាស្ត្រខ្មែរក្រហមទៅក្នុងកម្មវិធីសិក្សារបស់សាលានៅក្នុងប្រទេសកម្ពុជា ។ វគ្គបណ្តុះបណ្តាលគ្រូបង្រៀននេះ បានសម្គាល់នូវព្រឹត្តិការណ៍ដ៏មានសារៈសំខាន់លើកទីមួយ នៅក្នុងប្រវត្តិសាស្ត្រអប់រំរបស់កម្ពុជា ។ ខ្ញុំមានកិត្តិយសក្នុងការចែករំលែកបទពិសោធន៍នេះជាមួយអ្នកទាំងអស់គ្នា ។ ប៉ុន្មានឆ្នាំមិនយូរប៉ុន្មានកន្លងទៅនេះ លោក ឌី ខាំបូលី បានមកធ្វើការជាមួយខ្ញុំនៅឯសកលវិទ្យាល័យកុនខដៀ ក្នុងទីក្រុងម៉ុងរ៉េអាល់ ប្រទេសកាណាដា ។ យើងបានធ្វើការលើសេចក្តីព្រាងប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យជាភាសាអង់គ្លេស ។ លោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជាបានបញ្ជូន បូលី ឲ្យមកធ្វើកិច្ចការនេះជាមួយខ្ញុំ ។ អស់រយៈពេលជិត១៣សប្តាហ៍ គឺមានរយៈពេលជិតពេញមួយឆមាស បូលី និងខ្ញុំបានចំណាយពេលជាច្រើនម៉ោងរៀងរាល់សប្តាហ៍នៅក្នុងការិយាល័យរបស់ខ្ញុំ ពិនិត្យមើលយ៉ាងដិតដល់និងធ្វើការកែតម្រូវទៅលើអត្ថបទ ។ អាកាសធាតុត្រជាក់ក្នុងខែតុលា និងខែវិច្ឆិកាដែលកំពុងតែចូលមកដល់ បានចូលមកជំនួសអាកាសធាតុក្តៅនាខែកញ្ញាយ៉ាងឆាប់រហ័ស ។ ស្លឹកឈើបានប្រែទៅជាពណ៌ក្រហមនិងពណ៌លឿងមាស បន្ទាប់មកក៏ជ្រុះចុះមកលើដី ។ ព្រិលនិងភ្លៀងទឹកកកបានធ្លាក់ចុះ ។ បូលី បានពាក់អាវមួយជាន់ហើយមួយជាន់ទៀតដើម្បីរក្សាកម្តៅពេលធ្វើដំណើរទៅសកលវិទ្យាល័យកុនខដៀដែលមានចម្ងាយឆ្ងាយនិងផ្លូវរអិល ។ បូលី ញ៉ាំយ៉ាងច្រើនដើម្បីបង្កើនកម្លាំង ។ ជាចុងក្រោយ បូលី បានឆ្លងកាត់រាល់ឧបសគ្គទាំងអស់ ហើយថ្ងៃនេះយើងកំពុងតែពិភាក្សាគ្នា ថាតើត្រូវដាក់សៀវភៅរបស់ បូលី ទៅក្នុងបរិបទនៃអំពើប្រល័យពូជសាសន៍ នៅក្នុងពិភពលោកដោយរបៀបណា ។

## ការបង្រៀននៅក្នុងសង្គមកាណាដា-ការបង្រៀននៅក្នុងសង្គមកម្ពុជា

ខ្ញុំរស់នៅនិងបង្រៀននៅក្នុងប្រទេសកាណាដា ។ បើឈរលើស្តង់ដាររបស់ប្រទេសកម្ពុជា កាណាដា គឺជាប្រទេសអ្នកមាន ។ យើងភាគច្រើនមានម្ហូបអាហារគ្រប់គ្រាន់ ជម្រកសមរម្យ សម្លៀកបំពាក់ច្រើនសន្ធឹកសន្ធាប់ និងសន្តិសុខផ្ទាល់ខ្លួន ។ យើងអាចទទួលបានថ្នាំពេទ្យនិងវេជ្ជបណ្ឌិតល្អៗ ។ យើងផ្តល់ការអប់រំដល់កូនចៅយើងនិងបញ្ជូនកូនប្រុសកូនស្រីយើងជាច្រើនទៅសិក្សានៅតាមមហាវិទ្យាល័យនិងសកលវិទ្យាល័យនានា ដើម្បីយកសញ្ញាប័ត្រជាន់ខ្ពស់ដូចជា ផ្នែកមនុស្សជាតិ វិទ្យាសាស្ត្រសង្គម វិស្វកម្ម ពាណិជ្ជកម្ម និងវិទ្យាសាស្ត្រខាងជីវសាស្ត្រ ។

នៅក្នុងវិស័យនយោបាយ យើងដែលជាប្រជាជនកាណាដាមានសិទ្ធិនិងកាតព្វកិច្ច ដែលត្រូវបានកំណត់ដោយរដ្ឋធម្មនុញ្ញរបស់កាណាដាស្តីពីសិទ្ធិនិងសេរីភាព ។ នៅក្នុងច្បាប់របស់កាណាដា ធម្មនុញ្ញនេះបានផ្តល់ឲ្យយើងនូវសិទ្ធិសំខាន់ៗមួយចំនួនដូចជា ៖

១) សិទ្ធិក្នុងការទទួលបានការប្រព្រឹត្តមកលើស្មើៗគ្នា

២) សិទ្ធិដើរហើរដោយសេរីនៅជុំវិញកាណាដា

៣) សិទ្ធិក្នុងការគិតដោយសេរី

៤) សិទ្ធិក្នុងការបញ្ចេញមតិដោយសេរី

៥) សិទ្ធិក្នុងការគោរពជំនឿសាសនា ដោយគ្មានការធ្វើទុក្ខបុកម្នេញ

៦) សិទ្ធិក្នុងការប្រមូលផ្តុំដោយសន្តិភាព

៧) សិទ្ធិក្នុងការទទួលបានលិខិតឆ្លងដែន សម្រាប់ការធ្វើដំណើរជាអន្តរជាតិ

៨) សិទ្ធិក្នុងការបោះឆ្នោត និងសិទ្ធិឈរឈ្មោះឲ្យគេបោះឆ្នោតឲ្យ ។

យើងក៏មានកាតព្វកិច្ចដូចតទៅ ៖

១) យើងត្រូវយល់និងគោរពច្បាប់របស់កាណាដា ។

២) យើងត្រូវគោរពសិទ្ធិរបស់អ្នកដទៃ ពេលយើងបង្ហាញទស្សនៈរបស់យើងដោយសេរី ។

៣) យើងមានកាតព្វកិច្ចត្រូវជួយមនុស្សផ្សេងទៀតនៅក្នុងសហគមន៍របស់យើង ។

៤) យើងមិនត្រូវបានអនុញ្ញាតឲ្យអនុវត្តការរើសអើង ឬបង្កអំពើអយុត្តិធម៌ទៅលើអ្នកដទៃ ។

៥) យើងមានកាតព្វកិច្ចត្រូវបង់ពន្ធទៅលើប្រាក់ចំណូល ទៅឲ្យអាជ្ញាធរខេត្ត និងរដ្ឋាភិបាលសហព័ន្ធរបស់យើង ។

៦) ក្នុងករណីសង្គ្រាមឬជម្លោះស៊ីវិល យើងអាចត្រូវបានកេណ្ឌឲ្យបម្រើនៅក្នុងកងទ័ពរបស់ប្រទេសកាណាដា ។

យើងពង្រឹងសិទ្ធិនិងកាតព្វកិច្ចរបស់យើងនៅក្នុងប្រព័ន្ធអប់រំរបស់យើង ។ សាលានៅក្នុងប្រទេសកាណាដា បង្រៀនសិស្សអំពីសីលធម៌វិជ្ជា កេរដំណែលជាតិ សីលធម៌ពលរដ្ឋ និងអត្តសញ្ញាណជាតិរបស់យើងដែលមានឈ្មោះខ្ពស់ត្រដែត ។ តើវាមានន័យយ៉ាងដូចម្តេច?

១) សីលធម៌វិជ្ជាបង្រៀនអំពីតម្លៃនៃជីវិត និងកិត្យានុភាពរបស់បុគ្គលម្នាក់ៗ ។

២) កេរដំណែលរបស់កាណាដាសង្កត់ធ្ងន់ទៅលើការវិវត្តនៃលិទ្ធិប្រជាធិបតេយ្យនិងការធានាចំពោះបុគ្គលប្រឆាំងនឹងអំណាចផ្តាច់ការរបស់រដ្ឋាភិបាល ឬប្រឆាំងទៅនឹងការធ្វើទុក្ខបុកម្នេញពីសំណាក់ប្រជាជនភាគច្រើន ។

៣) នៅក្នុងវគ្គសិក្សាពីពលរដ្ឋវិជ្ជា សិស្សសិក្សាអំពីសារៈសំខាន់ ក្នុងនាមជាប្រជាពលរដ្ឋម្នាក់នៅក្នុងសង្គមប្រជាធិបតេយ្យមួយ ។

៤) កេរដំណែលជាតិរបស់កាណាដា សង្កត់ធ្ងន់ទៅលើនីតិរដ្ឋនៅក្នុងសង្គមកាណាដា ដែលជាគន្លឹះក្នុងការការពារសិទ្ធិ និងសេរីភាពរបស់បុគ្គល ដោយជំរុញសិស្សឲ្យធ្វើការប្រៀបធៀបរវាងប្រព័ន្ធនយោបាយប្រជាធិបតេយ្យ និងប្រព័ន្ធនយោបាយមិនមែនប្រជាធិបតេយ្យ ។

ការបង្រៀនអំពីប្រវត្តិវិទ្យានិងសង្គមវិទ្យានៃអំពើប្រល័យពូជសាសន៍នៅក្នុងប្រទេសកាណាដា បានពង្រឹងតម្លៃទាំងនេះ



វាគ្មិនជាតិ និងអន្តរជាតិដែលបានចូលរួមវគ្គបណ្តុះបណ្តាល "អប់រំពីអំពើប្រល័យពូជសាស

ឡើងវិញ ។ នៅពេលចាប់ផ្តើមបង្រៀនសិស្សអំពីសិទ្ធិមនុស្ស អំពើប្រល័យពូជសាសន៍ និងអំពើឧក្រិដ្ឋកម្មធ្ងន់ធ្ងរផ្សេងៗទៀត គ្រូត្រូវបង្ហាញសេចក្តីស្មោះត្រង់ប្រកបដោយបញ្ញាញាណ និងសេចក្តីក្លាហានប្រកបដោយសីលធម៌ ។ មិនមានប្រទេសឬសង្គមណាមួយដែលមិនដែលជួបប្រទះការរំលោភសិទ្ធិមនុស្សទាល់តែសោះនោះទេ ។ ប្រទេសកាណាដាក៏ដូចគ្នាដែរ ។ គ្រូត្រូវតែបង្ហាញនូវពេលវេលាទាំងឡាយក្នុងប្រវត្តិសាស្ត្រកាណាដា នៅពេលភាពដ៏ឧត្តុង្គឧត្តមរបស់កាណាដាត្រូវបានបំភ្លេចចោល ឬបោកប្រាស់ ដោយសារតែការប្រព្រឹត្តខុសជាលក្ខណៈប្រព័ន្ធរបស់សមាជិកនៃក្រុម ដោយផ្អែកទៅលើពូជសាសន៍ សាសនា វប្បធម៌ ភាសា ភេទ ឬទស្សនៈនយោបាយ ។ កាណាដាបានចាប់ជនជាតិកាណាដាដើមកំណើតជប៉ុនដាក់ក្នុងជំរុំឃុំខ្លួន ហើយបានរឹបអូសទ្រព្យសម្បត្តិរបស់គេនៅក្នុងអំឡុងពេលនៃសង្គ្រាមលោកលើកទីពីរ ដោយផ្អែកទៅលើការសង្ស័យទាំងស្រុងថា អ្នកទាំងនេះនឹងសហការជាមួយប្រទេសជប៉ុន ។ កាណាដាមិនបានផ្តល់ឱកាសឲ្យអ្នកទាំងនេះការពារខ្លួននៅក្នុងតុលាការតាមផ្លូវច្បាប់នោះទេ ។



ជូនកាលរដ្ឋាភិបាលកាណាដាបានបង្ខំកូនក្មេងជនជាតិដើមឲ្យរៀននៅក្នុងសាលាមួយប្រភេទដែលក្មេងទាំងនេះមិនត្រូវបានអនុញ្ញាតឲ្យនិយាយភាសាកំណើតរបស់ខ្លួន ហើយលក្ខខណ្ឌសុខភាពមិនល្អទើបបណ្តាលឲ្យគេជាច្រើនកើតជំងឺរបេង ។ យើងបានបង្រៀនកូនចៅរបស់យើងថា យើងបានធ្វើអំពើទាំងនេះ ហើយយើងនឹងមិនធ្វើអំពើទាំងនេះម្តងទៀតឡើយ ។

ខ្ញុំបានសង្ខេបអំពីតម្លៃមួយចំនួនដែលបានតម្រង់ទិសដៅដល់សង្គមកាណាដា ។ តើតម្លៃទាំងនេះមានទំនាក់ទំនងជាមួយនឹងសង្គមកម្ពុជានាពេលបច្ចុប្បន្នដែរឬទេ? តើភាពមានទ្រព្យសម្បត្តិរបស់កាណាដានិងភាពក្រីក្ររបស់កម្ពុជាធ្វើឲ្យតម្លៃរបស់ប្រទេសកាណាដាមិនមានទំនាក់ទំនង ឬមិនសមស្របសម្រាប់គ្រូបង្រៀនកម្ពុជា និងរបៀបដែលអ្នកទាំងនោះបង្រៀនដែរឬយ៉ាងណា? ជាបុគ្គល ខ្ញុំបដិសេធចំពោះការអះអាងនិងជំនឿដែលថា ជាគោលការណ៍សិទ្ធិមនុស្ស គឺមានលក្ខណៈជាសកលហើយត្រូវអនុវត្តជាសកល ។ ខ្ញុំជឿថា ស្ត្រីគួរមានសិទ្ធិស្មើនឹងបុរសហើយក្រុមភាគតិចផ្នែកនយោបាយនិងសាសនាត្រូវទទួលបានសេរីភាពពលរដ្ឋ និងនយោបាយ ។ ខ្ញុំជឿថា សិទ្ធិមនុស្សមិនមែនជាបាតុភូតវប្បធម៌ទេ ។ វប្បធម៌ក៏គ្មានតម្លៃជាសីលធម៌ខ្ពស់ជាងសិទ្ធិមនុស្សដែរ ដោយផ្អែកទៅលើកិត្យានុភាពរបស់បុគ្គលនីមួយៗ ។ សិទ្ធិរបស់ក្រុមមិនមែនសំខាន់ជាងសិទ្ធិរបស់បុគ្គលនោះទេ ។ ក្រុមដែលមិនត្រូវបានគេគោរពដូចជា ស្ត្រី មនុស្សក្នុងវណ្ណៈទាប ឬមនុស្សក្រៅវណ្ណៈក្នុងសង្គមសាសនាព្រាហ្មណ៍ មិនគួរទទួលបាននូវការដាក់កំហិតទៅលើតួនាទី បុព្វសិទ្ធិ និងកាតព្វកិច្ចនោះទេ ។ ហើយតម្លៃរបស់ខ្ញុំ បង្ហាញអំពីការបង្រៀនពីអំពើប្រល័យពូជសាសន៍នៅក្នុងបរិបទសកលលោក ។

ទោះជាយ៉ាងនេះក្តី តម្លៃរបស់ខ្ញុំមិនមែនចាំបាច់ត្រូវតែជាតម្លៃរបស់អ្នកនោះទេ ។ អ្នករស់នៅនិងបង្រៀននៅក្នុងសង្គមកម្ពុជា អ្នកដឹងច្រើនជាងខ្ញុំឆ្ងាយណាស់អំពីតម្រូវការនិងការចង់បានរបស់ប្រជាជនកម្ពុជា ។ ខ្ញុំនឹងមិនដាក់តម្លៃរបស់ខ្ញុំឲ្យអ្នកទាំងអស់គ្នាទទួលយកទេ ។ សុន្ទរកថារបស់ខ្ញុំនៅថ្ងៃនេះ គឺត្រូវបានរៀបរៀងឡើង ដើម្បីស្វែងរកវិធីដ៏ល្អបំផុតក្នុងការបង្រៀនប្រវត្តិសាស្ត្រខ្មែរក្រហមទៅឲ្យប្រជាជនកម្ពុជា ។ យើងនឹងរៀនទាំងអស់គ្នាក្នុងនាមជាដៃគូនៅក្នុងកិច្ចសន្ទនានេះ ។ ការស្តាប់គ្នានិងការចែករំលែកគ្នាទៅវិញទៅមកនឹងជួយឲ្យយើងទទួលបានផលប្រយោជន៍ពីការសន្ទនាប្រកបដោយភាតរភាពនេះ ។ យើងនឹងនិយាយទៅកាន់គ្នាទៅវិញទៅមក ដោយមិនបានដឹងតាំងពីដំបូងមកថាតើការសន្ទនារបស់យើងនឹងឆ្ពោះទៅកាន់ទិសដៅណាមួយ ។ ដូចជា ព្រីម៉ូ ឡីវី ដែលជាអ្នកនៅរស់រានមានជីវិតពីជំរំពលកម្ម និងជំរំសម្លាប់មនុស្សនៅអូសស្វិច និងជាអ្នកដែលសរសេរប្រវត្តិដ៏ល្បីល្បាញបំផុតមួយអំពីហូឡូខសត៍ យើងអាចនិយាយទៅកាន់គ្នាទៅវិញទៅមកបាន ។ ឥឡូវនេះ យើងនឹងចាប់ផ្តើមចូលប្រធានបទ និងសិក្សាទាំងអស់គ្នាអំពី «អំពើប្រល័យពូជសាសន៍ក្នុងបរិបទសកលលោក» ។

### តើអ្វីទៅជាអំពើប្រល័យពូជសាសន៍? តើអ្វីទៅជាអំពើឧក្រិដ្ឋកម្មធ្ងន់ធ្ងរ?

បើតាមខ្ញុំយល់ វិធីសាស្ត្ររបស់ខ្ញុំនៅថ្ងៃនេះត្រូវតាក់តែងឡើងទៅតាមតម្រូវការរបស់អ្នកទាំងអស់គ្នា ។ អ្នកបង្រៀនអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) នៅ

ក្នុងប្រទេសកម្ពុជា ។ កិច្ចការរបស់ខ្ញុំ គឺដាក់បទពិសោធន៍របស់ប្រទេសកម្ពុជាទៅក្នុងបរិបទសកលលោក អំពីប្រវត្តិសាស្ត្រនៃអំពើប្រល័យពូជសាសន៍ ។ ពាក្យប្រល័យពូជសាសន៍បានដាស់ការចងចាំឡើងវិញនូវការកាប់សម្លាប់ក្នុងទ្រង់ទ្រាយធំនៅក្នុងសតវត្សរ៍ទី២០នេះ ដូចជាអំពើប្រល័យពូជសាសន៍ទៅលើជនជាតិអាមេនៀ នៅក្នុងប្រទេសទួរគី ជនជាតិអ៊ុយក្រែននៅក្រោមរបបស្តាលីនក្នុងសហភាពសូវៀត ការសម្លាប់រង្គាលទៅលើជនជាតិជ្វីហ្វក្រោមរបបអ៊ីត្លែនៅទ្វីបអឺរ៉ុប និងការសម្លាប់ជនជាតិទូតស៊ីនៅក្នុងប្រទេសរ៉្វាន់ដា ។ ទោះជាពាក្យ «ប្រល័យពូជសាសន៍» ទើបតែត្រូវបានបង្កើតឡើងដោយលោក រ៉ាហ្វែល លីមគិន នៅក្នុងទសវត្សរ៍៤០ក៏ដោយ ក៏ព្រឹត្តិការណ៍ដែលមានអត្ថន័យបៀបនេះបានកើតមានឡើងតាំងពីដើមដំបូងនៃប្រវត្តិសាស្ត្រ ។

មានហេតុផលជាច្រើនក្នុងការសម្លឹងមើលឲ្យកាន់តែជិតទៅលើដើមកំណើតនៃអំពើប្រល័យពូជសាសន៍ ។ ទីមួយ មានមនុស្សតិចណាស់ដែលទទួលស្គាល់ថា អំពើនេះត្រូវបានអនុវត្តនៅក្នុងពេញមួយរយៈកាលនៃប្រវត្តិសាស្ត្រ និងនៅគ្រប់ទីកន្លែងទាំងអស់នៃពិភពលោក ។

សូមចាប់ផ្តើមជាមួយនឹងការពិតដែលថា «អំពើប្រល័យពូជសាសន៍» គឺជាបទឧក្រិដ្ឋនៅក្រោមច្បាប់អន្តរជាតិ ។ វាត្រូវបានកំណត់និយមន័យនៅក្នុងមាត្រា២ នៃអនុសញ្ញាអន្តរជាតិស្តីពីការបង្ការ និងការផ្តន្ទាទោសបទឧក្រិដ្ឋប្រល័យពូជសាសន៍ ដែលត្រូវបានស្នើឡើងនៅឆ្នាំ១៩៤៨ ដោយការបោះឆ្នោតរបស់មហាសន្និបាតអង្គការសហប្រជាជាតិ ។ អនុសញ្ញានេះត្រូវបានដាក់បញ្ចូលទៅក្នុងច្បាប់អន្តរជាតិ ដោយការផ្តល់សច្ចាប័នពីសំណាក់ប្រទេសជាច្រើននៅឆ្នាំ១៩៥១ ។ ដូច្នេះ តើមាត្រា២នៃអនុសញ្ញានេះនិយាយថាម៉េច ។ ខាងក្រោមនេះ គឺជាអត្ថន័យនៃអនុសញ្ញាជាប្រវត្តិសាស្ត្រនេះ ៖

**មាត្រា២**

នៅក្នុងអនុសញ្ញានេះ ពាក្យប្រល័យពូជសាសន៍មានន័យថាជាអំពើណាមួយក្នុងចំណោមអំពើទាំងប៉ុន្មានខាងក្រោមនេះ ហើយដែលត្រូវតែបានធ្វើឡើងក្នុងបំណងបំផ្លាញទាំងស្រុង ឬមួយផ្នែកនៃក្រុមជាតិមួយ ជនជាតិមួយ ពូជសាសន៍មួយ ឬក្រុមសាសនាមួយដូចជា ៖

ក) សម្លាប់សមាជិកទាំងឡាយនៅក្នុងក្រុម

ខ) បង្កការខូចខាតផ្នែកសរីរាង្គកាយ ឬផ្នែកសតិបញ្ញាដល់សមាជិកទាំងឡាយនៅក្នុងក្រុម

គ) បង្កឡើងដោយចេតនានូវស្ថានភាពរស់នៅរបស់ក្រុមដែលនាំដល់ការបំផ្លិចបំផ្លាញរូបរាងកាយក្រុមទាំងមូល ឬក៏មួយផ្នែក

ឃ) ដាក់បង្ខំនូវវិធានការនានា សំដៅរារាំងកំណើតទារកនៅក្នុងក្រុម

ង) ផ្ទេរទាំងបង្ខំនូវកុមារៗរបស់ក្រុមមួយទៅក្រុមមួយទៀត ។

និយមន័យនៃអំពើប្រល័យពូជសាសន៍របស់អង្គការសហប្រជាជាតិ គឺជាលទ្ធផលនៃការធ្វើសម្បទានឲ្យគ្នាទៅវិញទៅមកក្នុងចំណោមប្រទេសមហាអំណាច ក្នុងអំឡុងពេលនៃសង្គ្រាមត្រជាក់ ។ អនុសញ្ញាដាក់អំពើទាំងឡាយថាជាបទឧក្រិដ្ឋ ដើម្បីស្វែងរកការបំផ្លាញទៅលើក្រុមជាតិមួយ ជនជាតិមួយ ពូជសាសន៍មួយ ឬក្រុមសាសនាមួយតែប៉ុណ្ណោះ ។ អនុសញ្ញានេះបានដកចេញនូវក្រុមផ្សេងៗទៀតដូចជា ក្រុមសេដ្ឋកិច្ច ក្រុមនយោបាយ និងក្រុមសង្គមជាដើម ។ ទោះជាយ៉ាងនេះក្តី ក្រុមទាំងនេះឥឡូវនេះស្ថិតនៅក្នុងលក្ខន្តិកៈរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ ដែលជាប់ទាក់ទងទៅនឹង «ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ» ។ លក្ខន្តិកៈនេះរួមបញ្ចូលទាំងអំពើឧក្រិដ្ឋទាំងឡាយដូចជា ការធ្វើទុក្ខបុកម្នេញ ការសម្លាប់រង្គាល ការនិរទេស និងការរំលោភដោយផ្អែកទៅលើក្រុមនយោបាយឬសង្គមដែលមានលក្ខណៈជាប្រព័ន្ធនិងធំធេង ។

រដ្ឋអាជ្ញាបច្ចុប្បន្នចូលចិត្តកាត់ទោស «ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ» ជាង «ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍» ។ នេះគឺដោយសារថា ការកាត់ទោសពីបទឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ជាកិច្ចការដ៏លំបាកបំផុតដែលគេមិនដែលជួបប្រទះ ។ តម្រូវការគន្លឹះសម្រាប់កាត់ទោសអ្នកណាម្នាក់នៅក្រោមអនុសញ្ញារបស់អង្គការសហប្រជាជាតិ គឺភ័ស្តុតាងដ៏ច្រើនសន្ធឹកសន្ធាប់ដែលបង្ហាញថា ជនដៃដល់មានបំណងឧក្រិដ្ឋក្នុងការបំផ្លាញទាំងស្រុងមួយឬដោយផ្នែក ។ ប្រសិនបើជនដៃដល់បន្សល់ទុកនូវឯកសារ

បង្ហាញពីបំណងខុក្រិដ្ឋរបស់ខ្លួន កិច្ចការនេះនឹងមានលក្ខណៈងាយស្រួលជាងច្រើនណាស់ ។ ប៉ុន្តែភាពខ្ជីខ្ជារបៀបនេះកម្រមានណាស់ ។ ដូច្នេះ រដ្ឋអាជ្ញានៃករណីបទឧក្រិដ្ឋប្រល័យពូជសាសន៍ជាញឹកញាប់ត្រូវកសាងបំណងឧក្រិដ្ឋរបស់ជនដៃដល់ពីសកម្មភាពទាំងឡាយរបស់ជនដៃដល់ ហើយកិច្ចការនេះមានការលំបាកណាស់នៅក្នុងតុលាការ ។ វាមានលក្ខណៈសាមញ្ញច្រើនជាងនៅក្នុងការបង្ហាញការធ្វើទុក្ខបុកម្នេញ ការសម្លាប់រង្គាល និងការនិរទេសដែលធ្វើឡើងចំពោះបុគ្គល ដោយផ្អែកទៅលើសមាជិកភាពរបស់គេនៅក្នុងគណបក្សនយោបាយមួយ វណ្ណៈសង្គមមួយ ឬក្រុមផ្សេងៗទៀតដូចជា ក្រុមដែលបានកំណត់ដោយជាតិ ជនជាតិ ពូជសាសន៍ និងសាសនា ។ ដោយប្រើប្រាស់ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ អ្នកមិនចាំបាច់បង្ហាញពីបំណងក្នុងការបំផ្លាញក្រុមមួយនោះទេ ។

អ្នកស្រាវជ្រាវនិងអ្នកច្បាប់ជំនាញខាងឧក្រិដ្ឋកម្មអន្តរជាតិកាន់តែច្រើនឡើងៗនៅពេលសព្វថ្ងៃនេះ បានចាត់ទុកអំពើប្រល័យពូជសាសន៍ជាផ្នែកមួយនៃឧក្រិដ្ឋកម្ម ដែលគេឲ្យឈ្មោះថា «ឧក្រិដ្ឋកម្មធ្ងន់ធ្ងរ» ។ ឧក្រិដ្ឋកម្មប្រភេទនេះ រួមបញ្ចូលទាំងឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងឧក្រិដ្ឋកម្មសង្គ្រាមធ្ងន់ធ្ងរ ។ គេបានកត់សម្គាល់ឃើញថា អំពើប្រល័យពូជសាសន៍ជាញឹកញាប់ចាប់ផ្តើមពីឧក្រិដ្ឋកម្មសង្គ្រាមធ្ងន់ធ្ងរ និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ។ បទពិសោធន៍បានបង្រៀនថា ជាទូទៅអំពើប្រល័យពូជសាសន៍ផ្តើមចេញមួយជំហានម្តងៗ ពីការធ្វើទុក្ខបុកម្នេញ ការសម្លាប់រង្គាល ការនិរទេស និងការបោសសម្អាតក្រុមជនជាតិ ។

## អំពើប្រល័យពូជសាសន៍នៅក្នុងប្រវត្តិសាស្ត្រ

### ក) ការកសាងនិងរក្សាអាណាចក្រ

ទោះបីជាពាក្យ «ប្រល័យពូជសាសន៍» ទើបតែបង្កើតឡើងនៅពាក់កណ្តាលសតវត្សរ៍ទី២០ក្តី ពាក្យនេះបានពណ៌នាពីបាតុភាពមួយដែលមានចំណាស់ស្មើនឹងប្រវត្តិសាស្ត្រ ដែលត្រូវបានចងក្រងទុក ។ អំពើប្រល័យពូជសាសន៍កើតឡើងជាធម្មតានៅក្នុងអរិយធម៌បុរាណរបស់ប្រទេសអេហ្ស៊ីប ។ ជនជាតិម៉ាស្ស៊ីរីយ៉ាងបានអះអាងថា បានប្រព្រឹត្តអំពើនេះ ហើយករណីជាច្រើនត្រូវបានរកឃើញនៅក្នុងគម្ពីរប៊ីបចាស់ ។ ដើមកំណើតនៃអំពើប្រល័យពូជសាសន៍ហ៊ុមព័ទ្ធទៅដោយអតីតកាលដែលមិនត្រូវបានកត់




លោក ឆាំង យុ

សាស្ត្រាចារ្យ ហ្វ្រេង ឆក

សាស្ត្រាចារ្យ ដេវីត ឆេនល័រ

ត្រា ។ ប៉ុន្តែដោយ នៅក្នុងអតីតកាល អំពើប្រល័យពូជសាសន៍តែងតែត្រូវបានរាយការណ៍ភ្ជាប់ជាមួយនឹងសង្គ្រាម យើងអាចធ្វើការទស្សន៍ទាយអំពីដើមកំណើតរបស់វាបាន ។ ទីក្រុង រដ្ឋ និងអាណាចក្រមានទំហំតូចណាស់បើប្រៀបធៀបទៅនឹងស្តង់ដារទំនើបនាពេលបច្ចុប្បន្ន ។ ទីក្រុង រដ្ឋ និងអាណាចក្រទាំងនោះមានទីតាំងនៅតំបន់ដែលមានឈ្មោះថា ហ្វឺតថាល ក្រេសសិន ដែលស្ថិតនៅក្នុងតំបន់មជ្ឈិមបូព៌ានាពេលបច្ចុប្បន្ន ។ ជ្រលងនៃតំបន់ទិងរិស និង ដៃហ្វរាតសេ គឺជាតំបន់មានជីវជាតិនិងមានព្រំដែនធម្មជាតិតែបន្តិចបន្តួចប៉ុណ្ណោះ ។ តំបន់នេះលាតសន្ធឹងឆ្លងកាត់ផ្លូវដែលភ្ជាប់ទ្វីបអាស៊ី អឺរ៉ុប និងអាហ្វ្រិក ។ ជ្រលងតាមដងទន្លេនីលក៏មានសណ្ឋានប្រហាក់ប្រហែលនេះដែរ ។ ដូច្នេះឱកាសសម្រាប់ការប្រកួតប្រជែងនិងជម្លោះដែលអាចនាំទៅដល់សង្គ្រាមហាក់ដូចជាតែងតែកើតមានឡើងជានិច្ច ។ ទោះជាយ៉ាងនេះក្តី ពីដំបូងឡើយសង្គ្រាមទាំងនេះមិនបានបង្កើតឲ្យមានអ្វីនោះទេ ។ ក្រុមបរាជ័យបានវិលត្រឡប់ទៅផ្ទះវិញដើម្បីធ្វើការជ្រើសរើសនិងហ្វឹកហាត់កងទ័ពមួយទៀត ។ គេបានផលិតអាវុធបន្ថែម ហើយជួនកាលល្អជាងមុនទៀត ។ បន្ទាប់មក គេនឹងវិលត្រឡប់មកធ្វើការវាយប្រហារនៅក្នុងសង្គ្រាមថ្មីមួយ ដើម្បីយកមកវិញនូវអ្វីដែលគេបានបាត់បង់និងធ្វើការសងសឹក ។ យើងមិនចាំបាច់ធ្វើការស្រមៃច្រើនទេសម្រាប់មនុស្សម្នាក់ក្នុងការសម្រេចថា វិធីតែមួយគត់ក្នុងការរក្សាជ័យជម្នះ គឺសម្លាប់ផ្តាលសត្រូវឲ្យរលាយសាបសូន្យទាំងអស់មិនមែនត្រឹមតែកងចម្បាំងប៉ុណ្ណោះទេ ។ យើងគិតថាវិធីសាស្ត្រក្នុងការបញ្ចប់យុទ្ធនាការជ័យជម្នះមានរយៈកាលប្រហែលមួយពាន់ឆ្នាំ នៅក្នុងប្រទេសអេហ្ស៊ីប ។ ការផ្លាស់ប្តូរនេះមិនមែនកើតឡើងដោយសារការកើតមានឡើងនៃការខ្វល់ខ្វាយពីបញ្ហាមនុស្សធម៌នោះទេ ប៉ុន្តែដោយសារការមើលឃើញថាជនរងគ្រោះដែលនៅរស់មានតម្លៃជាងការដែលគេស្លាប់ ។

ដូចប្រទេសកម្ពុជាក្នុងបុរាណកាលដែរ រដ្ឋទាំងឡាយនៅក្នុងតំបន់ ហ្វឺតថាល ក្រេសសិន ប្រើប្រាស់កម្លាំងពលកម្មច្រើន ពីព្រោះជ្រលងប្រកបដោយជីវជាតិរបស់គេតម្រូវឲ្យមានប្រព័ន្ធធារាសាស្ត្រយ៉ាងល្អ ពីព្រោះព្រះជាម្ចាស់ជាច្រើនដែលគេគោរពបូជាតម្រូវឲ្យមានការសាងសង់ប្រាសាទជាច្រើន ហើយដោយមានអ្នកដឹកនាំតិចតួចណាស់ដែលពេញចិត្តនឹងរាជវាំងរបស់អ្នកដឹកនាំជំនាន់មុនៗ ។ ហេតុដូច្នេះហើយ មេដឹកនាំបានចំណាយធនធានយ៉ាងសម្បើមដើម្បីលើកតម្កើងរបបគ្រប់គ្រងរបស់ខ្លួន ។ ដូចនេះការយល់ដឹងថ្មីមួយដែលថា ចំណាប់ខ្មាំងមានតម្លៃប្រើប្រាស់ក្នុងនាមជាទាសករជាងសាកសពបានរីករាលដាលពេញក្នុងតំបន់នេះ ។

អំពើប្រល័យពូជសាសន៍ត្រូវបានបន្តអនុវត្តដោយរដ្ឋនិងអាណាចក្រ ដោយហេតុផលបីយ៉ាង ៈ

១) ដើម្បីកម្ទេចចោលនូវការគំរាមកំហែងពិតប្រាកដ ឬដែលបានដឹងមុន

២) ដើម្បីបំភិតបំភ័យសត្រូវពិតប្រាកដ ឬដែលអាចមើលឃើញ

៣) ដើម្បីទទួលបានធនធានសេដ្ឋកិច្ចដែលជារបស់អ្នកដទៃ ប៉ុន្តែមិនអាចដណ្តើមយកមកបាន តាមរយៈការប្លន់ ។

គោលបំណងទាំងបីនេះជាធម្មតាកើតឡើងក្នុងពេលដំណាលគ្នា ទោះបីជាក្នុងចំណោមនេះមានភាពលើសលុបជាងគោលបំណងផ្សេងទៀតនៅក្នុងស្ថានភាពជាក់លាក់ណាមួយ ។

ប្រវត្តិនៃអាណាចក្ររហូតមកទល់នឹងរយៈកាលសម័យទំនើបត្រូវបានកត់សម្គាល់ដោយការធ្វើទុក្ខបុកម្នេញតាមកាលវេលា ដែលជួនកាលរីកធំឡើងទៅជាអំពើប្រល័យពូជសាសន៍ដែលប្រព្រឹត្តឡើងដើម្បីកសាងអាណាចក្រ ឬរក្សាអាណាចក្រ ។ ចរិតលក្ខណៈដ៏សំខាន់មួយនៃប្រភេទអំពើប្រល័យពូជសាសន៍នេះគឺថា ក្រុមជនរងគ្រោះតែងតែស្ថិតនៅក្រោមសង្គមរបស់ជនដៃដល់ ។ យុទ្ធនាការរបស់ទីក្រុង អាតែនស ប្រឆាំងនឹងទីក្រុងមេលូស យុទ្ធនាការរបស់ទីក្រុង រ៉ូម ប្រឆាំងនឹងទីក្រុង ខាហ្សឹក យុទ្ធនាការរបស់ ហ្សង់ហ្ស៊ី ខាន់ ប្រឆាំងនឹងប្រជាជនជាច្រើន និង យុទ្ធនាការរបស់ ក្រូសាដឺរ ប្រឆាំងនឹងប្រជាជននៃទីក្រុងអ៊ិនតូញ និង ហ្សេរុសាឡឹម អាចជាឧទាហរណ៍ ។

## ១) ដើម្បីអនុវត្តជំនឿ មនោគមន៍វិជ្ជា ឬទ្រឹស្តី

ចាប់ផ្តើមជាមួយនឹងបូជនីយកិច្ច ធាតុផ្សំថ្មីមួយដែលលេចធ្លោជាងគេនៅក្នុងសតវត្សរ៍ទី២០នេះ គឺអំពើប្រល័យពូជសាសន៍ត្រូវបានធ្វើឡើងដើម្បីអនុវត្តជំនឿ មនោគមន៍វិជ្ជា ឬទ្រឹស្តី ។

បូជនីយកិច្ចដើម្បីដណ្តើមយកដែនដី ប៉ាឡេស្ទីន ជាថ្មីម្តងទៀត ក៏ដូចជាបូជនីយកិច្ចរបស់ជនជាតិ អាប៊ីកដេនសៀ នៅភាគខាងត្បូងប្រទេសបារាំង គឺជាសញ្ញាដំបូងមួយដែលគោលបំណងក្នុងការពង្រីកអាណាចក្រ និងផ្សព្វផ្សាយជំនឿកើតឡើងព្រមគ្នា ។ នៅចុងសតវត្សរ៍ទី១១ ក្រុមអ្នកចម្បាំងបានចាប់ផ្តើមយុទ្ធនាការដើម្បីផ្តល់សេរីភាពដល់ដែនដីពិសិដ្ឋពីពួកអត់សាសនា ។ នៅពេលគេលុកលុយដែនដី ហ្សេរុសាឡឹម គេបានសម្លាប់រង្គាលប្រជាជនដែលមិនមែនជាគ្រិស្តសាសនិកទាំងអស់ ។ ប៉ុន្តែ គេក៏បានបន្តរស់នៅទីនោះដើម្បីបង្កើតរាជាណាចក្រ និងប្រមូលយកទ្រព្យសម្បត្តិ ។ នៅដើមសតវត្សរ៍ទី១៣ ឡាងដុកដៀច (សព្វថ្ងៃ ស្ថិតនៅភាគខាងត្បូងប្រទេសបារាំង) ដែលជាតំបន់រុងរឿងជាងគេបំផុតនៅទ្វីបអឺរ៉ុប ត្រូវបានបំផ្លាញដោយអ្នកវាយប្រហារជនជាតិ អាប៊ីកដេនសៀ ។ បព្វជិតសាសនា បានចោទប្រកាន់អភិជននៅតំបន់ឡាងដុកដៀច ជាមួយនឹងពាក្យចចាមអារ៉ាម ដែលគំរាមកំហែងដល់អាជ្ញាធរទីក្រុងរ៉ូម ហើយបានយាងព្រះមហាក្សត្របារាំងឲ្យរៀបចំការវាយប្រហារទៅលើក្រុមជនដែលប្រឆាំងនឹងជំនឿសាសនាគ្រិស្ត ។ គាត់បានធ្វើរឿងនេះប្រកបដោយប្រសិទ្ធភាពបំផុត ដែលធ្វើឲ្យតំបន់នោះមិនអាចងើបឡើងវិញបាន ។ ខណៈពេលដែលក្រុមអ្នកប្រឆាំងសាសនាគ្រិស្តនិងបក្សពួករបស់ខ្លួនត្រូវបានកម្ទេចចោល តំបន់នោះក៏ត្រូវបានបញ្ចូលទៅក្រោមការគ្រប់គ្រងរបស់រាជាណាចក្របារាំង ។

អំពើប្រល័យពូជសាសន៍ដែលធ្វើឡើងដើម្បីមនោគមន៍វិជ្ជាសុទ្ធសាធដំបូងបំផុតប្រហែលជាការធ្វើទុក្ខបុកម្នេញទៅលើអ្នកកាន់សាសនាគ្រិស្តនៅក្នុងប្រទេសជប៉ុនក្នុងសតវត្សរ៍ទី១៧ ។ តុលាការ តុគុហ្គាវ៉ា បានប្រឈមមុខទៅនឹងការបះបោរពីរឿងពន្ធដារ ពីសំណាក់អ្នកចូលសាសនាគ្រិស្តក្នុងឆ្នាំ១៦៣៧ ។ ដោយត្រូវបានគេហៅថាការបះបោរ ស៊ីម៉ាបារ៉ា តុលាការ តុគុហ្គាវ៉ា បានកម្ទេចអ្នកបះបោរ និងបានបន្តទោសសម្លាប់រង្គាលអ្នកទាំងឡាយណាដែលមិនព្រមបោះបង់ចោលជំនឿសាសនាគ្រិស្តរបស់ខ្លួន ។ គេក៏បានដកជនបរទេសចេញពីប្រទេសជប៉ុន ក្នុងរយៈពេលពីររយឆ្នាំក្រោយមកទៀត ។

ពេលយើងចូលមកដល់សតវត្សរ៍ទី២០ គ្រប់អំពើប្រល័យពូជសាសន៍ធំៗទាំងអស់ត្រូវបានធ្វើឡើងដើម្បីពង្រឹងមនោគមន៍វិជ្ជា ។ នៅទីនេះ ក្រុមជនរងគ្រោះតែងតែមានទីតាំងនៅក្នុងសង្គមជាមួយនឹងជនដៃដល់ទាំងការរស់នៅនិងទំនាក់ទំនងក្នុងសង្គម ។ ពិសេសជាងនេះទៅទៀត អំពើប្រល័យពូជសាសន៍ទាំងនេះ ត្រូវបានប្រព្រឹត្តឡើងដោយការចំណាយយ៉ាងសម្បើមរបស់សង្គមជនដៃដល់ ទាំងការចំណាយផ្នែកសង្គមកិច្ចនិងសេដ្ឋកិច្ច ។ ប្រភេទនេះ ខុសពីអំពើប្រល័យពូជសាសន៍ដែលប្រព្រឹត្តឡើងដើម្បីពង្រីកនិងថែរក្សាអាណាចក្រ ។ អំពើប្រល័យពូជសាសន៍ប្រភេទនេះ ផលិតផលប្រយោជន៍ជាក់ស្តែងឲ្យជនដៃដល់ដូចជា ការលុបបំបាត់ការគំរាមកំហែង បំភិតបំភ័យខ្លាំង និងការទទួលបាននូវទ្រព្យសម្បត្តិ ។ វាគួរឲ្យកត់សម្គាល់ដែលថា ប្រការនេះគឺមិនពិតទេសម្រាប់អំពើប្រល័យពូជសាសន៍ទៅលើជនជាតិ អាមីនៀ ហ្វូឡូខសត៍ ការសម្លាប់រង្គាលទៅលើក្រុមជាច្រើនក្រោមរបបស្តាលីន និងការសម្លាប់រង្គាលប្រជាជនកម្ពុជាដែលរស់នៅតាមទីក្រុងដោយខ្មែរក្រហម ។ ក្នុងករណីអំពើប្រល័យពូជសាសន៍នៅរ៉្វាន់ដាប្រឆាំងនឹងជនជាតិទូតស៊ី ក្នុងឆ្នាំ១៩៩៤ ខណៈពេលដែលមានការអះអាងថាពួកទូតស៊ីបានគំរាមកំហែងដល់ការរស់រានរបស់ពួកហ៊ូទូ ។ ជនរងគ្រោះភាគច្រើន គឺជាកសិករ អ្នកធ្វើការងារ និងជនដែលគ្មានអាវុធជាតិទូតស៊ី គឺមិនមែនក្រុមទូតស៊ីដែលបានឈ្លានពានរ៉្វាន់ដាដើម្បីដណ្តើមយកដីវិញនោះទេ ។ ជាងនេះទៅទៀត ថ្នាក់ដឹកនាំដែលជាជនដៃដល់គឺជាក្រុមហ៊ូទូដែលស្ថិតនៅក្នុងរដ្ឋាភិបាលរ៉្វាន់ដា ។ គេបានអះអាងអំពីឧត្តមភាពរបស់ហ៊ូទូ និងពីភាពចង្រៃរបស់ទូតស៊ី ដែលតម្រូវឲ្យមានការកម្ទេចចោល ។

មានទម្រង់ជាច្រើនដែលអំពើប្រល័យពូជសាសន៍បែបមនោគមន៍វិជ្ជាមានលក្ខណៈប្រហាក់ប្រហែលគ្នា ៖

១) គេបញ្ចុះតម្លៃបុគ្គលដើម្បីប្រយោជន៍រួម និងបដិសេធលទ្ធិប្រជាធិបតេយ្យ និងជនទាំងឡាយណាដែលឲ្យតម្លៃទៅលើមនុស្សជាតិ ។

២) គេបូជាគ្រប់មធ្យោបាយ ដើម្បីសម្រេចបានលទ្ធផលចុងក្រោយ ពិសេសការសម្លាប់ដើម្បីសម្រេចបាននូវគោលដៅនយោបាយ ។

៣) គេបដិសេធនីតិរដ្ឋ តាមរយៈការគោរពរដ្ឋធម្មនុញ្ញ ឬដើម្បីឯករាជ្យភាពនៃតុលាការនិងចៅក្រម ។

៤) គេមិនផ្តល់សច្ចាប័ន និងសេចក្តីប្រកាសជាសកល ស្តីពីសិទ្ធិមនុស្សដែលអនុម័តដោយមហាសន្និបាតអង្គការសហប្រជាជាតិ នៅខែធ្នូ ឆ្នាំ១៩៤៨ ។

## កម្ពុជាប្រជាធិបតេយ្យនៅក្នុងប្រវត្តិសាស្ត្រនៃអំពើប្រល័យពូជសាសន៍

ការពិនិត្យមើលដោយសង្ខេបទៅលើប្រវត្តិនៃអំពើប្រល័យពូជសាសន៍ អនុញ្ញាតឲ្យយើងដាក់ការគ្រប់គ្រងរបស់ខ្មែរក្រហមនិងលទ្ធផលនៃរបបនេះទៅក្នុងបរិបទនៃអំពើប្រល័យពូជសាសន៍ និងឧក្រិដ្ឋកម្មធ្ងន់ធ្ងរដទៃទៀតបានទូលំទូលាយជាងមុន ។ អត្ថន័យមួយចំនួនបានលើកឡើង ៖

១) ព្រឹត្តិការណ៍ដើមក្នុងរបបកម្ពុជាប្រជាធិបតេយ្យគឺជាភាពផ្សេងៗគ្នានៃដំណើរស្វែងរកសង្គមល្អឥតខ្ចោះមួយនៃមនោគមន៍វិជ្ជា ម៉ាក្ស-លេនីន និង ម៉ៅ ។ ដោយផ្អែកលើមនោគមន៍វិជ្ជានេះ បក្សរបស់ខ្មែរក្រហមបានអនុវត្តនូវការពិសោធន៍ដ៏ធំធេងក្នុងការកសាងសង្គមក្នុងគោលបំណងលុបបំបាត់អតីតកាល ដើម្បីកសាងអនាគតល្អឥតខ្ចោះមួយ ។ ពាក្យស្លោកនៅក្នុងការចាប់ផ្តើមប្រវត្តិសាស្ត្រ គឺការបង្វិលពេលវេលាមកកាន់ "ឆ្នាំសូន្យ" ដែលជាគោលដៅច្បាស់លាស់មួយ ។ គោលដៅសម្រាប់អនាគតល្អឥតខ្ចោះមួយ តម្រូវឲ្យមានការបញ្ជូនអ្នករស់នៅក្នុងក្រុងភ្នំពេញយ៉ាងសាហាវព្រៃផ្សៃទៅកាន់ទីជនបទ និងការចាប់ផ្តើមដាក់ឲ្យមាននូវវិធានការបង្ខំឲ្យប្រជាជនធ្វើការជាទម្ងន់ដើម្បីអនុវត្តនូវគំនិតវិវើរវាយដែលគ្មានហេតុផលរបស់ខ្មែរក្រហម ក្នុងការកសាងប្រព័ន្ធធារាសាស្ត្រដ៏ច្រើនសន្ធឹកសន្ធាប់ ដើម្បីដាំដុះស្រូវរៀងរាល់ឆ្នាំ ។ ដំណើរការស្វែងរកសង្គមល្អឥតខ្ចោះនេះ ក៏ត្រូវបានមើលឃើញតាមរយៈគោលនយោបាយរបស់ខ្មែរក្រហមក្នុងការគូសបន្ទាត់រវាង "ប្រជាជនចាស់" នៅទីជនបទ និង "ប្រជាជនថ្មី" ដែលត្រូវបាននិរទេសពីទីក្រុង ។ "ប្រជាជនថ្មី" ដែលមានបាតដៃទន់ និងមានគំនិតទោរទៅរកខាងបស្ចិមប្រទេសប្រកបដោយភាពពុករលួយត្រូវបានប្រព្រឹត្តមកលើក្នុងនាមជាជនភាគតិចដែលជីវិតរបស់អ្នកទាំងនេះនឹងអាចត្រូវបាត់បង់គ្រប់ពេលវេលាទាំងអស់ ។ "ប្រជាជនចាស់" មើលឃើញប្រជាជនថ្មីថាបានរំលោភទៅលើច្បាប់ថ្មី ។

២) ការឡើងកាន់អំណាចរបស់ខ្មែរក្រហមកើតឡើងប្រឆាំងនឹងដំណើរនៃបដិវត្តន៍និងសង្គ្រាម ។ គេចាប់ផ្តើមដណ្តើមការកាន់កាប់ប្រទេសកម្ពុជាក្នុងអំឡុងពេលសង្គ្រាមវៀតណាម ហើយទទួលបានជំនួយយោធាយ៉ាងច្រើនសន្ធឹកសន្ធាប់ពីកុម្មុយនីស្តវៀតណាម ។ សង្គ្រាមបម្រើដល់ភាពត្រឹមត្រូវនៃអំពើព្រៃផ្សៃដែលរួមមាន ការសម្លាប់មន្ត្រីរបស់ លន់ នល់ ។ ស្ថានភាពនៃសង្គ្រាមក៏បម្រើដល់ការសម្ងាត់ជុំវិញបញ្ហាថាតើអ្នកណាដឹកនាំអង្គការ និងកន្លែងរស់នៅរបស់មេដឹកនាំខ្មែរក្រហម ។

៣) ដោយផ្អែកទៅលើការស្វែងរកសង្គមល្អឥតខ្ចោះរបស់គេនិងការចាប់ផ្តើមប្រវត្តិសាស្ត្រជាថ្មីម្តងទៀត ខ្មែរក្រហមបានបដិសេធនូវតម្លៃនៃវប្បធម៌ជាប្រពៃណី ដែលគេមើលឃើញថាមានសារៈសំខាន់ក្នុងការទទួលបានការអភិវឌ្ឍ ។ នៅក្រោមការបែងចែកជាថ្មីរបស់គេ សមាជិកគ្រួសារទាំងអស់នឹងលែងគោរពអំណាចរបស់ឪពុកម្តាយ ។ អង្គការបានដាក់ជំនួសអំណាចរបស់ឪពុកម្តាយឲ្យនៅក្រោមបញ្ជារបស់ខ្លួន ហើយបានប្រែក្លាយកុមារឲ្យទៅជាអ្នកយកការណ៍ពីឪពុកម្តាយទៅវិញ ។ ការគោរពចាស់ទុំនិងការអនុវត្តកសិកម្មបែបបុរាណក៏បានក្លាយទៅជាជនរងគ្រោះនៃការស្វែងរកអនាគតល្អឥតខ្ចោះរបស់ខ្មែរក្រហមផងដែរ ។ លទ្ធផល គឺជាគ្រោះមហន្តរាយមួយ ។ ប្រជាជនសាមញ្ញជួបនូវគ្រោះទុរ្ភិក្សនិងជំងឺ ។

៤)ដូច ស្តាលីន និង ម៉ៅ ដែរ ប៉ុល ពត បានបង្កើតខ្មាំងបន្តបន្ទាប់និងពួកវិទ្ធង្សនា ដើម្បីពន្យល់អំពីបរាជ័យរបស់គាត់ចំពោះផែនការសេដ្ឋកិច្ច និងបង្ហាញពីភាពត្រឹមត្រូវនៃការអនុវត្តអំពើឃោរឃៅរបស់អង្គការ ដែលផ្តោតទៅលើបន្សុទ្ធកម្មក្នុងទ្រង់ទ្រាយធំនៅក្នុងជួរបក្សនិងអំពើឃោរឃៅនៅភូមិភាគបូព៌ា ។ រាល់ការងាករេចេញពីបញ្ជានិងជំនឿរបស់អង្គការដូចជា ការរិះគន់ទៅលើភាពរីងស្ងួស និងកម្មវិធីដែលគ្មានភាពប្រាកដនៅជនបទជារបស់បក្សនឹងត្រូវចោទប្រកាន់ពីបទងាករេ ។

៥) ប៉ុល ពត និយាយពន្លើសជាប់ជានិច្ចអំពីការគំរាមកំហែងរបស់សត្រូវបរទេសដូចដែល ស្តាលីន, អ៊ីត្លែរ, និង ម៉ៅ ធ្វើដូច្នេះ

ដែរ ដើម្បីបង្ហាញពីភាពត្រឹមត្រូវរបស់ខ្លួនក្នុងការប្រព្រឹត្តអំពើឃោរឃៅបន្ទាប់ពីចុងបញ្ចប់នៃសង្គ្រាម និងដើម្បីពន្យល់ពីតម្រូវការក្នុងការដាក់ប្រទេសកម្ពុជាឲ្យនៅដាច់ពីពិភពលោក ។ ដោយឈរលើមូលហេតុនេះ ប៉ុល ពត បដិសេធមិនទទួលយកជំនួយបរទេសពីប្រទេសចក្រពត្តិនិយមនិងសង្គមនិយម បដិសេធមិនព្រមទទួលយកការដឹកជញ្ជូនថ្នាំពេទ្យដែលត្រូវការចាំបាច់ដើម្បីព្យាបាលជំងឺ និងបដិសេធមិនព្រមទទួលយកអាហារដើម្បីប្រយុទ្ធប្រឆាំងនឹងគ្រោះទុរ្ភិក្សដែលបណ្តាលឲ្យប្រជាជនកម្ពុជារាប់រយពាន់នាក់ស្លាប់បាត់បង់ជីវិត ។

តើវាជាបញ្ហាសម្រាប់សិស្សរបស់អ្នកដែរឬទេ ប្រសិនបើខ្មែរក្រហមប្រព្រឹត្តខក្រិដ្ឋកម្មប្រល័យពូជសាសន៍ ឬប្រព្រឹត្តអំពើខក្រិដ្ឋធ្ងន់ធ្ងរដទៃទៀត?

ឥឡូវនេះ អ្នកដឹងថាដើម្បីកាត់ទោសអ្នកណាម្នាក់ពីបទខក្រិដ្ឋប្រល័យពូជសាសន៍ តម្រូវឲ្យមានភ័ស្តុតាងគ្រប់គ្រាន់ដើម្បីបង្ហាញថាគេមានបំណងចង់បំផ្លាញក្រុមជាតិជនជាតិ ជាតិសាសន៍ ឬសាសនាណាមួយ ។ ម្យ៉ាងវិញទៀត អ្នកក៏បានដឹងដែរថា វាអាចធ្វើទៅបានក្នុងការកាត់ទោសអ្នកណាម្នាក់ពីបទខក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិចំពោះការសម្លាប់ ការធ្វើទុក្ខបុកម្នេញក្នុងនាមជាបុគ្គលដោយសារតែគេជាសមាជិកនៃក្រុមនយោបាយ ឬសង្គមណាមួយបន្ថែមពីលើសមាជិកភាពរបស់គេនៅក្នុងក្រុមជាតិជនជាតិ ជាតិសាសន៍ ឬសាសនាណាមួយ ។ សូមចងចាំថា ការសម្លាប់ជនស៊ីវិលស្លូតត្រង់ដោយសារតែស្ថិតនៅក្នុងវណ្ណៈសង្គមណាមួយគឺស្ថិតនៅក្នុងខក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ប៉ុន្តែមិនស្ថិតនៅក្នុងអនុសញ្ញាប្រល័យពូជសាសន៍របស់អង្គការសហប្រជាជាតិទេ ។ ហើយក៏សូមចងចាំដែរថា ការសម្លាប់ជនស្លូតត្រង់ដោយសារតែស្ថិតនៅក្នុងក្រុមនយោបាយណាមួយ គឺស្ថិតនៅក្នុងបទខក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ប៉ុន្តែមិនស្ថិតនៅក្នុងអនុសញ្ញាប្រល័យពូជសាសន៍របស់អង្គការសហប្រជាជាតិទេ ។ រហូតមកទល់នឹងថ្ងៃនេះ ការិយាល័យសហព្រះរាជអាជ្ញានៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាមិនទាន់បានចោទប្រកាន់ជនជាប់ចោទណាម្នាក់ជាមួយនឹងខក្រិដ្ឋកម្មប្រល័យពូជសាសន៍នៅឡើយទេ ។ ទោះជាយ៉ាងនេះក្តី សូមកត់សម្គាល់ថា សហព្រះរាជអាជ្ញាបានធ្វើការចោទប្រកាន់ពីបទខក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ។

តើវាមានបញ្ហាសម្រាប់សិស្សរបស់អ្នកដែរឬទេ ប្រសិនបើចុងចោទមិនត្រូវបានចោទប្រកាន់ពីខក្រិដ្ឋកម្មប្រល័យពូជសាសន៍? អ្នកនឹងកត់សម្គាល់ឃើញថា សៀវភៅដែលអ្នកនឹងប្រើប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) បាននិយាយពីពាក្យ «ប្រល័យពូជសាសន៍» ហើយពាក្យនេះលេចឡើងនៅពេលអ្នកនិពន្ធសរសេរអំពី «បូជនីយដ្ឋានប្រល័យពូជសាសន៍» ។ ឥឡូវនេះ អ្នកដឹងពីមូលហេតុហើយ ។ «បទខក្រិដ្ឋកម្មធ្ងន់ធ្ងរ» គឺជាប្រភេទមួយដែលអ្នកអាចគិតទៅដល់តង់ក្រណាត់មួយយ៉ាងធំដែលចងភ្ជាប់ទៅនឹងសសរបីយ៉ាងរឹងមាំ ៖ ខក្រិដ្ឋកម្មប្រល័យពូជសាសន៍ ខក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ឬខក្រិដ្ឋកម្មសង្គ្រាមធ្ងន់ធ្ងរ ។ វាមិនមានបញ្ហាអ្វីធ្ងន់ធ្ងរទេ ប្រសិនបើចុងចោទត្រូវបានកាត់ទោសដោយឈរនៅក្រោមតង់មួយនេះ ពីព្រោះគេប្រព្រឹត្តបទខក្រិដ្ឋប្រល័យពូជសាសន៍ ឬខក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ទោះជាខក្រិដ្ឋកម្មមួយណាក៏ដោយ ក៏ជាខក្រិដ្ឋកម្មធ្ងន់ធ្ងរបំផុតនៅលើពិភពលោក ។ ដូច្នេះ នៅពេលយើងបង្រៀនសិស្សរបស់យើងពីអំពើរបស់ខ្មែរក្រហម យើងនឹងជួយគេឲ្យយល់ពីអត្ថន័យពីរៈ ១) តើខ្មែរក្រហមធ្វើអ្វីខ្លះមកលើប្រជាជនខ្លួនឯង ២) ហេតុអ្វីបានជាគេធ្វើដូច្នេះ ។ នៅពេលយើងធ្វើដូច្នេះ យើងកំពុងតែបង្រៀនសិស្សរបស់យើងពីភាពខុសគ្នារវាងសង្គមមួយដែលអាស្រ័យលើតម្លៃរបស់មនុស្ស និងសិទ្ធិរបស់បុគ្គល និងសង្គមមួយដែលដាក់តម្រូវការរបស់សមូហភាពពីលើសិទ្ធិរបស់បុគ្គល ។ ហើយនៅពេលយើងពន្យល់អំពីមូលហេតុដែលខ្មែរក្រហមធ្វើដូច្នេះ ប្រការនេះនឹងជួយលើកទឹកចិត្តគេ ។ យើងកំពុងតែជួយសិស្សឲ្យយល់ពីលទ្ធផលដែលកើតចេញមកពីការអះអាងក្នុងការស្វែងរកសង្គមល្អឥតខ្ចោះមួយដែលមិនឲ្យតម្លៃទៅលើប្រពៃណីនិងដែលអះអាងថា គេនឹងចាប់ផ្តើមប្រវត្តិសាស្ត្រសាជាថ្មីម្តងទៀត ។ ខ្ញុំសង្ឃឹមថា អ្នកនឹងយល់ស្របថាមេរៀននេះមានសារៈសំខាន់ ប្រសិនបើយើងចង់សម្រេចបាននូវ «សង្គមល្អប្រសើរ» មួយ គឺមិនត្រឹមតែនៅកម្ពុជាប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងនៅកាណាដាទៀតផង ។ ខ្ញុំសូមអរគុណចំពោះការយកចិត្តទុកដាក់ស្តាប់របស់អ្នក ។

**វ៉ាហ្វ្រេង ឆក**

# បទពិសោធន៍អប់រំប្រវត្តិសាស្ត្រនិងការអភិវឌ្ឍជាតិ

ប្រទេសកម្ពុជាមានសក្តានុពលសេដ្ឋកិច្ច និងធម្មជាតិចម្រុះគួរជាទីមោទនៈបើយើងពិនិត្យមើលលើវិស័យសេដ្ឋកិច្ចជាសំខាន់នោះ ។ ប៉ុន្តែ បើយើងនាំការរំពឹងមើលពីជ្រុងនៃសកម្មភាពមនុស្សខ្មែរក្នុងកាលប្រវត្តិវិញ យើងនឹងអាចចោទជាចម្ងល់ថាតើហេតុអ្វីបានជាប្រជាជនខ្មែរស្លាប់ដោយសារការអត់ឃ្លាន និងការកាប់សម្លាប់គ្នាឯងក្នុងទសវត្សរ៍៧០ ?

សៀវភៅប្រវត្តិសាស្ត្រស្តីអំពីសម័យកម្ពុជាប្រជាធិបតេយ្យដែលឆ្លុះបញ្ចាំងពីរបបមួយដែលគ្រប់គ្រងដោយខ្មែរក្រហមបានទាក់ទាញមនុស្សខ្មែរចាស់ក្មេងជាច្រើននាក់ឲ្យអាន ដើម្បីស្វែងយល់តាមគោលគំនិតរបស់គេរៀងៗខ្លួនដែលចង់បាន ។ សកម្មភាពនេះបានបង្កលក្ខណៈងាយស្រួលក្នុងការអប់រំប្រវត្តិសាស្ត្រសម័យកម្ពុជាប្រជាធិបតេយ្យជាសាធារណៈ ។ ប៉ុន្តែ ក្នុងបរិបទអប់រំវិទ្យាសាស្ត្រប្រវត្តិវិទ្យាគួរត្រូវមានគ្រឹះដែលជាផ្នែកភ្ជាប់ចំណេះដឹងប្រវត្តិសាស្ត្រដែលត្រូវឈរលើតួនាទីសង្គមនិងតម្រូវការសង្គមជាការចាំបាច់ ។

ក្រោយថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ ប្រជាជាតិខ្មែរទាំងមូលបានពាំនាំនូវវិបត្តិសង្គមដ៏សែនជូរចត់ផ្សាយជូនពិភពលោកដោយការគាំពារនូវសេចក្តីឈឺចាប់ដែលបានជួបប្រទះក្នុងសម័យខ្មែរក្រហមដែលមានឈ្មោះជាផ្លូវការថា «កម្ពុជាប្រជាធិបតេយ្យ» ដែលផ្តើមក្នុងអំឡុងឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ ។ នេះគឺជាការបញ្ជាក់រួចជាស្រេចថា យើងជាខ្មែរមិនចង់ឃើញខ្មែរជំនាន់ក្រោយៗត្រូវទទួលរងទុក្ខវេទនាបែបនេះទៀតទេ ។ ដូច្នេះ ដើម្បីរារាំងមិនឲ្យមានការត្រឡប់មកវិញនូវរាល់អំពើអយុត្តិធម៌សង្គមប្រល័យជាតិឯងនេះ ការអប់រំប្រវត្តិសាស្ត្រជាតិស្តីពីសម័យកម្ពុជាប្រជាធិបតេយ្យត្រូវតែផ្អែកលើគោលការណ៍ចម្បងបីសំខាន់គឺ ៖

១) គោលការណ៍បង្រួបបង្រួមជាតិ

២) គោលការណ៍ស្នេហាជាតិ

៣) គោលការណ៍អភិវឌ្ឍន៍ជាតិ

### ក) គោលការណ៍បង្រួបបង្រួមជាតិ

ក្នុងបរិបទដែលប្រទេសកម្ពុជាកំពុងទទួលអំណោយផលក្នុងការស្តារប្រទេសឲ្យមានវឌ្ឍនភាព ក្រោមការជួយជ្រោមជ្រែងពីអន្តរជាតិនិងប្រជាជាតិផ្ទាល់ខ្លួននោះ ការនាំប្រទេសឲ្យមានសន្តិភាពគឺជាកត្តាគន្លឹះបំផុត ។ អ្នកអប់រំប្រវត្តិសាស្ត្រជាតិអំពីសម័យកម្ពុជាប្រជាធិតេយ្យគួរគប្បីទាញយកតែគោលព្រឹត្តិការណ៍សំខាន់ៗណាដែលអាចធ្វើឲ្យសិស្សយល់បានថា ការឈឺចាប់ទាំងឡាយនោះបង្កដោយក្រុមមេដឹកនាំកំពូលៗដោយមិនផ្តោតសកម្មភាពកំហុសសំដៅលើក្រុមកម្មាភិបាលតូចតាចដែលអាចជាឆ្នួនបំភិតបំភ័យនាំភាពអសកម្មដែលផ្ទុយទៅនឹងបរិបទសន្តិភាពរបស់សង្គមនាពេលបច្ចុប្បន្ន ។ ប្រការដែលត្រូវប្រកាន់គោលការណ៍នេះជាបឋមគឺមានន័យថា អ្នកអប់រំត្រូវប្រកាន់គោលជំហរបង្រួបបង្រួមជាតិដោយការយកវិធីអប់រំប្រវត្តិសាស្ត្រសម័យកម្ពុជាប្រជាធិបតេយ្យជាកញ្ចក់ឆ្លុះអំពីភាពគ្មានលំនឹងនយោបាយ ភាពមិនទុកចិត្តគ្នា ភាពគុំកួនប្រវត្តិសាស្ត្រ និងភាពគ្មានយុត្តិធម៌សង្គមថាជាដើមហេតុនៃការបែកបាក់សង្គមជាតិ ។ យោងលើកិច្ចការអប់រំដែលអាចទាញបញ្ជាក់ពីព្រឹត្តិការណ៍នៃសម័យកម្ពុជាប្រជាធិបតេយ្យ ដោយព្យាយាមបញ្ចូលគោលគំនិតអប់រំឲ្យមានសមានចិត្តស្រឡាញ់គ្នាគោរពសិទ្ធិ និងយោគយល់គ្នា អ្នកអប់រំអាចសម្រេចគោលការណ៍បង្រួបបង្រួមជាតិបាន ។ ទោះជាយ៉ាងនេះក្តី ការអប់រំប្រវត្តិសាស្ត្រសម័យកម្ពុជាប្រជាធិបតេយ្យក៏ត្រូវតែរួមបញ្ចូលគោលកាណ៍អប់រំជាតិនិយមដែរ ។

### ខ) គោលការណ៍ស្នេហាជាតិ

ស្មារតីបង្រួបបង្រួមជាតិជាមធ្យោបាយសម្រាប់ឈានដល់ការសម្រេចគោលការណ៍ស្នេហាជាតិ ដែលជាតួនាទីមួយទៀតក្នុងការអប់រំប្រវត្តិសាស្ត្រ ។ អ្នកអប់រំប្រវត្តិសាស្ត្រសម័យ

កម្ពុជាប្រជាធិបតេយ្យ ក៏ត្រូវតែមានគោលចំណុចសកម្មសម្រាប់អប់រំអំពីភក្តីភាពចំពោះជាតិដោយគូសបង្ហាញពីការបាត់បង់នូវមនសិការជាតិនិយមរបស់មេដឹកនាំសម័យកម្ពុជាប្រជាធិបតេយ្យមកធ្វើការបញ្ជាក់ ។ ដើម្បីផ្តោតចំណាប់អារម្មណ៍លើកិច្ចការនេះ ការចាប់យកព្រឹត្តិការណ៍អាជ្ញានិយមអត្តទត្តនិយម និងផ្តាច់ការនិយមដែលជាទង្វើរបស់មេដឹកនាំសម័យកម្ពុជាប្រជាធិបតេយ្យ មកធ្វើជាភ័ស្តុតាងអាចនាំមកនូវការវិនិច្ឆ័យពីកត្តាក្បត់ជាតិឯងរបស់មេដឹកនាំទាំងនោះ ។ ដូច្នេះ គោលការណ៍អប់រំប្រវត្តិសាស្ត្រជាតិអំពីសម័យកម្ពុជាប្រជាធិបតេយ្យអាចទាញបង្ហាញបានយ៉ាងងាយថា ការគ្មានមនសិការស្នេហាជាតិ គឺជាមោទកភាពជ្រុលនិយមរហូតដល់មានការប្រកួតប្រជែងដោយមិនបានគិតពីផលវិបាករបស់ជាតិនាពេលអនាគត ។ ដោយឈរលើមូលដ្ឋានស្នេហាជាតិ អ្នកអប់រំប្រវត្តិសាស្ត្រសម័យកម្ពុជាប្រជាធិបតេយ្យអាចបណ្តុះបាននូវទឹកចិត្តលះបង់ទាំងឡាយដើម្បីជាតិ សម្រាប់ជាជំហរដ៏មុតមាំក្នុងគោលការណ៍អភិវឌ្ឍដែលជាតម្រូវការចាំបាច់របស់សង្គមកំពុងអភិវឌ្ឍន៍នៃកម្ពុជាបច្ចុប្បន្ន ។

### ក) គោលការណ៍អភិវឌ្ឍន៍ជាតិ

សកម្មភាពសង្គមមួយមានដំណើរការអភិវឌ្ឍន៍បាន លុះត្រាតែសមាជិកសង្គមមានថាមពលគ្រប់គ្រាន់ទាំងស្មារតីបញ្ញាញាណ និងពលកម្ម ។ អ្នកអប់រំប្រវត្តិសាស្ត្រសម័យកម្ពុជាប្រជាធិបតេយ្យត្រូវតែប្រកាន់គោលការណ៍អភិវឌ្ឍន៍ជាតិដោយផ្តោតលើការប្រៀបធៀបគំនិតអប់រំក្នុងសម័យនេះជាមួយសម័យជឿនលឿនណាមួយ ។ លើសពីនេះ អ្នកអប់រំគួរទាញយកព្រឹត្តិការណ៍ណាដែលអាចបង្ហាញថា ជាគោលនយោបាយបញ្ច្រាសទិសអភិវឌ្ឍន៍នៃសម័យកម្ពុជាប្រជាធិបតេយ្យមកធ្វើជាភ័ស្តុតាងបញ្ជាក់ ។ ប៉ុន្តែ អ្នកអប់រំប្រវត្តិសាស្ត្រជាតិចាំបាច់ណាស់ត្រូវយល់ថា មាគ៌ាអភិវឌ្ឍន៍ត្រូវប្រកបដោយសកម្មភាពអ្វីជាមូលដ្ឋានដើម្បីធ្វើជាទុនត្រិះរិះពិចារណារកបទពិសោធន៍ប្រវត្តិសាស្ត្រមកធ្វើជាបទពិពណ៌នាបង្ហាញ ។

សម័យកម្ពុជាប្រជាធិបតេយ្យពោរពេញទៅដោយព្រឹត្តិការណ៍ជាប្រវត្តិដែលអាចយកមកបញ្ជាក់បានអំពីការដើរបញ្ច្រាសទិសរបស់អង្គការបដិវត្តន៍ថ្នាក់កំពូល ដោយបានបង្ខំប្រជាជនខ្មែរឲ្យទទួលយកភាពផ្តាច់ការបដិវត្តន៍ ដែលជាមូលហេតុនៃការបំផ្លាញកម្លាំងពលកម្មសង្គមដ៏ខ្លាំងក្លា ។ ជាមួយនេះដែរ ការបំបាត់សិទ្ធិសេរីភាពក្នុងការទទួលពុទ្ធិដើម្បីកិច្ចអភិវឌ្ឍ ក៏ជាកត្តាដែលត្រូវលើកមកធ្វើការអប់រំប្រវត្តិសាស្ត្រ អំពីសម័យកម្ពុជាប្រជាធិបតេយ្យដែរ ។ បំបាត់សមត្ថភាពជំនាញ និងបង្ខំការងារដោយមិនរវល់ពីការផ្តល់ឱកាសដែលជាការកំណត់ឯកត្តភាពការងារគឺជាការកាត់បន្ថយភាពជឿនលឿនដែលមិនបានជ្រើសរើសជំនាញសកម្មសម្រាប់កាងារដែលអារ្យសង្គមក្នុងលោកបានអនុវត្ត ។ ដូច្នេះ ការកំចាត់ធនធានមនុស្សសកម្មលើវិស័យសេដ្ឋកិច្ច សង្គម និងវប្បធម៌ដែលអ្នកដឹកនាំក្នុងសម័យកម្ពុជាប្រជាធិបតេយ្យបានប្រព្រឹត្តចំពោះប្រជាជនខ្មែរ គឺជាមេរៀនប្រវត្តិសាស្ត្រសម្រាប់ក្មេងជំនាន់ក្រោយត្រូវប្រុងប្រយត្ន័និងជៀសវាងឲ្យបាន ។

ទាំងនេះជាវិធី នៃការអប់រំប្រវត្តិសាស្ត្រជាតិអំពីរបបកម្ពុជាប្រជាធិបតេយ្យដើម្បីឆ្លើយតបទៅនឹងសំណូមពរនៃបរិបទកម្ពុជានាសម័យទំនើបដែលកំពុងឆក់ឱកាសសម្រាប់ស្ថាបនាជាតិក្រោយពីការដួលរលំរបបអតីតកាលមួយនេះ ។ តែទោះជាមានការពិចារណាលើមូលបទកិច្ចការអប់រំប្រវត្តិសាស្ត្រជាតិដោយឈរលើគោលការណ៍ជាមូលដ្ឋានទាំងបីខាងលើនេះក៏ដោយ យើងនៅតែមានភាពទូលាយជានិច្ចក្នុងការប្រើគោលវិធីដទៃណាដែលត្រូវបានវិភាគល្អិតល្អន់ថាជាការចាំបាច់ត្រូវតែអនុវត្ត ។ បន្ថែមពីនេះទៀត ដើម្បីគោរពគោលការណ៍អប់រំដែលត្រូវតែមានភាពឥតខ្ចោះ នោះការបើកទូលាយគួរតែត្រូវធ្វើឡើងដោយយោងទៅតាមលក្ខខណ្ឌជាក់ស្តែងនៃមជ្ឈដ្ឋានអប់រំនិងកម្រិតអប់រំមូលដ្ឋាន ។

ក្នុងលទ្ធភាពបង្ហាញដោយការប្រើគោលចំណុចសំខាន់ៗទាំងឡាយនៃប្រវត្តិព្រឹត្តិការណ៍ក្នុងសម័យកម្ពុជាប្រជាធិបតេយ្យដែលគួរគប្បីធ្វើការពិចារណា ផ្នែកខាងក្រោមនេះគឺជាកម្រងចំណុចព្រឹត្តិការណ៍ទាំងនោះ ។

### សម្រាប់គោលការណ៍បង្រួបបង្រួមជាតិ

- ការជម្លៀសប្រជាជនចេញពីទីក្រុង និងការកំណត់លក្ខណៈប្រជាជនតាមរយៈកាលធ្វើបដិវត្តន៍
- ការកំណត់ប្រភេទប្រជាជនដើម្បីកាន់អំណាច និងភាពលម្អៀងរបស់អង្គការ

◆ ការសង្ស័យគ្នាដោយបំពាក់ការតាមដានគ្នា ជាគោលជំហរអ្នកបដិវត្តន៍

◆ ការបន្តភាពរើសអើងក្នុងសង្គមបដិវត្តន៍ រវាងប្រជាជនមូលដ្ឋាននិងប្រជាជនថ្មី

◆ បំបាត់សម្ពន្ធ័ភាពសង្គមនិងគ្រួសារ

◆ បំបែកតួនាទីបុរសនិងស្ត្រី ក្នុងកិច្ចការសង្គមនិងគ្រួសារ

◆ ការអប់រំកុមារឲ្យផ្តាច់ទំនាក់ទំនងជាមួយឪពុកម្តាយ

◆ បក្សសម្ពន្ធ័បដិវត្តន៍

**សម្រាប់គោលការណ៍ស្នេហាជាតិ**

◆ ការប្រណាំងប្រជែងគ្នាក្នុងបក្ស

◆ គិតការងារបក្សជាងការងារជាតិ

◆ ការប្រើប្រាស់ប្រជាជនជាឧបករណ៍បំបែកបក្ស

◆ ការមិនស្វែងយល់ពីផលវិបាកជាតិដោយយកតាមមនោគមន៍វិជ្ជាបរទេស

**សម្រាប់គោលការណ៍អភិវឌ្ឍន៍ជាតិ**

◆ ការចល័តមនុស្ស

◆ ភាពគ្មានសាលារៀននិងការបណ្តុះបណ្តាល

◆ ការចោទប្រកាន់មនុស្ស ធ្វើទារុណកម្ម និងបង្អត់អាហារ

◆ ភាពគ្មានលក្ខណៈវិទ្យាសាស្ត្រក្នុងវិស័យសេដ្ឋកិច្ច

◆ ការបិទទ្វារមិនឲ្យមានទំនាក់ទំនងអន្តរជាតិទូលាយ

◆ កំណត់ការងារកសិកម្មជាអាទិភាពដោយគ្មានជម្រើសការងារ

◆ បំបាត់សិទ្ធិសម្រេច សិទ្ធិស្វែងយល់ ការពិភាក្សា និងការតវ៉ា

**សេចក្តីសន្និដ្ឋាន**

យោងតាមការរៀបរាប់ទាំងអស់ខាងលើ យើងសង្ឃឹមថាការអប់រំប្រវត្តិសាស្ត្រជាតិអំពីសម័យកម្ពុជាប្រជាធិបតេយ្យនឹងទទួលផ្លែផ្កាដ៏ប្រសើរដោយបណ្តុះអ្នកសន្តិភាពនិយម អ្នកជាតិនិយម និងជនចម្រើនសម្រាប់ចូលរួមយ៉ាងសកម្មក្នុងកិច្ចការស្តាបនារបស់កម្ពុជាដែលជាភារកិច្ចចាំបាច់បំផុតនាពេលបច្ចុប្បន្ន។ ជាមួយនេះដែរ ការបង្ហាញជនជំនាន់ក្រោយអំពីអំពើអយុត្តិធម៌សង្គមនៃសម័យកម្ពុជាប្រជាធិបតេយ្យ គឺមិនមែនជាការបំបែកបំបាក់ជាតិទេ តែគឺជាការបំពាក់ស្មារតីរួបរួមជាតិដោយនាំឲ្យគេបានយល់និងកំណត់ខ្លួនដើម្បីបញ្ចៀសរាល់ដានអសកម្មមិនរីកចម្រើនទាំងឡាយដែលបង្កើតឡើងក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ។ ម្យ៉ាងទៀត ការបង្ហាញបទពិសោធន៍ប្រវត្តិសាស្ត្រដែលប្រជាជនខ្មែរឆ្លងកាត់នៅសម័យនោះ នឹងនាំចិត្តជនជំនាន់ក្រោយឲ្យចេះពិចារណាអំពីការចេះស្រឡាញ់គោរពមនុស្សចាស់របស់គេដែលនៅមានជីវិតនៅឡើយ ហើយនេះគឺជាការអប់រំសង្គមយ៉ាងប្រសើរក្នុងន័យសីលធម៌។ ជាមួយនេះដែរ ការយកព្រឹត្តិការណ៍ប្រវត្តិនៃសម័យដ៏ជូរចត់នេះធ្វើជាមេរៀនប្រវត្តិសាស្ត្រដើម្បីធ្វើការវិនិច្ឆ័យនៃជនជំនាន់ក្រោយ គឺជាវិទ្យាសាស្ត្រអប់រំហើយមិនមែនសម្រាប់តែប្រជាជនកម្ពុជាប៉ុណ្ណោះទេ តែក៏សម្រាប់ការអប់រំមនុស្សក្នុងពិភពលោកដែរ។



សាស្ត្រាចារ្យ សំបូរ ម៉ាណារ៉ា

ជាអវសានមតិ យើងខ្ញុំសូមឲ្យមានការចូលរួមយ៉ាងសកម្មក្នុងកិច្ចការអប់រំប្រវត្តិសាស្ត្រជាតិដោយខិតខំគោរពតាមគោលការណ៍ទាំងបីខាងលើជាប្រចាំដើម្បីបង្កើតបាននូវសុខសន្តិភាពសម្រាប់ជាតិ តំបន់ និងពិភពលោកទាំងមូល។

**សំបូរ ម៉ា ណារ៉ា**

# វិនិច្ឆ័យទោសៈ ដំណើរការកាត់សេចក្តីរបស់តុលាការខ្មែរក្រហម

អត្ថបទនេះ ពិភាក្សាអំពីអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដែលត្រូវបានស្គាល់ច្រើនថាជាតុលាការខ្មែរក្រហម ។ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា គឺជាអង្គតុលាការពិសេសមួយដែលមានទីតាំងស្ថិតនៅក្នុងបរិវេណអាគារសង់ថ្មីរបស់បញ្ជាការដ្ឋានកងយោធពលខេមរភូមិន្ទ នៅជាយក្រុងភ្នំពេញ ភាគខាងលិច ។ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា គឺជាតុលាការកូនកាត់ ឬតុលាការចម្រុះដែលបង្កើតឡើងនិងធ្វើប្រតិបត្តិការដោយមន្ត្រីរបស់អង្គការសហប្រជាជាតិនិងរាជរដ្ឋាភិបាលកម្ពុជា ។ ចាប់តាំងពីការចាប់បើកទ្វារនៅឆ្នាំ២០០៦កន្លងមក អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាត្រូវបានប្រគល់ភារកិច្ចដ៏ធំធេងក្នុងការវិនិច្ឆ័យសេចក្តីលើឧក្រិដ្ឋកម្ម និងផ្តល់នូវវង្វាស់យុត្តិធម៌ជូនជនរងគ្រោះក្រោមរបបខ្មែរក្រហម ។ ខ្ញុំបានពិភាក្សាដោយសង្ខេបអំពីកម្លាំងមួយចំនួនដែលនាំឲ្យមានការបង្កើតតុលាការនេះ ដោយវិភាគទៅលើនីត្យានុកូលភាពជាមូលដ្ឋាន និងលក្ខណៈសម្បត្តិនៃស្ថាប័នវាយតម្លៃលើការវិវឌ្ឍមកទល់ពេលបច្ចុប្បន្ន ព្រមទាំងពិភាក្សាទៅលើសក្តានុពលដែលរួមចំណែកដល់យុត្តិធម៌ និងការផ្សះផ្សានៅក្នុងប្រទេសកម្ពុជា ។

## មូលហេតុដែលអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាមានសារសំខាន់យ៉ាងខ្លាំង

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាគឺជាស្ថាប័នមួយដែលមានសារសំខាន់យ៉ាងខ្លាំងខាងផ្នែកសីលធម៌ ច្បាប់ នយោបាយ និងការអប់រំ ។ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានបង្ហាញពីដំណាក់កាលចុងក្រោយបង្អស់នៅក្នុងដំណើរការបត់បែនដ៏វែងឆ្ងាយទាក់ទងនឹងកេរដំណែលនៃរបបខ្មែរក្រហមនៅកម្ពុជា ។ ក្នុងចន្លោះពីថ្ងៃ១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩ របបខ្មែរក្រហមបានគ្រប់គ្រងប្រទេសកម្ពុជា ដោយកណ្តាប់ដៃដែក ហើយប្រែឈ្មោះថា «កម្ពុជាប្រជាធិបតេយ្យ» និងអនុវត្តការគ្រប់គ្រងយ៉ាងព្រៃផ្សៃ ។ អំពើឃោរឃៅរបស់ខ្មែរក្រហមមិនគ្រាន់តែជាបំណែកខូចខាតកាលពីអតីតកាលរបស់កម្ពុជាប៉ុណ្ណោះទេ គឺវានៅតែតាមលងប្រជាជនកម្ពុជារាប់មិនអស់រហូតមកដល់សព្វថ្ងៃនេះ ហើយបណ្តាលឲ្យមានការបែកបាក់ប្រេះស្រាំនៅក្នុងសង្គមនិងនយោបាយនៅកម្ពុជាផងដែរ ។ បន្ទាប់ពីការទន្ទឹងរង់ចាំអស់បីទសវត្សរ៍ ប្រជាជនកម្ពុជាមានឱកាសស្វែងរកយុត្តិធម និងបោះជំហានសំខាន់មួយទៀតឆ្ពោះទៅរកការផ្សះផ្សា ។

អំពើយង់ឃ្នងដែលបានប្រព្រឹត្តឡើងក្នុងរបបកម្ពុជាប្រជាធិបតេយ្យ មិនគ្រាន់តែជាអំពើខុសឆ្គងពីអតីតកាលប៉ុណ្ណោះទេ ក៏ប៉ុន្តែវាដូចជាស្រមោលអន្ទោលតាមប្រាណក្នុងសង្គមកម្ពុជាសព្វថ្ងៃនេះថែមទៀត ។ អំពើយង់ឃ្នងទាំងនេះ បានផ្សារភ្ជាប់នៅក្នុងជម្លោះរាប់ទសវត្សរ៍ពាក់ព័ន្ធនឹងការរំលោភបំពានពីសំណាក់អ្នកខាងក្នុងនិងខាងក្រៅច្រើនរាប់មិនអស់ ។ ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ សម័យប៉ុលពតគឺជាសម័យដ៏សាហាវព្រៃផ្សៃនិងគួរឲ្យរន្ធត់បំផុតនៅក្នុងសោកនាដកម្មនេះ ។ គ្មានអ្វីអាចនឹងលុបបំបាត់ការឈឺចាប់របស់អ្នកនៅរស់រានមានជីវិតបានឡើយ ប៉ុន្តែចំពោះអ្នកគាំទ្រអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាជាច្រើន ការកាត់ទោសខ្មែរក្រហមបង្ហាញអំពីជំហរដ៏រឹងមាំមួយប្រឆាំងនឹងនិទ្ទណ្ឌភាពដែលអាចជួយប្រជាជនកម្ពុជាប្រឈមមុខនឹងអតីតកាល ហើយបន្តជីវិតរស់នៅរបស់ខ្លួនទៅមុខទៀត ។

## ការជម្នះនឹងនិទ្ទណ្ឌភាព

ហេតុផលធំបំផុតតែមួយគត់ក្នុងការបង្កើតសាលាក្តីខ្មែរក្រហម គឺដើម្បីផ្តល់នូវវង្វាស់យុត្តិធម៌ក្នុងកម្រិតណាមួយដល់សង្គមដែលទទួលរងនូវនិទ្ទណ្ឌភាពអស់រយៈពេលជាយូរមកហើយ ។ នៅខែមករា ឆ្នាំ១៩៧៩ នៅពេលរបបកម្ពុជាប្រជាធិបតេយ្យត្រូវបានដួលរលំទៅ វាំងននដែលហ៊ុមព័ទ្ធប្រទេសកម្ពុជាក៏ត្រូវបើកឡើងដែរដែលឯកសារផ្លូវការនិងភ័ស្តុតាងជាក់ស្តែងបានបង្ហាញអំពីការរំលោភបំពាននៅក្នុងកម្រិតមួយដ៏គួរឲ្យតក់ស្លុត ។ សំណល់ឆ្អឹងសាកសពពីអំពើព្រៃផ្សៃរបស់ខ្មែរក្រហមមានគ្រប់ទីកន្លែងតាមជនបទនៃប្រទេសកម្ពុជា ។ គុកបណ្តោះអាសន្ន ឧបករណ៍ធ្វើទារុណកម្ម និងរណ្តៅសាកសពរាប់ពាន់ដែលនាំឲ្យប្រជាជនកម្ពុជានឹក

ឃើញជារៀងរាល់ថ្ងៃនូវការឈឺចាប់ដែលបានទទួលរងទុក្ខវេទនាកាលពីសម័យប៉ុលពត ។ មជ្ឈមណ្ឌលឯកសារកម្ពុជាបានរកឃើញរណ្តៅសាកសពរួមប្រមាណពីរម៉ឺនរណ្តៅ និងអតីតមន្ទីរឃុំឃាំងខ្មែរក្រហមចំនួនជិតពីររយកន្លែងនៅទូទាំងប្រទេស ដែលភាគច្រើនមានបន្សល់នូវឧបករណ៍ធ្វើទារុណកម្មគួរឲ្យភ័យខ្លាច ។

អ្នកស្រាវជ្រាវជាន់ខ្ពស់មានជំនឿថា របបខ្មែរក្រហមបានឆក់យកជីវិតប្រជាជនអស់ប្រហែលពីមួយភាគប្រាំទៅមួយភាគបីនៃចំនួនប្រជាជនកម្ពុជាទាំងអស់ ។ តាមការពិត គំនរឆ្អឹងសាកសពមានច្រើននៅពាសពេញទាំងអស់ ហើយចំនួនអ្នកនៅរស់ក៏មានច្រើនដែរ ដែលបណ្តាលឲ្យពិភពលោកមិនអាចប៉ាន់ស្មានពីចំនួនមនុស្សដែលត្រូវស្លាប់បាន ។ ទោះបីជាចំនួនអ្នកស្លាប់ដ៏គួរឲ្យតក់ស្លុតនេះបង្ហាញឲ្យឃើញតែមួយផ្នែកនៃរូបភាពទាំងមូលក៏ដោយ ក៏ស្ថិតិតែម្យ៉ាងមិនអាចបន្ធូរបន្ថយសោកនាដកម្មដែលបន្សល់ទុកដោយរបបខ្មែរក្រហមបានឡើយ ។ ការបាត់បង់ជីវិតរបស់បុគ្គលគ្រប់គ្នា ជាម្តាយឬឪពុក បងប្អូនប្រុសស្រី កូនប្រុសកូនស្រី ប្តីឬប្រពន្ធ មិត្តភក្តិឬគូកន ។ ខណៈពេលដែលតម្រូវឲ្យមានការរកយុត្តិធម៌ចំពោះឧក្រិដ្ឋកម្មមួយចំនួនតូចរបស់ខ្មែរក្រហម រឿងរ៉ាវរបស់ជនរងគ្រោះម្នាក់ៗបង្ហាញឲ្យឃើញនូវការទទូចទាមទាររកយុត្តិធម៌កាន់តែមានឥទ្ធិពលខ្លាំងក្លាជាងមុនទៅទៀត ។

ឯកសារនិងចម្លើយកសិណសាក្សីជាភ័ស្តុតាងបង្ហាញប្រាប់អំពីទុក្ខវេទនានិងភាពសាហាវឃោរឃៅដែលមិននឹកស្មានដល់ ។ កម្មាភិបាលខ្មែរក្រហមតម្រូវឲ្យអ្នកភូមិឈរមើលមនុស្សជាទីស្រឡាញ់ត្រូវបានបាញ់សម្លាប់នៅនឹងមុខ ដោយសារតែកំហុសឆ្គងបន្តិចបន្តួចដូចជា លួចអង្ករ ឬបន្លែដើម្បីទប់ទល់ការស្រេកឃ្លាន ។ ស្ត្រីមានផ្ទៃពោះមួយចំនួនត្រូវបានចោទប្រកាន់ថាមានអាកប្បកិរិយាលាក់លៀម «ប្រឆាំងនឹងបដិវត្តន៍» ត្រូវបានចងព្យួរហើយវះពោះយកពោះវៀនមកបង្ហាញឲ្យអ្នកដទៃទៀតមើល ។ សាក្សីផ្ទាល់ភ្នែកថែមទាំងនិយាយប្រាប់អំពីទាហានខ្មែរក្រហមបោះកូនង៉ែតឡើងលើ ហើយចាក់ក្មេងនោះនឹងកាំបិតចំពុះទុងទាំងរស់ ។ នៅក្នុងគុកបណ្តោះអាសន្ន អ្នកសួរចម្លើយខ្មែរក្រហមបានធ្វើការសាកល្បងចោទប្រកាន់ដោយគ្មានមូលដ្ឋានអំពីការស៊ើបការណ៍សម្ងាត់ ឬការបំផ្លិចបំផ្លាញ ដោយចងជនរងគ្រោះទៅនឹងគ្រែដែលមានគ្រោងដែកច្រែះចាប់ ដុតជនរងគ្រោះនឹងរងើកភ្លើង ដកក្រចក និងជ្រមុជក្នុងទឹកត្រជាក់រហូតដល់លង់ ។ អ្នកទោសរាប់មិនអស់មិនដែលធ្លាប់បានប្រឈមមុខនឹងការកាត់សេចក្តីទាល់តែសោះ តែត្រូវបាននាំយកទៅកន្លែងរណ្តៅរួមជាកន្លែងដែលពេជ្ឈឃាតខ្មែរក្រហមសម្លាប់ជនរងគ្រោះជាមួយនឹងពូថៅដៃ ដើម្បីចៀសវាងចំណាយគ្រាប់កាំភ្លើងដ៏មានតម្លៃ ។

អ្នកដែលមិនទាន់ដល់ពេលត្រូវស្លាប់បាននៅស្រួលបន្តិច ។ ការចាប់រំលោភ និងការធ្វើទុក្ខបុកម្នេញលើសាសនាបានញាំញីពេញផ្ទៃប្រទេស ។ ប្រជាជនកម្ពុជាដែលមានជំងឺនិងចាស់ជរាដែលទទួលរងនូវការធ្វើការងារយ៉ាងធ្ងន់ធ្ងរដោយគ្មានម៉ោងពេលសម្រាក ពេលខ្លះបានប្រទះឃើញសាកសពនិងឆ្អឹងរបស់អ្នកជាទីស្រឡាញ់របស់ខ្លួនដែលបានស្លាប់ទៅ នៅពេលព្យាយាមធ្វើការងារដ៏លំបាកនៅតាមវាលស្រែ ។ ប្រជាជនសាមញ្ញភាគច្រើនធ្វើការងារដូចទាសករ ដោយលបលួចបរិភោគសត្វល្អិត និងសំបកឈើដើម្បីរស់ ហើយនឹកឆ្ងល់ថានឹងបានជួបជុំក្រុមគ្រួសាររបស់ខ្លួនម្តងទៀតដែរឬទេ ។ របបនេះ បានបដិសេធចោលនូវរាល់សិទ្ធិជាមូលដ្ឋានបំផុតស្តីអំពីការបូជា ការបញ្ចេញមតិដោយសេរី និងភាពស្និទ្ធស្នាល ។ កុមាររៀននៅសាលាត្រូវបានបង្រៀនឲ្យចេះស្តីបន្ទោស មិនទទួលស្គាល់ឪពុកម្តាយរបស់ខ្លួន ហើយបូជាជីវិតរបស់ខ្លួនសម្រាប់អង្គការតែប៉ុណ្ណោះ ។ កម្មាភិបាលក្មេងៗទាំងអស់នោះ គឺជាឧក្រិដ្ឋជនដែលត្រូវបានអប់រំបញ្ចុះបញ្ចូលឲ្យសម្លាប់ ប៉ុន្តែនៅក្នុងទស្សនៈជាច្រើន ក្មេងៗទាំងនោះក៏ជាជនរងគ្រោះនៃរបបនេះដែរ ។ សម័យកម្ពុជាប្រជាធិបតេយ្យបន្សល់ទុកនូវស្លាកស្នាមយ៉ាងជ្រាលជ្រៅ ។

អ្នកដឹកនាំជាន់ខ្ពស់ដែលបង្កើតរបបកម្ពុជាប្រជាធិបតេយ្យនៅតែរស់នៅដោយមានសេរីភាពយ៉ាងពេញលេញនៅឡើយកាលពីពេលថ្មីៗកន្លងទៅ ។ អ្នកខ្លះរស់នៅក្នុងផ្ទះវីឡាយ៉ាងសុខស្រួល ខណៈពេលដែលជនរងគ្រោះកំពុងតែប្រយុទ្ធនឹងបិសាចនៃអតីតកាល ។ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានផ្តល់នូវឱកាសមួយដែលហួសពេលកំណត់ជាយូរមកហើយ ដើម្បីជម្នះនឹងសំណល់គួរឲ្យស្អប់ខ្ពើមនៃការមិនដាក់ទោស ។ បីទសវត្សរ៍ក្រោយពីរបបប៉ុលពតដួលរលំ ពុំមានមេដឹកនាំខ្មែរក្រហមជាន់ខ្ពស់

ណាម្នាក់ត្រូវបានផ្តន្ទាទោសពីបទឧក្រិដ្ឋកម្មដោយតុលាការដែលសម្រេចតាមគោលការណ៍ច្បាប់ដែលគួរឲ្យជឿជាក់នៅឡើយទេ ។ ទោះបីជាយ៉ាងណាក៏ដោយ បញ្ហានេះប្រហែលជាផ្លាស់ប្តូរក្នុងពេលឆាប់ៗនេះ ។ ចាប់តាំងពីការចាប់ផ្តើមដំណើរការនៅក្នុងឆ្នាំ ២០០៦មក មន្ត្រីតុលាការបានបោះជំហានយ៉ាងសំខាន់ជាលើកដំបូងប្រឆាំងនឹងនិទ្ទណ្ឌភាពដោយនាំយកអតីតមេដឹកនាំខ្មែរក្រហមប្រាំរូបមកដាក់ឃុំ និងចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌ ។

ការជំនុំជម្រះក្តីលើមេដឹកនាំកម្ពុជាប្រជាធិតេយ្យម្នាក់គឺ ឌុច ដែលជាអតីតប្រធានគុកទួលស្លែង នៅក្នុងទីក្រុងភ្នំពេញនោះបានចាប់ផ្តើមហើយ ។ មេដឹកនាំជាន់ខ្ពស់ដែលនៅរស់បួននាក់ទៀតរួមមាន នួន ជា, អៀង សារី, ខៀវ សំផន, និង អៀង ធីរិទ្ធ ក៏កំពុងតែស្ថិតនៅក្នុងតុលាការនេះដែរ ។ អ្នកទាំងអស់ដែលមានមុខតំណែងខ្ពស់ៗ ហើយដែលជាសមាជិករបស់គណៈកម្មាធិការឡោងផឹតត្រូវបានកំណត់ថាជាមេដឹកនាំក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។

ពេលវេលាកំពុងតែដើរទៅមុខ ។ មេដឹកនាំជាន់ខ្ពស់ខ្មែរក្រហមបានស្លាប់អស់ជាច្រើននាក់នៅក្នុងទសវត្សរ៍កន្លងទៅ រួមទាំង ប៉ុល ពត ជាលេខាបក្ស សុន សេន រដ្ឋមន្ត្រីក្រសួងការពារជាតិ តា ម៉ុក សមាជិកគណៈកម្មាធិការមជ្ឈិម (ត្រូវបានស្គាល់ថាជា «អ្នកកាប់សម្លាប់») យុន យ៉ាត រដ្ឋមន្ត្រីក្រសួងអប់រំ និង កែ ពក មេបញ្ជាការភូមិភាគ ។ ជនដៃដល់លំដាប់ទី២នៃរបបខ្មែរក្រហមជាច្រើននាក់ទៀតក៏បានរស់នៅសុខស្រួលរហូតដល់ទីបញ្ចប់ ដោយគ្មានទទួលទណ្ឌកម្មអ្វីបន្តិចទាល់តែសោះ ។ ជនជាប់ចោទទាំងប្រាំរូបនាពេលបច្ចុប្បន្នមានអាយុកាន់តែច្រើន ហើយអ្នកខ្លះឬអ្នកទាំងអស់នេះអាចស្លាប់ឬបាត់បង់ស្មារតីមុននឹងប្រឈមមុខនឹងការផ្តន្ទាទោសតាមច្បាប់ ។ ការដែលបណ្តោយឲ្យមេដឹកនាំខ្មែរក្រហមទាំងអស់ស្លាប់ទៅដោយមិនបានឡើងតុលាការនោះ គឺជាការប្រមាថយ៉ាងធ្ងន់ធ្ងរចំពោះជនរងគ្រោះគ្មានកំហុសរាប់លាននាក់ ដែលជីវិតរបស់គាត់ត្រូវបានបែកខ្ញែកចេញពីគ្នា ។

## ការផ្តល់យុត្តិធម៌

រឿងច្បាស់ក្រឡែត ដើម្បីឲ្យអង្គជំនុំជម្រះវិសាមញ្ញទទួលបានជោគជ័យនោះ គឺត្រូវតែផ្តល់រង្វាស់យុត្តិធម៌មួយសំខាន់ក្រោមក្រសែភ្នែករបស់ប្រជាជនកម្ពុជា និងសហគមន៍អន្តរជាតិ ។ យុត្តិធម៌គឺជាទស្សនៈដែលមានលក្ខណៈស្មុគស្មាញមួយ ជាពិសេសចំពោះអំពើឃោរឃៅដ៏ច្រើនសន្ធឹកសន្ធាប់បែបនេះ ។ ការអនុវត្តនូវដំណើរការមួយ ហើយផ្តល់លទ្ធផលជាផ្លែផ្កាដែលអាចតម្រូវនូវសញ្ញាណយុត្តិធម៌របស់ជនរងគ្រោះផ្សេងៗគ្នា ដូច្នេះមិនមែនជារឿងងាយស្រួលនោះទេ ។ ការចេញដីកាចោទប្រកាន់មួយឬពីរ គឺពិតជាមិនគ្រប់គ្រាន់ឡើយ ។ ដូចដែលយើងនឹងលើកឡើង គឺអង្គជំនុំជម្រះវិសាមញ្ញត្រូវតែផ្តល់អាទិភាពចំពោះទស្សនៈយុត្តិធម៌តាមបែបផ្តន្ទាទោស ស្តារឡើងវិញ ព្រមទាំងគោរពតាមនីតិវិធីគ្រប់ជ្រុងជ្រោយ ។

យុត្តិធម៌មានន័យខុសៗគ្នាចំពោះប្រជាជនកម្ពុជា និងអ្នកសង្កេតការណ៍អន្តរជាតិលើតុលាការនេះ ។ ទស្សនៈយុត្តិធម៌តាមបែបដាក់ទោសបានផ្តល់មូលដ្ឋានខាងច្បាប់ឧក្រិដ្ឋកម្ម ។ លក្ខណៈសីលធម៌សមហេតុផលដែលជាមូលដ្ឋាននៃការផ្តន្ទាទោសតាមច្បាប់គឺជាជនល្មើសសាមញ្ញដែលបានបង្កឲ្យមានផលប៉ះពាល់ដល់សង្គមត្រូវតែផ្តន្ទាទោសនិងដាក់ទណ្ឌកម្មដោយរដ្ឋ ។ ជោគជ័យរបស់អង្គជំនុំជម្រះវិសាមញ្ញប្រាកដជាត្រូវវិនិច្ឆ័យមួយផ្អែកតាមលទ្ធភាពចំពោះការផ្តន្ទាទោសត្រឹមត្រូវតាមសីលធម៌ និងកំណត់ការដាក់ទោសឲ្យត្រឹមត្រូវតាមច្បាប់កំណត់ ។ ទោះជាយ៉ាងណាក៏ដោយ ការផ្តន្ទាទោសតាមច្បាប់ គឺគ្រាន់តែជាផ្នែកមួយនៃយុត្តិធម៌តែប៉ុណ្ណោះ ។ ជនរងគ្រោះអាចមានការពេញចិត្ត ដោយសារបានឃើញមេដឹកនាំខ្មែរក្រហមត្រូវបានធ្វើឲ្យអាម៉ាស់និងដាក់ទោសទណ្ឌ បើទោះបីជាកាត់ទោសឲ្យជាប់គុកអស់មួយជីវិត ក៏មិនងាយធ្វើឲ្យជនរងគ្រោះទទួលយកទាំងស្រុងបានដែរ ។

បញ្ហាជាគន្លឹះមួយដែលទាក់ទងនឹងការផ្តន្ទាទោសតាមច្បាប់គឺវិសាលភាពនៃការកាត់ទោស ។ ការកាត់សេចក្តីតែចំពោះមេដឹកនាំប៉ុន្មាននាក់មានន័យថា មន្ត្រីខ្មែរក្រហមថ្នាក់កណ្តាលជាច្រើននឹងត្រូវរួចខ្លួន ។ ដូចគ្នានេះដែរ កម្មាភិបាលថ្នាក់ក្រោមដែលបានប្រព្រឹត្តអំពើរំលោភបំពានជាក់ស្តែងយ៉ាងច្រើនលើសលប់នឹងនៅតែបន្តតាមលងអ្នករួចជីវិតមកដល់សព្វថ្ងៃជានិច្ចកាល ។ អង្គការសហប្រជាជាតិ និងរដ្ឋាភិបាលកម្ពុជាបានព្រមព្រៀងគ្នាក្នុងការកាត់ទោសតែ «មេដឹកនាំជាន់ខ្ពស់» និងអ្នកផ្សេងទៀតដែលគិតថាជា «អ្នកដែលទទួលខុសត្រូវខ្ពស់បំផុត» លើអំពើឃោរឃៅក្នុង

សម័យកម្ពុជាប្រជាធិបតេយ្យ ។ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ក៏ដូចជាតុលាការដទៃទៀតដែរបានទទួលការចោទប្រកាន់អំពី «យុត្តិធម៌ដែលមានលក្ខណៈជ្រើសរើស» ។ តុលាការនេះពុំអាចលុបបំបាត់ទាំងស្រុងនូវនិទ្ទណ្ឌភាពដែលនៅរុំរ៉ៃចាប់តាំងពីក្រោយសម័យកម្ពុជាប្រជាធិតេយ្យបានឡើយ ប៉ុន្តែតុលាការចាំបាច់ត្រូវតែធ្វើការឲ្យអស់ពីសមត្ថភាពដើម្បីរកឲ្យឃើញនិងដើម្បីកាត់សេចក្តីឲ្យបានជោគជ័យចំពោះមេខ្លោងដែលបង្កអំពើឃោរឃៅក្នុងសម័យខ្មែរក្រហម ។

បញ្ហាមួយដែលផ្តោតលើការនាំយកមកកាត់ទោសនិងផ្តន្ទាទោសតាមច្បាប់ គឺថាដីកាចោទប្រកាន់មានកម្រិតនឹងផ្តល់នូវយុត្តិធម៌ដែលមានលក្ខណៈស្តារឡើងវិញបន្តិចបន្តួចតែប៉ុណ្ណោះ ។ ការដាក់ក្រុមឃាតករខ្មែរក្រហមឲ្យជាប់គុកមិនបានទូទាត់សងជនរងគ្រោះ ឬ «ស្តារឡើងវិញ» នូវសុខុមាលភាពរបស់ជនរងគ្រោះឲ្យដូចដើមមុនឧក្រិដ្ឋកម្មបានកើតឡើងឡើយ ។ ការផ្តល់នូវយុត្តិធម៌ដែលមានលក្ខណៈស្តារឡើងវិញនៅប្រទេសមួយដែលទទួលរងទុក្ខយ៉ាងធ្ងន់ធ្ងរដូចជាប្រទេសកម្ពុជានេះ គឺជាការលំបាកបំផុត ក៏ប៉ុន្តែការចាប់ដំណើរការដើម្បីដោះស្រាយចំពោះសេចក្តីត្រូវការរបស់ជនរងគ្រោះគឺជារឿងសំខាន់ ។ ទោះបីជាយ៉ាងនេះក្តី ជនរងគ្រោះគួរតែជាអ្នកទទួលផលដំបូងគេបង្អស់ពីដំណើរការរកយុត្តិធម៌នេះ ។

ជាប្រវត្តិសាស្ត្រ យុត្តិធម៌ដែលមានលក្ខណៈស្តារឡើងវិញគឺជាចំណុចខ្សោយរបស់តុលាការអន្តរជាតិ ហើយវាបង្ហាញអំពីការពុះពារជាពិសេសមួយសម្រាប់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ ប្រាក់កាសមិនអាចជំនួសឲ្យការបាត់បង់ជីវិតអ្នកជាទីស្រឡាញ់ដោយសារអំពើរំលោភបំពានសិទ្ធិមនុស្សយ៉ាងធ្ងន់ធ្ងរបានឡើយ ។ ក៏ប៉ុន្តែអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ក៏ដូចជាតុលាការដទៃទៀតដែរ គឺខ្វះប្រភពធនធានក្នុងការផ្តល់នូវអ្វីមួយឲ្យលើសពីសំណងខាងហិរញ្ញវត្ថុ ។ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានប្រើវិធីសាស្ត្រថ្មីមួយចំពោះយុត្តិធម៌ដែលមានលក្ខណៈស្តារឡើងវិញ ។ តុលាការនេះបានបង្កើតយន្តការមួយសម្រាប់ការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងការជំនុំជម្រះសេចក្តី និងប្រមើលមើលអំពីសំណងតាម «ទម្រង់ជាសមូហភាព ឬជាលក្ខណៈសីលធម៌» ដូចជាបូជនីយ



លោក វ៉ាន់ថាន់ ពៅដារ៉ា

ដ្ឋានដើម្បីឧទ្ទិសដល់ជនរងគ្រោះ ឬមជ្ឈមណ្ឌលថែរក្សាសុខភាព ឬផ្តល់សេវាអប់រំដល់អ្នកដែលនៅរស់ ។ ជោគជ័យរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាលើកិច្ចខិតខំប្រឹងប្រែងផ្តល់សំណងដែលលក្ខណៈស្តារឡើងវិញនេះត្រូវការពេលវេលាច្រើនតទៅទៀតក្នុងការកំណត់នូវការយល់ឃើញរបស់សាធារណជនចំពោះតុលាការនេះ ។

ផ្នែកសំខាន់ទីបីនៃដំណើរការរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាគឺយុត្តិធម៌ត្រឹមត្រូវតាមនីតិវិធី ។ ដើម្បីសម្រេចបានលទ្ធផលត្រឹមត្រូវ គឺទាមទារឲ្យមានការជំនុំជម្រះសេចក្តីតាមលក្ខណៈត្រឹមត្រូវតាមច្បាប់ ។ ចំពោះអ្នកសង្កេតការណ៍មួយចំនួន វាពិតជាពិបាកណាស់ដែលយើងទាំងអស់គ្នាឃើញជនជាប់ចោទខ្មែរក្រហមទទួលបាននូវសិទ្ធិការពារតាមផ្លូវច្បាប់នោះ ដែលរបបកម្ពុជាប្រជាធិបតេយ្យដ៏ឃោរឃៅបានបដិសេធសិទ្ធិបែបនេះចំពោះប្រជាជនរាប់លាននាក់ ។ ប្រជាជនភាគច្រើននៅមានចម្ងល់ថា ជនជាប់ចោទដែលកំពុងស្ថិតនៅក្នុងការឃុំឃាំងពេលនេះមានទោសពីបទប្រព្រឹត្តខុសយ៉ាងធ្ងន់ធ្ងរ ក៏ប៉ុន្តែឧក្រិដ្ឋកម្មជាក់លាក់របស់អ្នកទាំងនេះនៅតែមិនទាន់រកឃើញនៅឡើយ ។ អ្នកសង្កេតការណ៍មួយចំនួនប្រហែលជាគិតថាវាជារឿងងាយ



ន ឆលីអារី កំពុងធ្វើបទកថា

ស្រួលដោយគ្រាន់តែដាក់អតីតមេដឹកនាំខ្មែរក្រហមឲ្យឈរជាជួរជាប់នឹងជញ្ជាំង រួចកេះកៃកាំភ្លើងទៅជាការស្រេច ។ ក្រោយពីមានការរំលោភបំពានសិទ្ធិមនុស្សគ្រប់ទីកន្លែង ការស្រេកឃ្លានឲ្យមានការផ្តន្ទាទោសមានសន្ទុះយ៉ាងខ្លាំងនិងគួរឲ្យយល់បាន ។ នេះជារឿងពិតនៅកម្ពុជា នៅពេលដែលបទដ្ឋានសាសនានិងវប្បធម៌រួមផ្សំជាមួយវេលាដែលកន្លងផុតយូរទៅហើយបានធ្វើឲ្យគំនុំសងសឹករបស់សាធារណជនថយនៅត្រឹមកម្រិតមួយទាប ។

ទោះបីជាយ៉ាងណាក៏ដោយ សិទ្ធិជនជាប់ចោទត្រូវតែគោរព ប្រសិនបើអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាត្រូវធ្វើជាតុលាការគំរូ មិនមែនជាតុលាការកង់គូរូមួយនោះទេ ។ គ្រប់តុលាការអន្តរជាតិ រួមទាំងតុលាការនូរិមបឺកផង ត្រូវបានស្តីបន្ទោសថាជា «យុត្តិធម៌របស់អ្នកឈ្នះ» ឬ «ការជំនុំជម្រះស្រមោល» ។ ការរិះគន់ទាំងនេះមិនមែនគ្មានមូលហេតុទាំងស្រុងនោះទេគឺដោយសារតុលាការទាំងនេះពិតជាឆ្លុះបញ្ចាំងពីតថភាពនយោបាយនៅពេលដែលតុលាការទាំងនោះត្រូវបានបង្កើតឡើង ។ មធ្យោបាយល្អបំផុតដើម្បីកាត់បន្ថយឥទ្ធិពលទិតៀនបែបនេះ គឺត្រូវលើកកម្ពស់តម្លាភាពនិងភាពយុត្តិធម៌ត្រឹមត្រូវ ។ សម្រាប់បញ្ហានេះ តុលាការនូរិមបឺកបានបង្កើតយុត្តិសាស្ត្រដ៏សំខាន់មួយដោយលើកលែងការចោទប្រកាន់ចំពោះពួកណាហ្ស៊ីមួយចំនួនតូច ពីព្រោះពុំមានភស្តុតាងគ្រប់គ្រាន់ ។ តុលាការអន្តរជាតិផ្សេងៗទៀតដូចជា តុលាការអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី និងរ៉ូវ៉ាន់ដាក៏បានលើកលែងការចោទប្រកាន់ដល់ជនជាប់ចោទមួយចំនួនដែរ ។ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ត្រូវគោរពតាមច្បាប់វិធាននៃនិតិវិធី និងវិធានភស្តុតាងដ៏ស្មុគស្មាញមួយចំនួនដែលរៀបចំធ្វើឡើងដើម្បីលើកកម្ពស់ភាពយុត្តិធម៌ត្រឹមត្រូវ ។ ប្រសិនបើអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាចង់ធ្វើជាគំរូយុត្តិធម៌ តុលាការនេះត្រូវតែប្រកាន់ឲ្យខ្ជាប់ខ្ជួនទៅនឹងច្បាប់ទាំងអស់នេះ ។

ការជំនុំជម្រះដោយយុត្តិធម៌ត្រឹមត្រូវទាមទារឲ្យការកាត់ទោសត្រូវពឹងផ្អែកទៅលើមូលដ្ឋានភស្តុតាងស្របតាមច្បាប់ ហើយចុងចោទដែលគួរឲ្យស្អប់ខ្ពើមបំផុតក៏ត្រូវតែមានលទ្ធភាពទទួលបានការគាំទ្រផ្នែកការពារដែរ ។ ដីកាសម្រេចអំពីទោសកំហុសមិនអាចធ្វើឡើងដោយលំៗបានឡើយ ។ មានភស្តុតាងសំខាន់ៗជាច្រើនដែលអាចប្រឆាំងនឹងមេដឹកនាំខ្មែរក្រហម ដោយរួមមានទាំងឯកសារជាផ្លូវការនៃកម្ពុជាប្រជាធិបតេយ្យ សក្ខីកម្មសាក្សី និងអដ្ឋិធាតុជាក់ស្តែងជាដើម ដែលបង្ហាញពីការទទួលខុសត្រូវរបស់ជនជាប់ចោទម្នាក់ៗចំពោះបទល្មើសជាក់លាក់នោះគឺមិនមែនជារឿងសាមញ្ញដូចយើងគិតទេ ។ ប្រសិនបើមិនអាចបង្ហាញភស្តុតាងជាក់លាក់បានគ្រប់គ្រាន់ ជនជាប់ចោទប្រាកដជាទទួលបានការលើកលែងការចោទប្រកាន់ ។

ការធ្វើបែបនេះចំពោះជនជាប់ចោទខ្មែរក្រហមប្រហែលជាពិបាកទទួលយកណាស់បើគិតតាមផ្លូវសីលធម៌និងនយោបាយ ក៏ប៉ុន្តែអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាគ្រាន់តែបំពេញអាណត្តិរបស់ខ្លួនក្នុងការស្វែងរកយុត្តិធម៌ឲ្យបានហ្មត់ចត់តែប៉ុណ្ណោះ ។ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាប្រហែលជាមិនអាចផ្តល់នូវការផ្តន្ទាទោស ឬការស្តារឡើងវិញឲ្យបាន «ពេញលេញទាំងស្រុង» ជូនប្រជាជនកម្ពុជានោះទេ ។ ក៏ប៉ុន្តែអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាត្រូវតែគ្រប់គ្រងដំណើរការប្រកបដោយយុត្តិធម៌ត្រឹមត្រូវមួយ ។ បន្ថែមទៅលើការធ្វើជាគំរូយុត្តិធម៌ត្រឹមត្រូវនិងតម្លាភាពផងនោះ ការប្រកាន់ខ្ជាប់ទៅនឹងគោលការណ៍យុត្តិធម៌តាមផ្លូវច្បាប់ដែលអាចសម្រួលដល់ការផ្ទេរចំណេះដឹងជាប្រយោជន៍ និងភាពជំនាញរវាងមន្ត្រីកម្ពុជានិងអន្តរជាតិដែលជួយពង្រឹងប្រព័ន្ធតុលាការកម្ពុជាដែលគេដឹងឮថាជាប្រព័ន្ធមួយដែលមានលក្ខណៈពុករលួយគ្រប់កន្លែងនិងសុសសាយ ។ កេរដំណែលសោកនាដកម្មមួយនៃរបបកម្ពុជាប្រជាធិបតេយ្យគឺអ្នកចេះដឹងនៅរស់ពីសម័យប៉ុលពតតែប៉ុន្មាននាក់ប៉ុណ្ណោះដែលបានបន្សល់ទុកនូវភាពកម្រនៃមេធាវីនិងអ្នកមានអាជីពដទៃៗទៀត ។ វាគឺជារឿងពិបាក

មួយក្នុងការកសាងប្រព័ន្ធច្បាប់ឲ្យរឹងមាំ ប្រសិនបើគ្មានចៅក្រមនិងមេធាវីចំនួនច្រើនដាក់លាក់បានទទួលការហាត់រៀនឲ្យបានល្អនោះ ។ សក្ខានុពលភាពសម្រាប់ផ្ទេរចំណេះដឹង គឺជាយន្តការសំខាន់មួយសម្រាប់បង្កើតតុលាការកូនកាត់ទាំងនៅក្នុងប្រទេសកម្ពុជានិងនៅប្រទេសដទៃទៀតដែលបំផ្លិចបំផ្លាញដោយសារសង្គ្រាម ។

ទស្សនៈយុត្តិធម៌ដែលមានលក្ខណៈផ្តន្ទាទោសស្តារឡើងវិញ និងស្របតាមនីតិវិធីពុំមែនដាច់ដោយឡែកពីគ្នាទាំងស្រុងនោះទេ ទោះបីជាពេលខ្លះ ទស្សនៈទាំងនេះស្ថិតនៅក្នុងភាពតានតឹង ឬលើកឡើងពីវិធីប្រើប្រាស់ប្រភពធនធានផ្សេងៗដែលមានកំណត់ក៏ដោយ ។ ការផ្តន្ទាទោសអាចជម្នះនឹងវប្បធម៌នៃនិទ្ទណ្ឌភាព និងផ្តល់ការផ្តន្ទាទោសផ្នែកសីលធម៌ទៅលើជនល្មើស ។ អ្នកគាំទ្រការកាត់ទោសសង្ឃឹមថា តុលាការនេះនឹងធ្វើឲ្យមានការញញើតក្នុងការប្រព្រឹត្តអំពើឧក្រិដ្ឋកម្មនៅថ្ងៃអនាគត និងជួយលើកកម្ពស់នីតិរដ្ឋ ។ យុត្តិធម៌ដែលមានលក្ខណៈស្តារឡើងវិញអាចជួយជួសជុលការខូចខាតផ្នែកសង្គមនិងសេដ្ឋកិច្ច ហើយដូច្នេះក៏ជួយសម្រួលដល់ការផ្សះផ្សាដែរ ។ ការធ្វើជាគំរូនៃយុត្តិធម៌ត្រឹមត្រូវតាមនីតិវិធីបានគឺអាចត្រួសត្រាយផ្លូវឆ្ពោះទៅរកនីតិរដ្ឋមួយដ៏រឹងមាំជាងមុនថែមទៀត ដោយដោះស្រាយបានទាំងអនាគតនិងទាំងអតីតកាលទៀតផង ។ លក្ខណៈយុត្តិធម៌ទាំងអស់នេះមានសារសំខាន់ខ្លាំងណាស់សម្រាប់ប្រទេសកម្ពុជា ក៏ដូចជាប្រទេសផ្សេងៗទៀតដែលញាំញីដោយការរំលោភបំពានសិទ្ធិមនុស្សយ៉ាងធ្ងន់ធ្ងរ ។ ការជម្នះរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា គឺត្រូវធ្វើឲ្យទស្សនៈទាំងនេះមានប្រសិទ្ធភាពបំផុត ដោយអនុលោមតាមលក្ខខណ្ឌពេលវេលានិងលុយកាក់ដែលមានកំណត់ ហើយដែលការទាមទារយុត្តិធម៌បែបនេះតុលាការណាក៏ពិបាកនឹងផ្តល់ជូនដែរ ។

## ការអនុវត្តមុខងារប្រាប់ការពិត

ចំពោះអ្នកសង្កេតការណ៍ជាច្រើនយល់ថា អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាប្រកាន់ខ្ជាប់ថានឹងអនុវត្តដំណើរការមុខងារយ៉ាងទូលំទូលាយលើសពីដំណើរកាត់សេចក្តីឲ្យបានត្រឹមត្រូវយុត្តិធម៌ និងចេញដីកាថ្កោលទោស ឬគ្មានទោសថែមទៀតផង ។ ប្រសិនបើធ្វើកិច្ចការរបស់ខ្លួនប្រកបដោយយុត្តិធម៌ត្រឹមត្រូវ តុលាការនេះអាចបម្រើជាយន្តការមួយដែលអាចប្រាប់ការពិតនិងរកតម្លៃប្រៀបមិនបាននៅក្នុងប្រទេសមួយដែលការអប់រំជាសាធារណៈអំពីសោកនាដកម្មនៃរបបខ្មែរក្រហមមានការខ្វះខាតខ្លាំង ។ រឿងដែលសំខាន់នោះ គឺអ្នកនៅរស់រានជីវិតពីសម័យ ប៉ុល ពត ទាំងអស់បានដឹងថា ការរំលោភបំពានសិទ្ធិមនុស្សយ៉ាងធ្ងន់ធ្ងរបានកើតឡើងពីឆ្នាំ១៩៧៥ដល់១៩៧៩ ក៏ប៉ុន្តែភាគតិចទេដែលដឹងអំពីវិសាលភាពនៃអំពើឃោរឃៅគ្រប់ជ្រុងជ្រោយ ។ មានជនរងគ្រោះរឹតតែតិចទៅទៀតដែលយល់ដឹងព្រាលៗអំពីមូលហេតុដែលនាំឲ្យមេដឹកនាំនិងកម្មាភិបាលខ្មែរក្រហមធ្វើទុក្ខទោសមកលើប្រជាជនខ្លួនឯងយ៉ាងដូច្នេះ ។ នៅក្នុងបទសម្ភាសន៍រាប់ពាន់របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ជនរងគ្រោះបានបង្ហាញចំណាប់អារម្មណ៍ក្នុងការចង់ឲ្យពន្យល់បកស្រាយរឿងពិតជាជាងការចង់សងសឹក ។ ដើម្បីប្រឈមមុខនឹងអតីតកាល ជនរងគ្រោះដែលមានស្លាកស្នាមដោយរបបគ្រប់គ្រប់របស់ខ្មែរក្រហម និងជនរងគ្រោះដែលបាត់បង់អ្នកជាទីស្រឡាញ់ទាំងអស់ចង់ដឹងពីមូលហេតុថាហេតុអ្វីបានជាធ្វើយ៉ាងដូច្នេះ ។

ដើម្បីបន្ថែមលើការទទួលបានផលប្រយោជន៍របស់អ្នករួចជីវិតពីរបបកម្ពុជាប្រជាធិបតេយ្យ ការផ្សព្វផ្សាយអំពីអង្គហេតុជាសាធារណៈអំពីរបបខ្មែរក្រហម អាចជួយកូនចៅរបស់ខ្លួនតាមរយៈការបង្ហាញពីតម្រូវការរបស់សង្គមមួយដែលមានលក្ខណៈត្រឹមត្រូវ និងមានសណ្តាប់ធ្នាប់ និងហានិភ័យនៃការធ្វើឲ្យខូចខាតដល់នីតិរដ្ឋ ។ បច្ចុប្បន្ន ប្រជាជនកម្ពុជាភាគច្រើនកើតក្រោយពេលរបបខ្មែរក្រហមត្រូវដួលរលំពីអំណាច ។ កូនចៅរបស់ជនរងគ្រោះពុំបានដឹងនូវការរងទុក្ខវេទនាផ្ទាល់របស់ឪពុកម្តាយរបស់ខ្លួននោះទេ ។ ក្មេងៗកម្ពុជាមួយចំនួនស្តាប់ឮអំពីសោកនាដកម្មនេះពីសាច់ញាតិនិងគ្រូៗរបស់ខ្លួន ប៉ុន្តែសម្រាប់ក្មេងជាច្រើនផ្សេងទៀត របបដ៏ខ្មៅងងឹតនេះបិទបាំងទៅដោយភាពអាថ៌កំបាំងនៅឡើយ ។ យុវជនយុវតីជាច្រើនមានការលំបាកក្នុងការស្វែងយល់អំពីការប្រឈមផ្នែកផ្លូវចិត្ត អារម្មណ៍ និងសង្គមដែលមនុស្សជំនាន់មុនបានជួបប្រទះ ដោយសារតែកង្វះខាតនៃការយល់ដឹងអំពីសម័យខ្មែរក្រហម ។

អស់រយៈពេលជាច្រើនឆ្នាំមកហើយ ការសិក្សានៅតាមសាលានៅកម្ពុជាមានបង្រៀនតែបន្តិចបន្តួចប៉ុណ្ណោះអំពីរបបខ្មែរ

ក្រហម ។ ទើបតែពេលថ្មីៗនេះ មានសៀវភៅសិក្សាអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យមួយចំនួនត្រូវបានទទួលស្គាល់និងបញ្ចូលទៅក្នុងកម្មវិធីសិក្សានៅសាលា ។ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាអាចបម្រើជាប្រភពមួយគួរឲ្យជឿជាក់បានអំពីប្រវត្តិសាស្ត្រនៃរបបនោះ ដោយរួមផ្សំនឹងរឿងរ៉ាវនៅក្នុងសៀវភៅសិក្សា សារមន្ទីរ និងសារព័ត៌មានផ្សេងៗទៀត ។ របាយការណ៍របស់តុលាការ ការផ្សាយតាមព័ត៌មាន ទស្សនកិច្ចជាសាធារណៈ និងការផ្សព្វផ្សាយរបស់មន្ត្រីអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា និងអង្គការក្រៅរដ្ឋាភិបាលអាចជួយផ្តល់ចម្លើយឲ្យបាន ។ មានតែការផ្តល់ចំណេះដឹងអំពីអតីតកាលដល់ក្មេងៗកម្ពុជាប៉ុណ្ណោះទេ ទើបក្មេងៗទាំងនោះអាចយល់អំពីប្រវត្តិនៃប្រទេសរបស់ខ្លួនដែលអាចសម្រេចបាននូវភាពបិទបាំងមួយកម្រិតខ្ពស់ជាងអ្វីដែលខ្លួនដឹងសព្វថ្ងៃ និងអាចរៀបចំខ្លួនឯងក្នុងការទប់ស្កាត់ការរំលោភសិទ្ធិមនុស្សនាពេលអនាគត ។

## ធ្វើជាគំរូជាអន្តរជាតិ

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានសារសំខាន់មិនមែនសម្រាប់តែប្រទេសកម្ពុជាប៉ុណ្ណោះទេ ។ នេះគឺជាតំណាងថ្មីៗបំផុតនៃកិច្ចខិតខំប្រឹងប្រែងជាអន្តរជាតិដែលមានលក្ខណៈធំធេងក្នុងការនាំយករបបឃោរឃៅឲ្យទទួលខុសត្រូវចំពោះការរំលោភបំពាននានានិងជំរុញការគោរពចំពោះសិទ្ធិជាមូលដ្ឋានផ្សេងៗទៀត ។ ចាប់តាំងពីជំនាន់នូរ៉េមប៊ឺកមក សមាជិកសំខាន់ៗនៃសហគមន៍អន្តរជាតិបានធ្វើការដើម្បីបង្កើតឲ្យមានដំណើរការជាអន្តរជាតិសម្រាប់ដោះស្រាយការកំណត់លើដំណើរការរឿងក្តីព្រហ្មទណ្ឌក្នុងស្រុកនៅក្នុងប្រទេសក្រោយជម្លោះ ។ នៅអំឡុងទសវត្សរ៍ ៩០ អង្គការសហប្រជាជាតិបានបង្កើតតុលាការអន្តរជាតិពិសេសសម្រាប់អតីតប្រទេសយូហ្គោស្លាវី និងរ៉ាន់ដា ហើយក្រោយមកទៀត គឺតុលាការអចិន្ត្រៃយ៍ព្រហ្មទណ្ឌអន្តរជាតិនៅទីក្រុងឡាអេ ។

តុលាការដែលគ្រប់គ្រងដោយអង្គការសហប្រជាជាតិត្រូវបានរិះគន់ចំពោះមូលហេតុមួយចំនួនរួមមាន ការចំណាយនិងចម្ងាយឆ្ងាយពីសង្គមដែលទទួលរងគ្រោះដូចជា ភូមិសាស្ត្រជាដើម ។ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា គឺជាឧទាហរណ៍មួយក្នុងចំណោមឧទាហរណ៍មួយចំនួនតូចស្តីអំពីជម្រើស «តុលាការចម្រុះ» ដែលទាក់ទងនឹងការចែករំលែកភារកិច្ចគ្នារវាងអង្គការសហប្រជាជាតិ និងរដ្ឋាភិបាលដែលមានឥទ្ធិពល ។ អ្នកគាំទ្រគំរូនេះជឿថា តុលាការចម្រុះនឹងផ្តល់សិទ្ធិឲ្យជនរងគ្រោះបញ្ចេញមតិ បានសម្របសម្រួលដល់ការផ្ទេរភាពជំនាញ និងផ្តល់យុត្តិធម៌ដោយចំណាយថវិកាអស់តិចនៅក្នុងប្រទេសមួយដែលត្រូវការលុយដើម្បីប្រើប្រាស់សម្រាប់កិច្ចការផ្សេងៗជាច្រើនទៀត ។ អ្នកជំទាស់គំរូតុលាការកូនកាត់នេះខ្លាចក្រែងថា ការធ្វើដៃគូជាមួយរដ្ឋាភិបាលដែលជាប់សង្ស័យអាចបន្ទាបសេចក្តីសុចរិតផ្នែកនីតិវិធីនិងច្បាប់របស់តុលាការដែលធ្វើឲ្យខូចកិត្តិនាមរបស់អង្គការសហប្រជាជាតិនិងបន្ថយភាពយុត្តិធម៌ដែលគួរឲ្យជឿជាក់នោះ ។ អ្នកខ្លះបារម្ភថា ការធ្វើការកាត់ទោសនៅក្នុងស្រុកអាចបើករបួសចាស់ឡើងវិញនឹងបង្កភាពរញ៉េរញ៉ៃក្នុងការស្វែងរកការផ្សះផ្សា ។ ការប្រព្រឹត្តរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាជាការសាកល្បងយ៉ាងសំខាន់សម្រាប់គំរូតុលាការចម្រុះ ។

## ការជះឥទ្ធិពលដល់នយោបាយកម្ពុជា

អាណត្តិរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មិនត្រឹមតែទាក់ទងនឹងច្បាប់ជាសំខាន់ប៉ុណ្ណោះទេ ក៏ប៉ុន្តែវាក៏មានការពាក់ព័ន្ធនឹងនយោបាយដ៏ធំធេងនៅក្នុងប្រទេសកម្ពុជាផងដែរ ។ ក្នុងឆ្នាំ១៩៧៩ នៅពេលដែលរបប ប៉ុល ពត ដួលរលំទៅ រដ្ឋាភិបាលថ្មីមួយដែលគាំទ្រដោយវៀតណាម បានកាន់កាប់ទីក្រុងភ្នំពេញ ។ រដ្ឋាភិបាលដែលដាក់ឈ្មោះប្រទេសសាជាថ្មីឡើងវិញថា សាធារណរដ្ឋប្រជាមានិតកម្ពុជានោះ បានអះអាងនូវអំណាច និងភាពស្របច្បាប់របស់ខ្លួនដោយសម្អាងជាចម្បងលើការជួយសង្គ្រោះប្រទេសកម្ពុជាឲ្យរួចផុតពីសោកនាដកម្មរបស់ខ្មែរក្រហម ។ ប៉ុន្មានឆ្នាំក្រោយមក ការដឹកនាំរបស់សាធារណរដ្ឋប្រជាមានិតកម្ពុជាបានបង្កើតគណបក្សប្រជាជនកម្ពុជាដែលគ្រប់គ្រងកម្ពុជាសព្វថ្ងៃនេះ ។ គណបក្សប្រជាជនកម្ពុជានិងអ្នកដឹកនាំអស់រយៈពេលជាយូររបស់ខ្លួន គឺសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន បន្តទាក់ទាញការគាំទ្រពីសាធារណជន ដោយសង្កត់ធ្ងន់លើតួនាទីរបស់ខ្លួននៅក្នុងការបោសសម្អាតខ្មែរក្រហមឲ្យអស់ពីប្រទេស ។

គណបក្សប្រឆាំងរួមមាន គណបក្សរាជានិយមហ៊្វុនស៊ិនប៉ិចគណបក្សសមរង្ស៊ី និងគណបក្សសិទ្ធិមនុស្សបានវាយប្រហារ

ចំពោះការអះអាងខាងលើនេះ ហើយបានចោទគណបក្សប្រជាជនកម្ពុជាថាបានធ្វើឲ្យការគោរពសិទ្ធិមនុស្សនៅកម្ពុជារឹតតែដុនដាបជាជាងការធ្វើឲ្យប្រសើរជាងមុន ។ រដ្ឋាភិបាលបរទេសនិងអង្គការសិទ្ធិមនុស្សមួយចំនួនក៏បាននិយាយដូចគ្នានេះដែរ ។ សាលាក្តីខ្មែរក្រហមពិតជាមានឥទ្ធិពលខ្លះៗទៅលើការយល់ឃើញរបស់សាធារណជនអំពីគណបក្សប្រជាជនកម្ពុជា ។ ប្រសិនបើសាលាក្តីដំណើរទៅបានល្អនោះ គណបក្សប្រជាជនកម្ពុជាប្រហែលជានឹងទទួលបានផលប្រយោជន៍នយោបាយសមល្មមដែរ ។ ប្រសិនបើការកាត់សេចក្តីមានការឆ្គាំឆ្គងនិងខ្វះសមត្ថភាព នោះវានឹងអាចទទួលផលផ្ទុយទៅវិញ ។ ដំណើរការអន់ថយនឹងប្រហែលជាធ្វើឲ្យសាធារណជន និងម្ចាស់ជំនួយអន្តរជាតិមានការខឹងសម្បានឹងរដ្ឋាភិបាល ជាពិសេសអំពើពុករលួយក្នុងតុលាការនៅប្រទេសកម្ពុជា ។ ការកាត់សេចក្តីទំនងជាមិនក្លាយជាបញ្ហាចម្បងនៅក្នុងនយោបាយថ្នាក់ជាតិនោះឡើយ ពីព្រោះពេលខ្លះការកាត់សេចក្តីនេះត្រូវបានចេញផ្សាយនៅក្នុងព័ត៌មានអន្តរជាតិអាចបង្កើតឲ្យមានការរំខានសំខាន់ៗផ្នែកក្នុងស្រុកនិងការទូតនាពេលខ្លីខាងមុខ ។ ត្រង់នេះហើយដែលថាការកាត់សេចក្តីមានសារសំខាន់ខ្លាំងណាស់ក្រៅពីបន្ទប់សវនាការ ។

## សរុបជារួមៈ ភារកិច្ចដ៏ខ្លាំងក្លាមួយចំនួន

គោលបំណងទាំងប៉ុន្មានខាងលើនេះមានចំនួនច្រើនអនេកដែលតម្រូវឲ្យតុលាការតែមួយគត់ឆ្លើយតប ។ កិច្ចការធំជាងគេមួយក្នុងចំណោមកិច្ចការដែលត្រូវប្រឈមមុខធំៗរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា គឺត្រូវរៀបចំចាត់ចែងការរំពឹងទុករបស់សាធារណជនអំពីអ្វីដែលខ្លួនអាចសម្រេចបានយ៉ាងពិតប្រាកដ ។ បើទោះបីជាតុលាការនេះបានជោគជ័យប៉ុនណាក៏ដោយក៏ការជំនុំជម្រះក្តីនឹងពុំមែនជាថ្នាំកែរោគបានគ្រប់យ៉ាងនោះទេ ។ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាមិនអាចព្យាបាលជំងឺសង្គមទាំងស្រុងដែលកំពុងតស៊ូជម្នះលើអំពើឃោរឃៅទ្រង់ទ្រាយធំបានគ្រប់ទាំងអស់ឡើយ ។ វាមិនអាចជំនួសការបាត់បង់អ្នកជាទីស្រឡាញ់ ហើយរឹតតែមិនអាចកែប្រែបញ្ហានយោបាយនិងសេដ្ឋកិច្ចដែលកើតចេញពីភាពគួរឲ្យតក់ស្លុតកាលសម័យខ្មែរក្រហមឡើយ ។ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាតែមួយមិនអាចផ្លាស់ប្តូរភារកិច្ចរបស់កម្ពុជា មិនអាចបញ្ចប់ឧក្រិដ្ឋកម្មនិងអំពើពុករលួយ មិនអាចនាំមកនូវការរីកចម្រើនដ៏ធំខាងផ្នែកសិទ្ធិមនុស្សនៅកម្ពុជាសព្វថ្ងៃ ឬមិនអាចដោះស្រាយសេចក្តីត្រូវការនៃការអភិវឌ្ឍផ្សេងទៀតបានទាំងស្រុងនោះទេ ។

ភាពសំខាន់ចាំបាច់របស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាស្ថិតនៅលើលទ្ធភាពក្នុងការធ្វើជាធាតុបន្ថែមនិងធាតុជំរុញការផ្លាស់ប្តូរនៅកម្ពុជា ។ ការជំនុំជម្រះក្តីអាចក្លាយជាជំហានចាំបាច់និងជាក់ស្តែងខ្លាំងឆ្ពោះទៅរកអនាគតជាក់លាក់មួយដ៏ប្រសើរដោយជម្នះនឹងនិទ្ទណ្ឌភាព ការធ្វើជាគំរូនៃការជំនុំជម្រះត្រឹមត្រូវចែករំលែកព័ត៌មានអំពីសម័យ ប៉ុល ពត និងទាញការយកចិត្តទុកដាក់ចំពោះតម្រូវការរបស់ជនរងគ្រោះ ។ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ក៏អាចផ្តោតលើការទាញចំណាប់អារម្មណ៍ជាតិនិងអន្តរជាតិឡើងវិញ លើបញ្ហាភារកិច្ចសិទ្ធិមនុស្ស និងបង្កើនទស្សនវិស័យដើម្បីការរីកចម្រើននាពេលអនាគត ។ ប្រសិនបើអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាអនុវត្តមុខងារទាំងអស់នេះបានល្អ នោះអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាប្រាកដជានឹងធ្វើការបម្រើសេវាកម្មដ៏អស្ចារ្យមួយយ៉ាងពិតប្រាកដ ។

## ប្រវត្តិនិងការវិវឌ្ឍរហូតមកទល់បច្ចុប្បន្នរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

ផ្នែកបន្ទាប់មកទៀត គឺពិភាក្សាដោយសង្ខេបអំពីប្រវត្តិកំណើតរបស់អង្គជំនុំជម្រះវិសាមញ្ញ រចនាសម្ព័ន្ធជាមូលដ្ឋាន ការអនុវត្តនិងការរំពឹងទុក ។ ខ្ញុំចាប់ផ្តើមដោយពិភាក្សាលើរបៀបដែលអង្គជំនុំជម្រះត្រូវបានបង្កើតឡើង និងវិភាគលើទម្រង់ពិសេសដែលតុលាការនេះប្រកាន់យក ។ បន្ទាប់មក ខ្ញុំនឹងធ្វើការវែកញែកអំពីប្រតិបត្តិការរយៈពេលបីឆ្នាំដំបូងរបស់តុលាការ ដោយពិនិត្យទៅលើទិដ្ឋភាពបីយ៉ាងនៃការងារគឺ ការស៊ើបអង្កេតរបស់តុលាការ ការគ្រប់គ្រងស្ថាប័ន និងការផ្សព្វផ្សាយដល់ជនរងគ្រោះ ។ ចុងបញ្ចប់ ខ្ញុំវិភាគអំពីរបៀបដែលអង្គជំនុំជម្រះវិសាមញ្ញអាចផ្តល់យុត្តិធម៌មួយដែលអាចជឿជាក់បាន និងការរួមចំណែកដល់ការផ្សះផ្សាពិតប្រាកដនៅកម្ពុជារហូតតទៅ ។

## ផ្លូវដ៏លំបាកឆ្ពោះទៅរកយុត្តិធម៌

ដើម្បីយល់អំពីភាពរឹងមាំ កង្វះខាត និងការវិវត្តមកទល់ពេល

បច្ចុប្បន្នរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា យើងចាំបាច់ត្រូវដឹងពីប្រវត្តិខ្លះៗរបស់តុលាការនេះជាមុនសិន ។ ហេតុដូច្នេះ ខ្ញុំចាប់ផ្តើមបរិយាយពីលំនាំទូទៅជាប្រវត្តិ និងនយោបាយនៅពីក្រោយការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ មានការទាមទាររកយុត្តិធម៌នៅក្នុងប្រទេសកម្ពុជារាប់មិនអស់ចាប់តាំងពីការដួលរលំនៃរបបកម្ពុជាប្រជាធិបតេយ្យ ។ ជនរងគ្រោះ អ្នកធ្វើការខាងសិទ្ធិមនុស្ស គណបក្សនយោបាយក្នុងស្រុក និងរដ្ឋាភិបាលអន្តរជាតិជាច្រើនបានទាមទារឲ្យមានការរកយុត្តិធម៌តាមកម្រិតផ្សេងៗគ្នា ។ ទោះបីជាយ៉ាងនេះក៏ដោយ ការបង្កើតតុលាការនេះនៅតែជាដំណើរការដ៏យឺតយ៉ាវនិងតឹងតែង ។ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានបើកទ្វារធ្វើការក្រោយពីការដួលរលំរបស់របបខ្មែរក្រហមអស់រយៈពេលជិតបីទសវត្សរ៍ ។

ការពន្យារពេលក្នុងការបង្កើតតុលាការនេះជាប់ជំពាក់ជំពិនយ៉ាងចម្បងនឹងអំណាចនយោបាយ ។ ចលនាតស៊ូរបស់ខ្មែរក្រហមកើតឡើងចំសន្ទុះនៃសង្គ្រាមត្រជាក់ ហើយការទទួលយកសមាជិកខ្មែរក្រហមតែងតែត្រូវប្រឫកប្រឫលជាមួយនឹងនយោបាយក្នុងស្រុក ក៏ដូចជាការប្រកួតប្រជែងផ្នែកនយោបាយជាអន្តរជាតិក្នុងការដណ្តើមយកឥទ្ធិពលជ្រៀតជ្រែកនៅកម្ពុជា ។ ទោះបីជាមានការអំពាវនាវនិងកិច្ចខំប្រឹងប្រែងដោយបុគ្គលនិងអង្គការក្រៅរដ្ឋាភិបាលមួយចំនួនក៏ដោយ ក៏ការទាមទារឲ្យមានការទទួលខុសត្រូវរបស់ខ្មែរក្រហមត្រូវបានកប់បាត់ទៅក្នុងការពិចារណាដែលមានលក្ខណៈនយោបាយ និងយុទ្ធសាស្ត្រនៅក្នុងដំណាក់កាលចុងក្រោយនៃសង្គ្រាមត្រជាក់ ។ សហគមន៍អន្តរជាតិបានជំរុញយ៉ាងខ្លាំងក្លាដោយចាប់ផ្តើមដាក់ឲ្យមានការទទួលខុសត្រូវ បន្ទាប់ពីមានការដកហូតកងទ័ពវៀតណាមចេញពីទឹកដីកម្ពុជាដោយការចរចារ ការគ្រប់គ្រងរបស់អង្គការសហប្រជាជាតិរយៈពេល១៨ខែ និងការបោះឆ្នោតជាសកលដែលរៀបចំឡើងដោយអង្គការសហប្រជាជាតិក្នុងការនាំមកនូវសន្តិភាពដល់ប្រទេស និងការបំបែកក្រុមខ្មែរក្រហមឲ្យទៅជាកម្លាំងនយោបាយនិងយោធាមួយផ្សេង ។

ចាប់ផ្តើមពីឆ្នាំ១៩៩៧ អង្គការសហប្រជាជាតិ និងរដ្ឋាភិបាលកម្ពុជាបានចាប់ផ្តើមធ្វើការចរចាតាមការទូតអស់រយៈពេលមួយទសវត្សរ៍ដើម្បីបង្កើតចេញជាតុលាការមួយនេះ ។ ភាពមិនចុះសម្រុងគ្នានៅពេលចរចានេះកើតចេញពីការទាមទារនូវ «សមភាពនៃឥទ្ធិពល» រវាងមន្ត្រីអង្គការសហប្រជាជាតិនិងមន្ត្រីខាងកម្ពុជា និងទំហំនៃយុត្តាធិការរបស់តុលាការនិងជនជាប់ចោទដែលត្រូវចោទប្រកាន់ និងច្បាប់នីតិវិធីដែលត្រូវយកមកប្រើនៅក្នុងតុលាការ ។ ក្រោយមកនៅឆ្នាំ២០០៣ គឺជាងមួយភាគបួននៃទសវត្សរ៍បន្ទាប់ពីការដួលរលំរបស់ខ្មែរក្រហម អង្គការសហប្រជាជាតិនិងរាជរដ្ឋាភិបាលកម្ពុជាបានព្រមព្រៀងគ្នាបង្កើតកិច្ចព្រមព្រៀងមួយ (កិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា) ដើម្បីបង្កើតអង្គបុរេជំនុំជម្រះ ។ មួយឆ្នាំក្រោយមករដ្ឋសភាជាតិកម្ពុជាបានអនុម័តច្បាប់ដើម្បីគ្រប់គ្រងដំណើរការរបស់តុលាការកូនកាត់នេះឡើង (ច្បាប់នេះក៏បានការយល់ស្របពីអង្គការសហប្រជាជាតិដែរ) ។

កិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិនិងរាជរដ្ឋាភិបាលកម្ពុជា គឺជាសមិទ្ធផលដែលចេញពីចម្បាំងនយោបាយដ៏ហត់នឿយជាមួយនឹងការតថ្លៃគ្នាទៅវិញទៅមករវាងរាជរដ្ឋាភិបាលកម្ពុជា និងអង្គការសហប្រជាជាតិ ។ ចំណុចសំខាន់នៃការចរចានេះទាក់ទិនទៅនឹងយុត្តាធិការតាមពេលវេលា យុត្តាធិការលើបុគ្គល និងយុត្តាធិការលើបទល្មើស ។ តុលាការនេះនឹងមានអំណាចកាត់សេចក្តីទៅលើតែជនមួយចំនួនដាក់លាក់ចំពោះបទឧក្រិដ្ឋមួយចំនួនដែលបានប្រព្រឹត្តនៅក្នុងអំឡុងពេលកាន់កាប់អំណាចរបស់ខ្មែរក្រហមប៉ុណ្ណោះ ។ ចំណុចសំខាន់មួយទៀតនៃការចរចាគឺ សមភាពនៃឥទ្ធិពលនៅក្នុងតុលាការ ។ មិនដូចជាតុលាការអន្តរជាតិផ្សេងទៀតដែលបុគ្គលិកភាគច្រើនជាមន្ត្រីអន្តរជាតិ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាត្រូវបានបង្កើតឡើងក្នុងលក្ខណៈមួយដើម្បីធានាឧត្តមភាពរបស់មន្ត្រីជាតិ ។ ច្បាប់ស្តីពីកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិនិងរាជរដ្ឋាភិបាលកម្ពុជា និងច្បាប់បង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានទទួលរងនូវការរិះគន់យ៉ាងខ្លាំងក្លាពីអ្នកអង្កេតអន្តរជាតិដែលអ្នកទាំងនោះទិតៀនថា ច្បាប់ទាំងពីរនេះផ្តល់អំណាចច្រើនពេកដល់រដ្ឋាភិបាលសម្តេច ហ៊ុន សែន ហើយបែរជាតថ្លៃចំពោះសេចក្តីសុចរិតនិងយុត្តិធម៌ទៅវិញ ។

រាល់តុលាការអន្តរជាតិទាំងអស់តែងឆ្លុះបញ្ចាំងពីតថភាព

នយោបាយ និងពាំនាំមកនូវភាពជំពាក់ជំពិនខាងផ្លូវនយោបាយជានិច្ច ។ ពុំមានអញ្ញត្តិកម្មទេចំពោះអង្គជំនុំជម្រះវិសាមញ្ញ ។ ទោះបីជាចំណេញឬខាត កម្រិតយុត្តាធិការនិងវចនាសម្ព័ន្ធធ្វើការរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដើរតួនាទីយ៉ាងសំខាន់ក្នុងទទួលបាននូវការទិញដេញថ្លៃពីភាគីដែលពាក់ព័ន្ធ ។ យ៉ាងណាមិញ កេរដំណែលនៃការចរចាដ៏គានគឺងនិងការតថ្លៃនយោបាយក្នុងអំឡុងពេលនៃការចរចាបានបន្សល់ទុកនូវស្នាមមិនស្រុះស្រួលនិងមិនទុកចិត្តគ្នា ។ ភាគច្រើននៃការវង្គាលនយោបាយកាលពីអំឡុងពេលចរចា នៅតែដិតដាមនិងតាមយាយីដល់ដំណើរការប្រព្រឹត្តទៅរបស់អង្គជំនុំជម្រះនៅពេលបច្ចុប្បន្នជានិច្ច ។ ជាក់ស្តែង យុត្តាធិការរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជានិងសមភាពឥទ្ធិពលដ៏សមរម្យនៅតែបន្តជាចំណុចសំខាន់នៃការពិភាក្សា ដូចជាមន្ត្រីកម្ពុជានិងមន្ត្រីអង្គការសហប្រជាជាតិតវ៉ាគ្នាចំពោះលទ្ធភាពក្នុងការចោទប្រកាន់ជនសង្ស័យបន្ថែម និងតតាំងគ្នាក្នុងការរកមធ្យោបាយដើម្បីដោះស្រាយវិបត្តិគ្រប់គ្រងនៅក្នុងតុលាការ ។

## តុលាការបានលេចចេញជារូបរាង

កិច្ចព្រមព្រៀងឆ្នាំ២០០៣ រវាងអង្គការសហប្រជាជាតិនិងរាជរដ្ឋាភិបាលកម្ពុជារួមជាមួយនឹងច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាឆ្នាំ២០០៤ មានខសំខាន់ដែលចាំបាច់ក្នុងការបង្កើតតុលាការខ្មែរក្រហម ។ ខនោះបានកំណត់នូវច្បាប់សំខាន់ៗដល់ការគ្រប់គ្រងដំណើរការរបស់តុលាការ និងបានបែងនូវលក្ខណៈគ្រប់គ្រងរដ្ឋបាលនិងវចនាសម្ព័ន្ធជាច្រើននៅក្នុងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ ផ្នែកនេះពិភាក្សាលើលក្ខណៈជាមូលដ្ឋានរបស់តុលាការនិងរបៀបដែលតុលាការនេះលេចឡើងជារូបរាងបន្ទាប់ពីមានការចុះហត្ថលេខាលើច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។

បន្ថែមលើសេចក្តីសម្រេចអំពីរយៈពេលដែលត្រូវយកមកអនុវត្ត និងមនុស្សដែលត្រូវនាំយកមកកាត់ទោស ស្ថាបនិករបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាត្រូវតែកំណត់ឲ្យច្បាស់លាស់នូវយុត្តាធិការនៃបទល្មើស ។ នេះមានន័យថាត្រូវធ្វើការសម្រេចលើឧក្រិដ្ឋកម្មផ្សេងៗក្នុងរបបកម្ពុជាប្រជាធិបតេយ្យដែលអាចយកមកធ្វើជំនុំជម្រះបាន ។ មន្ត្រីរបស់អង្គការសហប្រជាជាតិនិងកម្ពុជាបានទាញយកទាំងច្បាប់អន្តរជាតិនិងច្បាប់ជាតិ ហើយជាចុងក្រោយបានសម្រេចយកឧក្រិដ្ឋកម្មចំនួនប្រាំបីដែលក្នុងនោះរួមមាន អំពើប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មសង្គ្រាម ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ការធ្វើទារុណកម្ម មនុស្សឃាត ការធ្វើទុក្ខបុកម្នេញលើសាសនា ព្រមទាំងបទឧក្រិដ្ឋពីរបីផ្សេងទៀតដែលមិនសូវស្គាល់ដែលជាបទល្មើសអន្តរជាតិមិនត្រូវបានជំនុំជម្រះកាលពីមុន ។

និយមន័យផ្នែកច្បាប់ទាក់ទិននឹងឧក្រិដ្ឋកម្មទាំងនេះ គឺមិនមានភាពច្បាស់លាស់មួយចំនួន ។ យុត្តិធម៌តម្រូវឲ្យចុងចោទខ្មែរក្រហមត្រូវជំនុំជម្រះទោសចំពោះតែឧក្រិដ្ឋកម្មដែលកើតឡើងក្នុងពេលដែលទាំងច្បាប់ព្រហ្មទណ្ឌអន្តរជាតិ និងច្បាប់កម្ពុជានៅជាធរមានក្នុងទសវត្សរ៍៧០តែប៉ុណ្ណោះ ។ ដូចដែលលោកស្រី ហេន រៀបរាប់ច្បាប់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ទុកចំហចំពោះសំណួរសំខាន់ៗស្តីពី «ធាតុផ្សំ» ច្បាស់លាស់ (អំពើជាក់លាក់និងចេតនាប្រព្រឹត្តបទល្មើស) ដែលព្រះរាជអាជ្ញាត្រូវតែបង្ហាញភស្តុតាងដើម្បីធានាឲ្យបាននូវការចោទប្រកាន់លើបទល្មើសជាក់លាក់មួយ ។ ច្បាប់នេះក៏បានទុកចំហនូវបញ្ហាច្បាប់ដ៏ស្មុគស្មាញមួយចំនួនជុំវិញទម្រង់នៃការទទួលខុសត្រូវលើបទឧក្រិដ្ឋកម្មឲ្យថែមទៀត ។ ក្នុងករណីនៃបទល្មើសរំលោភសិទ្ធិមនុស្សធ្ងន់ធ្ងរ ការដាក់ឲ្យមេដឹកនាំជាន់ខ្ពស់ទទួលខុសត្រូវទាមទារឲ្យបង្ហាញថាមេដឹកនាំទាំងនោះបានចេញបញ្ជានិងមានជាប់ពាក់ព័ន្ធនឹងការឃុបឃិតគ្នា បើមិនអ៊ីចឹងទេនឹងត្រូវទទួលខុសត្រូវដោយប្រយោលចំពោះឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងដោយសហសេវិក ឬអ្នកនៅក្រោមបង្គាប់របស់ខ្លួន ។ ការបង្កើតឲ្យមានការទទួលខុសត្រូវលើឧក្រិដ្ឋកម្មដោយផ្ទាល់និងដោយប្រយោលរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាអាចមានផលប៉ះពាល់ជាក់ស្តែងខ្លាំងទៅលើការជំនុំជម្រះទាំងនោះ ។

សារសំខាន់ស្មើគ្នានោះ គឺច្បាប់និងវិធានផ្សេងៗដែលបង្កើតឡើងដើម្បីធានាសិទ្ធិរបស់ចុងចោទ ។ ដូចដែលបានលើកឡើងខាងលើ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាអាចចាត់ទុកថាទទួលជោគជ័យបាន ប្រសិនបើតុលាការនេះអាចរៀបចំឲ្យចុងចោទ

ធ្វើការការពារក្ដី និងគោរពតាមសញ្ញាណជាទូទៅនៃយុត្តិធម៌ត្រឹមត្រូវតាមនីតិវិធី ។ ការការពារផ្នែកច្បាប់គឺផ្ដល់ឲ្យចុងចោទខ្មែរក្រហម ដោយអនុលោមតាមច្បាប់ស្ដីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជានិងនៅក្នុងច្បាប់ផ្សេងៗទៀតដែលពាក់ព័ន្ធ ។ វិធានផ្ទៃក្នុងទើបតែបង្កើតឡើងនៅក្នុងឆ្នាំ២០០៧ ប៉ុណ្ណោះ ដើម្បីគ្រប់គ្រងលើដំណើរការផ្ទៃក្នុងរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។

ជាចុងក្រោយ គឺជាការស័ក្ដិសមណាស់ក្នុងការពិចារណាលើរចនាសម្ព័ន្ធផ្នែកតុលាការ និងរដ្ឋបាលដែលមានចែងនៅក្នុងកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិនិងកម្ពុជា ជាពិសេសច្បាប់ស្ដីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ ការព្រួយបារម្ភភាគច្រើនទៅលើរចនាសម្ព័ន្ធនិងនីតិវិធីរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា គឺទាក់ទងនឹងលក្ខណៈចម្រុះនៃតុលាការនេះ ។ កិច្ចការស៊ើបអង្កេត ចោទប្រកាន់ និងជំនុំជម្រះក្ដីនឹងត្រូវបានបែងចែកភារកិច្ចរវាងបុគ្គលិកកម្ពុជានិងអន្តរជាតិ ។ ការបែងចែកនេះមានចំណុចខ្លាំងមួយចំនួនដូចជា សក្ដានុពលសម្រាប់ជំនាញបន្ថែមនិងជំនាញការផ្សេងៗ ជាពិសេសលទ្ធភាពនៃការផ្ទេរចំណេះដឹងដែលមានប្រយោជន៍ផ្សេងៗទៅវិញទៅមក ។ ក៏ប៉ុន្តែនៅមានបញ្ហាខ្លះៗទាក់ទងនឹងរចនាសម្ព័ន្ធនិងលទ្ធភាពនៃការផ្អាកដំណើរការរបស់ស្ថាប័ន ក៏ដូចជាភាពស្មុគស្មាញនៃនីតិវិធីនៅក្នុងសំណុំរឿងជាក់លាក់មួយចំនួនរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។

## ការវាយតម្លៃនូវកិច្ចការរបស់អង្គជំនុំជម្រះរហូតមកទល់សព្វថ្ងៃ

នៅពេលដែលអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាលេចចេញជារូបរាងឡើង និងចាប់ផ្ដើមកិច្ចការរបស់ខ្លួនក្នុងឆ្នាំ ២០០៦ តុលាការនេះមានការកំណត់អាណត្តិក្រោមផ្លូវការរយៈពេលបីឆ្នាំ ហើយបានខិតខំស្វះស្វែងរកថវិកាដើម្បីជម្នះលើនិទ្ទណ្ឌភាពរបស់ខ្មែរក្រហម ដោយត្រូវបញ្ជូនមេដឹកនាំខ្មែរក្រហមដែលរស់រានមានជីវិតទៅកាត់ទោស ។ រយៈពេលជាងបីឆ្នាំរបស់ខ្លួន អង្គជំនុំជម្រះបានខំប្រឹងបំពេញក្ដីសង្ឃឹមរបស់អ្នកគាំទ្រខ្លួន ព្រមទាំងការបារម្ភពីសំណាក់អ្នករិះគន់ ។ ចំពោះអ្នកគាំទ្រអង្គជំនុំជម្រះវិញ តុលាការនេះបានចាត់ដំណើរការសំខាន់ឆ្ពោះទៅរកយុត្តិធម៌ ។ ចំពោះអ្នករិះគន់វិញ តុលាការនេះមានលក្ខណៈជាឆាកល្ខោននិងបរាជ័យ ។ ការពិតស្ថិតនៅចន្លោះនៃការយល់ឃើញទាំងនេះ ។

ចាប់តាំងពីឆ្នាំ២០០៦មក មានការរីកចម្រើនមួយគួរឲ្យកត់សម្គាល់ ។ ការស៊ើបអង្កេតត្រូវបានធ្វើឡើង ជនសង្ស័យសំខាន់ៗប្រាំនាក់ស្ថិតក្នុងការឃុំឃាំង សវនាការដោយអង្គបុរេជំនុំជម្រះជាច្រើនត្រូវបានបើក ហើយការជំនុំជម្រះទោសលើ ឌុច ត្រូវបានចាប់ផ្ដើមជាបន្តបន្ទាប់ ។ តុលាការក៏បានបង្កើតអង្គភាពរដ្ឋបាលមួយចំនួន ព្រមទាំងបានកែលម្អកិច្ចការផ្សព្វផ្សាយរបស់ខ្លួនដល់សាធារណជនតាមរយៈការបង្កើតអង្គភាពជនរងគ្រោះថ្មីមួយ ។ ការជំនុំជម្រះបទឧក្រិដ្ឋឲ្យមានប្រសិទ្ធភាពមិនមែនជារឿងងាយស្រួលធ្វើប៉ុន្មានទេ ជាពិសេសនៅពេលដែលទំហំនៃបទឧក្រិដ្ឋដែលបានប្រព្រឹត្តមានលក្ខណៈធំធេង ។ កិច្ចការប្រឈមមានកាន់តែច្រើនសម្រាប់តុលាការថ្មីមួយដែលប្រើប្រាស់ច្រើនភាសា បម្រើឲ្យម្ចាស់ជំនួយផ្សេងៗគ្នា ព្រមទាំងអនុវត្តវិធាននិងនីតិវិធីដោយផ្អែកលើភាពបញ្ចូលគ្នាដ៏ស្មុគស្មាញរវាងច្បាប់ទម្លាប់ជាតិនិងអន្តរជាតិ ។ ដោយពិនិត្យលើបញ្ហាទាំងអស់នេះ យើងអាចនិយាយបានថាអង្គជំនុំជម្រះសម្រេចបាននូវការរំពឹងទុកគួរសម ។

ទោះជាយ៉ាងណាក៏ដោយ ដំណើរការកាត់ទោសនេះគឺនៅមានកិច្ចការជាច្រើនទៀតដែលត្រូវបំពេញ ហើយកំពុងតែដើរលើផ្លូវដ៏ពិបាក ។ ការខ្វែងគំនិតគ្នា បញ្ហា និងរឿងអាស្រូវអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាជាច្រើនបានលេចឡើងដែលគំរាមកំហែងដល់ប្រសិទ្ធភាពរបស់តុលាការ ហើយជួនកាលអាចធ្វើឲ្យខូចដល់កិត្យានុភាពរបស់តុលាការ ព្រមទាំងអាចធ្វើឲ្យអន្តរាយដល់ការមានតុលាការក៏អាចថាបាន ។ មានការប្រឈមជាច្រើននៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា គឺទាក់ទងនឹងភាពតានតឹងរវាងមន្ត្រីកម្ពុជានិងបរទេស ។ ដូច្នេះការសម្របសម្រួលជាច្រើនចាំបាច់ត្រូវធ្វើពេញមួយដំណើរការ ដើម្បីរក្សាឲ្យតុលាការនេះមានដំណើរការទៅមុខ ។ តុលាការនេះធ្វើដំណើរទៅមុខយឺតយ៉ាវ ហើយអ្នកវិភាគមួយចំនួនបានរិះគន់ដល់ដំណើរការដ៏យឺតយ៉ាវក្នុងការស៊ើបអង្កេត ។ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានបង្កើតឡើងសម្រាប់អាណត្តិបីឆ្នាំ និងថវិកាដែលឆ្លើយតប

ទៅនឹងអាណត្តិនោះ ។ ជាការច្បាស់ណាស់ថា បច្ចុប្បន្ននេះតុលាការត្រូវការពេលវេលានិងថវិកាច្រើនជាងអ្វីដែលខ្លួនបានគ្រោងទុកកាលពីដំណាក់កាលដំបូងថែមទៀត ដើម្បីបញ្ចប់ការងាររបស់ខ្លួន ។ ចំពោះអ្នករិះគន់បាននិយាយថា អង្គជំនុំជម្រះមិនបានផ្តល់ការផ្សព្វផ្សាយព័ត៌មានដល់ជនរងគ្រោះគ្រប់គ្រាន់ទេ ហើយបានសម្រេចចេញដីកាជាច្រើនដែលគុណភាពរបស់វាអាចប្រែប្រួលបាន ។ ប្រហែលជាអាចពិបាកជាងនេះទៀតនោះ គឺការចោទប្រកាន់ដែលមន្ត្រីរបស់អង្គជំនុំជម្រះគ្រប់គ្រងស្ថាប័នមិនបានល្អ ដែលបណ្តែតបណ្តោយឲ្យមានអំពើពុករលួយជ្រាបចូលក្នុងដំណើរការនេះ ។ អ្នកសង្កេតការណ៍មួយចំនួន រួមទាំងអ្នកគាំទ្រសិទ្ធិមនុស្សបានគាំទ្រឲ្យមានការបិទដំណើរការអង្គជំនុំជម្រះទាំងមូលទៀតផង ។

## ការវិនិច្ឆ័យខាងផ្លូវច្បាប់របស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

ចាប់តាំងពីពាក់កណ្តាលឆ្នាំ២០០៧មក អង្គបុរេជំនុំជម្រះដែលមានចៅក្រមខ្មែរបីរូបនិងអន្តរជាតិពីររូបបានបើកសវនាការជាសាធារណៈជាច្រើន ហើយចេញសេចក្តីសម្រេចសំខាន់ៗមួយចំនួន ។ សេចក្តីសម្រេចជាច្រើនទាក់ទងនឹងសិទ្ធិខាងផ្លូវច្បាប់និងភាពត្រឹមត្រូវតាមផ្លូវច្បាប់នៃការឃុំខ្លួនជនសង្ស័យដោយអង្គជំនុំជម្រះ ។ ជនជាប់ចោទមួយចំនួនបានប្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាឃុំខ្លួនរបស់សហចៅក្រមស៊ើបអង្កេត ដោយអះអាងថាខ្លួនមានជំងឺឈឺថ្កាត់ធ្ងន់ធ្ងរដែលមិនអាចស្ថិតក្នុងមន្ទីរឃុំឃាំងឬមិនអាចចូលរួមក្នុងសវនាការបាន ។ ឌុច បានស្វែងរកការដោះលែងដោយសម្អាងលើហេតុផលថា សិទ្ធិរបស់ខ្លួនត្រូវបានរំលោភបំពានដោយតុលាការយោធានៅភ្នំពេញ ត្រឹមពេលដែលជាប់ឃុំមុនការកាត់ទោសដែលចាប់ផ្តើមតាំងពីឆ្នាំ១៩៩៩ ហើយបានអូសបន្លាយលើសពីរយៈពេលបីឆ្នាំដែលច្បាប់កម្ពុជាបានកំណត់ ។ អៀង សារី បានតវ៉ាថា គាត់គួរតែត្រូវទទួលបានការរួចផុតពីការកាត់ទោសបើយោងតាមគោលការណ៍អំពី «ការកាត់ទោសពីរដង» គឺកាត់ទោសកំបាំងមុខម្តងរួចទៅហើយពីបទប្រល័យពូជសាសន៍ដោយតុលាការក្នុងឆ្នាំ១៩៧៩ ។ អៀង សារី ក៏បានប្តឹងឧទ្ធរណ៍ប្រឆាំងនឹងការឃុំខ្លួនបណ្តោះអាសន្ន ដោយចង្អុលបង្ហាញដល់ការលើកលែងទោសនិងអនុគ្រោះទោស ដែលគាត់បានទទួលនៅពេលដែលផ្តាច់ខ្លួនចុះចូលជាមួយរដ្ឋាភិបាលនៅឆ្នាំ១៩៩៦ ។

អង្គបុរេជំនុំជម្រះបានបដិសេធលើគ្រប់បណ្តឹងឧទ្ធរណ៍ទាំងអស់របស់ជនត្រូវចោទ ។ អង្គបុរេជំនុំជម្រះបានពុះពារនឹងបញ្ហាផ្សេងៗទៀតជាច្រើន ។ បញ្ហាទាំងនោះរួមមានសិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងការចូលរួមក្នុងដំណើរការកាត់ទោស ទម្រង់នៃការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌ ដែលអាចទទួលយកបាន ព្រមទាំងវិសាលភាពនៃសិទ្ធិរបស់ជនជាប់ចោទក្នុងការទទួលបានការបកប្រែឯកសារនៅក្នុងសំណុំរឿង ។

## ការគ្រប់គ្រងស្ថាប័នតុលាការ

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាមិនមែនគ្រាន់តែជាកន្លែងកាត់ក្តីតែប៉ុណ្ណោះទេ ប៉ុន្តែវាជាស្ថាប័នមួយដែលមានលក្ខណៈការិយាធិបតេយ្យដ៏ស្មុគស្មាញដែលទទួលរងនូវការឃ្លាំមើល និងឥទ្ធិពលផ្នែកនយោបាយទៀតផង ។ បើគ្មានការគ្រប់គ្រងស្ថាប័ននេះឲ្យមានប្រសិទ្ធភាពទេនោះ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាមិនអាចអនុវត្តមុខងារខាងផ្លូវច្បាប់តាមអាណត្តិនិងផ្សព្វផ្សាយដល់សាធារណជនបានឡើយ ។ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាប្រឈមមុខនឹងការលំបាកជាច្រើនដែលគ្រប់តុលាការអន្តរជាតិនិងតុលាការកូនកាត់ផ្សេងៗទៀតបានជួបប្រទះដែរ គឺរបៀបនៃការបង្កើតឲ្យមានលក្ខណៈការិយាធិបតេយ្យយ៉ាងច្បាស់លាស់ពីសំណាក់ការទាក់ទងនឹងម្ចាស់ជំនួយដែលចង់បានតាមចិត្តខ្លួននិងស្មុគស្មាញដ៏ច្រើន ការប្រមូលផ្តុំបុគ្គលិកចម្រុះជាតិសាសន៍ ការគ្រប់គ្រង ភាសា និងសម្ភារៈដែលគួរឲ្យឈឺក្បាល ព្រមទាំងការជម្នះនឹងរឿងក្តីព្រហ្មទណ្ឌដ៏លំបាកថែមទៀតផង ។

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានសម្រេចលទ្ធផលបណ្តើរហើយ ក៏ប៉ុន្តែតុលាការនេះបានជួបប្រទះនឹងកិច្ចការលំបាកៗជាច្រើនទៀតទាក់ទិននឹងរដ្ឋបាល ។ ក្នុងចំណោមកិច្ចការលំបាកៗបំផុតទាំងនេះ គឺបញ្ហាពុករលួយដែលចោទមានឡើងនៅក្នុងតុលាការ ។ ក្នុងឆ្នាំ២០០៧ អធិការកិច្ចដែលធ្វើឡើងដោយកម្មវិធីអភិវឌ្ឍន៍របស់អង្គការសហប្រជាជាតិបានកត់សម្គាល់ថាមានការចោទប្រកាន់ទាក់ទិននឹងការកាត់លុយពីបុគ្គលិកសម្រាប់ជាថ្នូរនឹងការងារ ការអនុវត្ត ការជ្រើសរើសបុគ្គលិកមិនត្រឹមត្រូវ

តាមលក្ខខ័ណ្ឌ ព្រមទាំងការប្រព្រឹត្តអំពើមិនគប្បីផ្សេងៗទៀត ។ មានបុគ្គលិករបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាមួយចំនួនបានចេញមកបញ្ជាក់អះអាងអំពីបញ្ហាទាំងនោះ ។ ហេតុការណ៍បានបង្កឲ្យមានវិបត្តិយ៉ាងធ្ងន់ធ្ងរដូចជា ការទម្លាក់កំហុសគ្នាទៅវិញទៅមករវាងអង្គការសហប្រជាជាតិនិងរាជរដ្ឋាភិបាលកម្ពុជា ហើយនឹងការជំរុញឲ្យប្រទេសអ្នកផ្តល់ជំនួយផ្អាកការរួមវិភាគទានខាងផ្នែកហិរញ្ញវត្ថុជាដើម ។ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានចាត់វិធានការឆ្លើយតបមួយចំនួន ដោយចេញជាសេចក្តីណែនាំថ្មីៗ និងបង្កើតគណៈកម្មការប្រឆាំងអំពើពុករលួយថ្មីមួយ ។ ម្យ៉ាងវិញទៀត ការព្រួយបារម្ភអំពីអំពើពុករលួយនៅមិនទាន់រសាយនៅឡើយ ហើយវិធានការដែលចាត់ឡើងមកទល់សព្វថ្ងៃនេះពុំបានធ្វើឲ្យប្រទេសម្ចាស់ជំនួយនិងអ្នកសង្កេតការណ៍ពេញចិត្តឡើយ ។

ការព្រួយបារម្ភផ្សេងទៀតអំពីប្រតិបត្តិការរបស់តុលាការគឺទាក់ទងទៅនឹងពេលវេលា និងការចំណាយថវិកាសម្រាប់ដំណើរការទាំងមូល ។ តុលាការបានចាប់ផ្តើមតាមថវិកាដែលអនុម័តដំបូងចំនួន៥៦លានដុល្លារ ដែលមួយផ្នែកបានមកពីការរួមវិភាគទានរបស់សហគមន៍អន្តរជាតិ ។ ថវិកានេះសំដៅទុកចំណាយលើដំណើរសាលាក្តីទាំងមូលសម្រាប់រយៈពេល៣ឆ្នាំ ។ យ៉ាងណាមិញនៅដើមឆ្នាំ២០០៨ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានប៉ាន់ប្រមាណលើតម្រូវការថវិកាប្រមាណ១១៤លានដុល្លារបន្ថែមទៀត សម្រាប់បំពេញកិច្ចការរបស់ខ្លួនឲ្យចប់ចុងចប់ដើម ។ ប្រទេសម្ចាស់ជំនួយមិនរីករាយឡើយ ដោយសារតែមានការចោទឡើងពីបញ្ហាពុករលួយ ។ ដូច្នេះ តុលាការនេះបានកាត់បន្ថយនូវការស្នើថវិការបស់ខ្លួនឲ្យស្ថិតនៅក្នុងកម្រិតមួយសមរម្យ ហើយបានស្នើសុំថវិកាប្រមាណ៥០លានដុល្លារបន្ថែម ។ សព្វថ្ងៃនេះមានការប៉ាន់ប្រមាណថា ការជំនុំជម្រះទោសលើជនជាប់ចោទ៤នាក់ទៀតនឹងចាប់ផ្តើមដំណើរការនៅឆ្នាំ២០១០ ។ ប្រសិនបើអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាសម្រេចចោទប្រកាន់ជនជាប់ចោទបន្ថែមទៀត ការចំណាយនឹងត្រូវកើនឡើងជាមិនខាន ។ ប្រទេសម្ចាស់ជំនួយបានចាត់វិធានការដើម្បីបង្កើនថវិកា និងពិនិត្យមើលលើការចំណាយទាំងនោះ ក៏ប៉ុន្តែការជជែកលើបញ្ហាថវិកាទំនងជាអូសបន្លាយបន្តទៅទៀត ។

មតិរិះគន់មួយចំនួនលើកឡើងថា អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាកំពុងតែចំណាយខ្ជះខ្ជាយលើថវិកាទាំងនោះ ដែលគួរតែយកទៅប្រើប្រាស់ឲ្យមានប្រសិទ្ធភាពសម្រាប់គម្រោងអភិវឌ្ឍន៍សម្រាប់សេចក្តីត្រូវការរបស់កម្ពុជាវិញ ។ អ្នកគាំទ្រដំណើរការនេះឆ្លើយតបវិញថា ការចំណាយរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា គឺទាបជាងបើប្រៀបធៀបនឹងដំណើរការតុលាការអន្តរជាតិដូចជា តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី និងរ៉ាន់ដា ។ លើសពីនេះទៀត ថវិកាដែលផ្តល់ឲ្យតុលាការមិនគួរចាំបាច់ផ្តល់ជូនរហូតនោះឡើយ ។ មានការវាយតម្លៃលើការអះអាងទាំងឡាយ និងការវាស់ស្ទង់មើលពីវិធានការទាំងឡាយដែលម្ចាស់ជំនួយនិងអង្គជំនុំជម្រះប្រកាន់យក ដើម្បីលើកកម្ពស់ការគ្រប់គ្រងហិរញ្ញវត្ថុឲ្យបានល្អ ។

**ការផ្សព្វផ្សាយរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាឲ្យដល់ជនរងគ្រោះ**

ទិដ្ឋភាពសំខាន់ទីបីនៃកិច្ចប្រតិបត្តិការរបស់តុលាការ គឺការផ្សព្វផ្សាយឲ្យដល់ផ្ទះរបស់អ្នករស់រានមានជីវិតពីរបបកម្ពុជាប្រជាធិបតេយ្យ និងប្រជាជនសាមញ្ញផ្សេងៗទៀត ។ ប្រសិនបើតុលាការចង់ទទួលបានជោគជ័យ ចាំបាច់ត្រូវតែគិតថា ការចូលរួមរបស់ជនរងគ្រោះគឺសំខាន់ខ្លាំងណាស់ ។ ការជំនុំជម្រះទោសលើមេដឹកនាំខ្មែរក្រហមមិនមែនគ្រាន់តែជាការអនុវត្តច្បាប់ឲ្យតែបាននោះទេ គឺថែមទាំងតំណាងឲ្យកិច្ចខំប្រឹងប្រែងជួយដល់ប្រជាជនរាប់លាននាក់ឲ្យសះស្បើយ និងកែលម្អដល់មូលដ្ឋានគ្រឹះនៃយុត្តិធម៌និងសិទ្ធិមនុស្សនៅក្នុងសង្គមមួយដែលបញ្ហាទាំងនេះមិនត្រូវបានយកចិត្តទុកដាក់ខ្លាំងក្លា ។ អង្គជំនុំជម្រះអាចបំពេញបេសកកម្មទាំងអស់នេះបាន ដរាបណាប្រជាជនកម្ពុជាអាចតាមដាន យល់ដឹង និងចូលរួមយ៉ាងពេញលេញក្នុងដំណើរការរបស់តុលាការ ។

អង្គជំនុំជម្រះវិសាមញ្ញ គឺជាផ្នែកមួយនៃការវិវត្តន៍ទាក់ទិននឹងការចូលរួមរបស់ជនរងគ្រោះនៅក្នុងតុលាការអន្តរជាតិនិងតុលាការកូនកាត់ ។ ការទទួលបានសិទ្ធិចូលរួមរបស់ជនរងគ្រោះដែលមានកម្រិត ត្រូវបានសម្របសម្រួលឲ្យមានប្រសិទ្ធភាពនៅឯតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី

និងប្រទេសវ៉ាន់ដា ដែលផ្ទុយពីតុលាការពិសេសសម្រាប់ប្រទេសសេរ៉ាឡេអូន ដែលតុលាការនេះបានកែលម្អយ៉ាងខ្លាំងក្នុងការភ្ជាប់ទំនាក់ទំនងរវាងសហគមន៍ក្នុងស្រុកនិងដំណើរការជំនុំជម្រះ ។

អនុលោមតាមក្របខ័ណ្ឌការងារសម្រាប់ជនរងគ្រោះចូលរួមនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ជនរងគ្រោះអាចចូលរួមដោយផ្ទាល់ក្នុងដំណើរការសវនាការតាមរយៈការដាក់ពាក្យបណ្តឹងផ្លូវការ ធ្វើជាសាក្សី ឬចូលរួមក្នុងដំណើរការដើមបណ្តឹងរដ្ឋប្បវេណី ។ ជនរងគ្រោះក៏អាចចូលរួមតាមរយៈការប្រជុំរៀនសូត្រ ចូលរួមស្តាប់ដំណើរការរបស់តុលាការ និងវេទិកាពិភាក្សានៅតាមភូមិ ។ មានកិច្ចការលំបាកៗជាច្រើនដែលអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាត្រូវប្រឈមមុខក្នុងការឆ្លើយតបនឹងតម្រូវការរបស់ជនរងគ្រោះកម្ពុជារាប់លាននាក់ ។ កិច្ចការលំបាកទាំងនេះរួមមាន ភាពស្មុគស្មាញខាងផ្លូវច្បាប់ក្នុងការបញ្ចូលដើមបណ្តឹងរដ្ឋប្បវេណី ភាពលំបាកក្នុងការគ្រប់គ្រងពាក្យបណ្តឹងរបស់ជនរងគ្រោះ និងកិច្ចសម្របសម្រួលនឹងសកម្មភាពរបស់អង្គការក្រៅរដ្ឋាភិបាលដែលជាប់ពាក់ព័ន្ធ ព្រមទាំងតម្រូវការសម្រាប់ការផ្សព្វផ្សាយយ៉ាងរឹងមាំ និងសម្រាប់កម្មវិធីគាំពារសាក្សី ។

## តួនាទីដែលរំពឹងទុករបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាចំពោះយុត្តិធម៌និងការផ្សះផ្សា

ផ្នែកចុងក្រោយនៃអត្ថបទនេះពិភាក្សាពីរបៀបដែលអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាខិតខំប្រឹងប្រែងដើម្បីសម្រេចបាននូវវង្វាស់នៃយុត្តិធម៌និងការផ្សះផ្សានៅកម្ពុជា ។ ដូចដែលបានសង្កត់ធ្ងន់ខាងលើ តុលាការមិនមែនជាឱសថសម្រាប់ព្យាបាលរបួសដែលបង្កឡើងដោយអំពើសាហាវព្រៃផ្សៃរបស់ខ្មែរក្រហមទាំងស្រុងទេ ។ នេះគឺជាផ្នែកមួយនៃដំណើរការព្យាបាលដ៏ទូលំទូលាយដែលកើតមានទាំងនៅក្នុងសង្គមនិងបុគ្គល ។ ទាំងផ្នែកឯកជននិងសាធារណៈ ប្រជាជនកម្ពុជាបានស្វែងរកទម្រង់នៃការផ្សះផ្សាជាយូរណាស់មកហើយ មុនពេលដែលតុលាការនេះត្រូវបានបង្កើតឡើង ។ កិច្ចខំប្រឹងប្រែងទាំងនេះបានជួយដល់អ្នកនៅរស់រានមានជីវិត និងក្រុមគ្រួសាររបស់ខ្លួនឲ្យចាប់ផ្តើមកសាងនិងចូលរួមកែលម្អស្ថិរភាពសង្គមក្រោយពីមានជម្លោះប្រដាប់អាវុធដែលអូសបន្លាយអស់ជាច្រើនទសវត្សរ៍ ។

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាមានសក្តានុពលដើម្បីផ្តល់យុត្តិធម៌ដែលនឹងរួមចំណែកដល់ការផ្សះផ្សាយ៉ាងពិតប្រាកដ ។ ដើម្បីធ្វើដូច្នេះបាន អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានខិតខំប្រឹងប្រែងយ៉ាងខ្លាំងក្លាដើម្បីលើកកម្ពស់ដល់ការផ្សព្វផ្សាយជូនសាធារណជន ។ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ត្រូវតែផ្តោតលើតម្រូវការរបស់ប្រជាជនសាមញ្ញដូចដែលបានធ្វើយ៉ាងដាច់ខាតចំពោះដំណើរការច្បាប់យ៉ាងត្រឹមត្រូវ ។ នេះជាការចាំបាច់ដែលត្រូវស្នើសុំពីតុលាការដែលទទួលខុសត្រូវលើរឿងក្តីព្រហ្មទណ្ឌដែលមានភាពស្មុគស្មាញបែបនេះ ។ បើទោះបីជាអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដំណើរការរឿងក្តីប្រកបដោយភាពឥតខ្ចោះ ដោយចេញដីកាសម្រេចសមហេតុផលក៏ដោយ ក៏ភាពចន្លោះប្រហោងនឹងអាចមាន ប្រសិនបើសាធារណជនមិនអាចតាមដាន និងមិនយល់អំពីដំណើរការនេះ ។

តាមការពិត អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាមិនមែនធ្វើសកម្មភាពតែឯកឯងនោះទេ ហើយអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាក៏មិនមែនជាអង្គភាពមួយដែលទទួលខុសត្រូវក្នុងការផ្សព្វផ្សាយដល់សាធារណជនតែឯងដែរ ។ តុលាការនេះ គ្រាន់តែជាស្ថាប័នមួយឈានមុខគេក្នុងការដោះស្រាយលើបញ្ហានានាដែលភ្ជាក់ងាររដ្ឋាភិបាល អង្គការអន្តរជាតិ អង្គការក្រៅរដ្ឋាភិបាល ក្រុមសាសនា និងប្រជាជនសាមញ្ញចូលរួមដោះស្រាយ ។ តុលាការនេះទាក់ទាញឲ្យមានការចាប់អារម្មណ៍ទៅលើកេរដំណែលខ្មែរក្រហមផងដែរ ។ សាលារៀន អង្គការក្រៅរដ្ឋាភិបាល មណ្ឌលសុខភាព ព្រមទាំងអ្នកផ្តល់សេវាអប់រំនិងក្រុមប្រឹក្សាចាំបាច់ត្រូវតែចាប់យកឱកាសនេះដើម្បីដោះស្រាយនូវតម្រូវការរបស់សាធារណជនក្នុងការទទួលបានព័ត៌មានក្នុងប្រឹក្សានិងការពិភាក្សាជាដើម ។ យើងសម្គាល់ឃើញថាមានកិច្ចខិតខំប្រឹងប្រែងមួយចំនួនកំពុងធ្វើឡើង ព្រមទាំងការសង្កត់ធ្ងន់លើសារសំខាន់ចំពោះកិច្ចខិតខំប្រឹងប្រែងទាំងអស់គ្នាដើម្បីធ្វើឲ្យដំណើរការរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាឈានទៅរកភាពជោគជ័យនិងដើម្បីបន្តការកាត់សេចក្តីប្រកបដោយភាពមោះមុតជានិច្ចឆ្ពោះទៅរកយុត្តិធម៌ ការផ្សះផ្សា និងនីតិរដ្ឋ ។ **ចន ឆឈីអារី**

# ពិភពលោកនៅសែនឆ្ងាយ

**(តចប់)**

ខ្ញុំមានការស្អុតចិត្តនិងឈឺចាប់យ៉ាងខ្លាំង ដូចជាគេយកពូថៅមកកាប់លើក្បាល និងយកម្ទុលមកចាក់ដោតបេះដូងអីចឹង ។ ខ្ញុំខំអត់ធ្មត់លេបនូវការឈឺចាប់ទាំងនោះ ហើយក៏ខំដញ្ជូនកណ្តាប់ស្រូវដាក់រទេះដោយគិតក្នុងចិត្តថា គាត់ជាមនុស្សកាចសាហាវនិងឃោរឃៅបំផុត ព្រោះពេលគាត់មានឋានៈជាថ្នាក់ស្រុក គាត់ធ្លាប់បញ្ជាឲ្យសម្លាប់មនុស្សដោយគ្មានធម៌មេត្តាបន្តិចណាឡើយ ។ ជាធម្មតា អង្គការឲ្យរៀបជួរកណ្តាប់ខាងលើតែបួនជាន់ទេ ប៉ុន្តែគាត់ប្រាប់ឲ្យខ្ញុំរៀបដល់ទៅ៦ជាន់ ហើយចង់ឲ្យជាប់ទៀត ។ «បើអ្នកធ្វើប៉ុណ្ណឹងមិនកើត មិនបាច់រស់នៅលើទឹកដីកម្ពុជាទេ» ។ គាត់មិនត្រឹមតែប្រមាថខ្ញុំប៉ុណ្ណោះទេ ថែមទាំងប្រមាថទៅលើសិទ្ធិរស់រាននៅលើទឹកដីកម្ពុជាថែមទៀត ។ ខ្ញុំខំរៀបកណ្តាប់ឡើងទៅលើឲ្យបាន៦ជាន់ ដោយលួចញែកមែកស្រូវដាក់សង្កត់ពីលើគ្នាដើម្បីកុំឲ្យរជ្រុះ និងបោះខ្សែក្រវាត់ចុះឡើងទៅតាមក្បូនខ្នាតប្រទាក់គ្នា រួចរឹតគំនរកណ្តាប់ស្រូវឲ្យហាប់ណែនល្អ ។ ពេលឃើញខ្ញុំចងកណ្តាប់រួច គាត់ក៏ភ្ញាក់ខ្លួនព្រើត ដោយមិននឹកស្មានថា ខ្ញុំអាចធ្វើបានដូច្នេះសោះ រួចគាត់ក៏បានទៅអង្រួនកណ្តាប់នោះមើល ។ ដោយឃើញកណ្តាប់នោះជាប់ល្អ គាត់ក៏ឈប់ប្រមាថខ្ញុំទៀត ហើយខំប្រើសម្តីទន់ភ្លន់មកវិញថា «កាលពីមុនឯងមិនដែលចងកណ្តាប់នេះត្រូវទាល់តែសោះ រហូតធ្វើឲ្យ តាយ៉យ ដែលជាគណៈស្រុកជេរបន្ទោសរាល់លើក» ។ បន្ទាប់មក គាត់ក៏ព្យាយាមបំបោលគោយ៉ាងលឿនដើម្បីឲ្យកណ្តាប់ស្រូវរជ្រុះ ប៉ុន្តែកណ្តាប់នោះមិនជ្រុះទាល់តែសោះ ។

## វដ្តប្រហារភូមិភាគបូព៌ា

មកដល់ចុងខែមករា ឆ្នាំ១៩៧៨ នៅពេលព្រឹកមួយ ខ្ញុំបានប្រទះឃើញក្បួនទ័ពយ៉ាងច្រើនសន្ធឹកសន្ធាប់ ដើរបន្តកន្ទុយគ្នាជាជួរយ៉ាងវែង និងមានរបៀបរៀបរយ ធ្វើដំណើរពីទិសខាងជើងទៅទិសខាងត្បូង (ខាងចុងភូមិឆ្ពោះទៅខាងដើមភូមិ) ។ កងទ័ពទាំងនោះពាក់មួកប៉េរ៉េ រុំក្រមា ពាក់ស្បែកជើងកង់ឡាន និងមានឯកសណ្ឋានពណ៌ត្រីអ៊ី ប្រដាប់ដោយអាវុធអាកា៤៧គ្រប់ដៃ ដោយក្នុងកងទ័ព១០នាក់មានម្នាក់កាន់កាំភ្លើងបេ៤០មួយដើម ។ ចំណែកអ្នកដើរនៅខាងមុខគឺជាមេបញ្ជាការ និងនៅជួរកណ្តាលមានមេបញ្ជាការធំម្នាក់ជិះលើសេះ មានថង់យាមនិងក្រវាត់កាំភ្លើងខ្លី ហើយមានអង្គរក្សបួននាក់ការពារអមសងខាង ។ នៅពីក្រោយមេបញ្ជាការធំមានរទេះសេះពីរគ្រឿងដឹកកេសគ្រាប់និងកងទ័ពជាច្រើនរាប់រយនាក់ ។

បីថ្ងៃក្រោយមក ខ្ញុំក៏បានឮស្នូរផ្ទុះអាវុធនៅទិសខាងត្បូង ដោយគ្រាប់កាំភ្លើងនីមួយៗបាញ់រះតទល់គ្នាយ៉ាងច្បាស់ មានគ្រាប់បែកដៃនិងគ្រាប់កាំភ្លើងធំបេ៤០ផ្ទុះលាយមួយៗផង ។ ការប្រយុទ្ធគ្នានេះមានរយៈពេលជាច្រើនម៉ោងទើបស្ងាត់ទៅវិញ ។ បន្ទាប់ពីហេតុការណ៍នេះ ស្រាប់តែឮពាក្យចចាមអារ៉ាមរបស់អ្នកស្រុកថា ទ័ពមជ្ឈិមប្រយុទ្ធគ្នាជាមួយទ័ពស្រុក ។ ទំនងជាទ័ពមជ្ឈិមពិបាកបង្ក្រាបទ័ពស្រុកហើយ ឬមួយបើប្រឹងប្រយុទ្ធគ្នាតទៅទៀតអាចមានការខូចខាតធ្ងន់ធ្ងរ ទើបទ័ពមជ្ឈិមស្រែកអំពាវនាវដាក់មីក្រូសុំឲ្យទ័ពស្រុកទម្លាក់អាវុធព្រមចុះចាញ់ និងគោរពតាមទ័ពមជ្ឈិមបក្ស បើមិនដូច្នេះទេនឹងមានទ័ពរថក្រោះមកធ្វើអន្តរាគមន៍ជាមិនខាន ហើយទ័ពមជ្ឈិមសន្យាថានឹងមិនយកទោសពៃរ៍ដល់កងទ័ពណាមួយឡើយ ។ ចាប់តាំងពីពេលនោះមក ក៏លែងមានឮសំឡេងផ្ទុះអាវុធតទៅទៀត ហើយទ័ពមជ្ឈិមក៏ដើរវាតទីអំណាចនៅតំបន់ភាគខាងត្បូងដោយសុវត្ថិភាព និងគ្មានការប្រឆាំងតបតអ្វីឡើយ ។ ក្រោយពីលេចឮពាក្យចចាមអារ៉ាមថា ទ័ពមជ្ឈិមបានចាប់គណៈស្រុកមកកាត់ក្បាល រួចយកទៅដោតនៅបង្គោលរបងក៏កើតមានភាពក្រឡាប់ចាក់នៅក្នុងជួរបដិវត្តន៍ ។ ទន្ទឹមនឹងនោះដែរក៏លេចឮពាក្យចចាមអារ៉ាមស្ងាត់ៗថា លេខាបក្សភូមិភាគបូព៌ាម្នាក់ឈ្មោះ សោ ភឹម និងប្រពន្ធឈ្មោះ យាយការ៉ូ ដែលមានមាឌធំបានបើកឡានបួនទៅប្រាំគ្រឿងជាមួយអង្គរក្សរបស់គាត់ ឆ្ពោះទៅកាន់ទីក្រុងភ្នំពេញដើម្បីជួបមជ្ឈិមបក្ស ប៉ុន្តែត្រូវទ័ពមជ្ឈិមពទ្ធ័ស្ទាក់បាញ់សម្លាប់ចោលគ្មានសេសសល់សូម្បីតែម្នាក់នៅម្តុំជិតភូមិព្រែកពោធិ៍ ស្រុកស្រីសន្ធរ ខេត្តកំពង់ចាម ។ នេះអាចបញ្ជាក់

ថាមជ្ឈិមបក្សបានបដិសេធនិងធ្វើការបង្ក្រាបរដ្ឋអំណាចភូមិភាគបូព៌ាទាំងមូល ឬអាចហៅថាជារដ្ឋប្រហារភូមិភាគបូព៌ាតែម្តង ។ ដោយសារសភាពការណ៍ប្រែប្រួលរហ័សពេក ប្រជាជនបែរជាភ័យខ្លាចនិងមិនទុកចិត្តថាតើខាងណាជារដ្ឋអំណាចពិតប្រាកដដែលត្រូវគោរពនិងដើរតាម ហើយវង្វេងវង្វាន់មិនដឹងថាមកពីរឿងហេតុអ្វី ។ ដើម្បីធ្វើឲ្យសភាពការណ៍បានវិលត្រឡប់មករកសភាពដូចដើមវិញ មជ្ឈិមបក្សបានប្រើទទ្ធាកចក្របាចខិតប័ណ្ណទម្លាក់មកក្នុងភូមិឃុំនានាគ្រប់ទីកន្លែង ដើម្បីបំភ្លឺប្រជាជនអំពីសភាពការណ៍បដិវត្តន៍ ។ ព្រឹកមួយនៅម៉ោងប្រហែល៩ ខ្ញុំបានឮសំឡេងទទ្ធាកចក្រមួយគ្រឿងហោះលាន់ឮពេញមេឃឆ្លងកាត់ពីលើភូមិ ។ ខ្ញុំគិតថាវាជាប្រភេទយន្តហោះរបស់លោកសេរី ដែលមកបំផុសចលនាតស៊ូដើម្បីសេរីភាព ប៉ុន្តែដល់ពេលមើលទៅទង់ជាតិក្រោមឯណោះវិញ ឃើញទង់ជាតិពណ៌ក្រហម រូបប្រាសាទកំពូលបីពណ៌លឿង ទើបដឹងថាជាយន្តហោះមជ្ឈិមបក្សនៅភ្នំពេញ ។ ហោះក្រឡឹងបានមួយជុំ យន្តហោះនោះក៏បានទម្លាក់កម្ទេចខ្មៅតូចៗចេញតាមបង្អួចព្រោងព្រាត ពេលនោះដោយស្មានថាគេទម្លាក់គ្រាប់ ខ្ញុំក៏រត់គេចពួននៅក្រោមដើមឈើ ។ បន្តិចក្រោយមក អ្នកស្រុកបានស្រែកថាគេបាចសំបុត្រ ។ ដោយដឹងថាសំបុត្រធ្លាក់មកចំភូមិហើយ យន្តហោះនោះក៏ហោះបន្ទាបខ្លួនយ៉ាងទាបពីលើចុងឈើ ដែលមើលទៅធំខ្លាំងណាស់ និងមានសំឡេងខ្ទរខ្លាំងគួរឲ្យខ្លាច ជាហេតុធ្វើឲ្យក្មេងៗភ័យនាំគ្នាស្រែកយំនៅក្រោមផ្ទះ ។ បន្ទាប់មក យន្តហោះនោះក៏ហោះឆ្ពោះទៅភូមិឃុំដទៃទៀតដើម្បីបាចសំបុត្រឲ្យបានគ្រប់ទីកន្លែង រហូតដល់ជិតពេលថ្ងៃត្រង់ទើបហោះត្រឡប់ទៅវិញ ។ ពេលក្រដាសខិតប័ណ្ណធ្លាក់ដល់ដី មានតាម្នាក់បានរើសលួចយកឲ្យខ្ញុំមើល ទើបខ្ញុំដឹងថា មជ្ឈិមបក្សចង់ជម្រាបដល់ប្រជាជនទាំងអស់ដែលស្នេហាបដិវត្តន៍ឲ្យបានជ្រាបថា ឈ្មោះ សោ យ៉ាន ហៅ សោ ភឹម ដែលជាលេខាបក្សភូមិភាគបូព៌ាបានក្បត់នឹងអង្គការបដិវត្តន៍ ។ ដូច្នេះ មជ្ឈិមបក្សសូមធ្វើការបដិសេធឈប់ទទួលស្គាល់ឈ្មោះនេះចាប់ពីពេលនេះតទៅ ហើយអង្គការបានចាត់តាំងសមមិត្ត តាំង សេងហុង ជាលេខាបក្សភូមិភាគបូព៌ាថ្មី និងសូមឲ្យប្រជាជនយើងទទួលស្គាល់គាត់ និងចូលរួមចំណែកនៅក្នុងបដិវត្តន៍ខាងមជ្ឈិមបក្ស ។ អត្ថន័យនៅក្នុងសំបុត្រនោះគឺសំដៅផ្តួលមេដឹកនាំភូមិភាគ និងធ្វើឲ្យអំណាចថ្នាក់ក្រោមស្ងប់ចិត្ត រួចយល់ព្រមទម្លាក់អាវុធចុះ និងយល់ព្រមឲ្យមជ្ឈិមបក្សរៀបចំរដ្ឋអំណាចថ្មី ។ ក្រោយពីគណៈស្រុកត្រូវគេកាត់ក្បាល រដ្ឋអំណាចភូមិឃុំនាំគ្នាហេលហាលដូចជាពស់អត់ក្បាល ដោយសារគេផ្តាច់ខ្សែរយៈការងារ និងផែនការចាត់តាំងអស់រលីង ។ នៅខណៈនោះមេដឹកនាំទាំងឡាយមានការភ័យខ្លាចយ៉ាងខ្លាំង ព្រោះខ្លាចប្រជាជនធ្វើការសងសឹក ដូច្នេះហើយបានជាពេលទៅណាមកណា គេតែងលីខ្សែកង់ផ្លុងកដងវែងជាប់ខ្លួនជានិច្ច ដើម្បីការពារខ្លួននិងដើម្បីបញ្ជាក់ប្រាប់គេឯងថាគាត់ទៅកាប់ឆ្ការព្រៃ ។

## មិត្តចាស់បែកចិត្ត

ក្រោយមកទៀតទើបប្រជាជនដឹងថា ទ័ពមជ្ឈិមគឺជាទ័ពរបស់ភូមិភាគនិរតី ដែលអ្នកទាំងនោះមានអភ័យឯកសិទ្ធិពិសេសពីមជ្ឈិមបក្សដើម្បីដើរបង្ក្រាបរដ្ឋអំណាចគ្រប់គ្រងរបស់ភូមិភាគបូព៌ាទាំងមូល ។ អ្នកទាំងនោះដើរតាមដាន និងស្រាវជ្រាវរកក្បាលម៉ាស៊ីនដឹកនាំធំៗគ្រប់ជាន់ថ្នាក់ ចាប់តាំងពីថ្នាក់ភូមិភាគ ថ្នាក់តំបន់ និងថ្នាក់ស្រុកដែលជាដំណាក់កាលមេមាន់ចឹកសម្លាប់កូនខ្លួនឯង ព្រោះមជ្ឈិមបក្សលែងយោគយល់និងត្រាប្រណីដល់កូនចៅភូមិភាគបូព៌ាតទៅទៀតហើយ ។ ដោយសារតែអឺចឹងហើយ ទើបថ្នាក់ដឹកនាំធំៗត្រូវគេយកទៅសម្លាប់ចោល ចំណែកបុគ្គលិកនៅតាមក្រសួងមន្ទីរដែលស្ថិតនៅក្រោមឱវាទរបស់អង្គការត្រូវបានគេរំសាយឲ្យវិលត្រឡប់មកផ្ទះសម្បែងតាមមូលដ្ឋានរៀងៗខ្លួនវិញ ។

អាស្រ័យហេតុនេះហើយ ទើបជនបដិវត្តន៍ទាំងអស់ដែលធ្លាប់តែបម្រើអង្គការលើបានវិលត្រឡប់មកផ្ទះដើម្បីជួបជុំឪពុកម្តាយនិងក្រុមគ្រួសារខ្លួនវិញ ដែលធ្វើឲ្យសភាពការណ៍នៅក្នុងភូមិមានសភាពអ៊ូអរជាងមុន ។ ជនបដិវត្តន៍ទាំងអស់ដែលឥឡូវនេះហៅថាមន្ត្រីរាជការ គឺភាគច្រើនជាយុវវ័យដែលធ្លាប់បានបម្រើបដិវត្តន៍តាំងពីជំនាន់សង្គ្រាមមក ព្រោះពេលនោះគ្រប់ក្រុមគ្រួសារដែលមានកូនពេញវ័យត្រូវតែបញ្ជូនកូនរបស់ខ្លួនឲ្យចូលបម្រើកងទ័ពបដិវត្តន៍ ដោយខ្លះធ្វើជាយោធា ហើយខ្លះទៀតចូលជាបុគ្គលិកក្រសួងមន្ទីរ ។ ចាប់តាំងពីអ្នកទាំងនោះចាកចេញពីផ្ទះសម្បែងរបស់ខ្លួនមក ឪពុកម្តាយព្រមទាំងបងប្អូនទាំងអស់មិនបាន

ដឹងទេថាតើអ្នកទាំងនោះទៅរស់នៅកន្លែងណា ឬទៅធ្វើការនៅកន្លែងណា ហើយនៅជាមួយនរណាឡើយ ដោយអង្គការធ្វើការលាក់ការណ៍យ៉ាងសម្ងាត់បំផុត និងហាមមិនឲ្យប្រាប់សូម្បីតែឪពុកម្តាយបង្កើតរបស់ខ្លួន។ មិនតែប៉ុណ្ណោះ ឈ្មោះកំណើតរបស់អ្នកទាំងនោះក៏ត្រូវអង្គការប្តូរជាឈ្មោះបដិវត្តន៍ដែរ។ ដូច្នេះហើយទើបរាល់ការងារបដិវត្តន៍ និងរចនាសម្ព័ន្ធរបស់អ្នកដឹកនាំថ្នាក់លើទាំងអស់ ចាប់ពីថ្នាក់ស្រុកឡើងទៅ គឺមានលក្ខណៈអាថ៌កំបាំងរកស្មានមិនត្រូវ ព្រោះប្រជាជនមិនអាចដឹងនិងមិនអាចយល់ថាតើអង្គការមានសមាជិកប៉ុន្មានរូប មានរូបរាងមុខមាត់និងប្រវត្តិរូបពិតប្រាកដយ៉ាងដូចម្តេចទេ។ ជាងនេះទៅទៀត អង្គការលើក៏បានក្លាយទៅជាក្រុមមួយដ៏អាថ៌កំបាំង ប្រៀបដូចជាអាទិទេពឬបិសាចដែលមានតែព្រលឹងវិញ្ញាណ គ្មានរូបរាង ប៉ុន្តែមានអំណាចនិងអានុភាពដ៏អស្ចារ្យ អាចគ្រប់គ្រងនិងក្តោបក្តាប់លើប្រជាជនព្រមទាំងអាចក្តាប់សភាពការណ៍បានយ៉ាងណែននិងមានប្រសិទ្ធភាពជាទីបំផុត។ រចនាសម្ព័ន្ធគ្រប់គ្រងរបស់អង្គការដ៏អាថ៌កំបាំងនេះយើងអាចប្រៀបប្រដូចវាបានទៅនឹងរបៀបគ្រប់គ្រងរបស់ពួកភេរវករសម្រាប់ធ្វើភេរវកម្មវាយឆ្មក់ដូច្នេះដែរ ព្រោះអ្នកទាំងនោះមានចរិតកាចសាហាវ ឃោរឃៅ និងអាថ៌កំបាំង ហើយសម្លាប់មនុស្សគ្មានត្រាប្រណី ដែលជាមូលហេតុធ្វើឲ្យប្រជាជនយើងខ្លាចរអាចំពោះអង្គការលើទាំងអស់។ ដោយសារតែរដ្ឋប្រហាររបស់ភូមិភាគបូព៌ាធ្វើឲ្យអង្គការប្រចាំនៅតាមភូមិភាគបែកសំបុក ទើបធ្វើឲ្យប្រជាជនបានដឹងខ្លះៗពីមេដឹកនាំមួយចំនួនដូចជា សោ យ៉ាន់ ហៅ សោ ភឹម ជាលេខាភូមិភាគបូព៌ា សមមិត្ត ឈាន លេខាតំបន់២២ សមមិត្ត យ៉យ លេខាស្រុកជាដើម។

នៅកាលៈទេសៈនោះ បរិវារទាំងអស់របស់អង្គការត្រូវវិលត្រឡប់មកកាន់ការដ្ឋានរៀងៗខ្លួនវិញ ចំណែកមារបស់ខ្ញុំម្នាក់ដែលជាប្អូនខាងម្តាយខ្ញុំនិងជាជនបដិវត្តន៍តាំងពីឆ្នាំ១៩៧០មក ក៏បានវិលត្រឡប់មកផ្ទះវិញ ដោយមានទាំងប្រពន្ធនិងកូនតូចម្នាក់មកផង។ គាត់មានឋានៈជាប្រធានភ័ស្តុភារតំបន់២២ ហើយក៏ជាបុគ្គលិកពេទ្យប្រចាំតំបន់ដែរ។ សហករណ៍នៅពេលនោះស្ថិតនៅក្រោមការដឹកនាំរបស់សមមិត្តប្រធានឃុំចាស់ដដែល ដោយគាត់បានទទួលសមាជិកថ្មី ហើយចាត់ចែងឲ្យធ្វើការងារ និងហូបបបបរួមដូចជាប្រជាជនទូទៅដែរ ដោយម្នាក់ៗទន្ទឹងរង់ចាំពេលមជ្ឈិមបក្សចុះមករៀបចំរដ្ឋអំណាចថ្មី ទើបគេអាចចូលបម្រើការងារបានដូចមុន។ នៅពេលនោះ ដោយសារតែខ្ញុំមើលថែទាំគោមិនបានល្អរហូតគោចេះតែស្គមទៅៗ ទើបសមមិត្តប្រធាន «គ» ដកគោពីខ្ញុំយកទៅឲ្យកសិករដទៃមើលថែវិញ ហើយប្រគល់មេគោមួយយ៉ាងស្គមកំព្រឹងឃើញតែឆ្អឹងស្ទើរដើរមិនរួចឲ្យមកខ្ញុំមើលថែវិញ។ ក្មេងៗទាំងឡាយដែលជួបមុខខ្ញុំតែងតែនាំគ្នាសើច ព្រោះខ្ញុំធ្លាប់តែកាន់គោខ្លាំងៗល្បីៗ តែនៅពេលនេះបែរជាមកកាន់មេគោកញ្ចាស់ហើយស្គមទៅវិញ។ ប៉ុន្តែ ខ្ញុំគ្មានការខ្មាសអៀនអ្វីទាំងអស់ ព្រោះកាលដែលខ្ញុំអាចថែបំប៉នគោមិនឲ្យដួលស្លាប់បានគឺជាភារកិច្ចដ៏ថ្លៃថ្លាបំផុតហើយ។ ដោយសារតែមេគោកម្សត់មួយនេះមិនមានកម្លាំងចុះប្រាំងឆ្លងទៅត្រើយម្ខាងបាន ខ្ញុំក៏ដឹកវាទៅឲ្យស៊ីស្មៅនៅតាមភ្លឺស្រែខាងក្រោយភូមិ។

នៅទីនោះ ខ្ញុំមានការត្រេកអរណាស់ដែលបានជួបមិត្តចាស់ម្នាក់ជាជនបដិវត្តន៍ទើបរំសាយ។ បន្ទាប់មក ខ្ញុំបានដឹកគោឆៀងទៅក្បែរដើម្បីសួរសុខទុក្ខមិត្តចាស់ ប៉ុន្តែគេបែរជាធ្វើព្រងើយមិនស្គាល់ខ្ញុំ ដោយគ្រាន់តែសម្លឹងមើលមុខខ្ញុំបានបន្តិចក៏ងាកមុខបែរចេញភ្លាម ហើយមិនព្រមនិយាយរកខ្ញុំសូម្បីតែមួយម៉ាត់។ គ្រាន់តែឃើញអាកប្បកិរិយាមិត្តខ្ញុំបែបនេះភ្លាម ខ្ញុំមានអារម្មណ៍ស្រងាកចិត្តយ៉ាងក្រៃលែង ហើយយល់ថាប្រហែលជាខ្ញុំជាប្រជាជន១៧មេសា ជាវណ្ណៈថោកទាបដែលបដិវត្តន៍មិនចូលចិត្តហើយ ទើបវាធ្វើបែបនេះដាក់ខ្ញុំ។ ក្រោយពីគេធ្វើជាមិនស្គាល់ ខ្ញុំក៏ដឹកមេគោដ៏កម្សត់នេះដើរបង្ហួសទៅវិញ។ ដោយសារតែបដិវត្តន៍កុម្មុយនីស្តនេះហើយ ទើបធ្វើឲ្យជាតិខ្មែរទាំងមូលបែងចែកនិន្នាការនយោបាយ មនោគមន៍វិជ្ជា និងទស្សនវិជ្ជាយ៉ាងសាហាវបំផុត។ ប្រហែលជា១០ថ្ងៃក្រោយមក មាតូចដែលជាប្អូនប្រុសពៅរបស់ម្តាយខ្ញុំ មានអាយុ១៨ឆ្នាំ ចាប់ផ្តើមឈឺចុកពោះរលាកខ្នែងពោះវៀន។ ឈឺអស់រយៈពេលពីរថ្ងៃ ជីតានិងមាខ្ញុំក៏បានសុំច្បាប់ប្រធានសហករណ៍ដឹកមាតូចតាមទូកយកទៅមន្ទីរពេទ្យតំបន់។ លុះស្អែកឡើងពេលល្ងាច ខ្ញុំបានឃើញគាត់ដឹកអ្នកជំងឺត្រឡប់មកវិញ ដោយពុំបានព្យាបាលអ្វីទាំងអស់ ពីព្រោះពេលធ្វើរដ្ឋប្រហារ ពេទ្យធំៗត្រូវបានមជ្ឈិមបក្សចាប់យកទៅសម្លាប់ចោល ហើយមួយ

ចំនួនទៀតបានគេចខ្លួនបាត់អស់ ទើបធ្វើឲ្យមន្ទីរពេទ្យមានសភាពស្ងាត់ជ្រងំ ។ ដូច្នេះ អ្នកជំងឺដែលត្រូវធ្វើការវះកាត់បានត្រឹមតែអង្គុយមើលរហូតដល់មាខ្ញុំដាច់ខ្យល់ស្លាប់ ។

## មជ្ឈិមបក្សហៅថ្នាក់ដឹកនាំមូលដ្ឋានទៅរៀនសូត្រ

នៅខែមីនា ឆ្នាំ១៩៧៨ ទ័ពមជ្ឈិមបានចុះមកដល់ឃុំរបស់ខ្ញុំរយៈពេលបីថ្ងៃដើម្បីក្តាប់សភាពការណ៍ លុះក្តាប់ព័ត៌មានបានលម្អិតនិងច្បាស់លាស់ហើយ គេក៏ចាប់ផ្តើមបញ្ជាឲ្យអ្នកមូលដ្ឋានកោះហៅប្រជាជនទាំងអស់មកប្រជុំមីទ្ទីងដែលធ្វើឡើងនៅក្នុងបរិវេណវត្តមួយនៅចុងឃុំដែលគេធ្លាប់តែប្រជុំជារៀងរាល់លើក ។

អង្គប្រជុំលើកនេះមានលក្ខណៈពិសេសជាងលើកមុនៗ ព្រោះមានសមាជិកមជ្ឈិមបក្សជាអធិបតី និងសមាជិកចូលរួមច្រើនដូចជា កងចល័ត ប្រជាជនទាំងអស់, បុគ្គលិកក្រសួងមន្ទីរ និងថ្នាក់ដឹកនាំថ្នាក់មូលដ្ឋានចាប់ពីប្រធាន«ក», «ខ», «គ», «ឃ», «ង» ។ ដោយសារតែមានមនុស្សចូលរួមច្រើន មីទ្ទីងត្រូវធ្វើឡើងនៅមុខព្រះវិហារដែលមានដើមស្វាយពីរទៅបីដើមជាម្លប់ដើម្បីងាយស្រួលប្រជុំ ។ ចំណែកនៅខាងមុខអង្គប្រជុំវិញ មានរៀបចំគុកណៈអធិបតីមួយយ៉ាងវែងដែលមានសមាជិកមជ្ឈិមបក្សប្រហែល២០នាក់អង្គុយយ៉ាងត្រៀបត្រា និងស្លៀកពាក់ខោអាវពណ៌ខ្មៅមើលទៅដូចជាហ្វូងសត្វក្អែក ។ ចំណែកទាហានយោធាវិញស្លៀកពាក់ខោអាវគ្រីអ៊ី និងពាក់មួកប៉េរ៉េ ព្រមទាំងស្ពាយកាំភ្លើងគ្រប់ដៃឈរយាមបណ្តាក់គ្នាពទ្ធ័ជុំវិញនៅតាមដងផ្លូវនិងនៅខាងក្នុងព្រៃក្រោយវត្តជាហូរហែ ។ លុះដល់ពេលសមល្មមហើយ គណៈអធិបតីម្នាក់ដែលស្លៀកពាក់ខោអាវពណ៌ខ្មៅ និងមានសម្បុរខ្មៅបានឡើងនិយាយ ។ ក្រោយពីគោរពអង្គប្រជុំរួច គាត់បានលើកសរសើរពីមាគ៌ានយោបាយរបស់អង្គការ ដែលបានដឹកនាំនិងកសាងប្រទេសបានរីកចម្រើនលើគ្រប់វិស័យ ។ ម្យ៉ាងវិញទៀតអង្គការមជ្ឈិមបក្សតែងយកចិត្តទុកដាក់លើកតម្កើងជីវភាពនិងការហូបចុករបស់ប្រជាជនយើង ដោយជារៀងរាល់មួយត្រីមាសម្តង មជ្ឈិមបក្សតែងជួយឧបត្ថមតាមមូលដ្ឋានដូចជា ទឹកក្រូចទឹកដោះគោ ត្រីខកំប៉ុង និងមីជាដើម មិនដែលអាក់ខានឡើយ ។ ក្រោយមកទៀត គាត់ក៏បានសួរទៅអង្គប្រជុំទាំងមូលថាតើបងប្អូនធ្លាប់ឃើញរបស់អស់ទាំងនោះដែរឬទេ? រួចទាំងអស់គ្នាក៏ស្រែកថាមិនដែលឃើញទេ ។ ឆ្លៀតឱកាសនេះ វាក៏បានទម្លាក់កំហុសទាំងអស់ទៅលើមេដឹកនាំភូមិភាគបូព៌ាចាស់ថា មកពីអ្នកទាំងនោះមានគំនិតក្បត់ប្រឆាំងនឹងអង្គការមជ្ឈិមបក្សនិងមិនបានគិតគូរពីសុខទុក្ខរបស់ប្រជាជនយើង ទើបធ្វើឲ្យប្រជាជនយើងលំបាកវេទនា អត់បាយក្រហាយទឹកបែបនេះ ។ លើសពីនេះទៅទៀតអ្នកទាំងនោះបានលួចយកស្រូវជាច្រើនសន្ធឹកសន្ធាប់ទៅលាក់ទុកនៅក្នុងព្រៃដោយរួមមានទាំងគ្រាប់រំសេវផងដើម្បីធ្វើការបះបោរ



កងកុមារក្នុងរបបកម្ពុជាប្រជាធិបតេយ្យ

ប្រឆាំងនឹងអង្គការមជ្ឈិមបក្ស ដោយមិនឲ្យអង្គការដឹងខ្លួន ។ ចាប់ពីពេលនេះតទៅ អង្គការមជ្ឈិមបក្សនឹងរៀបចំមូលដ្ឋានសាជាថ្មីឡើងវិញ ដោយឲ្យប្រជាជនមានបាយហូបគ្រប់គ្រាន់ទាំងពេលព្រឹកនិងពេលល្ងាច ព្រមទាំងមានបន្ថែមហូបទៀតផង ដូច្នេះសូមបងប្អូនហូបឲ្យបានឆ្អែត បើមានការខ្វះខាតខាងមជ្ឈិមបក្សនឹងជួយឧបត្ថមបន្ថែម ។ ដោយសារតែអត់ឃ្លានជាយូរមកហើយ គ្រាន់តែឮពាក្យបែបនេះភ្លាមប្រជាជនទាំងអស់ស្រែកអរគ្រប់ៗគ្នា ហើយទះដៃដោយមិនដឹងខ្លួនពីព្រោះទាំងអស់គ្នាគិតថា ការលំបាកវេទនា

អត់ឃ្លានកន្ទួងមកពិតជាបណ្ដាលមកពីមេដឹកនាំភូមិភាគបូព៌ាក្បត់ ពិតប្រាកដមែន ។ ចំណែកខ្ញុំវិញបែរជាគិតឃើញថា ទឹកដោះគោ ត្រីខកំប៉ុង ទឹកក្រូច និងមីជាដើម សុទ្ធតែជាអាហាររបស់អ្នកមូលធននិយម និងសេរីនិយម ដូច្នេះការអួតអាងនេះអាចជាពាក្យបោកប្រាស់ ។

ចុងក្រោយមេឃោសនាទាំងនោះក៏បាននិយាយការពារថ្នាក់ដឹកនាំមូលដ្ឋានភូមិឃុំថា គាត់ទាំងអស់គ្នាគ្មានកំហុសអ្វីទេ



ព្រោះគាត់ធ្វើតាមតែបញ្ជារបស់ថ្នាក់លើប៉ុណ្ណោះ ។ ដូច្នេះ គាត់មានសិទ្ធិរស់នៅនិងធ្វើការងារជាបន្តទៀត ដោយហាមមិនឲ្យប៉ះពាល់គាត់សូម្បីតែមួយសរសៃសក់ ហើយចុងបញ្ចប់ គេក៏រំសាយអង្គប្រជុំហើយឲ្យប្រជាជនត្រឡប់ទៅផ្ទះវិញ ។ ចំណែក ថ្នាក់ដឹកនាំភូមិឃុំទាំងអស់ ដែលពីមុននាំគ្នាអង្គុយកើតទុក្ខឱនមុខក្រៀមក្រំ ពេលដែលឮថាមជ្ឈិមបក្សមិនយកទោសពៃរ៍នោះក៏នាំគ្នាងើបមុខឡើង រួចសើចសប្បាយរីករាយគ្រប់ៗគ្នា ។ ស្អែកពេលល្ងាច បន្ទាប់ពីហូបបាយល្ងាចរួច ទ័ពមជ្ឈិមដែលមានគ្នាបួននាក់បានមកហៅសមមិត្តប្រធានឃុំ ប្រធានភូមិ ប្រធានយុវវ័យ ប្រធាននារី និងប្រធាន «គ» ឲ្យទៅរៀនសូត្រ ។ ដោយគិតថា ក្រោយពីរៀនសូត្ររួចនឹងឲ្យកាន់ការងារនិងបន្តមុខតំណែងដដែល គាត់ទាំងអស់ក៏នាំគ្នាស្លៀកពាក់ស្អាតបាតចេញទៅតាមគេ ។ ទាំងអស់គ្នាត្រូវគេបណ្ដើរយកទៅបាត់អស់ ប៉ុន្តែនៅសល់ប្រធាន «គ» ម្នាក់ ព្រោះនៅពេលយប់ទើបគាត់ត្រឡប់មកពីស្រែ ។ ដោយមិនទាន់បានហូបបាយ ទាហានទាំងនោះមានការខឹងសម្បារយ៉ាងខ្លាំង ហើយក៏ប្រាប់គាត់ឲ្យទៅជាប្រញាប់ដោយមិនចាំបាច់ហូបបាយ ឬដូរខោអាវអ្វីទាំងអស់ ហើយថែមទាំងបន្ទោសថាយូរជាងគេ ដោយសារតែគាត់ម្នាក់ ។

លុះព្រឹកស្អែកឡើង ម៉ោងប្រហែលជា៩ព្រឹកពេលកំពុងអារខុសនៅមាត់ទន្លេ ខ្ញុំក៏ប្រទះឃើញទ័ពមជ្ឈិម២នាក់ដែលមានកាន់កាំភ្លើងគ្រប់ដៃ ដោយម្នាក់មានសម្បុរខ្មៅ និងម្នាក់ទៀតសម្បុរសដូចជាកូនចៅចិនបានដើរសំដៅទៅកាន់ផ្ទះរបស់សមមិត្តកម្មាភិបាលស្រុកម្នាក់ដែលគេបានរំសាយមកមូលដ្ឋានវិញ ។ ទាហានទាំងពីរនាក់នោះបានមកឈររេរានៅខាងក្រោមផ្ទះ ដោយម្នាក់ឡើងទៅមើលនៅលើផ្ទះ រួចប្រាប់ទៅកាន់អ្នកនៅក្នុងចង្ក្រានបាយថា «ឆាប់ទៅហៅសមមិត្តកម្មាភិបាលពីស្រែឲ្យទៅរៀនសូត្រ» ។ បន្តិចក្រោយមក មានក្មេងម្នាក់បានមកប្រាប់ថា មិន ឃើញគាត់ទេ ។ ទាហានទាំងនោះក៏បានផ្ដាំប្រាប់ទៅវិញថា «បើហៅតាមសម្រួលមិនព្រមទៅ ប្រយ័ត្នគេទៅចាប់ដល់កន្លែង ដោយគ្មាននរណាទទួលខុសត្រូវទេ» ។ ក្រោយពីឃើញកម្មាភិបាលម្នាក់នោះដើរមកផ្ទះទាំងប្រឡាក់ភក់ពេញខ្លួន គាត់ក៏ត្រូវបានបណ្ដើរឆ្ពោះទៅកាន់ក្បាលភូមិ ដោយទាហានទាំងនោះដើរតាមពីក្រោយចម្ងាយប្រហែល១០ម៉ែត្រ ។ ពេលនោះ ដៃគូអារខុសជាមួយខ្ញុំបានប្រាប់ថា កុំមើលគេឲ្យសោះ គិតតែពីអារខុសឲ្យសកម្មទៅ ។ ក្រោយពីគេបណ្ដើរគាត់ទៅហួសឆ្ងាយបន្តិចហើយ ខ្ញុំក៏ខំលួចសម្លឹងមើលពីក្រោយ ដោយក្ដីអាណិតចំពោះរូបគាត់ ព្រោះគិតថាប្រហែលជាគេយកគាត់ទៅសម្លាប់ចោលហើយ ។

រយៈពេល៥ថ្ងៃក្រោយមក ថ្នាក់ដឹកនាំទាំងអស់ដែលទ័ពមជ្ឈិមហៅទៅរៀនសូត្រក៏បាត់ដំណឹងរហូត ។ ដូច្នេះ ពាក្យថារៀនសូត្រគ្រាន់តែជាពាក្យបោកបញ្ឆោតប៉ុណ្ណោះដើម្បីយកអ្នក

ទាំងនោះទៅសម្លាប់ចោលតែម្តង ព្រោះគ្មាននរណាហ៊ានល្មើសនឹងបញ្ជារបស់ថ្នាក់លើឡើយ ។

## ឡើងធ្វើជាប្រធានក្រុមកុមារ

ទ័ពនិរតីមជ្ឈិមបានបោះទីតាំងកងទ័ព និងការិយាល័យចាត់ចែងការងារនៅក្នុងអតីតភូមិខ្ញុំ ដែលគ្មានប្រជាជនរស់នៅ ហើយម្យ៉ាងជាតំបន់ហាមឃាត់យ៉ាងតឹងរ៉ឹងផង ព្រោះនៅទីនោះមិនអនុញ្ញាតឲ្យប្រជាជនឆ្លងកាត់ទេ ។ ហើយទីនោះក៏ជាកន្លែងដែលគេយកថ្នាក់ដឹកនាំភូមិឃុំចាស់ៗគ្រប់កន្លែងទៅរៀនសូត្រផងដែរ ។ អស់រយៈពេល៥ថ្ងៃ ដែលនៅក្នុងភូមិខ្ញុំគ្មានប្រធានឃុំ ប្រធានភូមិ ប្រធាន គ ដឹកនាំប្តូរត្រួតត្រា ប៉ុន្តែប្រជាជននៅតែនាំគ្នាធ្វើការតាមមុខសញ្ញារៀងៗខ្លួនដដែលដោយនឹកក្នុងចិត្តថា គេដូរថ្នាក់ដឹកនាំមែន ប៉ុន្តែរបបគ្រប់គ្រងនៅតែអនុវត្តន៍របបសហករណ៍ហូបបាយរួមដដែល ។

រយៈពេល២ថ្ងៃក្រោយមកទៀត ទើបយើងឮដំណឹងថា គេរើសបានប្រធានឃុំ ប្រធានភូមិថ្មីហើយ ។ ប្រធានភូមិជាលោកគ្រូរបស់ខ្ញុំ ហើយគាត់ក៏ជាអតីតគ្រូបង្រៀននៅក្នុងសាលាបឋមសិក្សាបដិវត្តន៍នៅឆ្នាំ១៩៧០ដែរ ។ ចំណែកអនុប្រធានវិញ ជាគ្រូបង្រៀននៅសាលាបឋមសិក្សាបដិវត្តន៍ដែរ ហើយក៏ជាសមាជិកអចិន្ត្រៃយ៍នៃអតីតអ្នកកត់ត្រារបស់ប្រធានឃុំចាស់ម្នាក់ឈ្មោះសមមិត្ត ឆ្នាំង ។ មានព្រឹកមួយ ពេលខ្ញុំកំពុងអារខសនៅមាត់ទន្លេ ក៏បានឃើញលោកគ្រូខ្ញុំជិះកង់ទន្ទឹមគ្នាជាមួយអនុប្រធានរបស់គាត់ ហើយបានលើកដៃស្រែកប្រាប់ខ្ញុំថា គាត់បានឡើងធ្វើជាប្រធានភូមិហើយ ។ ខ្ញុំក៏ខំសើចចេញធ្មេញដើម្បីសម្តែងការអបអរសាទរចំពោះគាត់ ។ កាលដែលមជ្ឈិមបក្សជ្រើសរើសយកមេដឹកនាំភូមិឃុំថ្មីដូច្នេះ អាចបញ្ជាក់បានថាវាសនាមេដឹកនាំភូមិឃុំចាស់ៗពិតជាស្ថិតនៅក្នុងភាពងងឹតជាមិនខាន ។ ស្អែកបន្ទាប់ពីហូបបាយថ្ងៃត្រង់រួច ខ្ញុំបានដើរកាត់ក្បែរពំនូកចំបើងមួយ ក៏ស្រាប់តែឃើញគ្រូខ្ញុំម្នាក់កំពុងនាំទ័ពមជ្ឈិម២នាក់ជីកកំណាប់មួយនៅខាងក្រោមពំនូកចំបើងនោះ ។ ដោយចង់ដឹងពេក ខ្ញុំក៏ដើរទៅឈរមើលព្រោះគិតថាប្រហែលមានកាំភ្លើងហើយ ប៉ុន្តែក្រោយពីគាស់រួច គឺឃើញតែមានបញ្ជីស្ថិតិមួយបាច់ធំដែលគេរុំយ៉ាងជិតដោយក្រណាត់កៅស៊ូជាច្រើនជាន់ ការពារកុំឲ្យជ្រាបទឹក ។ រឿងសម្ងាត់បែបនេះ ពិតជាមជ្ឈិមបក្សឈ្លេចសួរចម្លើយពីសមមិត្តប្រធានឃុំចាស់ហើយ បានជាគេដឹងពីទីកន្លែងលាក់របស់យ៉ាងច្បាស់ដូច្នេះ ។ ក្រោយពីរើលាចេញបានបន្តិច ទើបដឹងថាជាបញ្ជីស្ថិតិពិតប្រាកដមែន រួចគ្រូខ្ញុំក៏រុំខ្ចប់វាទៅវិញ ។ ដោយសារក្រណាត់កៅស៊ូនៅខាងក្រៅប្រឡាក់ដីស្រមក គាត់ក៏បញ្ជាឲ្យខ្ញុំលើកបញ្ជីនោះទៅទុកនៅឯមន្ទីរឃុំ ។ ទៅដល់មន្ទីរឃុំភ្លាម សមមិត្ត ឆ្នាំង ដែលជាគណៈអចិន្ត្រៃយ៍ បានចេញមកទទួលយកបញ្ជីនោះពីខ្ញុំ រួចខ្ញុំក៏សុំលាគាត់ត្រឡប់មកទៅផ្ទះវិញ ព្រោះប្រញាប់យកគោទៅឃ្វាល ។ លុះស្អែកឡើង ស្រាប់តែបាត់ដំណឹងលោកគ្រូរបស់ខ្ញុំនិងអនុប្រធានរបស់គាត់ រហូតធ្វើឲ្យគ្រួសារគាត់និងអ្នកស្រុកមានការងឿងឆ្ងល់ ព្រោះខាងមជ្ឈិមបក្សមិនបានប្រាប់ដំណឹងអ្វីទាំងអស់ ហើយចំណែកអ្នកស្រុកវិញក៏មិនហ៊ានចូលទៅក្បែរមជ្ឈិមបក្សដែរ ។

ប៉ុន្តែរយៈពេល៥ថ្ងៃក្រោយមក ទើបមជ្ឈិមបក្សចាត់តាំងសមមិត្ត ឆ្នាំង ឲ្យមកធ្វើជាប្រធានភូមិថ្មី និងចាត់តាំងប្រធានឃុំថ្មីមួយដែលជាកសិករស្លូតបូតម្នាក់និងមានរាងចំណាស់បន្តិចមិនសូវចេះអក្សរមកធ្វើជំនួសកន្លែងមុន ។ ចាប់តាំងពីពេលនោះមកទើបអ្នកស្រុកសន្និដ្ឋានថា គ្រូរបស់ខ្ញុំត្រូវមជ្ឈិមបក្សចាប់យកទៅសម្លាប់ចោល ។ ដោយសារសមមិត្ត ឆ្នាំង ធ្លាប់ធ្វើជាអ្នកកត់ត្រានិងជាអតីតប្រធានឃុំចាស់ផង ដូច្នេះគាត់យល់កិច្ចការក្នុងភូមិឃុំបានច្រើន រួចគាត់ក៏ចាប់ផ្តើមរៀបចំរចនាសម្ព័ន្ធដឹកនាំមូលដ្ឋានថ្មីដែលដឹកនាំដោយរូបគាត់ផ្ទាល់តែម្តង ។ គាត់បានរៀបចំចាត់តាំងប្រធាន «ក» «ខ» «គ» សាជាថ្មីនៅតាមគ្រប់ក្រុមរោងបាយទាំងអស់ ដោយទាំងអស់គ្នាសុទ្ធតែគោរពកោតខ្លាចនិងអនុវត្តតាមការចង្អុលណែនាំរបស់សមមិត្ត ឆ្នាំង មិនឲ្យមានការទាស់ចិត្តបន្តិចណាឡើយ ។ ស្អែកបន្ទាប់មក ប្រធាន «គ» ដែលឡើងមកថ្មីនៅក្នុងក្រុមរោងបាយខ្ញុំបានប្រាប់ខ្ញុំថា ម៉ោង៤ល្ងាចនេះត្រូវទៅប្រជុំនៅមន្ទីរឃុំជាមួយសមមិត្ត ឆ្នាំង ។ នៅល្ងាចនោះ ខ្ញុំខំរូតរះដឹកគោឡើងតាំងពីថ្ងៃខុសសព្វមួយដង លុះពេលទៅដល់មន្ទីរឃុំ ក៏ឃើញសមមិត្ត ឆ្នាំង កំពុងបើកអង្គប្រជុំកុមារនៅទូទាំងភូមិដែលមានកុមារជាច្រើនអង្គុយយ៉ាងត្រៀបត្រា ។ សមមិត្ត ឆ្នាំង ប្រជុំកុមារទាំងអស់ក្នុងគោលបំណងរៀបចំរចនាសម្ព័ន្ធដឹកនាំថ្មីសម្រាប់កុមារ ដោយនៅ

ក្នុងនោះរួមមាន គ្រូបង្រៀនជាប្រធានក្រុមក្តាប់កុមារ ប្រធានក្តាប់រួម និងប្រធានកុមារទាំង៥ក្រុម ដែលមានឈ្មោះខ្ញុំជាប្រធានក្រុមកុមារទី៤ ។ ពេលខ្ញុំទៅដល់ គាត់បានប្រកាសឈ្មោះខ្ញុំម្តងទៀត និងបង្ហាញមុខខ្ញុំឲ្យកុមារទាំងអស់ស្គាល់ ។

ពេលនោះ កុមារទាំងអស់ខំសម្លឹងមើលមកខ្ញុំយ៉ាងរហ័ស ហើយទះដៃអបអរសាទរ ។ ចុងបញ្ចប់ គាត់បានមានមតិផ្តាំផ្ញើឲ្យកុមារទាំងអស់ខិតខំធ្វើការងារនិងគោរពតាមការដឹកនាំរបស់អង្គការ រួចក៏ប្រកាសរំសាយ ។ តែមួយពព្រិចភ្នែកសោះ ខ្ញុំក៏ក្លាយខ្លួនជាប្រធានក្រុមកុមារដោយមិនដឹងខ្លួន ។ ខ្ញុំគិតថា សមមិត្ត ឆ្នាំង ប្រាកដជាមើលមកខ្ញុំច្រឡំហើយ ពីព្រោះសមមិត្ត ឆ្នាំង ធ្លាប់ចូលបម្រើបដិវត្តន៍ជិតនាន់លោកគ្រូរបស់ខ្ញុំ ដូច្នេះគាត់ធ្លាប់ឃើញខ្ញុំរៀនជាមួយគ្រូរបស់ខ្ញុំ ប៉ុន្តែគាត់មិនបានដឹងទេថា ខ្ញុំទៅរៀនបន្តនៅទីក្រុងភ្នំពេញទេ ។ ក្រោយពីឃើញខ្ញុំលីបញ្ជីជាមួយលោកគ្រូរបស់ខ្ញុំ គាត់ក៏ចាប់អារម្មណ៍ខ្ញុំ ហើយចាត់តាំងខ្ញុំឲ្យឡើងធ្វើជាប្រធានក្រុមកុមារដោយគ្មានការសង្ស័យសូម្បីតែបន្តិច ។

ពេលត្រឡប់មកផ្ទះវិញ ខ្ញុំមានអារម្មណ៍ច្របូកច្របល់ អង្គុយក៏មិនសុខ ដេកក៏មិនស្រណុកព្រោះមិននឹកស្មានថា សមមិត្ត ឆ្នាំង បែរជាចាត់តាំងខ្ញុំឲ្យធ្វើជាប្រធានក្រុម ។ ប្រសិនបើមានឈ្មោះល្បីបែបនេះ អ្នកស្រុកប្រាកដជាចាប់អារម្មណ៍នឹងខ្ញុំគ្រប់ៗគ្នា ចំណែកអ្នកដែលស្គាល់ប្រវត្តិខ្ញុំនឹងអាចយកមកនិយាយប្រាប់មជ្ឈិមបក្សជាមិនខាន ។ ម្យ៉ាងវិញទៀត ការធ្វើជាថ្នាក់ដឹកនាំគេមិនអាចលាក់ប្រវត្តិរូបរបស់ខ្លួនពីអង្គការបានទេ ។ ខ្ញុំគិតថា ក្នុងកាលៈទេសៈបែបនេះ ខ្ញុំមិនគួរធ្វើជាដើមឈើខ្ពស់នោះទេ គឺខ្ញុំត្រូវតែធ្វើជាដើមឈើទាបៗបាំងភ្នែកគេឯងវិញ ទើបបានសុខសាន្តនិងមានជីវិតបន្តទៀត ។ ក្រោយពីគិតបានល្អិតល្អន់ហើយ ខ្ញុំក៏សម្រេចចិត្តថានឹងទៅកាន់មន្ទីរឃុំវិញដើម្បីប្រាប់បង ឆ្នាំង ថា ខ្ញុំជាប្រជាជន១៧ មេសាទេ ដូច្នេះសូមបងដកឈ្មោះខ្ញុំចេញពីប្រធានកុមារទៅ ដោយទុកឲ្យគេអ្នកថ្មីឡើងធ្វើជំនួសវិញ ខ្ញុំសូមតែធ្វើជាអ្នកអារខសធម្មតាបានហើយ ។ គ្រាន់តែខ្ញុំទៅដល់មន្ទីរឃុំភ្លាម បង ឆ្នាំង ក៏បានចាកចេញទៅដែរ រួចខ្ញុំក៏អង្គុយរង់ចាំគាត់រហូតដល់ម៉ោង៩ល្ងាច ទើបគេគោះជួងចេញធ្វើការ ។ ខ្ញុំក៏ត្រឡប់មកផ្ទះវិញសិន ដោយគិតក្នុងចិត្តថា ព្រឹកស្អែកត្រូវតែទៅសុំគាត់ឲ្យបាន កុំឲ្យមានឈ្មោះល្បីទាន់ ។ លុះដល់ស្អែកព្រឹកឡើង គេមិនទាន់ទាំងគោះជួងផង កុមារទាំងអស់បានមកដល់ក្រោមផ្ទះខ្ញុំយ៉ាងរញៀវខ្មៀវខ្វារ ហើយស្រែកហៅខ្ញុំឲ្យនាំពួកគេទៅដកកក់នៅឯបឹងខាងក្រោយភូមិសម្រាប់ធ្វើខ្សែរចងសំណាប ។ រាល់ទឹកមុខនិងកាយវិការរបស់កុមារទាំងនោះ ហាក់ដូចជាកញ្ច្រោលចង់ឲ្យខ្ញុំដឹកនាំគេ ជាហេតុធ្វើឲ្យខ្ញុំទន់ចិត្តចេញទៅបំពេញការងារទាំងមិនដឹងខ្លួន ។ ពេលនោះហើយដែលធ្វើឲ្យខ្ញុំខកខានមិនបានទៅសុំបង ឆ្នាំង ឲ្យលុបឈ្មោះចេញ ។ គ្រាន់តែទៅដល់បឹងនោះភ្លាម ខ្ញុំក៏ចាប់ផ្តើមរាប់ចំនួនកុមារទាំងអស់ រួចបែងចែកកុមារទាំងនោះជាក្រុមតូចៗ ដោយក្នុងមួយក្រុមៗមានគ្នា៥នាក់ឲ្យទទួលខុសត្រូវមើលគ្នាទៅវិញទៅមកក្រែងមានកុមារលង់ទឹក ព្រោះយើងមិនអាចក្តាប់កុមារទាំងអស់បានទេ ។ នៅពេលត្រឡប់ទៅផ្ទះវិញ ខ្ញុំក៏រាប់ចំនួនកុមារសាជាថ្មីដែរ ។ លុះដល់ពេលល្ងាច ខ្ញុំបានដឹកនាំកុមារទាំងអស់ឲ្យទៅឃ្វាលគោ ។ ដោយសារការងារខ្ញុំចេះតែប្រព្រឹត្តទៅបានយ៉ាងល្អប្រសើរ ធ្វើឲ្យខ្ញុំចេះតែទៅបំពេញការងារជាបន្តបន្ទាប់រៀងរាល់ថ្ងៃ ។ បីថ្ងៃក្រោយមក ស្រាប់តែមានក្មេងស្រីអាយុ៨ឆ្នាំម្នាក់បានដឹកមេគោចាស់មួយក្បាលយកមកប្រគល់ឲ្យខ្ញុំ ដោយនិយាយថា មជ្ឈិមបក្សបានហៅគ្រួសារនិងប្រពន្ធកូនអ្នកដឹកនាំចាស់ៗទាំងអស់ឲ្យទៅតាមប្តីដើម្បីរៀនសូត្រអស់ហើយ ។ ជាការពិត កម្មាភិបាលថ្នាក់មូលដ្ឋានទាំងនោះគឺសុទ្ធតែជាអ្នកខិតខំបម្រើបដិវត្តន៍ឲ្យចេញជាសង្គមសហករណ៍បាយរួម ប៉ុន្តែនៅទីបំផុតបែរជាត្រូវអង្គការទម្លាក់កំហុស រួចយកទៅសម្លាប់ចោលទាំងពូជ ។

នៅយប់មួយ ខ្ញុំបានគេងគិតពីរឿងមួយចំនួនរួចសួរខ្លួនឯងថាហេតុអ្វីបានជាបង ឆ្នាំង ចាត់តាំងខ្ញុំឲ្យធ្វើជាប្រធានក្រុមកុមារ? តើនេះជាគុណបុណ្យរបស់គ្រូខ្ញុំឬដែលគាត់បានប្រើខ្ញុំឲ្យលីបញ្ជីទៅមន្ទីរឃុំ ហើយធ្វើឲ្យបង ឆ្នាំង បានស្គាល់ខ្ញុំ? ប្រសិនបើលោកគ្រូរបស់ខ្ញុំមិនបាត់ខ្លួនទេនោះ ខ្ញុំក៏មិនបានធ្វើជាប្រធានក្រុមកុមារដែរ ព្រោះថាគ្រូរបស់ខ្ញុំគាត់បានស្គាល់ពីប្រវត្តិរបស់ខ្ញុំច្បាស់ណាស់គឺខ្ញុំជាប្រជាជន១៧មេសា ។ ខ្ញុំក៏ដឹងពីកំហុសរបស់ខ្លួនឯងដែរ មិនគួរណាឲ្យកុមារទាំងអស់នោះអូសទាញឲ្យធ្វើជាមេដឹកនាំក្រុមកុមារសោះ ។ តើនៅពេលខាងមុខខ្ញុំអាចឈរជើងបានយូរប៉ុន្មានទៅ បើសង្គមមនុស្សពោរពេញទៅដោយការចាក់រុកនិងញុះញង់

ឥតឈប់ឈរបែបនេះ ហើយម្យ៉ាងសង្គមបដិវត្តន៍គឺជាសង្គមអង្គការភ្នែកម្នាស់ ដូច្នេះខ្ញុំពិតជាមានអាយុមិនវែងទេ ។

លុះក្រោយមកទៀតទើបខ្ញុំដឹងថា អ្វីដែលខ្ញុំបានគិតពីមុនមកថាត្រឹមត្រូវបែរជាខុសទៅវិញ ព្រោះថាប្រសិនបើខ្ញុំសុំដកឈ្មោះពីសមមិត្ត ឆ្នាំង ដោយប្រាប់ថាខ្ញុំជាប្រជាជន១៧មេសា នោះខ្ញុំប្រាកដជាត្រូវគេបញ្ជូនឲ្យទៅរស់នៅជាមួយប្រជាជនជម្លៀសតាំងពីដំបូង ហើយប្រសិនបើខ្ញុំនៅតែធ្វើជាអ្នកអារខសធម្មតាដូចដើម ក៏ប្រធាន គ នៅតែរុញខ្ញុំឲ្យជម្លៀសចេញកាន់តែឆាប់ដែរ ព្រោះថាអ្នកស្រុកស្គាល់ខ្ញុំច្រើន ។ ប៉ុន្តែនៅពេលដែលខ្ញុំបានចូលទៅក្នុងជួរអ្នកដឹកនាំ ឋានៈរបស់ខ្ញុំបែរជាអាចបិទមាត់អ្នកដែលធ្លាប់ស្គាល់ខ្ញុំបានមួយភាគធំ ដែលទាំងអស់នេះយើងអាចនិយាយថាជាវាសនាដែលយើងមិនអាចមើលឃើញ ។

## ខ្លាចអង្គការដឹងថាជាប្រជាជន១៧មេសា

៥ថ្ងៃក្រោយពីយកគ្រួសារនិងប្រពន្ធកូនរបស់ថ្នាក់ដឹកនាំចាស់ៗយកទៅរៀនសូត្រ ទ័ពមជ្ឈិមក៏ចាប់ផ្តើមមានផែនការថ្មីមួយទៀត គឺឆែកឆេររកកម្លាំងប្រដាប់អាវុធក្រែងមានលាក់ខ្លួននៅក្នុងមូលដ្ឋាន ។ លើកនេះ ទ័ពមជ្ឈិមបានកោះហៅប្រជាជនដែលមានកម្លាំងពេញទាំងអស់ឲ្យទៅប្រជុំដែលជាធម្មតាគេតែងប្រជុំនៅពេលព្រឹក ដើម្បីពេលល្ងាចអាចយកគោទៅឃ្វាលបាន ប៉ុន្តែលើកនេះគេបែរជាប្រជុំនៅពេលល្ងាចទៅវិញ ។

នៅពេលប្រជុំ ប្រសិនបើមានកម្លាំងពេញណាមិនទៅចូលរួមប្រជុំ នោះនៅពេលដែលគេឆែកឆេររកឃើញ គេនឹងចោទថាជាខ្មាំង ។ នៅពេលកំពុងប្រជុំ កម្លាំងទ័ពមជ្ឈិមបានចាប់ផ្តើមពង្រាយគ្នាឆែកឆេរចាប់តាំងពីក្បាលភូមិមក ដោយមានមុខសញ្ញាខុសៗគ្នាជាច្រើនខ្សែ គឺខ្សែទីមួយឆែកឆេរក្នុងព្រៃមាត់ទន្លេ ខ្សែទីពីរដើរឆែកឆេរនៅខាងក្រោមនិងខាងលើផ្ទះ ខ្សែទីបីដើរនៅខាងក្រោយផ្ទះរុករកនៅតាមគុម្ពចេក ខ្សែទីបួនដើររុករកនៅក្រោយភូមិនិងមួយខ្សែទៀតដើររុករាននៅក្នុងព្រៃក្រោយបឹង ។ ធ្វើបែបនេះប្រសិនបើគេចាប់បាននរណាម្នាក់ ម្នាក់នោះប្រាកដជាត្រូវគេចាប់យកទៅសម្លាប់ចោលជាមិនខាន ប៉ុន្តែជាសំណាងល្អទ័ពមជ្ឈិមពុំបានឆែកឆេររកឃើញអ្វីទេ ។ នៅក្នុងអង្គប្រជុំ ទ័ពមជ្ឈិមក៏ឆ្លៀតឱកាសរកមើលមេដឹកនាំចាស់ៗក្រែងមាននៅសល់ ហើយហាក់ដូចជាចង់បញ្ចេញកាយវិការកាចសាហាវ ដោយបានផ្លោងគ្រាប់ជាច្រើននៅក្បែរកន្លែងប្រជុំ ។ លុះដល់ពេលល្ងាច ទើបគេអនុញ្ញាតឲ្យប្រជាជនត្រឡប់ទៅផ្ទះវិញ ។ ជីដូនខ្ញុំម្នាក់បានរៀបរាប់ប្រាប់ថា ទ័ពមជ្ឈិមបានមករើកកាយនៅក្នុងផ្ទះ ហើយបានឃើញវ៉ាលិសមួយធ្វើពីក្រណាត់អង្រឹងថ្មីចែស ក៏ចោទថាជារបស់កងទ័ព ហើយសួររកម្ចាស់ ប៉ុន្តែយាយខ្ញុំបានអង្វរគេថា ខ្ញុំគ្រាន់តែជាកងចល័តប៉ុណ្ណោះ ។ គេបន្តឆែកឆេរទៀតក៏រកឃើញអាវគេតារ៉ុងថ្មីចែស ពណ៌អាចម៍សេះ ដែលគេគិតថាពិតជារបស់កម្មាភិបាលហើយ ។ ជីដូនខ្ញុំក៏នៅតែអង្វរទ័ពទាំងនោះទៀត តែដោយសារនៅយូរទៅ ឃើញតែរបស់មិនឃើញម្ចាស់គេក៏ចុះពីលើផ្ទះដើម្បីទៅឆែកឆេរនៅកន្លែងផ្សេងទៀត ។ នេះជាវិធីឆែកឆេរគ្រង់ៗតែម្តង ដើម្បីរកមនុស្សដែលលាក់ខ្លួនមិនព្រមទៅប្រជុំដើម្បីក្របួច រួចចោទថាជាខ្មាំងតែម្តង ។

២ថ្ងៃក្រោយមក សមមិត្ត ឆ្នាំង បានរៀបចំគម្រោងប្រជុំជួរអ្នកដឹកនាំទាំងអស់ ដើម្បីធ្វើការបូកសរុបការងារ ប្រចាំថ្ងៃនៅរៀងរាល់ពេលព្រលប់នៅឯមន្ទីរឃុំ ។ នៅពេលនោះ សមមិត្តប្រធានគថ្មី ក៏បានហៅខ្ញុំឲ្យទៅចូលរួមប្រជុំដែរ ព្រោះគាត់រាប់អានជាមួយខ្ញុំណាស់ ហើយក៏ចាត់ទុកខ្ញុំថាជាសហការីធ្វើការងារដ៏ល្អរបស់គាត់ដែរ ដោយសារកាលគាត់នៅជាប្រជាជនធម្មតា ខ្ញុំធ្លាប់ទៅជួយជួសជុលផ្ទះរបស់គាត់ដែលលិចដោយទឹកភ្លៀង ។ នៅក្នុងអង្គប្រជុំនេះ សមមិត្ត ឆ្នាំង បានឲ្យប្រធានក្រុមទាំងអស់ឡើងរាយការណ៍ពីសកម្មភាពការងារប្រចាំថ្ងៃដោយរួមមានទាំងគុណសម្បត្តិនិងគុណវិបត្តិ ។ ចុងបញ្ចប់សមមិត្ត ឆ្នាំង ជាអ្នកអារកាត់និងដោះស្រាយបញ្ហាទាំងអស់ ដោយរួមទាំងការអនុវត្តផែនការថ្មីបន្ត ។ ចំណែកខាងការងារខ្ញុំវិញ គឺមិនទាន់ឲ្យបង្រៀនកុមារនៅឡើយទេ ពីព្រោះវាជាដំណាក់កាលសម្រុកដកស្ទូង ដូច្នេះតម្រូវឲ្យនាំកុមារទាំងអស់ទៅដកកក់សម្រាប់យកមកធ្វើខ្សែចងសំណាបឲ្យបានច្រើន ចំណែកពេលល្ងាចវិញ ត្រូវនាំគ្នាទៅឃ្វាលគោ ។ ដោយសារតែពេលវេលាចេះតែរំកិលទៅមុខ ថ្ងៃបុណ្យចូលឆ្នាំថ្មីគួបផ្សំនឹងថ្ងៃជ័យជម្នះ១៧មេសាផង មជ្ឈិមបក្សក៏មានគម្រោងជម្លៀសប្រជាជនមួយចំនួនឲ្យទៅរស់នៅតំបន់ភូមិភាគកណ្តាលវិញ ពីព្រោះនៅទីនោះសម្បូរស្រូវទុំបាក់កច្រើនដោយសារមិនមានមនុស្សច្រូត ។ រហូតដល់ថ្ងៃទី១៧ ខែមេសា ដែលជាថ្ងៃបុណ្យបង្ហើយ

សមមិត្តប្រធាន គ ថ្មី ក៏ប្រកាសឲ្យប្រជាជនដែលមានឈ្មោះបានដឹងខ្លួនជាមុន រួចត្រៀមខ្លួនចេញដំណើរទៅធ្វើការនៅភូមិភាគកណ្តាល ។ លុះស្អែកព្រឹកឡើង ប្រធាន«គ» ថ្មី បានដើរប្រាប់ប្រជាជននៅតាមផ្ទះនីមួយៗឲ្យរៀបចំខោអាវ ចំណែកខ្ញុំវិញបានគេចខ្លួនដោយដឹកនាំក្មេងៗទៅដកកក់នៅក្នុងបឹងក្រោយភូមិ ។ រហូតដល់ម៉ោងប្រហែលជា៨ព្រឹក ប្រធាន «គ» ថ្មី បានដើរដេញប្រជាជនជាច្រើនឲ្យចេញដំណើរដោយ នៅក្នុងនោះក៏មានជីតាខ្ញុំម្នាក់បានមកជូនដំណើរមាខ្ញុំដែរដែរ ប៉ុន្តែជូនបានត្រឹមតែខ្លោងទ្វារវត្តប៉ុណ្ណោះ ព្រោះគេមិនចង់ឲ្យមានការភាន់ច្រឡំរវាងអ្នកដែលត្រូវគេជម្លៀស និងអ្នកដែលត្រូវនៅ ។

នៅម៉ោង៩ព្រឹក ខ្ញុំបានត្រឡប់មកផ្ទះវិញ រួចក៏ចូលសម្ងំគេងនៅក្នុងផ្ទះរហូត ។ បន្តិចក្រោយមក សមមិត្តប្រធាន «គ» ថ្មី ក៏បានចូលមកហៅខ្ញុំឲ្យរៀបចំខោអាវទៅជាមួយគេដែរ ប៉ុន្តែម្តាយខ្ញុំបានដោះសារដោយក្រឡៃពាក្យ១៧មេសា មកជាពាក្យ៧៣វិញ ។ ដោយសមមិត្តនោះក្តាប់ប្រវត្តិរូបខ្ញុំមិនបានច្បាស់លាស់ គាត់ក៏វិលត្រឡប់ទៅវិញ ។ ខ្ញុំភ័យខ្លាំងណាស់ ក៏សម្ងំលាក់ខ្លួននៅលើផ្ទះរហូត ដោយមិនហ៊ានចុះមកក្រោមទេ រួចបន់ស្រន់សំពះនិងបួងសួងទៅដល់ព្រះអាទិទេព សូមឲ្យជួយការពាររូបខ្ញុំបានរួចផុតពីគ្រោះមួយនេះ ។ មួយសន្ទុះក្រោយមក សមមិត្តប្រធាន គ ក៏បានត្រឡប់មកវិញម្តងទៀត រួចបានប្រាប់ម្តាយខ្ញុំថា ឲ្យខ្ញុំរៀបចំខ្លួនចេញដំណើរទៅជាមួយគេ ព្រោះខ្ញុំជាប្រជាជន១៧មេសាទេ ប៉ុន្តែម្តាយខ្ញុំនៅតែប្រកែកថាមានការភាន់ច្រឡំថាខ្ញុំជាប្រជាជន១៧មេសា តាមពិតខ្ញុំជាប្រជាជន៧៣ទេ ។ ដោយសារតែមានការរាប់អានគ្នា គាត់ក៏លែងមានយោបល់រួចវិលត្រឡប់ទៅផ្ទះវិញទៅ ។ អស់រយៈពេលប្រហែលជាកន្លះម៉ោង ទើបខ្ញុំចុះពីលើផ្ទះដើរតម្រង់ទៅកាន់រោងបាយ ដើម្បីជួយដញ្ជូនចានឲ្យចុងភៅ ។ ដោយសារតែអ្នកនៅក្នុងរោងបាយស្គាល់ប្រវត្តិខ្ញុំច្បាស់ គេក៏បានសួរនាំខ្ញុំថា «ហេតុអ្វីបានជាខ្ញុំមិនទៅជាមួយគេ?» ខ្ញុំក៏ឆ្លើយថា «ខ្ញុំធ្វើការឲ្យអង្គការ ដូច្នេះគេមិនឲ្យខ្ញុំទៅទេ» ។ ក្រោយពីដញ្ជូនចានរួច ខ្ញុំក៏សុំគេដួសបាយឲ្យខ្ញុំមួយចានហូបខ្លួនឯង រួចក៏ចេញដំណើរទៅឃ្វាលគោជាមួយក្មេងៗ ។ លុះពេលល្ងាចឡើង ខ្ញុំមិនបានទៅចូលរួមប្រជុំទេ ដូច្នេះខ្ញុំមិនបានដឹងទេថា មានរឿងអ្វីកើតឡើងចំពោះរូបខ្ញុំ ។ ព្រឹកស្អែកឡើង ខ្ញុំក៏ដឹកនាំកុមារទាំងអស់ទៅធ្វើការដូចធម្មតា រួចពេលល្ងាចទើបទៅចូលរួមប្រជុំនៅឯមន្ទីរឃុំ ។ នៅពេលប្រជុំនោះ ខ្ញុំបានជួបជាមួយសមមិត្ត ប្រធាន គ ថ្មី ប៉ុន្តែជាសំណាងល្អគាត់មិនបានសួរនាំអ្វីបន្តទៀត ដោយគាត់ធ្វើដូចជាមិនដឹងមិនឮ ។ ក្រោយពីបានស្តាប់របាយការណ៍ជម្លៀសប្រជាជន១៧មេសា គ្រូបង្រៀនចាស់ និងអ្នកធ្វើការនៅក្នុងក្រសួងមន្ទីររួច គាត់ក៏បានសួរនាំពីកសិករម្នាក់ដែលស្ម័គ្រចិត្តចូលបម្រើទ័ព រួចគេក៏រាយការណ៍ថាបានបញ្ជូនទៅអស់ហើយ ។ ក្រោយមក សមមិត្តឆ្នាំង បានរៀបរាប់ថា នៅតាមការដ្ឋានកងចល័ត១៧មេសាទាំងអស់ មជ្ឈិមបក្សបានជម្លៀសទៅអស់ហើយ ដោយមិនមាននៅសេសសល់សូម្បីតែម្នាក់ ។ គ្រាន់តែឮសម្តីបែបនេះភ្លាម ខ្ញុំមានអារម្មណ៍ព្រឺក្បាលខ្លាក ហើយបារម្ភថាប្រសិនបើសមមិត្តប្រធានថ្មីនិយាយពីឈ្មោះខ្ញុំនោះ ខ្ញុំប្រាកដជាចប់ហើយ ប៉ុន្តែប្រហែលជាគាត់គិតថា ទុកឲ្យបង ឆ្នាំង ជាអ្នកសម្រេចហើយ ព្រោះគាត់ជាមនុស្សវៃឆ្លាត និងដឹងនូវរាល់កិច្ចការទាំងអស់ តែតាមពិតទៅគាត់មិនដឹងរឿងថាខ្ញុំជាប្រជាជន១៧មេសាទេ ។ អារម្មណ៍ខ្ញុំពេលនោះប្រៀបដូចជាកូនចៀមពាក់ស្បែកខ្លាទៅចូលរួមប្រជុំជាមួយហ្វូងខ្លា ហ៊ានតែនរណាបង្អើបតែបន្តិច ខ្ញុំប្រាកដជាចប់ហើយ ។ ហេតុនេះហើយ គ្រាន់តែអង្គប្រជុំចប់សព្វគ្រប់ភ្លាម ខ្ញុំក៏ឆាប់រូតរះត្រឡប់ទៅផ្ទះវិញដែរ ។

## បូកស្ថិតិប្រជាជន

ដោយសារតែប្រជាជននាំគ្នាគិតថា អង្គការមជ្ឈិមបក្សជាអង្គការមហាឈ្លាសវៃ មហាភ្លឺស្វាង មហាអស្ចារ្យ ទើបប្រជាជនគ្រប់ៗគ្នាយល់ថា ការជម្លៀសប្រជាជន១៧មេសា និងអ្នកដែលធ្លាប់ធ្វើការនៅតាមក្រសួងមន្ទីរដែលនៅសេសសល់ឲ្យទៅរស់នៅភូមិភាគកណ្តាល ដែលសម្បូរទៅដោយស្រូវទុំបាក់ករកមនុស្សច្រូតមិនបាននោះ ពិតជាគិតគូរបានល្អិតល្អន់ណាស់ ។ ប្រសិនបើមជ្ឈិមបក្សមានគំនិតអាក្រក់ចង់សម្លាប់មនុស្សទាំងនោះគឺមិនអាចធ្វើទៅបានទេ ព្រោះមនុស្សមានចំនួនច្រើនរាប់រយនាក់ ដូច្នេះបើមានហេតុការណ៍ណាមិនស្រួល ទាំងអស់គ្នាប្រាកដជានាំគ្នាបះបោរប្រឆាំងជាមិនខាន ។

រយៈពេលបីថ្ងៃកន្លងផុតទៅ ប្រជាជននាំគ្នាសង្ស័យព្រោះ

បានឮដំណឹងជាសម្ងាត់ថា ទ័ពមជ្ឈិមបានសម្លាប់ប្រជាជនដែលជម្លៀសទៅទាំងអស់ដោយឲ្យមនុស្សទាំងនោះអង្គុយរង់ចាំនៅក្នុងទីធ្លាវត្តដែលមានយោធាកាន់កាំភ្លើងយាមហ៊ុមព័ទ្ធជុំវិញយ៉ាងតឹងរ៉ឹងបំផុត ហើយចាក់មីក្រូយ៉ាងទ្រហឹងរកស្តាប់អ្វីមិនឮ បន្ទាប់មកហៅមនុស្សមួយក្រុមតូចៗចេញតាមច្រកមួយ ។ ពេលទៅដល់ទីឆ្ងាយដាច់ហ្វូងចូលភូមិខ្ញុំ ដែលជាកន្លែងស្ងាត់ហើយ យោធាជាច្រើននាក់បានភ្ជង់កាំភ្លើងរួចចងប្រជាជនទាំងនោះយកទៅសម្លាប់ចោលភ្លាមៗតែម្តង ។ ចំណែកមនុស្សជាច្រើនដែលនៅចាំនៅឯវត្តត្រូវចាក់មីក្រូបន្ទប់ដើម្បីកុំឲ្យដឹងរឿង អ៊ីចឹងហើយបានជាម្នាក់ៗបន់ឲ្យតែគេហៅឈ្មោះខ្លួនឲ្យបានមុននឹងឆាប់បានឡើងលើរថយន្ត ។ ទ័ពមជ្ឈិមធ្វើរបៀបនេះរហូតទាល់តែអស់មនុស្សដោយគ្មាននរណាម្នាក់បានដឹងរឿងនេះសូម្បីតែបន្តិច រួចគេយាមល្បាតដោយមិនឲ្យមានអ្នកនរណាលាក់ខ្លួនឬអាចមានជីវិតដោយលួចរត់ចេញពីបរិវេណនេះបានជាដាច់ខាត ។ អ្នកដែលរៀបចំគម្រោងសម្លាប់នេះពិតជាមានយុទ្ធសាស្ត្រនិងយុទ្ធវិធីជាក់លាក់និងល្អិតល្អន់ខ្លាំងណាស់ ព្រោះគម្រោងការនេះគ្មានប្រជាជនណាម្នាក់បានដឹងខ្លួនថាត្រូវគេយកទៅសម្លាប់សោះឡើយ ហើយក៏គ្មានប្រជាជនណាម្នាក់ស្រែកឆោឡោនិងបង្កភាពច្របូកច្របល់ដែរ ។ ពេលនេះហើយទើបប្រជាជនបានដឹងខ្លួនថា ទ័ពមជ្ឈិមជាមនុស្សអាក្រក់ ព្រោះគេបានសងគុណប្រជាជនយើងដោយអំពើអមនុស្សធម៌និងឈឺចាប់បំផុត ។ ចំណែកខ្ញុំគិតថា របបសង្គមនេះបង្កើតឡើងគឺដើម្បីងាយស្រួលក្នុងការសម្លាប់មនុស្សឲ្យបានច្រើន ហើយអ្នកដែលរៀបចំគម្រោងការនេះគឺជាអង្គការមហាលោតផ្លោះ មហាអស្ចារ្យ ហើយប្រាកដជានៅមានបន្តទៀត គឺសម្លាប់មិនឲ្យរកភ័ស្តុតាងឃើញ ។ ក្រោយពីសម្លាប់ប្រជាជនដែលជម្លៀសចេញរួចរាល់ហើយ ប្រជាជននៅក្នុងសហករណ៍នាំគ្នាធ្វើការងារតាមមុខសញ្ញារៀងៗខ្លួនដដែល ។

ចំណែកខ្ញុំក៏នៅតែដឹកនាំកុមារដូចដើមដោយរក្សាទឹកមុខរឹងមាំ តាំងចិត្តក្លាហានដើម្បីកុំឲ្យក្មេងៗចាប់អារម្មណ៍ដឹងពីប្រវត្តិរបស់ខ្ញុំ ។ រាល់ការប្រជុំនៅពេលល្ងាច ខ្ញុំនៅតែមិនហ៊ាននិយាយអ្វីច្រើនទេ ម្យ៉ាងទៀតខ្ញុំត្រូវទៅអង្គុយនៅជិតសមមិត្ត ឆ្នាំង ដើម្បីឲ្យអ្នកដទៃយល់ថា ខ្ញុំជាមនុស្សជិតស្និទ្ធជាមួយគាត់ ហើយសមមិត្ត ឆ្នាំង ក៏ជាសហការីជិតស្និទ្ធរបស់អង្គការដែរ ដូច្នេះប្រសិនបើគាត់រាយការណ៍ប្រាប់មជ្ឈិមបក្សអំពីរឿងខ្ញុំ នោះគេនឹងចុះមកចាត់ការភ្លាម ។ តើខ្ញុំអាចលាក់បាំងរឿងនេះដល់ពេលណា? ខ្ញុំជឿថា មិនយូរប៉ុន្មានទេសមមិត្ត ឆ្នាំង ប្រាកដជាដឹងរឿងមិនខាន ។

អស់រយៈពេលប្រហែលជាងកន្លះខែ ចូលដល់ខែឧសភា ពេលប្រជុំបូកសរុបការងារនៅល្ងាចមួយ ប្រធានក្រុមទីបីបានលើកឡើងថា មាននៅសល់គ្រូបង្រៀនចាស់ម្នាក់ រួចសមមិត្ត ឆ្នាំង ក៏កត់ឈ្មោះទុក ។ ស្អែកឡើងពេលថ្ងៃទ័ពមជ្ឈិមបីនាក់បានទៅដល់លើផ្ទះលោកគ្រូនោះ រួចឲ្យគាត់រៀបចំខោអាវចេញដំណើរទៅជាមួយគេ ចំណែកប្រពន្ធកូនវិញ ចង់ទៅក៏បានមិនចង់ទៅក៏បាន ។ ប្រពន្ធគាត់ចង់ទៅតាមប្តីដែរ ប៉ុន្តែគាត់គិតថា ប្រសិនបើគាត់ទៅតាម គាត់រួមទាំងកូនប្រាកដជាស្លាប់ទាំងអស់គ្នាជាមិនខាន ដូច្នេះគាត់ក៏សម្រេចចិត្តមិនទៅ ។ ចំណែកលោកគ្រូម្នាក់នោះវិញ នៅពេលដែលដឹងថាគេហៅយកទៅសម្លាប់ គាត់ក៏អស់វិញ្ញាណពីខ្លួនរលីង រហូតមិនអាចដើរទៅណារួច ។ តាមពិតទៅ គាត់ជាកសិកររស់នៅក្នុងតំបន់រំដោះតាំងពីដើមមក គ្រាន់តែគាត់ខិតខំរៀនសូត្រច្រើនជាងគេរហូតបានក្លាយខ្លួនជាគ្រូបង្រៀនប៉ុណ្ណោះ ប៉ុន្តែបែរជាត្រូវអង្គការចាត់ទុកថាជាខ្មាំងទៅវិញ ។

ហេតុនេះហើយ នៅពេលទៅប្រជុំម្តងៗ ខ្ញុំតែងតែភ័យខ្លាចក្រែងមានគេរាយការណ៍ថា មាននៅសល់ម្នាក់ទៀតគឺខ្ញុំដែលជាប្រជាជន១៧មេសា ។ នៅរដូវទឹកឡើង ក្មេងៗមិនអាចយកគោទៅចងនៅលើវាលស្រែបានទេ ទើបនាំគ្នាយកគោទៅចងចោលនៅក្រោមដើមឈើខាងក្រោយផ្ទះ រួចខ្ញុំក៏បានរាយការណ៍ប្រាប់សមមិត្តប្រធានថ្មីឲ្យស្នើសុំទូកធំមួយដើម្បីក្មេងៗអាចជិះទៅបោចស្មៅឲ្យគោស៊ី ។ រាល់ព្រឹក ខ្ញុំតែងនាំក្មេងធំៗឡើងទូកទៅបោះបង្គោលកណ្តាលទឹកត្រឹមចង្កេះ រួចឲ្យក្មេងៗចុះទៅបោចស្មៅក្នុងទឹកយកមកឲ្យគោស៊ីប្រសើរជាងឲ្យគោស៊ីចំបើង ។ ពេលកំពុងបោចស្មៅ ស្រាប់តែមានក្មេងស្រីចម្លែកម្នាក់អាយុប្រហែល១៤ឆ្នាំជាកូនរបស់សមមិត្តម្នាក់ដែលធ្លាប់ធ្វើជាសមាជិកគណៈស្រុក ហើយត្រូវទ័ពមជ្ឈិមយកទៅរៀនសូត្រលេចមុខឡើង ហើយមកសុំខ្ញុំទៅបោចស្មៅជាមួយក្មេងឯទៀតនៅក្នុងក្រុម ។

ដោយសារតែក្មេងនោះបានលាក់ខ្លួនយូរថ្ងៃមកហើយ ខ្ញុំគិតថាក្មេងនេះគ្មានកំហុសអ្វីជាមួយបដិវត្តន៍ទេ ខ្ញុំក៏អនុញ្ញាត ។ ប៉ុន្តែ ស្អែកឡើងក្រោយពីសមមិត្តប្រធាន «ខ» ដឹងរឿងនេះ គាត់បានប្រាប់ខ្ញុំមិនឲ្យយកក្មេងនោះទៅជាមួយទេ បើខ្ញុំនៅចចេសទៀត ខ្ញុំប្រាកដជាមានទោសមិនខាន ។

ព្រុដូច្នេះក្មេងស្រីនោះក៏សម្ងំលាក់ខ្លួននៅលើផ្ទះរហូតមិនហ៊ានចេញទៅក្រៅទេ ។ ពេលចេញទៅប្រជុំ ខ្ញុំភ័យណាស់ខ្លាចគេលើករឿងដែលខ្ញុំយកក្មេងចម្លែកចូលក្នុងក្រុម ហើយមិនរាយការណ៍ប្រាប់អង្គការ ប៉ុន្តែអង្គប្រជុំមិនបានលើកឡើងពីរឿងនេះទេ គិតតែពីរឿងដកស្ទូងនិងធ្វើស្រែទៅតាមមុខសញ្ញារៀងខ្លួនៗប៉ុណ្ណោះ ។ មួយសប្តាហ៍ក្រោយមក សមមិត្តប្រធាន «ខ» បានមកស្រែកប្រាប់ខ្ញុំថា ល្ងាចនេះមិនបាច់ទៅឃ្វាលគោទេ ព្រោះសមមិត្តប្រធានភូមិហៅឲ្យខ្ញុំទៅមន្ទីរឃុំនៅវេលាម៉ោងពីររសៀលនេះ ។ ម្តាយខ្ញុំព្រួបែបនេះគាត់ភ័យជាខ្លាំង ព្រោះគិតថាប្រហែលជាគេហៅទៅឲ្យទ័ពមជ្ឈិមចាប់ខ្លួនហើយ ។ ប៉ុន្តែខ្ញុំបែរជាដើរទៅកាន់មន្ទីរឃុំដោយគ្មានអារម្មណ៍ភ័យព្រួយអ្វីទាំងអស់ ព្រោះសមមិត្តប្រធានភូមិទើបតែឡើងមកថ្មីធ្លាប់រាប់អានជិតស្និទ្ធជាមួយខ្ញុំដែរ ។ នៅពេលទៅដល់ខ្ញុំមិនឃើញគាត់ទេ ឃើញតែទាហានមជ្ឈិម៤នាក់ស្ពាយកាំភ្លើងឈររេរានៅទីនោះ ក្រោយមកទើបឃើញសមមិត្តប្រធានភូមិមកដល់ហើយប្រាប់ខ្ញុំថា ទៅជួយបូករបាយការណ៍ស្ថិតិជាមួយគាត់ ។ ពេលគាត់កំពុងឈររេរាមានប្រជាជនម្នាក់បានមកកេះគាត់ឲ្យចេញឆ្ងាយពីខ្ញុំបន្តិចហើយខ្សឹបព្រុៗថា «វាជាប្រជាជន១៧មេសាទេ ទុកវាធ្វើអី? ហេតុអ្វីមិនឲ្យគេចាប់យកទៅសម្លាប់?» ខ្ញុំគិតថា ជីវិតខ្ញុំចប់ហើយ ប៉ុន្តែសមមិត្តប្រធានភូមិបែរជានៅស្ងៀម ព្រោះគាត់ក៏មានវិប្បដិសារីដែលបានបញ្ជូនប្អូនរបស់គាត់ដែលធ្លាប់ធ្វើការនៅក្នុងក្រសួងមន្ទីរឲ្យទៅទ័ពមជ្ឈិមសម្លាប់ ។ ម្យ៉ាងវិញទៀត អំណាចក្នុងការសម្លាប់មនុស្សគឺស្ថិតនៅលើកណ្តាប់ដៃសមមិត្ត ឆ្នាំង ជាអ្នកសម្រេច ដូច្នេះប្រសិនបើកសិករនោះរាយការណ៍ទៅគាត់ នោះខ្ញុំប្រាកដជាស្លាប់ហើយ ។ បន្ទាប់មក ស្រាប់តែមានទ័ពមជ្ឈិមម្នាក់ឡើងជណ្តើរតម្រង់មករកខ្ញុំ ធ្វើឲ្យខ្ញុំបារម្ភជាខ្លាំង ព្រោះគិតថាប្រហែលជាកសិករនោះទៅរាយការណ៍ឲ្យគេមកចាប់ខ្លួនខ្ញុំហើយ ។ ពេលកំពុងអន្ទះអន្ទែងនោះ ... 

ពេលកំពុងអន្តុយនៅកន្លែងសមមិត្ត ឆ្នាំង ធ្វើការ ទ័ពមជ្ឈិមម្នាក់នោះបេះតែសម្លឹងមកខ្ញុំដោយកែវភ្នែកយ៉ាងមុតរហូត បន្ទាប់មកក៏ដើរមកជិតខ្ញុំ រួចសុំក្រដាសដែលខ្ញុំកំពុងមើលយកមកពិនិត្យហើយនិយាយថាហេតុអ្វីក៏យូរខ្លាំងម្ល៉េះ ។ ពេលនោះខ្ញុំបានធូរក្នុងទ្រូងបន្តិច រួចក៏ប្រាប់ទៅវិញថា ខ្ញុំទើបតែមកបូកនៅថ្ងៃនេះទេ ពីមុនមកមានអ្នកដទៃមកបូក ប៉ុន្តែបូកមិនទាន់ចេញ ដូច្នេះល្ងាចនេះប្រាកដជារួចរាល់ហើយ ។ ទ័ពនោះក៏ប្រាប់មកវិញថា ថ្ងៃស្អែកខ្ញុំមកយកមែនទែនហើយ រួចក៏ចុះទៅវិញបាត់ ។

បើតាមស្ថិតិដែលគេឲ្យយកមកធ្វើមានគំរូស្រាប់ ខ្ញុំគ្រាន់តែស្រង់ចំនួនប្រជាជនដែលនៅសល់រួមមាន មនុស្សចាស់ជរា មនុស្សចាស់អាចធ្វើការបាន កសិករម៉ែៗ កម្លាំងយុវជនយុវនារី ក្មេងៗដែលអាចធ្វើការកើត ក្មេងៗដែលមិនទាន់អាចធ្វើការបាន និងចំនួនគោ ក្របី សេះ រទេះគោ រទេះសេះ នង្គ័ល រនាស់ ទូកកាណូតនិងចំនួនដីស្រែចម្ការ ។ល ។ ដោយឃើញថា នៅតែបូកសរុបចំនួនប្រជាជន ខ្ញុំក៏បើកបញ្ជីស្ថិតិប្រជាជនក្នុងភូមិមើលក្នុងនោះខ្ញុំឃើញមានរាយឈ្មោះប្រជាជនទៅតាមប្រភេទគ្រួសារនីមួយៗ ដោយមានគ្រួសារមួយចំនួន គេគូសប៊ិចក្រហមនៅពីក្រោមយ៉ាងវែង ដែលគ្រួសារនោះជាប្រជាជន១៧មេសា ហើយដែលត្រូវគេជម្លៀសយកទៅបាត់អស់ហើយ ។ ពេលនោះខ្ញុំក៏ខំបើករកមើលឈ្មោះរបស់ខ្ញុំដែរ ប៉ុន្តែមិនឃើញមានគូសប៊ិចក្រហមទាល់តែសោះ អ៊ីចឹងមានន័យថា គេភ្លេចគូសឈ្មោះរបស់ខ្ញុំជាមិនខានបានជាខ្ញុំអាចរួចខ្លួន ។ ទោះបីជាគេមិនគូសប៊ិចក្រហមនៅពីក្រោមឈ្មោះរបស់ខ្ញុំក៏ដោយ ក៏មានមនុស្សមួយចំនួនបានដឹងពីប្រវត្តិខ្ញុំច្បាស់ដែរ ប៉ុន្តែដោយសារសមមិត្ត ឆ្នាំង មិនដឹងពីប្រវត្តិខ្ញុំ ទើបបានជាខ្ញុំអាចនៅបន្តការងារនៅទីនេះបាន ។

## បែកការណ៍

នៅក្នុងខែសីហា ឆ្នាំ១៩៧៨ ទឹកឡើងកាន់តែពៀបមាត់ប្រាំងទន្លេ នៅពេលនោះសហករណ៍ហូបបាយរួមកំពុងស្ថិតនៅក្រោមការគ្រប់គ្រងផ្ទាល់របស់ទ័ពនិរតីមជ្ឈិម ដែលកន្លងមកនេះអ្នកទាំងនោះបានជម្លៀសប្រជាជនមួយភាគធំយកទៅសម្លាប់យ៉ាងអាថ៌កំបាំង ព្រោះគេមិនទុកចិត្តប្រជាជនអំពីរបៀបគ្រប់គ្រងបដិវត្តន៍ មហាលោតផ្លោះ មហាអស្ចារ្យ របស់ខ្លួនដែលជាអង្គការ ។

ពីមួយថ្ងៃទៅមួយថ្ងៃ ខ្ញុំរស់នៅទាំងព្រលឹងចុងសក់ ព្រោះមិនដឹងថាថ្ងៃណាគេយកទៅសម្លាប់នោះទេ។ នៅល្ងាចថ្ងៃមួយ គេប្រជុំថ្នាក់ដឹកនាំដូចធម្មតា ប៉ុន្តែប្រធានក្រុមនីមួយៗបាននិយាយត្អូញត្អែរពីការខ្វះខាតស្មៅឲ្យគោស៊ី ព្រោះតែប្រធានក្រុមកុមារទាំងអស់ឈប់រវីរវល់ជាមួយការងាររបស់ខ្លួន ជាហេតុធ្វើឲ្យកុមារមិនអាចដោះស្រាយបញ្ហាឲ្យស្មៅដល់គោបាន គឺឲ្យគោស៊ីតែចំបើងប៉ុណ្ណោះ។ ក្រោយមក គេបានប្រៀបធៀបនិងលើកសរសើរដល់ក្រុមរបស់ខ្ញុំ ដែលមានខ្ញុំជាអ្នកដឹកនាំក្មេងៗទៅបោចស្មៅក្នុងទឹកសម្រាប់ផ្គត់ផ្គង់ចំណីដល់គោ។ សមមិត្ត ឆ្នាំង ក៏បានដឹងពីរឿងនេះដែរ ប៉ុន្តែគាត់មិនដឹងថាត្រូវចាត់វិធានយ៉ាងដូចម្តេចចំពោះប្រធានក្រុមកុមារផ្សេងៗទៀត ពីព្រោះគាត់ទាំងនោះជាប្រជាជនមូលដ្ឋាន។ ម្យ៉ាងវិញទៀត ក្រោយពីសមមិត្ត ឆ្នាំង ជម្លៀសប្រជាជនឲ្យទៅទំពនិរតីសម្លាប់ ប្រជាជនទាំងនោះហាក់ដូចជាលែងជឿទុកចិត្តលើសមមិត្ត ឆ្នាំង ទៀត ដូច្នេះហើយបានជានៅពេលមានទឹកជំនន់ជួបការលំបាក គេនាំគ្នាប្រគល់ការងារឲ្យទៅក្មេងៗជាអ្នកទទួលខុសត្រូវជំនួសវិញ។

ស្អែកឡើងនៅពេលល្ងាច គេក៏នាំគ្នាមកប្រជុំម្តងទៀត ប៉ុន្តែលើកនេះប្រធានក្រុមទាំងឡាយហាក់ដូចជាមកយឺតខុសធម្មតា ចំណែកសមមិត្ត ឆ្នាំង វិញ បែរជាមកដល់មុនគេខុសពីរាល់ដង។ ក្រោយពីជួបខ្ញុំតែពីរនាក់ស្ងាត់ៗគាត់ក៏ប្រាប់ខ្ញុំថាខ្ញុំជាប្រជាជន១៧មេសាទេ ដូច្នេះគាត់នឹងដកខ្ញុំចេញពីតំណែងប្រធានក្រុមកុមារវិញនៅពេលណាដែលគាត់រកអ្នកថ្មីមកជំនួសបាន។ នេះគឺជាដំណាក់ការចុងក្រោយ នៃជីវិតរបស់ខ្ញុំហើយ ពីព្រោះអាថ៌កំបាំងទាំងឡាយត្រូវបានលាតត្រដាងក្រោយពេលដែលមានការលើកសរសើរពីរូបខ្ញុំ រួចបន្ទាប់អ្នកដទៃ ទើបធ្វើឲ្យមានភាពក្តៅក្រហាយនិងការប្រណែនឈ្នានីសកើតឡើង រហូតនាំគ្នាប្រាប់សមមិត្ត ឆ្នាំង ថា ខ្ញុំជាប្រជាជន១៧ មេសា។ នេះពិតជាដូចការគិតស្មានរបស់ខ្ញុំពីមុនមកមែន បើខ្ញុំចូលបម្រើការងារនៅក្នុងជួរដឹកនាំបដិវត្តន៍ គឺខ្ញុំពិតជាត្រូវជួបប្រទះនូវផលវិបាកនៅពេលចុងក្រោយជាមិនខាន។ បន្តិចក្រោយមក ប្រធានក្រុមផ្សេងៗទៀតក៏បានមកជួបជុំគ្នា រួចនាំគ្នាប្រជុំដូចធម្មតា។ សមមិត្ត ឆ្នាំង ជាមនុស្សឆ្លាតខ្លាំងណាស់ ព្រោះគាត់អាចក្តាប់សភាពការណ៍នៅក្នុងភូមិឃុំបានយ៉ាងល្អ ម្យ៉ាងទៀតគាត់អាចអារកាត់បញ្ហាទាំងឡាយដោយគ្មានទើសទាល់ត្រង់ណាទេ ដោយបានធ្វើឲ្យមនុស្សទាំងអស់គ្នានៅក្នុងភូមិគោរពកោតខ្លាចគាត់ថាជាអ្នកដឹកនាំដ៏ឈ្លាសវៃ ប៉ុន្តែគាត់មិនបានដឹងខ្លួនទេថា ការឈ្លាសវៃរបស់គាត់បានដឹកនាំប្រជាជនទៅរកមហាសោកនាដកម្មដ៏ធំធេងមួយ។ ពីព្រោះតែអំណាចផ្តាច់ការនេះហើយ ទើបធ្វើឲ្យមនុស្សដែលស្ថិតនៅក្នុងអំណាចនោះជាប់ជំពាក់វាក់វិនមិនអាចថយក្រោយបាន ហើយនាំគ្នាខំអនុវត្តទៅតាមបទបញ្ជារបស់ថ្នាក់លើតៗគ្នាយ៉ាងត្រង់ភ្លឹង រហូតធ្វើឲ្យអ្នកដែលក្តាប់អំណាចថ្នាក់លើឈ្លក់វង្វេងនិងមើលឃើញថា ខ្លួនឯងជាមនុស្សប្រសើរខ្ពង់ខ្ពស់ រួចសម្លឹងមើលមកប្រជាជនគ្រាន់តែជាឧបករណ៍របស់ខ្លួនតែប៉ុណ្ណោះ។ នៅក្នុងអង្គប្រជុំ ខ្ញុំខ្លាចតែសមមិត្ត ឆ្នាំង លើកពីរឿងរបស់ខ្ញុំមកនិយាយទេ ព្រោះមិនដឹងថាត្រូវយកមុខទៅទុកនៅឯណា ប៉ុន្តែដោយសារតែស្ថានភាពប្រធានក្រុមកុមារមានសភាពដុនដាបពេក ទើបគាត់មិនលើកមកនិយាយ ហើយទុកឲ្យខ្ញុំនៅធ្វើការបន្តទៀត។

ពេលត្រឡប់មកដល់ផ្ទះវិញ ខ្ញុំមានអារម្មណ៍ពិបាកចិត្តយ៉ាងខ្លាំង ហើយបាននិយាយរឿងនេះប្រាប់ទៅដល់ម្តាយ រួចគាត់ក៏នៅស្ងៀមលែងមាត់កអ្វីទាំងអស់។ សង្គមបដិវត្តន៍អយុត្តិធម៌ណាស់ បង្កើតសាលាឲ្យរៀន ហើយបែរជាបិទទៅវិញ គ្រាន់តែខ្ញុំភៀសខ្លួនទៅតំបន់ លន់ នល់ ដើម្បីស្វែងរកចំណេះវិជ្ជាបន្តក៏ក្លាយទៅជាប្រជាជន១៧មេសា ដែលជាខ្មាំងរបស់អង្គការនិងជាមុខសញ្ញាត្រូវកម្ទេចចោលទៅវិញ។ ដូច្នេះ ខ្ញុំខំបន់ស្រន់សូមកុំឲ្យមានអ្នកណាចូលមកជំនួសតំណែងខ្ញុំឲ្យសោះ ព្រោះបើមានអ្នកថ្មីចូលមកជំនួស នោះជីវិតរបស់ខ្ញុំពិតជាត្រូវបាត់បង់ជាមិនខាន។

**ទំពព្រៃ**

ស្អែកបន្ទាប់ ខ្ញុំបានដឹកនាំក្មេងៗឡើងជិះទូក រួចឆ្លងទន្លេទៅត្រើយម្ខាងដើម្បីបោចស្មៅនៅក្នុងទឹកដូចរាល់ដង ប៉ុន្តែអារម្មណ៍ខ្ញុំបង្កប់ដោយទុក្ខព្រួយ តែខ្ញុំខំរក្សាអាកប្បកិរិយាដដែល ដើម្បីកុំឲ្យក្មេងៗដឹង និងបាក់ទឹកចិត្តលែងធ្វើការបន្តទៀត។ ម្យ៉ាងវិញទៀត ជីវិតខ្ញុំអាចបន្តពីមួយថ្ងៃទៅមួយថ្ងៃបាន ក៏ដោយសារតែខ្ញុំធ្វើការងារនៅក្នុងសហករណ៍បានល្អនិងជោគជ័យដែរ។

ចេញទៅបោចស្មៅម្តងនេះ មានក្មេងម្នាក់ប្រាប់ខ្ញុំថាគេបានឃើញទួលមួយដែលមានស្មៅនិងស្លឹកឫស្សី ប៉ុន្តែនៅខាងក្រោយមានផ្លូវខ្មោច ហើយមិនទាន់មានអ្នកណាធ្លាប់ទៅប្រូតនៅឡើយទេ។ ខ្ញុំក៏សួរទៅវិញថា ផ្លូវខ្មោចដែលនិយាយនោះជាផ្លូវខ្មោចថ្មីឬចាស់? ក្មេងនោះឆ្លើយថាជាផ្លូវខ្មោចចាស់ដែលមានតាំងពីសង្គមចាស់មកម្ល៉េះ។ ក្មេងៗគ្រាន់តែឮថាផ្លូវខ្មោចក៏នាំគ្នាខ្លាចរអាគ្រប់ៗគ្នា។ ប៉ុន្តែខ្ញុំបានពន្យល់ក្មេងទាំងនោះឲ្យឈប់ខ្លាច ព្រោះខ្មោចមិនមានទេនៅលើលោកនេះ យើងត្រូវតាំងចិត្តជាអ្នកវិទ្យាសាស្ត្រ ក្លាហាន ហ៊ានពិនិត្យរើកញែករកការពិត និងហ៊ានប្រយុទ្ធតតាំងនឹងបាតុភូតធម្មជាតិ នោះយើងប្រាកដជាលែងខ្លាចខ្មោចទៀតហើយ។ ក្រោយពីស្តាប់ការណែនាំរបស់ខ្ញុំរួចហើយ ក្មេងៗទាំងនោះហាក់ដូចជាលែងខ្លាចខ្មោច រួចនាំគ្នាអុំទូកតម្រង់ទៅទួលផ្លូវខ្មោចនោះ។ ពេលទៅដល់ទីនោះ យើងក៏ប្រទះឃើញផ្លូវខ្មោចនោះមែន ដែលធ្វើឲ្យយើងមានអារម្មណ៍ត្រេកអរព្រោះនៅទីនោះមានដុះស្មៅជាច្រើន។ ខ្ញុំបានប្រាប់ក្មេងៗទាំងនោះថា មិនត្រូវត្រេកអរខ្លាំងពេកទេ ព្រោះនៅក្នុងស្មៅនេះអាចមានពស់អសិរពិស ដូច្នេះមុននឹងចូលប្រូតត្រូវវាយបង្អើលវាឲ្យចេញសិន ដោយត្រូវវាយពីជ្រុងម្ខាងទៅជ្រុងម្ខាងទៀត ហើយទុកផ្លូវឲ្យវារត់ចេញ ព្រោះបើមិនទុកផ្លូវទេវានឹងបកមកខាំយើងជាមិនខាន។ ក្មេងៗបាននាំគ្នាអនុវត្តតាមសម្តីរបស់ខ្ញុំទាំងអស់ ដោយវាយបង្អើលសត្វទាំងអស់ រួចទើបចាប់ផ្តើមប្រូតស្មៅ។

ពេលល្ងាច ខ្ញុំក៏ទៅប្រជុំបូកសរុបការងារប្រចាំថ្ងៃនៅឯមន្ទីរឃុំដូចរាល់ដង ប៉ុន្តែនៅពេលប្រជុំ អារម្មណ៍របស់ខ្ញុំផ្តោតទៅលើតែសមមិត្ត ឆ្នាំង ប៉ុណ្ណោះ ព្រោះខ្ញុំខ្លាចគាត់លើករឿងរាវផ្ទាល់ខ្លួនរបស់ខ្ញុំមកនិយាយ តែសំណាងល្អ គាត់មិនបានលើករឿងខ្ញុំមកនិយាយទេ គឺគ្រាន់តែដោះស្រាយបញ្ហានៅក្នុងក្រុមនីមួយៗប៉ុណ្ណោះ។ ពេលត្រឡប់មកដល់ផ្ទះវិញ ម្តាយខ្ញុំបានលួចខ្សឹបប្រាប់ខ្ញុំថា គាត់ឮគ្នាគាត់និយាយថា ពីយប់មិញមានទ័ពព្រៃឡោមព័ទ្ធផ្ទះរបស់សមមិត្ត ឆ្នាំង។ ខ្ញុំក៏ប្រាប់គាត់វិញថា សមមិត្ត ឆ្នាំង គ្មានអ្វីប្លែកទេ ទំនងជាគាត់ខំរក្សាអាកប្បកិរិយា និងគោលជំហរជាអ្នកដឹកនាំហើយ ទើបគាត់មិនបានបង្ហាញឲ្យថ្នាក់ក្រោមដឹងពីវិបត្តិផ្ទាល់ខ្លួនគាត់ដែលកំពុងជួបប្រទះ ម្យ៉ាងទៀតគាត់នៅតែបញ្ជានិងចាត់តាំងការងារយ៉ាងសកម្មនិងក្លាហានជានិច្ច។ នៅយប់នោះ ទ័ពព្រៃមានគ្នាប្រហែលជា៧ទៅ៨នាក់ ដែលប្រដាប់ដោយកាំភ្លើងគ្រប់ដៃ បានមកគោះទ្វារផ្ទះសមមិត្ត ឆ្នាំង រួចចាប់គាត់ធ្វើជាចំណាប់ខ្មាំងអស់រយៈពេលពេញមួយយប់។ ទ័ពព្រៃទាំងនោះបានគាបសង្កត់គាត់ឲ្យព្រមចុះចាញ់ ហើយបង្ខំគាត់ឲ្យធ្វើការជាមនុស្សក្បាលពីរ គឺនៅពេលថ្ងៃបម្រើឲ្យខាងទ័ពនិរតីមជ្ឈិម ចំណែកពេលយប់បម្រើឲ្យខាងទ័ពព្រៃ។ ទ័ពទាំងនោះបានហាមសមមិត្ត ឆ្នាំង មិនឲ្យយកមនុស្សទៅសម្លាប់បន្តទៀត ហើយត្រូវចូលរួមប្រយុទ្ធជាមួយទ័ពនិរតីមជ្ឈិម និងត្រូវផ្តល់អង្ករ ត្រី ព្រមទាំងសាច់ទៅដល់ទ័ពព្រៃផង បើសិនជាគាត់ហ៊ានក្បត់ ហើយបែកការណ៍នោះគេនឹងសម្លាប់គាត់ទាំងគ្រួសារ។ ពេលឃើញទ័ពព្រៃចូលមកបែបនេះ សមមិត្ត ឆ្នាំង ភ្ញាក់ខ្លួនព្រឺតព្រោះមិននឹកស្មានថា គាត់បោសសម្អាតមនុស្សមិនឲ្យអស់ រួចអ្នកដែលនៅសល់បែរជាមានអាវុធគ្រប់ដៃ ហ៊ានចេញមុខមកប្រឆាំងនឹងរដ្ឋអំណាចរបស់គាត់ដែលមានខ្នងក្រាស់ដូចជាមជ្ឈិមបក្សដ៏មហាអស្ចារ្យបែបនេះសោះ។ ពេលនោះ បណ្តាញទ័ពព្រៃហាក់ដូចជានៅបង្កប់យ៉ាងជ្រៅក្នុងសហករណ៍ ព្រោះគេអាចក្តាប់សភាពការណ៍បានយ៉ាងច្បាស់ ដែលធ្វើឲ្យសមមិត្ត ឆ្នាំង ត្រូវតែយល់ព្រមចុះចាញ់និងគោរពទៅតាមលក្ខខណ្ឌរបស់ទ័ពព្រៃដាក់ឲ្យធ្វើ។ ថ្វីដ្បិតតែទ័ពព្រៃមានចំនួនតិច ប៉ុន្តែទ័ពទាំងនោះមានអានុភាពខ្លាំងក្លាណាស់ ព្រោះមានកាំភ្លើងដែលអាចសម្លាប់មនុស្សពេលណាក៏បាន ហេតុនេះហើយទើបធ្វើឲ្យអ្នកនយោបាយគ្រប់គ្រងអំណាចអាចបញ្ជានិងបត់បែនសង្គមបដិវត្តន៍ឲ្យក្រឡាប់ចាក់បែបនេះបាន។

នៅពេលនោះ កាំភ្លើងមានចំនួនត្រឹមតែ២ទៅ៣ដើមប៉ុណ្ណោះ ប៉ុន្តែអាចគំរាមនិងបញ្ជាសមមិត្ត ឆ្នាំង ឲ្យផ្លាស់ប្តូរគំនិតបាន ព្រោះគាត់ខ្លាចគេយកទៅសម្លាប់ចោលទាំងគ្រួសារ។ ដោយសារតែកម្លាំងទ័ពព្រៃដ៏តូចនេះហើយ ទើបអាចជួយសង្គ្រោះជីវិតរបស់ខ្ញុំបាន ព្រោះវាបានបង្អាក់ចលនាយកមនុស្សទៅសម្លាប់បានមួយចំណែកធំ ប៉ុន្តែវាហាក់ដូចជានៅឆ្ងាយដូចជើងមេឃ ពីព្រោះកម្លាំងទ័ពព្រៃតិចណាស់បើប្រៀបទៅនឹងទ័ពមជ្ឈិមបក្សកុម្មុយនីស្តដែលកំពុងគ្រប់គ្រងមនុស្ស។

នៅពេលដែលទឹកចាប់ផ្តើមលិចផ្លូវនៅសល់តែទីទួលសម្រាប់ដាក់គោនិងការងារបង្កបង្កើនផលនៅក្នុងសហករណ៍ក៏គ្មានអ្វីធ្វើ  អ្នកស្រុកដែលមានរបបដីស្រែតាំងពីមុនមកបាននាំគ្នាជិះទូកចុះឡើងទៅដកស្ទូងនិងច្រូតកាត់ស្រូវប្រាំង ។ ចំណែកខ្ញុំបានដឹកនាំក្រុមក្មេងៗទៅធ្វើការនៅក្នុងវត្តមួយដែលមានរូបព្រះពុទ្ធបដិមាជាច្រើនត្រូវបានវាយកម្ទេចចោល  ហើយក៏ជាទីកន្លែងដែលខ្មែរក្រហមយកមនុស្សទៅសម្លាប់ដោយទម្លាក់ទៅក្នុងអណ្តូងដែរ ។ ប៉ុន្មានថ្ងៃក្រោយមកទៀត ទឹកបានឡើងលិចរោងបាយរួមចុងភៅមិនអាចរកកន្លែងដាំបាយខ្ទះគ្នោតបាន  គេក៏ចែកចានឆ្នាំងនិងរបបអង្ករប្រហុកជារបបពលកម្មមួយថ្ងៃសម្រាប់មួយថ្ងៃឲ្យប្រជាជនដាំបបរតាមផ្ទះរៀងៗខ្លួនវិញ ។ ដូច្នេះ យើងទាំងអស់គ្នាហាក់ដូចជាមានសេរីភាពក្នុងការហូបចុក  ហើយអាចច្នៃម្ហូបអាហារទៅតាមចិត្តចង់ ។ ដោយសាររកស្មៅសម្រាប់គោស៊ីលែងបាន ខ្ញុំក៏នាំក្មេងៗបោចស្លឹកឫស្សី និងស្លឹកកំប្លោកជំនួសវិញ ។

ចាប់តាំងពីមានទឹកលិចភូមិមក  ការប្រជុំបូកសរុបការងារថ្នាក់ដឹកនាំនៅឯមន្ទីរឃុំក៏ផ្អាកដែរ  តែបង ឆ្នាំង តែងតែប្រចាំការនៅទីនោះដដែល ។  ប៉ុន្មានថ្ងៃក្រោយទើបមានទ័ពនិរតីមជ្ឈិមជិះកាណូតធំល្មមគ្មានដំបូលមានទ័ពជាង២០នាក់ប្រដាប់អាវុធគ្រប់ដៃចុះមកត្រួតពិនិត្យសភាពការណ៍និងពង្រឹងជំហរបង ឆ្នាំង ។ ក្រោយពីពិនិត្យរួច  គេក៏ទារអង្ករពីបង ឆ្នាំង  ចំនួន៤ទៅ៥បាវដើម្បីយកទៅមូលដ្ឋានរបស់ខ្លួននៅស្រែទិសខាងត្បូងជាទីតាំងរបស់គាត់ ។

## សារាចរពីអង្គការ

ពីមួយថ្ងៃទៅមួយថ្ងៃទឹកកាន់តែលិចខ្លាំងឡើងៗធ្វើឲ្យប្រជាជនខ្លះដែលមានផ្ទះទាបៗត្រូវលិចអស់គ្មានកន្លែងរស់នៅ ។ ក្រោយពីទឹកស្រក  នៅក្នុងរោងបាយក៏មានបិទប្រកាសរបស់គណៈកម្មាធិការមជ្ឈិមបដិវត្តន៍មួយសន្លឹកដែលមានអក្សរវាយអង្គុលីលេខនិងមានអត្ថន័យជាសង្ខេបដូចតទៅ ៖ គណៈកម្មាធិការមជ្ឈិមបក្សបដិវត្តន៍កម្ពុជាសូមប្រកាសផ្សព្វផ្សាយជូនដល់កម្មាភិបាលដឹកនាំទទួលខុសត្រូវគ្រប់ជាន់ថ្នាក់ឲ្យបានជ្រាបថា  ចាប់ពីពេលចុះហត្ថលេខានេះតទៅប្រជាជនទាំងមូលត្រូវមានសិទ្ធិរស់នៅស្មើភាពគ្នា គ្មានការបែងចែកចាស់ឬថ្មី ហាមមិនឲ្យមានការប៉ះពាល់ដល់អាយុជីវិតសូម្បីតែម្នាក់តទៅទៀតជាដាច់ខាត ។  សូមកម្មាភិបាលដឹកនាំគ្រប់ជាន់ថ្នាក់គោរពអនុវត្តន៍ដោយភារកិច្ចទទួលខុសត្រូវបដិវត្តន៍ខ្ពស់បំផុត ។  ដោយស្មារតីសាមគ្គីភាពរៈ  បដិវត្តន៍ ។ ធ្វើនៅភ្នំពេញ ឆ្នាំ១៩៧៨ ។ ទោះជារឿងនេះគួរឲ្យរីករាយបំផុតយ៉ាងណាក៏ដោយ  ក៏ប្រជាជនគ្រប់គ្នានៅតែរក្សាភាពស្ងប់ស្ងាត់មិនហ៊ានហ៊ើកព្រៀវឡើយ ។ ប៉ុន្មានថ្ងៃមកទៀត នៅតាមចង្ក្រានបាយរួមពេលដែលដីគោករឹងអាចដើរបាន  ពួកនិរតីមជ្ឈិមក៏បាននាំទ័ពជាច្រើនចុះមកពង្រឹងមូលដ្ឋានភូមិឃុំខ្ញុំឡើងវិញ  ដោយបញ្ជាឲ្យប្រជាជនហូបបាយរួមនិងធ្វើការរួមឡើងវិញ  ថែមទាំងមានតំណាងម្នាក់នៅធ្វើការអមជាមួយបង ឆ្នាំង ទៀតផង ។

## ជម្លៀសចេញពីភូមិ

នៅថ្ងៃទី២៧ ខែធ្នូ ឆ្នាំ១៩៧៨ ប្រធានក្រុមបានប្រាប់ប្រជាជននៅតាមផ្ទះថា  យើងត្រូវជម្លៀសទៅភូមិភាគកណ្តាលហើយ  ដោយថ្ងៃនេះមិនចាំបាច់ទៅធ្វើការអ្វីទេត្រូវនាំគ្នាទៅរៀបចំអីវ៉ាន់  ហើយទៅបើកយកអង្ករ  ចាននិងឆ្នាំងពីរោងបាយសម្រាប់ត្រៀមខ្លួនធ្វើដំណើរទៅឆ្ងាយ ។  បន្ទាប់ពីធ្វើតាមសម្តីរបស់អង្គការហើយ  គ្រួសារខ្ញុំក៏រៀបចំអីវ៉ាន់ដាក់ក្នុងរទេះដៃរុញមួយធ្វើពីកង់ឈើ  ព្រលឹមឡើងក៏ចេញដំណើរជាមួយអ្នកភូមិទាំងអស់គ្នា ។  ពេលខ្ញុំរុញរទេះដៃជាមួយប្អូនៗរបស់ខ្ញុំរហូតដល់ពាក់កណ្តាលភូមិក៏ប្រទះឃើញខ្មោចមួយអណ្តែតទឹកកណ្តាលទន្លេនិងឃើញទ័ពនិរតីចំនួនបីនាក់ជិះកង់ឌុបកសិករម្នាក់ដែលខ្ញុំមិនស្គាល់អត្តសញ្ញាណរបស់គាត់ទេចងស្លាបសេកនិងរុំមុខជិតដោយក្រណាត់ខ្មៅឌុបយកទៅក្បាលភូមិទំនងជាយកទៅសម្លាប់ ។  នៅវេលាថ្ងៃត្រង់  ពេលមកដល់វត្តមួយនៅកណ្តាលឃុំដែលជាកន្លែងធ្លាប់ប្រជុំមីទ្ទីង  យើងទាំងអស់គ្នាក៏នាំគ្នាឈប់សម្រាកហូបបាយនិងគេងនៅទីនេះមួយយប់ ។

នៅថ្ងៃទី២៩  ខ្ញុំក៏រុញរទេះដៃដែលផ្ទុកអីវ៉ាន់ជាច្រើនដើរបន្តទៅមុខទៀត  រហូតដល់ពេលព្រលប់ទើបទៅដល់ទីរួមស្រុកមួយ ។  ក្នុងពេលនោះ  ខ្ញុំសង្កេតឃើញហ្វូងមនុស្សមួយក្រុមតូចកំពុងដើរព័ទ្ធមិត្ត ឆ្នាំង  និងក្រុមគ្រួសាររបស់គាត់មិនឲ្យចាកចេញពីហ្វូងប្រជាជនឡើយ  ពីព្រោះមិត្ត ឆ្នាំង  ជាមនុស្សជិតស្និទ្ធរបស់ពួកមជ្ឈិម ប្រសិនបើមិត្ត ឆ្នាំង ជាប់ជាចំណាប់ខ្មាំងទ័ពមជ្ឈិមក៏មិន

ហ៊ានប៉ះពាល់ដល់ហ្វូងប្រជាជនដែរ ។

នៅថ្ងៃ៣០ គេក៏បញ្ជាឲ្យចេញដំណើរទៅមុខទៀតរហូតដល់ពេលព្រលប់ទើបយើងទៅដល់ទីវាលមួយដែលនៅខាងឆ្វេងដៃមានទួលមួយនិងដើមពោធិ៍មួយដើម ។ នៅយប់នោះ ខ្ញុំឮដំណឹងថា នៅមូលដ្ឋានសហករណ៍ភូមិឃុំដែលនៅទិសខាងលិចភូមិខ្ញុំមិនព្រមគោរពតាមបញ្ជារបស់មជ្ឈិមដែលជម្លៀសទេរហូតធ្វើឲ្យទ័ពមជ្ឈិមធ្វើការហ៊ុមព័ទ្ធ ។ ក្រោយមកក៏ឮដំណឹងថា អ្នកទាំងនោះត្រូវបានដោះលែង ព្រោះមានទ័ពផ្សេងមកជួយ ។

នៅថ្ងៃ៣១ មានបញ្ជាឲ្យដើរទៅមុខទៀតឆ្ពោះទៅទិសខាងជើងខេត្តកំពង់ចាម រហូតដល់ពេលយប់ទើប ទៅដល់ចម្ការកៅស៊ូពាមជាំង ។ ក្រោយពីឆ្លងផុតទីនេះ យើងក៏បានមកដល់ភូមិអ្នកស្រុកដែលមានប្រជាជនរស់នៅយ៉ាងច្រើន ។ យើងមានការចម្លែកចិត្តជាខ្លាំងពេលមកដល់ ព្រោះប្រជាជននៅទីនេះបែរជានាំគ្នាសម្ងំនៅក្នុងផ្ទះបិទទ្វារជិត ឃើញតែពន្លឺចង្កៀងប្លុងៗទៅវិញ មិនបានទទួលស្វាគមន៍រាក់ទាក់ជាមួយយើងឡើយ ។ ព្រលឹមឡើងពេលកំពុងតែបន្តដំណើរទៅមុខយើងស្រាប់តែឮសំឡេងគ្រាប់បែកផ្ទុះនៅទិសខាងកើត ។ បន្តិចក្រោយមកទៀត ខ្ញុំក៏ឮសូរសំឡេងគ្រាប់បែកផ្ទុះជាច្រើនគ្រាប់នៅកំពង់ចម្លងទន្លេបិទ ។ ដោយសារតែមិនអាចធ្វើដំណើរទៅមុខទៀត បានយើងក៏បកក្រោយត្រឡប់មកព្រៃចម្ការកៅស៊ូវិញ ។

នៅថ្ងៃទី៣ ពេលធ្វើដំណើរត្រឡប់មកផ្ទះវិញ ខ្ញុំឃើញតាមផ្លូវមានសភាពស្ងាត់ជ្រងំ ។ នៅទីនោះរហូតដល់ថ្ងៃទី៧ មករា ១៩៧៩ ខ្ញុំបានស្តាប់វិទ្យុផ្សាយសំឡេងរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជាថា ប្រទេសរបស់យើងត្រូវបានរំដោះហើយ ។ ចំណែកឯមេដឹកនាំធំៗបានក៏នាំគ្នារៀសខ្លួនទៅកាន់ភូមិភាគពាយ័ព្យ ។ ដំណឹងនេះបានធ្វើឲ្យប្រជាជនមានការត្រេកអរជាខ្លាំង ដែលបញ្ជាក់ថាប្រទេសយើងមានសិទ្ធិនិងសេរីភាពឡើងវិញហើយ ។

**ហេង ខុន**

## លិខិតពីមិត្តអ្នកអាន

***សូមគោរពលោកនាយកមជ្ឈមណ្ឌលឯកសារស្រាវជ្រាវកម្ពុជា!***

ខ្ញុំបាទមានកិត្តិយសសូមប្រកាសជូនដំណឹងអំពីការស្រាវជ្រាវរកជនរងគ្រោះ!

នៅសម័យខ្មែរក្រហម ខ្ញុំរស់នៅភូមិតាឥន្ទ (បច្ចុប្បន្នហៅភូមិត្រពាំងវែងខាងលិច) ឃុំត្រពាំងរាំង ស្រុកជុំគិរី ខេត្តកំពត ។ កាលនោះខ្ញុំនៅកុមារតូចនៅឡើយ ។ ថ្ងៃមួយខ្ញុំបានជួបបុរសម្នាក់មាឌក្រអាញសាច់ដុំធំៗ សម្បុរស្រអែម គាត់ឈ្មោះ ឡុង អាន ជាអ្នកប្រដាល់កាលពីសង្គមចាស់ ។ ពេលខ្ញុំបានជួបនិងឃើញគាត់ អ្នកស្រុកខ្ញុំបានសុំឲ្យគាត់សាកបញ្ចេញក្បាច់ប្រដាល់មើល គាត់ក៏បានធ្វើឲ្យមើលដូចជាក្បាច់ចាប់ទាត់ធាក់យ៉ាងស្ទាត់ជំនាញគួរឲ្យចង់មើលនិងស្ងើចសរសើរពីវិជ្ជារបស់គាត់ ។ គាត់ជាប្រជាជនថ្មីមិនដឹងគាត់ជម្លៀសមកពីភូមិឃុំស្រុកខេត្តណាទេ មកនៅភូមិតារាជ្យជាប់នឹងភូមិរបស់ខ្ញុំ ។ ក្រោយមកខ្ញុំបានសាកសួររកឈ្មោះគាត់ អ្នកភូមិបានប្រាប់ខ្ញុំថា គាត់ត្រូវគេយកទៅសម្លាប់បាត់ហើយ តែខ្ញុំមិនបានសួរថាតើគេយកគាត់ទៅសម្លាប់នៅកន្លែងណាទេ ។ រហូតមកដល់ពេលនេះ ខ្ញុំនៅតែនឹកឃើញគាត់និងសែនស្រណោះអំពីជីវិតរបស់គាត់ក៏ដូចបងប្អូនពូមីងខ្ញុំនិងជនរួមជាតិដែលទទួលរងគ្រោះត្រូវឈ្លបសម្លាប់ដូចសត្វធាតុ ។

ព័ត៌មានដែលខ្ញុំបានដឹងខាងលើចាត់ទុកជាការជូនដំណឹងដល់បងប្អូន សាច់ញាតិ ឪពុកម្តាយរបស់គាត់បានជ្រាបនឹងដឹងឮខ្លះៗតែប៉ុណ្ណោះ ។ ប្រសិនបើបងប្អូនមិនទាន់បានដំណឹងនេះ ហើយចង់ដឹងព័ត៌មានលម្អិតសូមអញ្ជើញទៅជួបអ្នកភូមិខាងលើប្រហែលនឹងបានដំណឹងបន្ថែមទៀតជាពុំខាន ។

សូមអរគុណក្នុងការចុះផ្សាយនូវដំណឹងនេះទុកជាប្រយោជន៍ដល់គ្រួសារទៅតាមផ្លូវធម៌ ឬជាប្រវត្តិសាស្ត្រផងដែរ ។

**គុខរ៉ា**





ឧបត្ថម្ភការបោះពុម្ពផ្សាយដោយរដ្ឋាភិបាល ដេនម៉ាក ន័រវ៉េ ស៊ុយអែត និងសហរដ្ឋអាមេរិក
អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា ប្រកាសទេសរដ្ឋមន្ត្រីនិងរដ្ឋមន្ត្រីក្រសួងព័ត៌មានលេខ ០២៩១ពម/៩៩ចុះថ្ងៃទី២ ខែសីហា ឆ្នាំ១៩៩៩

**មជ្ឈមណ្ឌលឯកសារកម្ពុជា : ការិយាល័យព័ត៌មានសាធារណៈ**
ផ្ទះលេខ ៦៦, មហាវិថីព្រះសីហនុ ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ : (៨៥៥) ២៣ ២១១ ៨៧៥ ទូរសារ : (៨៥៥) ២៣ ២១០ ៣៥៨

DC-Cam/PIR : #66 ◆ Preah Sihanouk Blvd ◆ Phnom Penh ◆ Cambodia ◆ Tel: (855) 23 211 875 ◆ Fax: (855) 23 210 358 ◆ dccam@online.com.kh ◆ www.dccam.org.
A magazine of the Documentation Center of Cambodia: Searching for the truth. ◆ Number 116, August 2009 ◆ Funded by Denmark, Norway, Sweden, and USA.
Licensed by the Ministry of Information of the Kingdom of Cambodia, Prakas No.0291 P.M/99, 2 August 1999.